ក្រសួងអប់រំ យុវជន និងកីឡា

ហាមលក់

កម្មសិទ្ធិរបស់រដ្ឋ

# ប្រវត្តិវិទ្យា

## ១២







គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

# បញ្ជីខ្ចីសៀវភៅ

សាលារៀន :......................................................................

កំរងសាលារៀន :......................................................................

ស្រុក / ខ័ណ្ឌ :......................................................................

ខេត្ត / ក្រុង :......................................................................

ថ្ងៃ ខែ ឆ្នាំ ដែលសាលារៀនទទួលបានសៀវភៅ :...........................

| ឈ្មោះសិស្ស ខ្ចីសៀវភៅ | ថ្ងៃ ខែ ឆ្នាំ ខ្ចីសៀវភៅ | សភាពលក្ខណៈ សៀវភៅ | ថ្ងៃ ខែ ឆ្នាំ សងសៀវភៅ | សភាពលក្ខណៈ សៀវភៅ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ចំពោះគ្រូបង្រៀន

សូមសរសេរឈ្មោះសិស្សអោយបានច្បាស់នៅក្នុងខ្ទង់ " ឈ្មោះសិស្សខ្ចីសៀវភៅ " ។ សូមប្រើអក្សរខាងក្រោមនេះ ដើម្បីបញ្ជាក់សភាពលក្ខណៈរបស់សៀវភៅ :

ក. (សៀវភៅថ្មី)

ខ. (សៀវភៅប្រើហើយ ដែលនៅមានសភាពល្អ)

គ. (សៀវភៅប្រើហើយ ដែលមានសភាពមធ្យម)

ឃ. (សៀវភៅប្រើហើយ ដែលមានសភាពអន់ ឬចាស់)

សូមលើកទឹកចិត្តសិស្ស និងជួយសិស្សក្នុងការថែរក្សាសៀវភៅដែលបានខ្ចី ។

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាល័យហ៊ុនសែនអង្គស្នួល
បណ្ណាល័យ [illegible]
លេខ.......ថ្ងៃទី.......ខែ.......ឆ្នាំ.......

# ប្រវត្តិវិទ្យា

## ថ្នាក់ទី ១២

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៩ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក មួង សុជាត | លោក ស៊ីវ ធួន |
| | លោក ដៀប សុផល | លោកស្រី ងួន សុខកែវ |
| **អ្នកត្រួតពិនិត្យបច្ចេកទេស** | លោក ជុំ សត្យា | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ខាត់ ធី | |
| **អ្នករចនាទំព័រ** | លោក ជុំ សត្យា | |
| **គណៈកម្មការពិនិត្យ** | លោកស្រី មុំ មេត | លោកស្រី ព្រាប សុភួង |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១៤៩១ អយក.ប្រក. ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី ៦ ឆ្នាំ ២០១៥ ចំនួន ២៣ ០០០ ច្បាប់

ISBN 9-789-995-001-407

# អារម្ភកថា

សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី 12នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2005-2009) របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាថ្មី មុខវិជ្ជាប្រវត្តិវិទ្យានេះ យើងបានរៀបចំតាក់តែងឡើងមាន 3 ជំពូក និងមាន 22 មេរៀន ។

ខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះនឹងជួយលោកគ្រូ-អ្នកគ្រូនិងប្អូនៗសិស្សានុសិស្សឱ្យមានចំណេះដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ពីមូលហេតុនៃសង្គ្រាម ផាតុផ្សំនៃទំនាស់ និងទំនាក់ទំនងល្អរវាងប្រទេសនានាក្នុងតំបន់ និងពិភពលោកក្នុងឆន្ទៈរួមនៃមនុស្សជាតិជំរុញការអភិវឌ្ឍប្រកបដោយសុខសន្តិភាព និងសម្បូររុងរឿង ។

គ្រប់មេរៀនទាំងអស់នៅក្នុងសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី 12 មានទម្រង់ដូចៗគ្នាគឺមានការកំណត់វត្ថុបំណងមេរៀន សំណួរវាយតម្លៃបញ្ចប់ជំពូកនីមួយៗសម្រាប់ប្អូនៗឱ្យយល់ដឹងពីរបៀបឆ្លើយ ព្រមទាំងផ្តល់ការវាយតម្លៃពីការយល់ដឹងរបស់ប្អូនៗ ក្រោយពីបញ្ចប់មេរៀននៃជំពូកនីមួយៗទៀតផង ។

ក្រោយបញ្ចប់ការសិក្សា ប្អូនៗនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថល្អប្រកបដោយធនធានងាយស្រួលទៅបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ឬអាចរួមចំណែកកែច្នៃកម្រិតជីវភាពគ្រួសារ សហគមន៍ និងសង្គមដោយផ្ទាល់ ។ ម្យ៉ាងទៀត សៀវភៅនេះមានការចូលរួមផ្តល់មតិយោបល់ពីសំណាក់លោកគ្រូ-អ្នកគ្រូនៅតាមបណ្តាខេត្ត ក្រុង រាជធានីមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធយើងខ្ញុំសង្ឃឹមថាសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី 12 ថ្មីនេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។

គណៈកម្មការនិពន្ធប្រវត្តិវិទ្យារីករាយនឹងទទួលយកមតិកែលម្អពីសំណាក់លោកគ្រូ-អ្នកគ្រូនិងប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ទំព័រ


ជំពូកទី 1 : ប្រវត្តិសាស្ត្រពិភពលោក ........ 01

មេរៀនទី 1 : សហរដ្ឋអាមេរិក (1860-1990) ........ 02

មេរៀនទី 2 : ចក្រភពអង់គ្លេស ........ 12

មេរៀនទី 3 : សាធារណរដ្ឋបារាំង ........ 22

មេរៀនទី 4 : សហព័ន្ធអាល្លឺម៉ង់ (1945-1991) ........ 32

មេរៀនទី 5 : ប្រទេសអ៊ីតាលី ........ 38

មេរៀនទី 6 : សហភាពសូវៀត (1945-1991) ........ 44

មេរៀនទី 7 : សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ........ 54

មេរៀនទី 8 : ប្រទេសឆេកូស្លូវ៉ាគី ........ 62

មេរៀនទី 9 : ប្រទេសប៉ូឡូញ ........ 68

មេរៀនទី 10 : សហព័ន្ធយូហ្គោស្លាវី ........ 74

មេរៀនទី 11 : បញ្ហាទូទៅក្នុងពិភពលោក ........ 84

មេរៀនទី 12 : ដំណើរវិវត្តន៍សកលភាវូបនីយកម្ម ........ 94

ជំពូកទី 2 : ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ........ 103

មេរៀនទី 1 : ប្រទេសកម្ពុជាក្រោមអាណានិគមបារាំង (1863-1953) ........ 104

មេរៀនទី 2 : របបសង្គមរាស្ត្រនិយម (1955-1970) ........ 120

មេរៀនទី 3 : សាធារណរដ្ឋខ្មែរ (1970-1975) ........ 132

មេរៀនទី 4 : កម្ពុជាប្រជាធិបតេយ្យ (1975-1979) ........ 142

មេរៀនទី 5 : សាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា (1979-1993) ........ 158

ជំពូកទី 3 : ប្រវត្តិសាស្ត្រតំបន់ក្នុងសង្គ្រាមត្រជាក់ ........ 173

មេរៀនទី 1 : បម្រែបម្រួលសង្គមអាស៊ីអាគ្នេយ៍ក្រោយសង្គ្រាមលោកលើកទី 2 ........ 174

មេរៀនទី 2 : ប្រទេសវៀតណាម ........ 180

មេរៀនទី 3 : ប្រទេសថៃ ........ 186

មេរៀនទី 4 : បណ្ដាប្រទេសនៅតំបន់មជ្ឈិមបូព៌ា ........ 192

មេរៀនទី 5 : ប្រទេសអ៊ីស្រាអែល ........ 198

ជំពូកទី 1

# ប្រវត្តិសាស្ត្រពិភពលោក



សង្គ្រាមលោកលើកទី 2 ត្រូវបានបញ្ចប់នៅឆ្នាំ 1945 ។ សង្គ្រាមថ្មីមួយទៀតបានកើតឡើងគឺ សង្គ្រាមត្រជាក់(សង្គ្រាមមនោគមន៍វិជ្ជា) ដែលបង្កើតឡើងដោយមហាអំណាចធំៗពីរលើពិភពលោក គឺសហភាពសូវៀត និងសហរដ្ឋអាមេរិក ។ សង្គ្រាមនេះបានអូសបន្លាយអស់រយៈពេលជាង 40ឆ្នាំ (1945-1990) ។ សង្គ្រាមនេះបញ្ចប់ត្រឹមលោកប្រធានាធិបតីសហរដ្ឋអាមេរិក រ៉ូណាល់រីគេន និងប្រធានាធិបតីសហភាពសូវៀត មីខាអ៊ីល ហ្គោបាឆូវ ជួបចរចាគ្នានិងការវាយបំបែករបងជញ្ជាំងក្រុងប៊ែរឡាំង ។ សង្គ្រាមត្រជាក់បានបញ្ចប់ តែសង្គ្រាមភេរវកម្មបានកើតឡើងរំខានសេចក្ដីសុខសាន្ត និងការអភិវឌ្ឍរបស់ពិភពលោក ។

មេរៀនទី

# 1 សហរដ្ឋអាមេរិក (1860-1998)

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ការកែលម្អ និងការអនុវត្តកម្មវិធីថ្មីក្នុងនយោបាយអាមេរិក ។
- វិភាគមូលហេតុនៃវិបត្តិឆ្នាំ 1929 និងដំណោះស្រាយ ។
- ចង់កសាងប្រទេសឱ្យជឿនលឿនដូចសហរដ្ឋអាមេរិក ។

សហរដ្ឋអាមេរិកជាទឹកដីនៃជាតិឥណ្ឌាស្បែកក្រហម ។ នៅដើមសតវត្សទី 16 មានពួកនិគមជនអឺរ៉ុបបានទៅតាំងលំនៅ ដោយបានបំផ្លាញភូមិករនិងជីវិតជនជាតិដើម ។ សហរដ្ឋអាមេរិកក្លាយជាទឹកដីនៃជនភៀសខ្លួនពីទ្វីបអឺរ៉ុបម្ដងបន្តិចៗរហូតដល់បង្កើតជារដ្ឋ 13 នៅត្រើយអាត្លង់ទិកប៉ែកខាងកើត ។ សហរដ្ឋអាមេរិកមានផ្ទៃក្រឡា 9 363 000 km$^2$ ឈរលើលំដាប់ថ្នាក់ទី 4 បន្ទាប់ពីសហព័ន្ធរុស្ស៊ី កាណាដា និងចិន ។ លាតសន្ធឹងពីជើងទៅត្បូង 2 500 km ចាប់តាំងពីព្រំប្រទល់ប្រទេសកាណាដាមកដល់ព្រំដែនប្រទេសម៉ិកស៊ិកនិងពីលិចទៅកើតប្រវែង 4 500 km ពីញូវយ៉កទៅសាន់ហ្វ្រាន់ស៊ីស្កូ(ពីអាត្លង់ទិកទៅប៉ាស៊ីហ្វិក) ។ សហរដ្ឋអាមេរិកគឺជាប្រទេសទី 1 ដែលបានប្រកាសឯករាជ្យពីអង់គ្លេសនៅថ្ងៃទី 4 ខែកក្កដា ឆ្នាំ 1776 និងមានរដ្ឋធម្មនុញ្ញលើកដំបូងរបស់ខ្លួននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដែលបានប្រកាសក្នុងទីក្រុងភីឡាដែលភីនៅឆ្នាំ 1787 ហើយដាក់ឱ្យប្រើប្រាស់នៅឆ្នាំ 1789 ។ រដ្ឋនីមួយៗតំណាងដោយសញ្ញាផ្កាយលើទង់ជាតិ ។ រដ្ឋពីរចូលជាសមាជិកសហរដ្ឋចុងក្រោយគឺរដ្ឋអាឡាស្កានៅឆ្នាំ 1958 និងប្រជុំកោះហាវ៉ៃនៅឆ្នាំ 1959 [1] សរុបទាំងអស់ 50 រដ្ឋ ។

## 1. ស្ថាប័ននយោបាយ

រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកមានទម្រង់ប្រជាធិបតេយ្យសេរីពហុបក្ស ផ្អែកលើអធិបតេយ្យភាព និងសេរីភាពបុគ្គលដែលចែងអំពីការបែងចែកអំណាច 3 ដាច់ពីគ្នា ។

(1) Larousse 1988

## 1.1. អំណាចប្រធានាធិបតី

អំណាចប្រធានាធិបតីជាអំណាចនីតិប្រតិបត្តិ ប៉ុន្តែមានសិទ្ធិទូលំទូលាយ ។ ប្រធានាធិបតីជ្រើសតាំងដោយការបោះឆ្នោតសម្រាប់អាណត្តិ 4ឆ្នាំ ហើយអាចឈរឈ្មោះបាន 2 អាណត្តិ ប្រសិនបើប្រធានាធិបតីរូបណាដែលមានស្នាដៃក្នុងការដោះស្រាយបញ្ហាជាតិធំៗ ។ - ប្រធានាធិបតីជាអគ្គមេបញ្ជាការកងទ័ពជាតិ អាចលើកទ័ពចូលកន្លែងណាមួយនៅលើពិភពលោក ដូចជាការលើកទ័ពចូលកោះគ្រើណាដឆ្នាំ 1983 លើកទ័ពទៅឈូងសមុទ្រពែក្សដើម្បីដោះស្រាយវិវាទគូវ៉ែត និងអ៊ីរ៉ាក់ ។ ព្រឹត្តិការណ៍សង្គ្រាមភេរវកម្មទៅលើអគារពាណិជ្ជកម្មនៅញូវយ៉កនាថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2001 សហរដ្ឋអាមេរិកបានចោទថាប៊ីនឡាដិន(Ben Laden) ជាមេភេរវជនអាល់កៃដា ដែលកំពុងលាក់ខ្លួននៅអាហ្វហ្គានីស្ថានគឺជាអ្នកបង្ក ហើយបានប្រកាសលើកទ័ពតាមប្រមាញ់ និងកម្ទេចសំបុកក្រុមភេរវកម្មអាល់កៃដានៅឆ្នាំ 2001 ។ ក្រៅពីនេះ ប្រធានាធិបតីមានសិទ្ធិបង្កើតគំនិតផ្តួចផ្តើមធ្វើច្បាប់អ្វីមួយ ។ ប្រធានាធិបតីត្រូវមានអនុប្រធានាធិបតីមួយនាក់ដើម្បីធ្វើការជំនួសនៅពេលដែលប្រធានាធិបតីមានជំងឺ ឬទទួលមរណភាព ឬត្រូវដកហូតពីតំណែង ។ នៅក្នុងអាណត្តិទី 2 លោក និច សុន ត្រូវដកហូតពីតំណែងដោយសាររឿងអាស្រូវ វ៉ាទ័រហ្គេត[1] ហើយអនុប្រធានាធិបតី ជេរ៉ាហ្វ ហ្វ័រដ ឡើងជំនួស ។

## 1.2. អំណាចសភា

សភាមានពីរគឺ សភាតំណាងរាស្ត្រនិងព្រឹទ្ធសភា ។ សភាតំណាងរាស្ត្រមានចំនួនសមាជិក 435 រូបមានអាណត្តិ 2ឆ្នាំ ចំណែកព្រឹទ្ធសភាមានអាណត្តិ 6ឆ្នាំប៉ុន្តែត្រូវបោះឆ្នោតដើម្បីប្តូរចំនួន $\frac{1}{3}$ រៀងរាល់ 2ឆ្នាំម្តង សមាជិកព្រឹទ្ធសភាមានចំនួន 100រូប (ក្នុងមួយរដ្ឋមាន 2រូប) ។ ព្រឹទ្ធសភាដើរតួយ៉ាងសំខាន់ ព្រោះជាអ្នកតំណាងរដ្ឋនីមួយៗ ជាអ្នកមានសិទ្ធិពិនិត្យលើការតែងតាំងមន្ត្រីជាន់ខ្ពស់ និងជាអ្នកឱ្យសច្ចាប័នលើសន្ធិសញ្ញាផ្សេងៗដោយសំឡេង $\frac{2}{3}$ ។ សភាមិនអាចទម្លាក់ប្រធានាធិបតីពីតំណែងបានឡើយ លើកលែងតែបានប្រព្រឹត្តអំពើក្បត់ជាតិ និងអំពើឧក្រិដ្ឋកម្មនៅក្នុងតំណែង ។

## 1.3. តុលាការជាន់ខ្ពស់

តុលាការជាន់ខ្ពស់ជាអំណាចទី 3 ដែលមានប្រធានមួយរូប និងសមាជិក 8រូបកាន់តំណែងអស់មួយជីវិត មានសិទ្ធិទុកជាមោឃៈនូវច្បាប់ទាំងឡាយណាដែលមិនស្របនិងរដ្ឋធម្មនុញ្ញ ។ សមាជិកតុលាការជាន់ខ្ពស់ត្រូវបានជ្រើសចេញពីចំណោមអ្នកច្បាប់ដែលមានឈ្មោះល្បីនៅតាមរដ្ឋ ឬក្នុងចំណោមអ្នកដែលមានចំណេះដឹងខ្ពស់ ដែលគេទទួលស្គាល់ទូទាំងសហរដ្ឋអាមេរិក ។

---

(1). ទីស្នាក់ការគណៈបក្សប្រជាធិបតេយ្យ

### 1.4. គណបក្សនយោបាយ

គណបក្សនយោបាយមានពីរដែលប្រជែងគ្នាដឹកនាំឆាកនយោបាយសហរដ្ឋអាមេរិក គឺគណបក្សសាធារណរដ្ឋ និងគណបក្សប្រជាធិបតេយ្យ ។ គណបក្សសាធារណរដ្ឋប្រមូលផ្តុំដោយពួកពាណិជ្ជករធំៗ និងពួកម្ចាស់កសិដ្ឋាននៅប៉ែកខាងលិចប្រទេស ។ គណបក្សប្រជាធិបតេយ្យប្រមូលផ្តុំដោយពួកបញ្ញវ័ន្ត និយោជិត កម្មករ និងជនជាតិភាគតិចនៅតាមទីក្រុងធំៗមានជនជាតិអៀរឡង់ អ៊ីតាលី និងពួកស្បែកខ្មៅ ។

## 2. ការកែលម្អនិងការកំណត់កម្មវិធីថ្មី

### 2.1. សហរដ្ឋអាមេរិកនៅចន្លោះសង្គ្រាមលោកទាំងពីរ

នៅក្រោយសង្គ្រាមលោកលើកទី ១ ប្រទេសអឺរ៉ុបត្រូវស្តារឡើងវិញ ដោយពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រាក់កម្ចីពីសហរដ្ឋអាមេរិក ។ នៅដើមឆ្នាំ 1920 ប្រទេសទាំងនោះបានខ្ចីប្រាក់ពីធនាគារសហរដ្ឋអាមេរិកចំនួន 10 ពាន់លានដុល្លារ ។ ទំនិញអាមេរិកក៏បានហូរចូលទៅក្នុងទ្វីបអឺរ៉ុបគិតជាទឹកប្រាក់ 7 ពាន់លានដុល្លារក្នុង ១ ឆ្នាំៗ ។ សន្ទុះសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានរីកចម្រើនខ្ពស់បំផុតដែលពីមុនមិនធ្លាប់មាន ។ នៅពេលនោះដែរ សង្គមអាមេរិកបានប្តូរមុខមាត់ថ្មីទាំងស្រុង ។ រោងចក្រឧស្សាហកម្មខិតខំផលិតឱ្យទាន់តម្រូវការទីផ្សារ ដូចជារថយន្ត វិទ្យុ និងមុខទំនិញផ្សេងៗជាច្រើនទៀត ។ ការរីកលូតលាស់ខាងសេដ្ឋកិច្ចនេះមានរយៈពេលជិត 10 ឆ្នាំ (ឆ្នាំ 1922 - 1929) ប៉ុន្តែក្រោយមកសេដ្ឋកិច្ចសហរដ្ឋអាមេរិកក៏បានជួបវិបត្តិមួយធ្ងន់ធ្ងរ ។

នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី ១ ប្រធានាធិបតីអាមេរិក វូដ្រូវិលសុន (Woodrow Wilson 1916 - 1920) បានបញ្ជាឱ្យដកទ័ពសហរដ្ឋអាមេរិកពីទ្វីបអឺរ៉ុបដើម្បីរួបរួមគ្នាពង្រឹងការអភិវឌ្ឍកសាងសេដ្ឋកិច្ចផ្ទៃក្នុង ។ ប្រធានាធិបតីអាមេរិកដែលបន្តតំណែងពីលោក វិលសុន បាននាំគ្នាកសាងសេដ្ឋកិច្ចតាមទ្រឹស្តីដើម "ទុកឱ្យគេធ្វើ" (Laissez faire) បណ្តាលឱ្យផលិតផលកើនច្រើនហួសហេតុពេកនៅពេលដែលតម្រូវការទីផ្សាររួមតូច វិបត្តិសេដ្ឋកិច្ចមួយបានកើតឡើង ។ ការអនុវត្តទ្រឹស្តីនេះនាំមកនូវបរិមាណទំនិញកើនឡើងមិនធ្លាប់មានពីមុនមក ។ គ្រាន់តែនៅទីក្រុងឌីត្រូត (Detroit) រោងចក្រផលិតរថយន្ត (Ford) បានបញ្ចេញរថយន្ត 9 000 គ្រឿងក្នុងមួយថ្ងៃ ។ ដូច្នេះ បរិមាណច្រើនបានតម្រូវឱ្យតម្លៃរថយន្តចុះថោកពីតម្លៃ ១ 200 ដុល្លារមក 825 ដុល្លារក្នុងមួយគ្រឿង ។ រថយន្តកាន់តែច្រើនតម្រូវការកញ្ចក់ និងកង់រថយន្តកាន់តែកើនឡើង ។ សម័យសេដ្ឋកិច្ចធ្លាក់ចុះបានជះឥទ្ធិពលមិនល្អដល់ពួកកសិករដែរ ។ កាលពីមុនសហរដ្ឋអាមេរិកជាអ្នកនាំចេញស្រូវសាលីធំជាងគេលើពិភពលោកត្រូវកាត់បន្ថយបរិមាណនាំចេញ ប៉ុន្តែតម្លៃនៅទីផ្សារអន្តរជាតិនៅតែធ្លាក់ចុះដដែល ។

បញ្ហាមួយទៀតគឺប្រជាជនដែលមានប្រាក់ទិញទំនិញ អាស្រ័យដោយខ្ចីប្រាក់ពីធនាគារ ។ ការខ្ចីប្រាក់ហើយមិនបានបង្វិលទាន់ពេលវេលាធ្វើឱ្យធនាគារអស់ប្រាក់បង្វិលនិងត្រូវក្ស័យធន ។ ប្រការនេះធ្វើឱ្យអ្នកមានប្រាក់ផ្ញើក្នុងធនាគារខ្លាចធនាគារដួលរលំបាត់បង់ទឹកប្រាក់របស់ខ្លួន គេប្រញាប់ប្រញាល់ទៅដកប្រាក់ពីធនាគារវិញ ។ នៅឆ្នាំ 1929 មានធនាគារចំនួន 700 បានបិទទ្វារ ។ ការបាត់បង់ប្រាក់កម្ចីពីធនាគារនេះហើយបណ្តាលឱ្យប្រជាជនកាត់បន្ថយតម្រូវការសម្ភារៈប្រើប្រាស់ ជាហេតុនាំឱ្យផលិតផលឧស្សាហកម្មសល់ និងគ្មានទីផ្សារ ។ តាមការធ្វើជំរឿននៅឆ្នាំ 1928 បានបង្ហាញថាប្រជាជនអាមេរិកចំនួន 60% រកបានមិនដល់ 2 000 ដុល្លារផងក្នុងមួយឆ្នាំ ។ ក្រៅពីនោះ 40% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ។ នៅចន្លោះឆ្នាំ 1929 ដល់ 1933 មានពាណិជ្ជករជាង 100 ពាន់នាក់ត្រូវក្ស័យធន និងកម្មករចំនួន 13 លាននាក់គ្មានការងារធ្វើ ។

### វិបត្តិសេដ្ឋកិច្ចឆ្នាំ 1929




## 2.2. វិធានការថ្មី (New Deal)


លោក រូស្វែល

លោក ប្រង់ឃ្លីនរូស្វែល (Franklin D.Roosevelt 1933 – 1945) ជាបេក្ខជនប្រធានាធិបតីមកពីគណបក្សប្រជាធិបតេយ្យ បានយកឈ្នះលោកហ៊ូវើរ (Herbert Hoover) នៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកឆ្នាំ 1932 ។ នៅពេលចូលកាន់តំណែងក្នុងសេតវិមាន លោកបានទាញអារម្មណ៍ប្រជាជនអាមេរិកចំពោះសុខភាពសេដ្ឋកិច្ចដែលកំពុងដុនដាបផ្ទុយពីលោក ហ៊ូវើរ ដែលពុំអើពើអំពីអន្តរាគមន៍របស់រដ្ឋាភិបាលនៅក្នុងវិស័យសេដ្ឋកិច្ច ។ លោក ប្រង់ឃ្លីន រូស្វែល បានរៀបចំផែនការដើម្បីព្យាបាលវិបត្តិសេដ្ឋកិច្ចឆ្នាំ 1929 ក្រោមវិធានការថ្មី (New Deal) ដែលមានន័យថាជាការជួយសង្គ្រោះសេដ្ឋកិច្ចជាបន្ទាន់តាមកំណែទម្រង់របស់រដ្ឋាភិបាល ។

លោក រូស្វែល ប្រើពេលចំនួន 100 ថ្ងៃក្នុងការរៀបចំផែនការស្តារសេដ្ឋកិច្ច ។ លោកក៏បានប្រើបណ្តាញព័ត៌មានវិទ្យុដើម្បីជូនប្រជាជាតិជ្រាបអំពីគម្រោងផែនការនេះ ។ ជាជំហានដំបូង គេបង្កើតភ្នាក់ងាររដ្ឋបាលសហព័ន្ធ(Federal Emergency Relief Administration = FERAL) នៅឆ្នាំ 1933 ។ ភ្នាក់ងារនេះជួយដល់អ្នកអត់ឃ្លាន និងគ្មានជម្រកជាទឹកប្រាក់ 500 លានដុល្លារ សម្រាប់ផ្តល់អាហារ សម្លៀកបំពាក់ និងការងារ ។ ក្រៅពីនេះមាន

- ភ្នាក់ងារកិច្ចការរដ្ឋបាលស៊ីវិល (The Civic Work Administration = CWA) មានទិសដៅបង្កើនមុខរបរឱ្យបានច្រើន ។ នៅរដូវរងាឆ្នាំ 1933-1934 ពលរដ្ឋអាមេរិក 4 លាននាក់មានការងារធ្វើ ដោយរដ្ឋាភិបាលបានបង្កើតការងារជាច្រើនដូចជា កសាងផ្លូវ សាលារៀន អាកាសយានដ្ឋាន ស្ពាន មន្ទីរពេទ្យ និងនាវាចម្បាំង ។
- ភ្នាក់ងារកិច្ចការរដ្ឋបាលសាធារណៈ( The Public Work Administration = PWA) សម្រាប់ជួយកសិករ ។ នៅខែឧសភា ឆ្នាំ 1933 បង្កើតភ្នាក់ងាររដ្ឋបាលកសិកម្ម ( Agricultural Adjustment Administration) ដើម្បីជួយកសិករបង្កើនប្រាក់ចំណូល ។
- ភ្នាក់ងារមូលនិធិសាជីវកម្មកម្ចី( The Home Owner Corporation = HOLC) ជួយប្រាក់ដល់ប្រជាជន ដើម្បីមានប្រាក់បង់ការទៅម្ចាស់បំណុល ចៀសវាងការបាត់បង់ផ្ទះសំបែង ។
- ភ្នាក់ងារជួយយុវជន ( The Civilian Corporation Corps = CCC) ជួយយុវជនដែលមានអាយុចន្លោះពី 18 ទៅ 25 ឆ្នាំក្នុងពេល 6 ខែ ឱ្យបោះជំរំនៅជនបទដាំដើមឈើនៅវាលទំនាប ដើម្បីទប់ទល់ពីសំណឹកទឹកភ្លៀង និងចម្រោះជីជាតិ ដោយរដ្ឋឧបត្ថម្ភជាជម្រក ស្បៀង សម្លៀកបំពាក់ និងផ្តល់ប្រាក់សម្រាប់ហោប៉ៅក្នុងមួយថ្ងៃ 1 ដុល្លារ ។
- នៅក្នុងមហាវិបត្តិសេដ្ឋកិច្ច ប្រជាជនអស់ជំនឿលើធនាគារ ប្រាក់បញ្ញើត្រូវគេដកអស់ ធ្វើឱ្យធនាគារជាច្រើនត្រូវបិទទ្វារ ។ នៅឆ្នាំ 1933 គេបានបង្កើតច្បាប់ ជួយធនាគារឱ្យបើកទ្វារឡើងវិញដោយរដ្ឋឱ្យខ្ចីប្រាក់ ។

វិធានការថ្មីមិនបានរំដោះប្រជាជនឱ្យរួចពីគ្រោះក្រីក្រទាំងស្រុងឡើយ មានប្រជាជនស្បែកខ្មៅត្រឹមតែ $\frac{1}{3}$ ប៉ុណ្ណោះទទួលបានការសង្គ្រោះនេះ ហើយពួកកសិករជាច្រើនទៀតស្ថិតក្នុងភាពទន់ខ្សោយនៅឡើយ ។

### 2.3. សហរដ្ឋអាមេរិកនៅក្រោយសង្គ្រាមលោកលើកទី 2

ក្រោយសង្គ្រាមលោកលើកទី 2 មានតែសហរដ្ឋអាមេរិកមួយប៉ុណ្ណោះដែលបានគេចផុតពីការខូចខាតខាងសេដ្ឋកិច្ច ព្រោះសហរដ្ឋអាមេរិកស្ថិតនៅឆ្ងាយពីទ្វីបអឺរ៉ុបរាប់ពាន់គីឡូម៉ែត្រ ។

សហរដ្ឋអាមេរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចគ្មានគូប្រៀប ។ ប្រទេសមហាអំណាចនៅអឺរ៉ុបភាគច្រើនត្រូវការមូលធន និងជំនួយដើម្បីស្តារសេដ្ឋកិច្ចជាតិខ្លួនឡើងវិញ ។ ការស្រេកឃ្លានអាហារបានជំរុញឱ្យកសិករអាមេរិកពង្រីកវិស័យកសិកម្ម ដើម្បីបំពេញតម្រូវការទីផ្សារអឺរ៉ុបដ៏ធំធេង ។

នៅចន្លោះឆ្នាំ 1939-1945 ផលទុនសរុបរបស់សហរដ្ឋអាមេរិកបានកើនឡើងពី 95 ដល់ 215 ពាន់លានដុល្លារ ។

នៅចន្លោះឆ្នាំ 1990-2000 សហរដ្ឋអាមេរិកមានកំណើនប្រជាជនខ្លាំងដោយសារការហូរចូលនៃចំណាកស្រុកមកពីទ្វីបអាស៊ី ជាពិសេសគឺអាស៊ីអាគ្នេយ៍ អាមេរិកកណ្តាលនិងខាងត្បូងដែលស្វះស្វែងរកផ្លូវចូលទៅសហរដ្ឋអាមេរិក ដោយមូលហេតុសេដ្ឋកិច្ច និងនយោបាយ ម្យ៉ាងទៀតរួមទាំងកំណើននៃប្រជាជនស្បែកខ្មៅដើមកំណើតអាហ្វ្រិកផងបានជំរុញសហរដ្ឋអាមេរិកឱ្យក្លាយជាប្រទេសដែលមានប្រជាជនច្រើន លំដាប់ទី 3 បន្ទាប់ពីប្រទេសចិនប្រជាមានិត និងឥណ្ឌា ។

ប្រជាជនអាមេរិកបានកែច្នៃជីវភាពឱ្យក្លាយជាសង្គមសម្ភារៈស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ។ គេបានបង្កើតនូវប្រព័ន្ធផ្សព្វផ្សាយពាណិជ្ជកម្មបង្ហាញផលិតផលថ្មីៗដូចជា ទូរទស្សន៍ពណ៌ ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនលាងចានឆ្នាំង ចង្ក្រានអគ្គិសនី ... ។ គ្រឿងសង្ហារិមដ៏ប្រណីត ម៉ាស៊ីនត្រជាក់ រហូតដល់រថយន្តសម្រាប់ទៅធ្វើការផ្ទាល់ខ្លួនទៀតផង ។

## 3. សហរដ្ឋអាមេរិកនាទសវត្សរ៍ឆ្នាំ 60-80 នៃស. វទី 20

### 3.1. សហរដ្ឋអាមេរិកក្នុងសករាជព្រំដែនថ្មី (New Frontier)

លោកចន កេណ្ណឌី មានដើមកំណើតជាជនជាតិអៀរឡង់មកពីគណបក្សប្រជាធិបតេយ្យបានចូលកាន់តំណែងប្រធានាធិបតីសហរដ្ឋអាមេរិកក្នុងឆ្នាំ 1960 ក្នុងអាយុ 43 ឆ្នាំ បន្តពីលោកអេស៊ិនហាវ័រមកពីគណបក្សសាធារណរដ្ឋ ។ អស់រយៈពេល 8 ឆ្នាំក្នុងរដ្ឋបាលអេស៊ិនហាវ័រ សហរដ្ឋអាមេរិកមានកំណើនសេដ្ឋកិច្ចយឺត អតិផរណាជាប្រចាំ និងកំណើនអ្នកឥតការងារធ្វើខ្ពស់ ហើយតម្លៃប្រាក់ដុល្លារចុះថោក ។ កិត្យានុភាពសហរដ្ឋអាមេរិកត្រូវបាត់បង់នៅឆ្នាំ 1957 ដោយសហភាពសូវៀតបានបង្ហោះយានស្ពុតនិក (Sputnik) ជាលើកដំបូងរបស់ខ្លួន ។ ប្រធានាធិបតី កេណ្ណឌី បានបង្ហាញនយោបាយព្រំដែនថ្មីរបស់លោកគឺការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការយឺតយ៉ាវផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា ដែលជាវិបត្តិបន្សល់ពីប្រធានាធិបតីអាណត្តិមុន ។

នៅថ្ងៃទី 22 ខែវិច្ឆិកា ឆ្នាំ 1963 ប្រធានាធិបតីកេណ្ណឌី(1960-1963) ត្រូវគេធ្វើឃាតនៅទីក្រុងដាឡាស(Dallas) នៃរដ្ឋតិចសាស ហើយអនុប្រធានាធិបតីចនសុន(Lyndon Jonhson 1963-1969) ជាអ្នកកាន់ដំណែងបន្ត និងរ៉ាប់រងផែនការមួយចំនួនដែលសេសសល់ពីអាណត្តិ កេណ្ណឌី ។ ម្យ៉ាងទៀត សង្គ្រាមវៀតណាមបានចោទជាបញ្ហាដល់សេដ្ឋកិច្ចអាមេរិក (ចំណាយប្រាក់ 20 ពាន់លានដុល្លារ ឆ្នាំ 1965-1973) ។

លោក និចសុន (Richard Nixon 1969-1974) បានឡើងជាប្រធានាធិបតីបន្ត ។ ការកង្វល់របស់លោក គឺបញ្ចប់សង្គ្រាមនៅវៀតណាម ។ នៅទីបំផុត សហរដ្ឋអាមេរិកបានបញ្ចប់សង្គ្រាមដោយឈប់ផ្តល់ជំនួយខាងសេដ្ឋកិច្ច និងយោធាទុកឱ្យវៀតណាមខាងជើងមានឱកាសចូលកាន់កាប់ក្រុងព្រៃនគរ នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1975 ។ ការទម្លាក់គ្រាប់បែកលើជនស៊ីវិល ការសម្លាប់រង្គាល នាំឱ្យមានប្រតិកម្មរិះគន់ពីសភាដែលឈ្លោះទៅរកការផ្តាច់ជំនួយទាំងស្រុងដល់វៀតណាមខាងត្បូងនៅឆ្នាំ 1973 ។ លោក និចសុន ជាប្រធានាធិបតីតែម្នាក់គត់នៅក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក ដែលត្រូវដកហូតពីតំណែងដោយសាររឿងអាស្រូវ វ៉ាទ័រហ្គេត (Watergate) ក្នុងសម័យបោះឆ្នោត ដោយលោកបានលាលែងពីតំណែងនៅថ្ងៃទី 9 ខែមេសា ឆ្នាំ 1974 ។

## ៣.2. សហរដ្ឋអាមេរិក និងការវិវត្តនៃសង្គ្រាមត្រជាក់

សង្គ្រាមត្រជាក់ គឺការប្រណាំងប្រជែងខាងការអភិវឌ្ឍគ្រឿងសព្វាវុធ និងបច្ចេកវិទ្យា រវាងប្លុកកុម្មុយនិស្តនិងប្លុកសេរី ពោលគឺជាការកាច់បំបាក់គ្នារវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀត ។ ចំណុចសំខាន់នៃសង្គ្រាមនេះផ្តើមចេញពីបញ្ហាអាល្លឺម៉ង់ នៅពេលដែលប្រទេសនេះក្លាយជាទីប្រសព្វមុខនៃមនោគមន៍វិជ្ជាទាំងពីរក្រោយបញ្ចប់សង្គ្រាមលោកលើកទី 2 ។

នៅឆ្នាំ 1957 សហភាពសូវៀតបានបង្ហោះយានស្ពុតនិក(Sputnik) មានមនុស្សជិះលើកដំបូងគឺលោក យូរីហ្គាហ្គារិន(Youri Gagarine) ទៅកាន់ទីអវកាស ។ ការឆ្លើយតបនិងរបកគំហើញរបស់សូវៀត ប្រធានាធិបតី កេណ្ណឌី បានជំរុញឱ្យអង្គការអវកាសណាសា(National Aeronautics and Space Administration) ធ្វើការស្រាវជ្រាវនៅក្នុងទីអវកាស ដោយប្រើថវិកាសហព័ន្ធយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ នៅឆ្នាំ 1967 សហរដ្ឋអាមេរិកបានយកឈ្នះសូវៀត ដោយសម្រេចឱ្យមានមនុស្សជាន់លើឋានព្រះចន្ទលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិក្នុងការឈ្លោះទៅរកភពខែ ។

## ក. សហរដ្ឋអាមេរិកក្នុងអាណត្តិ កេណ្ណឌី


លោក កេណ្ណឌី


លោក ចនសុន

ប្រធានាធិបតីសហរដ្ឋអាមេរិកកេណ្ណឌី ជាអ្នកទទួលខុសត្រូវចំពោះមុខប្រជាជាតិអាមេរិកទាំងមូល ប្រសិនបើសង្គ្រាមបរមាណូផ្ទុះឡើង ។ ចំពោះដំណោះស្រាយបញ្ហាអាយុជីវិតនេះ សហរដ្ឋអាមេរិកបានគំរាមថានឹងលើកទ័ពវាយឡើងកោះគុយបា ប្រសិនបើនាវាដឹកក្បាលបរមាណូរបស់សូវៀតចូលទៅចតក្នុងកំពង់ផែគុយបា ។ ចម្លើយតបរបស់វិមានក្រឹមឡាំង(Kremlin)បានប្រកាសថា បើសហរដ្ឋអាមេរិកមិនវាយឡើងគុយបានោះទេ សហភាពសូវៀតនឹងដកថយ ។ នៅថ្ងៃទី 29 ខែតុលា ឆ្នាំ1962 គ្រូតឆូវ បានបញ្ជាឱ្យជម្លៀសក្បាលកាំជ្រួចចេញពីគុយបា ក្រោមការត្រួតពិនិត្យនៃអង្គការសហប្រជាជាតិ ។ បញ្ហាវិបត្តិកាំជ្រួចនៅគុយបារកកលនិងនាំពិភពលោកទៅដល់មាត់ទ្វារនៃសង្គ្រាមលោកលើកទី 3 ។

## ខ. សហរដ្ឋអាមេរិកនៅក្នុងអាណត្តិ ជីមីកាទ័រ


លោក ជីមីកាទ័រ


លោក អាយ៉ាតូឡា ខូមេនី (អ៊ីរ៉ង់)

នៅក្នុងអាណត្តិលោក កាទ័រ សហរដ្ឋអាមេរិកត្រូវថយឥទ្ធិពលលើឆាកអន្តរជាតិនៅចំពោះបញ្ហាអាស្រូវនៅអ៊ីរ៉ង់ ដោយសារមានការឃុំឃាំងបុគ្គលិកស្ថានទូតអាមេរិកអស់រយៈពេល 444 ថ្ងៃនៅក្រុងតេហេរ៉ង់ នៅឆ្នាំ 1974 ។ នៅឆ្នាំ 1979 សូវៀតលើកទ័ពចូលលុកលុយអាហ្វហ្គានីស្ថាន ។ ចំណុចទាំងនេះបញ្ជាក់ពីការចុះថយឥទ្ធិពលសហរដ្ឋអាមេរិកនៅចំពោះមុខសហភាពសូវៀត ។ បរាជ័យនយោបាយក្រៅប្រទេសបានកាត់បន្ថយអាណត្តិប្រធានាធិបតីកាទ័រ ឱ្យនៅតែមួយអាណត្តិ ដោយត្រូវចាញ់បេក្ខជនប្រធានាធិបតីពីគណបក្សសាធារណរដ្ឋ រីកេន នៅក្នុងការបោះឆ្នោតនៅឆ្នាំ 1980 ។

## គ. សហរដ្ឋអាមេរិកក្នុងអាណត្តិ រ៉ូណាល់ រីគេន



លោក រីគេន

- អាណត្តិទី I (1981 -1984) : នៅក្នុងតំណែងប្រធានាធិបតីថ្មីដោយចាប់ផ្តើមនយោបាយទ័ពព្រៃផ្តាច់ការ ដូចជាគាំទ្ររបបកុងត្រាស (Contras) នៅនីការ៉ាហ្គា ជាពិសេសការប្រឆាំងនឹងឥទ្ធិពលសូវៀតនៅអាមេរិកខាងត្បូង ដោយហៅសហភាពសូវៀតថា ចក្រភពបិសាច (Axe of Evil) រាប់បញ្ចូលទាំងប្រទេសមួយចំនួនដូចជា គុយបា និងអ៊ីរ៉ង់ជាដើម ។ លោក រីគេនបានរៀបចំគម្រោងបង្កើតប្រព័ន្ធសង្គ្រាមផ្កាយប្រឆាំងនឹងគូបដិបក្ខដោយចំណាយថវិកាជាច្រើនឥតគណនា ព្រោះជាការទាមទារបច្ចេកវិទ្យាខ្ពស់បំផុត ។ លោក រីគេន បានដាក់ពង្រាយកាំជ្រួចផុន ភើស៊ីង II (Pershing II) លើទ្វីបអឺរ៉ុបដើម្បីប្រឆាំងនឹងកាំជ្រួចផុនទំនើប អេស អេស20 (SS 20) របស់សហភាពសូវៀត ។ កងទ័ពសហរដ្ឋអាមេរិកបើកការវាយប្រហារឡើងកោះគ្រើណាដ ដែលគាំទ្រដោយគុយបាក្នុងការបង្ហាញពីជំហររបស់សហរដ្ឋអាមេរិកតាមរយៈកម្លាំងយោធា ។




វិបត្តិនៅគុយបា (1962)

- អាណត្តិទី 2 (1984-1988) ៖ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានឱនភាពយ៉ាងខ្លាំងដោយការចំណាយទៅលើការរត់ប្រណាំងសព្វាវុធ និងបានក្លាយជាប្រទេសជំពាក់បំណុលច្រើនបំផុតលើពិភពលោក ។ ដើម្បីកាត់បន្ថយវិបត្តិនេះ រីគេន បានប្ដូរឥរិយាបថទៅរកភាពសម្របសម្រួលជាមួយសហភាពសូវៀត ដែលនយោបាយចុងក្រោយនេះទុកឱ្យប្រធានាធិបតីថ្មីជាអ្នកអនុវត្តបន្ត ។
- ការរត់ប្រណាំងសព្វាវុធ បានធ្វើឱ្យប្រធានាធិបតីចុងក្រោយនៃសហភាពសូវៀតលោក ហ្គោបាឆូវកាត់បន្ថយការចំណាយរបស់សហភាពសូវៀតនៅក្រៅប្រទេសដូចជា ការដកទ័ពសូវៀតចេញពីអាហ្វហ្គានីស្ថាន (1988-1989) និងបដិសេធឈប់ផ្ដល់ជំនួយដល់រដ្ឋាភិបាលសម្ព័ន្ធភាពលើពិភពលោក ។ នៅចុងបំផុតលោក ហ្គោបាឆូវ ខិតខំប្រើនយោបាយសម្របសម្រួលជាមួយលោកខាងលិចដើម្បីបញ្ចប់ភាពតានតឹង ។ តាមសន្ធិសញ្ញាវ៉ាស៊ីនតោននៅខែធ្នូ ឆ្នាំ 1987 បានសម្រេចកាត់បន្ថយគ្រឿងសព្វាវុធទាំងសងខាងឱ្យអស់ពីអឺរ៉ុប ។ នៅឆ្នាំ 1990 តាមការចរចានៅប៉ារីស បានកាត់បន្ថយអាវុធនុយក្លេអ៊ែររវាងបក្សអូតង់ និងវ៉ាសូវីក្នុងចំនួនខ្ពស់បំផុត ។

## ? សំណួរ

1. តើផែនការញូវឌាល ជាអ្វី ? នរណាជាអ្នកបង្កើតឡើង ?
2. ហេតុអ្វីបានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចនៅក្រោយសង្គ្រាមលោកលើកទី 2 ?
3. តើព្រំដែនថ្មីជាអ្វី ? ហើយមានទិសដៅអ្វីខ្លះ ?
4. ក្រោយសង្គ្រាមត្រជាក់ តើប្រទេសអឺរ៉ុបខាងកើតមានការប្រែប្រួលដូចម្ដេច ?

មេរៀនទី

# 2 ចក្រភពអង់គ្លេស

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយពីនយោបាយរបស់អង់គ្លេសពីឆ្នាំ 1945-1995 ។
- រៀបរាប់ពីវិបត្តិនៅអ៊ុលស្ទ័រ ។
- ប្រៀបធៀបការដឹកនាំរបស់គណបក្សការងារនិយម និងគណបក្សអភិរក្សនិយម ។

អង់គ្លេសជាប្រទេសដែនកោះឬអឺរ៉ុបដីទឹក ពុះខណ្ឌពីអឺរ៉ុបដីគោកដោយច្រកសមុទ្រម៉ង់(Manche)ដែលមានចម្ងាយ 32 km បែងចែកជាទឹកដី 4 ផ្នែកគឺ គ្រង់ប្រឹតាញ អេកូស ប្រទេសហ្គាល់ និង អៀរឡង់ខាងជើង ។ ចក្រភពអង់គ្លេសមានទំហំ 224 046 km$^2$ មានប្រជាជន 58 លាននាក់(2006) ។ ចក្រភពអង់គ្លេសជាមហាអំណាចអាណានិគមធំជាងគេនៅមុនសង្គ្រាមលោកលើកទី ១ ជាប្រទេសរៀមច្បងខាងបដិវត្តន៍ឧស្សាហកម្មដោយសារសម្បូរធ្យូងថ្ម ហើយជាប្រទេសមហាអំណាចជើងទឹកទី ១ នៅលើពិភពលោកមុនសង្គ្រាមលោកលើកទី 2 អង់គ្លេសបាននាំមុខខាងវិស័យពាណិជ្ជកម្មនិងយោធា ។




*ផែនទីចក្រភពអង់គ្លេស*

# 1. ប្រទេសអង់គ្លេសនិងសង្គ្រាមលោកលើកទី 2



លោក វិនស្តុន ឆឺឈីល

ប្រទេសអាល្លឺម៉ង់បានចូលលុកលុយប្រទេសប៉ូឡូញនៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 1939 ។ នេះគឺជាការបើកឆាកនៃសង្គ្រាមលោកលើកទី 2 ។ ពីរថ្ងៃក្រោយមក អង់គ្លេស និងបារាំងបានប្រកាសសង្គ្រាមនឹងអាល្លឺម៉ង់ ។ នៅខែមេសា ឆ្នាំ 1940 កងទ័ពអាល្លឺម៉ង់បានចូលលុកលុយប្រទេស ដាណឺម៉ាក និងន័រវែស ។ កងទ័ពអង់គ្លេសបានទទួលបរាជ័យក្នុងបេសកកម្មដើម្បីជួយប្រទេសន័រវែស ។ ពេលនោះលោក សំប៊ែឡាំង មកពីគណបក្សអភិរក្សនិយមបានចុះចេញពីតំណែងនៅថ្ងៃទី 10 ខែមិថុនា ឆ្នាំ 1940 ហើយ វិនស្តុន ឆឺឈីល (Winston Churchill) បានឡើងជានាយករដ្ឋមន្ត្រីបន្ត នៅក្នុងរាជរដ្ឋាភិបាលសម្ព័ន្ធភាពដែលមានគណបក្ស 3 គឺអភិរក្សនិយម ការងារនិយម និងសេរីនិយម ។ នៅថ្ងៃទី 12 ខែឧសភា ឆឺឈីលបានថ្លែងនៅមុខសភាដោយសម្ដីគួរឱ្យគោរពថា ខ្ញុំគ្មានអ្វីជូនប្រជាជនអង់គ្លេសទេគឺមានតែឈាម ការតស៊ូ ទឹកភ្នែក និងញើសប៉ុណ្ណោះដើម្បីដណ្ដើមយកជ័យជម្នះ ។ នៅឆ្នាំ 1940 នៅពេលដែលបារាំងទទួលបរាជ័យ ឆឺឈីលបានចងសម្ព័ន្ធមិត្តជាមួយសហរដ្ឋអាមេរិក ។

អាចជាភ័ព្វសំណាងរបស់អង់គ្លេសដែរ ដោយនៅថ្ងៃទី 7 ខែធ្នូ ឆ្នាំ 1941 ទ័ពជើងអាកាសជប៉ុនបានវាយប្រហារលើមូលដ្ឋានសឹកដ៏ធំរបស់សហរដ្ឋអាមេរិកប្រចាំប៉ាស៊ីហ្វិក ភាលហាប័រ (Pearl Harbor) នៅក្នុងរដ្ឋហាវ៉ៃ ។ ពេលនោះសង្គ្រាមលោកលើកទី 2 បានរីកធំថែមទៀតនៅប៉ាស៊ីហ្វិករវាងសហរដ្ឋអាមេរិក និងជប៉ុន ។ មិនតែប៉ុណ្ណោះ សហរដ្ឋអាមេរិកបានប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់ដែលជាដៃគូជប៉ុន ហើយបើកការវាយប្រហារឡើងគោកនៅ ន័រម៉ង់ឌី (ប្រទេសបារាំង) រួមជាមួយកងទ័ពអង់គ្លេស ។ នៅពេលដែលអាល្លឺម៉ង់ចូលលុកលុយសហភាពសូវៀត ឆឺឈីល បានចរចាជាមួយស្តាលីន (Stalin) ដើម្បីបើកសមរភូមិខាងកើត ។ ឆឺឈីល ជួយសម្រួលឱ្យមានសន្និសីទជាច្រើនដូចជាសន្និសីទតេហេរ៉ង់ កេបិច យ៉ាល់តា និងផតដាមជាដើម ដើម្បីបញ្ចប់សង្គ្រាមលោកលើកទី 2 ។ ដោយសារគំនិតប្រឆាំងកុម្មុយនីស្ត អង់គ្លេសបានក្លាយជាដៃគូប្រឆាំងនឹងសហភាពសូវៀតនៅសម័យសង្គ្រាមត្រជាក់ ។ ឆឺឈីលបានថ្លែងនៅហ្វុលតុន លើទឹកដីសហរដ្ឋអាមេរិកថា ពេលនេះវាំងននដែកបានបែងចែកទ្វីបអឺរ៉ុបជាពីរគឺ ខាងលិច និងខាងកើត ។

## 2. គណបក្សការងារនិយម (1945-1951)

លោក ក្លីមិន អាតលី (Clement Attlee) មកពីគណបក្សការងារនិយមបានបន្តតំណែងនាយករដ្ឋមន្ត្រីដែលអនុវត្តនយោបាយក្នុងការស្តារប្រទេសនៅក្រោយសង្គ្រាម ។

### 2.1. នយោបាយរដ្ឋឧបត្ថម្ភ (WelFare State)

ពាក្យនេះហៅចំពោះនយោបាយរបស់គណបក្សការងារនិយមដែលបានដឹកនាំប្រទេសចាប់ពីឆ្នាំ 1945-1951 ដើម្បីជួយសង្គ្រោះប្រជាជន 25 លាននាក់ដែលជាអ្នកឥតការងារធ្វើ អ្នកជំងឺ ស្ត្រីមេម៉ាយ មន្ត្រីចូលនិវត្តន៍ និងចាស់ជរា ។

#### ក. សេវាសុខភាព

គេបានបង្កើតមន្ទីរពេទ្យជាច្រើនដើម្បីផ្តល់សេវាថែទាំសុខភាពដែលធានាដល់ការព្យាបាលជំងឺ និងចែកចាយថ្នាំដោយឥតគិតថ្លៃ សម្រាប់ប្រជាជន 95% ដោយស្មើភាព និងគ្មានការរើសអើង ។ រដ្ឋបានបង្កើតភ្នាក់ងារសុខភាពចំនួន 34 ពាន់នាក់ទូទាំងប្រទេស ចាប់ពីទីក្រុងរហូតដល់ជនបទដោយចំណាយប្រាក់ចំនួន 400 លានផោន ស្មើនឹង 3.5% នៃថវិកាជាតិ ។ លោក ប៊ីវ៉ាន់ (Bevan) ជារដ្ឋមន្ត្រីក្រសួងសុខាភិបាលបានប៉ាន់ប្រមាណឃើញថា មានមនុស្ស 8.5 លាននាក់ត្រូវការព្យាបាលធ្មេញនិងភ្នែកដោយតម្រូវការវ៉ែនតាចំនួន 5 លានសម្រាប់ ។

#### ខ. បញ្ហាលំនៅឋាន (1945-1950)

ដើម្បីចៀសវាងការរីកដុះដាលនៃសំណង់អនាធិបតេយ្យនៅតាមទីក្រុង រាជរដ្ឋាភិបាលបានសាងសង់លំនៅឋានចំនួន 157 ពាន់ខ្នង និងផ្ទះល្វែងចំនួន 806 ពាន់ខ្នងថែមទៀត ជួសជុលផ្ទះបាក់បែកចំនួន 333 ពាន់ខ្នងផ្សេងទៀត ។ នៅក្នុងការដោះស្រាយនូវវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលអង់គ្លេសបានធ្វើជាតូបនីយកម្មចាប់ពីរោងចក្រ ធនាគារ ផ្លូវដែក កំពង់ផែ ធនធានរ៉ែ និងត្បូងថ្មផ្សេងៗជាច្រើនទៀត ។

### 2.2. ការធ្លាក់ចុះនៃចក្រភព

នៅក្រោយសង្គ្រាមលោកលើកទី 2 ចក្រភពអង់គ្លេសដែលធ្លាប់រុងរឿងបានចុះអន់ថយដោយសារប្រទេសនៅក្រោមអាណានិគមនៃទ្វីបផ្សេងៗបានបះបោរក្រោកឡើងទាមទារឯករាជ្យជាបន្តបន្ទាប់ ។ នៅទ្វីបអាស៊ី ឥណ្ឌាបានទាមទារឯករាជ្យព្រមទាំងបានបង្កើតនូវរដ្ឋមួយទៀតគឺសាធារណរដ្ឋប៉ាគីស្ថាននៅឆ្នាំ 1947 ដែលបង្កើតនូវអស្ថិរភាពនយោបាយ និងសង្គម គឺបញ្ហាការស្មៀដែលម្ខាងនៅ

ឥណ្ឌា និងម្ខាងទៀតនៅប៉ាគីស្ថាន ហើយសព្វថ្ងៃប្រទេសទាំងពីរនេះជាប្រទេសផលិតអាវុធបរមាណូដូចគ្នា ហើយភាគីទាំង 2 តែងតែដណ្តើមឧត្តមភាពគ្នាឥតឈប់ឈរ ។ នៅឆ្នាំ 1948 អង់គ្លេសបានប្រគល់ឯករាជ្យឱ្យកោះស្រីលង្កាទៀត ។ ទោះបីជាប្រទេសនៅក្នុងឧបទ្វីបឥណ្ឌាទាំងបីនេះមានវិវាទនឹងគ្នាយ៉ាងណាក៏ដោយក៏នៅតែជាសមាជិកនៃអង្គការកំម៉ុនវិល (Commonwealth)[(1)] ជាមួយគ្នាដដែល ។ នៅឆ្នាំ 1949 សាធារណរដ្ឋអៀរឡង់សេរីឬអៀរឡង់ខាងត្បូងបានទាមទារឯករាជ្យ និងផ្តាច់ចេញពីអង្គការកំម៉ុនវិល ។ ចំណែកដែនដីញូវហ្វោនឡិន (New Foun Land) ត្រូវបញ្ចូលទៅជាខេត្តមួយនៃប្រទេសកាណាដា ។ សាធារណរដ្ឋអាហ្វ្រិកខាងត្បូងបានឯករាជ្យតាំងពីឆ្នាំ 1931 ជាមួយនឹងអូស្ត្រាលី នូវែលសេឡង់ ហើយប្រទេសទាំងនេះបានចាកចេញពីអង្គការកំម៉ុនវិលនៅឆ្នាំ 1961 ក្រោយមកប្រទេសអង់គ្លេសបានធ្វើអន្តរាគមន៍ទៅរករបបប្រកាន់ពូជសាសន៍រវាងស្បែកស និងស្បែកខ្មៅ ដែលហៅថា របបអាប៉ាថេត (Apartheid) ។ នៅទសវត្សរ៍ឆ្នាំ 50 មានប្រទេសក្រោមអាណានិគមអង់គ្លេសកាន់តែច្រើនថែមទៀតបានទទួលឯករាជ្យដូចជា ព្រុយណេ ហ្គាណា កេនយ៉ា ម៉ាឡេស៊ី ប៉ាពូហ្គីណេ នីហ្សេរីយ៉ា ស៊ូដង់ ទីប្រជុំកោះសូឡូម៉ុង អ៊ូហ្គង់ដា ... ។ ទោះជាយ៉ាងណាក៏ដោយប្រទេសអាណានិគមអង់គ្លេសភាគច្រើននៅតែជាសមាជិកនៃអង្គការកំម៉ុនវិលដដែល ។

## 3. រដ្ឋាភិបាលអភិរក្សនិយម (1951-1964)

នៅក្នុងដំណាក់កាលនេះ គេឃើញនាយករដ្ឋមន្ត្រី 4 រូបគឺ

- លោក វិនស្តុន ឆឺឈីល តំណែងលើកទី 2 : 1951-1955
- លោក អង់តូនី អេដែន (Anthony Eden) : 1955-1957
- លោក ហារូល ម៉ាក់មីឡិន (Harold Macmillan) : 1957-1963
- លោក អាឡិច ឌូក្លាសហូម (Alec Douglas Home) : 1963-1964

អស្ថិរភាពនយោបាយការបរទេសរបស់ចក្រភពអង់គ្លេសកើតឡើងនៅពេលដែលចក្រភពអង់គ្លេសកំពុងវិកវរ ដោយវិបត្តិអាណានិគមនោះ អឺរ៉ុបដីគោកបានបង្កើតសហគមន៍មួយហៅថាផ្សាររួមអឺរ៉ុប ដែលបង្កើតដោយបារាំង និងប្រទេស 5 ផ្សេងទៀតនៅអឺរ៉ុប ។ អង់គ្លេសបានប្រកែកមិនព្រមចូលរួមជាមួយអង្គការផ្សាររួមអឺរ៉ុបនេះពីព្រោះចក្រភពអង់គ្លេសយល់ឃើញថាគេមានទីផ្សារកំម៉ុនវិលដ៏ធំ ការចូលរួមក្នុងផ្សាររួមអឺរ៉ុបនាំឱ្យខូចឯករាជ្យរបស់ប្រទេសខ្លួន ។

---

(1). រដ្ឋសហធន

នៅក្រោយសង្គ្រាមលោកលើកទី2 អង់គ្លេសមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ជាពិសេសគឺការចូលរួមក្នុងការបង្កើតសន្ធិសញ្ញាអាត្លង់ទិកខាងជើង (North Atalantic Treaty Organization = NATO) ដើម្បីការពារទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក ។ ចក្រភពអង់គ្លេសបានចូលប្រឡូកក្នុងសង្គ្រាមកូរ៉េឆ្នាំ 1950-1953 ។

នៅឆ្នាំ 1956 នៅក្រោមការដឹកនាំរបស់ ណាសែរ ប្រទេសអេហ្ស៊ីបបានធ្វើជាតូបនីយកម្មព្រែកជីក ស៊ុយអេ (Suez Canal) ដែលកាន់កាប់ដោយបារាំង និងអង់គ្លេស ។ ប៉ុន្តែ ក្រោមការគាបសង្កត់ពីសំណាក់អង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក និងសហភាពសូវៀត បារាំង និងអង់គ្លេសបានដកថយពីព្រែកជីកនេះ ។

ដោយយល់ឃើញថាការចូលជាសមាជិកទីផ្សាររួមអឺរ៉ុបអាចឱ្យអង់គ្លេសមានផលចំណេញច្រើនខាងសេដ្ឋកិច្ច ជាពិសេសវិស័យពាណិជ្ជកម្ម រដ្ឋាភិបាលខ្ទង់ក្លាសហ្វូម បានដាក់ឈ្មោះសុំចូលជាសមាជិកផ្សារនេះ ប៉ុន្តែត្រូវបរាជ័យដោយសារ លោក ដឺហ្គោល ប្រធានាធិបតីបារាំងប្រើសិទ្ធិវេតូនៅថ្ងៃទី 14 ខែមករា ឆ្នាំ 1963 ។ ដឺហ្គោលបានយល់ឃើញថាចក្រភពអង់គ្លេសជាដៃគូជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ប្រទេសបារាំងចង់រក្សាឯករាជ្យ និងអធិបតេយ្យភាព មិនចង់ឱ្យមានឥទ្ធិពលសហរដ្ឋអាមេរិកនៅទ្វីបអឺរ៉ុបជាពិសេសគឺតួនាទីរបស់អាមេរិកនៅក្នុងសម្ព័ន្ធអាត្លង់ទិកខាងជើង ដែលមានសហរដ្ឋអាមេរិកជាអ្នកដឹកនាំ និយាយឱ្យចំគឺ ការបដិសេធឧត្តមភាពទាំងសហរដ្ឋអាមេរិក និងសហភាពសូវៀត ។ នយោបាយនេះតម្រូវឱ្យបារាំងប្រឹងប្រែងបង្កើតកម្លាំងបរមាណូដោយខ្លួនឯងដើម្បីឱ្យមានតុល្យភាព និងមហាអំណាចទាំងពីរ ។ តាំងពីពេលនោះមកបារាំងតែងធ្វើការសាកល្បងអាវុធប្រភេទនេះ នៅក្នុងតំបន់ប៉ាស៊ីហ្វិកលើកោះម៉ូរូអា ដែលធ្វើឱ្យអូស្ត្រាលីប្រឆាំងយ៉ាងខ្លាំងក្លា ។ ដោយសារគំនិតចង់ពង្រីកសហគមន៍ផ្សាររួមអឺរ៉ុប ទើបក្រោយមកចក្រភពអង់គ្លេសបានចូលជាសមាជិកនៅឆ្នាំ 1973 នៅក្នុងអាណត្តិប្រធានាធិបតីបារាំង ប៉ុមពីឌូ(Georges Pompidou) ។

រដ្ឋាភិបាល ហារ៉ូល វិលសុន (Harold Wilson 1964-1970) គណបក្សការងារនិយម នៅពេលឡើងកាន់អំណាចលោក វិលសុន ត្រូវប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចដែលបន្សល់ទុកពីអាណត្តិមុន ជាពិសេសគឺអតុល្យភាពពាណិជ្ជកម្ម ។ ចក្រភពអង់គ្លេសមានបំណុលបរទេសជាច្រើន ជាពិសេសគឺសហរដ្ឋអាមេរិក ។ ដើម្បីស្តារវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលបានដំឡើងពន្ធដារលើទំនិញគ្រប់ប្រភេទ ។ នៅថ្ងៃទី 11 ខែមិថុនា ឆ្នាំ 1967 អង់គ្លេសត្រូវទទួលបរាជ័យទៀតក្នុងការបញ្ចូលបេក្ខភាពនៅក្នុងទីផ្សាររួមអឺរ៉ុបដែលធ្វើឱ្យរដ្ឋាភិបាល វិលសុន កាន់តែមានការលំបាកខ្លាំងក្នុងបញ្ហាសេដ្ឋកិច្ច ។

## 4. រដ្ឋាភិបាល អេតវត ហ៊ីត (Edward Heath 1970-1974)

នៅឆ្នាំ1970 លោក អេតវត ហ៊ីត មកពីគណបក្សអភិរក្សនិយមបានឈ្នះឆ្នោត ដែលពេលនោះលោក អេតវត ហ៊ីត ជានាយករដ្ឋមន្ត្រី ។ បញ្ហាដែលចម្រូងចម្រាស គឺបញ្ហាដាក់បេក្ខភាពចក្រភពអង់គ្លេសចូលទីផ្សាររួមអឺរ៉ុបនៅឆ្នាំ 1971 ។ ការជួបគ្នារវាង ហ៊ីត និងប៉ុមពីឌូ មានការរីកចម្រើនទៅមុខយ៉ាងខ្លាំង អាស្រ័យដោយអង់គ្លេសបានធ្វើការបរិច្ចាគយ៉ាងច្រើនចំពោះសំណើរបស់ភាគីបារាំង ហើយឈានទៅដល់កិច្ចព្រមព្រៀងនៅថ្ងៃទី 23 ខែមិថុនា ឆ្នាំ 1971 នៅលុចសំបួ ។ កិច្ចព្រមព្រៀងនេះចែងអំពីការយល់ព្រមផ្តល់ចរាចរណ៍ទំនិញដោយសេរីជាមួយអឺរ៉ុបដីគោក ដោយកាត់បន្ថយពន្ធដារលើការនាំចូលចំនួន 20% ក្នុងដំណាក់កាលអន្តរកាលចំនួន 5 ឆ្នាំ ដោយគិតចាប់តាំងពីកិច្ចព្រមព្រៀងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 1973 ។ ទន្ទឹមនឹងនោះដែរ ចក្រភពអង់គ្លេសបានដំឡើងពន្ធដារលើការនាំចូលពីប្រទេសកំម៉ុនវិល ព្រោះចង់បញ្ចៀសការប្រកួតប្រជែងពីខាងក្រៅ ។ ការចូលជាសមាជិកទីផ្សាររួមអឺរ៉ុបបណ្តាលឱ្យប្រទេសអង់គ្លេសជួបប្រទះនូវភាពស្មុគស្មាញជាមួយប្រទេសសមាជិកអង្គការកំម៉ុនវិល ដោយការដំឡើងលើពន្ធនាំចូលពីប្រទេសដៃគូពាណិជ្ជកម្មរបស់អង់គ្លេសដូចជា អូស្ត្រាលី នូវែលសេឡង់ កាណាដា ព្រមទាំងប្រទេសនៅអាស៊ីមួយចំនួនដូចជា ហុងកុង ម៉ាឡេស៊ី ស្រីលង្កា និងសិង្ហបុរីជាដើម ។

## 5. គណបក្សការងារនិយម (1974-1979)

នៅឆ្នាំ 1974 គណបក្សការងារនិយមបានឈ្នះឆ្នោតហើយលោក ហារ៉ូល វិលសុន បានឡើងជានាយករដ្ឋមន្ត្រីម្តងទៀត ប៉ុន្តែនៅឆ្នាំ 1976 វិលសុនបានលាលែងពីតំណែង ហើយលោក ចេម កាឡាហ្គាន (James Callaghan) មកពីគណបក្សការងារនិយមដូចគ្នាបានបន្តតំណែងនេះ ។ ដើម្បីស្តារវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលបានធ្វើជាតូបនីយកម្មលើវិស័យឧស្សាហកម្មដូចជា រោងចក្ររថយន្ត រោងចក្រដំឡើងយន្តហោះ និងក្រុមហ៊ុនមួយចំនួនទៀត ។ ដោយសារតែភាពរ៉ាំរ៉ៃនៃវិបត្តិសេដ្ឋកិច្ច ចក្រភពអង់គ្លេសបានលុបចោលនូវគម្រោងសាងសង់ផ្លូវក្រោមបាតសមុទ្រដែលតភ្ជាប់អឺរ៉ុបដីគោក និងអឺរ៉ុបដីទឹក ។

ចំពោះការស្ថាបនាយន្តហោះ កុងគក (Concord) ជាប្រភេទយន្តហោះខ្នាតធំ ល្បឿនលឿនជាងសំឡេងក៏ត្រូវផ្អាក ក្រោយពេលយន្តហោះប្រភេទនេះផលិតបានតែមួយឈុតគត់ ។ ដើម្បីស្តារសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត រដ្ឋាភិបាលបានកាត់បន្ថយទៅលើមុខចំណាយខាងយោធា (នៅឆ្នាំ 1976 រដ្ឋាភិបាលបានប្រកាសឱ្យដកទ័ពអង់គ្លេសទាំងអស់ពីតំបន់ខាងកើតព្រែកជីកស៊ុយអេ)

សំណង់នាវាចម្បាំង ព្រមទាំងកាត់បន្ថយចំនួនទ័ព និងយន្តហោះ។ វិធានការទាំងអស់នេះ ធ្វើឱ្យរដ្ឋាភិបាលបន្សល់នូវទឹកប្រាក់ចំនួន 47 ពាន់លានដុល្លារនៅឆ្នាំ 1984 ស្មើនឹង 4.5% នៃផលទុនជាតិសរុប។ ទោះជាយ៉ាងណា អង់គ្លេសបានស្តារសេដ្ឋកិច្ចនៅកម្រិតទាបនៅឡើយម្យ៉ាងទៀតបញ្ហាអ៊ុលស្ទ័រ(Ulster) ដែលរ៉ាំរ៉ៃក៏នៅតែមិនអាចដោះស្រាយបាន។



*យន្តហោះដឹកអ្នកដំណើរប្រភេទលឿនជាងសំឡេង កុងកត (ផលិតដោយក្រុមហ៊ុនបារាំងនិងអង់គ្លេស)*

នៅក្នុងតំណែងរបស់លោក កាឡាហ្គាន អតិផរណាបានថយចុះពី 15% មកត្រឹម 8% នៅឆ្នាំ 1976។ រដ្ឋាភិបាលសន្សំប្រាក់បាន 20 ពាន់លានដុល្លារ។ ទោះបីជាមានការងើបឡើងវិញនៃសេដ្ឋកិច្ចក៏ដោយ ក៏កំណើនចំនួនអ្នកឥតការងារធ្វើកើនឡើងខ្ពស់ដដែល គឺមានចំនួនរហូតដល់ 1.5 លាននាក់ស្មើនឹង 7% នៃប្រជាជនសកម្ម។ បើគិតជាផលទុនជាតិក្នុងស្រុកសរុប ចក្រភពអង់គ្លេសមានចំណាត់ថ្នាក់លេខ 6 បន្ទាប់ពីសហរដ្ឋអាមេរិក ជប៉ុន អាល្លឺម៉ង់ អ៊ីតាលី ជាពិសេសគឺទាបជាងបារាំងឆ្ងាយបើគិតពីចំណូលប្រចាំឆ្នាំរបស់ប្រជាជនម្នាក់ (អង់គ្លេសរកបាន 7 920 ដុល្លារ ចំណែកបារាំងវិញគឺ 11 730 ដុល្លារ)។

# ៦. រដ្ឋាភិបាលម៉ាការេត ថាត់ឆឺ (Magaret Thatcher 1979-1990)

## ៦.១. ការឡើងកាន់តំណែង និងដំណោះស្រាយនយោបាយ



លោកស្រី ម៉ាការេតថាត់ឆឺ

នៅក្នុងការបោះឆ្នោតឆ្នាំ 1979 លោកស្រីម៉ាការេត ថាត់ឆឺ មកពីគណបក្សអភិរក្សនិយម ដែលជាស្ត្រីលើកដំបូងមានអាយុ 61 ឆ្នាំបានឡើងជានាយករដ្ឋមន្ត្រីតែមួយគត់នៅក្នុងប្រវត្តិសាស្ត្រប្រទេសអង់គ្លេស ។ ថាត់ឆឺបានជាប់ឆ្នោតពីរលើកទៀតនៅឆ្នាំ 1983 និងឆ្នាំ 1987 លោកស្រីជាអ្នកកាន់តំណែងយូរជាងគេបង្អស់រហូតដល់ 11 ឆ្នាំ ។ លោកស្រីជាអ្នកនយោបាយថ្មីដែលពុំសូវមានអ្នកប្រឆាំង ហើយលោកស្រី ត្រូវបានប្រសិទ្ធនាមជាស្ត្រីដែកថែប ។

នៅដើមឆ្នាំ 1982 មានសង្គ្រាមតូចឱ្យភ្ញាក់ផ្អើលមួយនៅទ្វីបអាមេរិកខាងត្បូងដើម្បីកាន់កាប់ទីប្រជុំកោះ ហ្វកឡិន(Falklands) ដែលមានចម្ងាយ 515 km ពីឆ្នេរប្រទេសអាហ្សង់ទីន ។ អង់គ្លេសបានបញ្ជូននាវា និងយន្តហោះ ព្រមទាំងកងទ័ពចំនួន 30 ពាន់នាក់ទៅកាន់ទីនោះ ។ ការចូលកាន់កាប់កោះនេះបានធ្វើឱ្យទាហានអង់គ្លេសចំនួន 225 នាក់បាត់បង់ជីវិត និងចំណាយថវិកាអស់ 700 លានផោន ។

ជ័យជម្នះលើកោះ ហ្វកឡិន ធ្វើឱ្យប្រជាប្រិយភាពរបស់ ម៉ាការេត ថាត់ឆឺ កើនឡើងពី 32% ទៅដល់ 52% នៅឆ្នាំ 1982 ។ ថាត់ឆឺបានចំណេញខាងនយោបាយយ៉ាងច្រើនក្នុងការកាត់បន្ថយការជំទាស់ពីគណបក្សប្រឆាំង ម្យ៉ាងទៀត ដោយសារការបែកបាក់ផ្ទៃក្នុងរបស់គណបក្សការងារនិយមនៅឆ្នាំ 1981 ផង ។ ក្នុងវិស័យឧស្សាហកម្មការខួងប្រេងនៅក្នុងលំហសមុទ្រខាងជើង(North Sea) បានកាត់បន្ថយនូវការនាំចូលប្រេងពីប្រទេសអារ៉ាប់ អង់គ្លេសធ្លាប់ទទួលការឈឺចាប់ដោយសារវិបត្តិប្រេងឡើងថ្លៃ ដែលធ្វើឱ្យវិស័យឧស្សាហកម្មដែលផ្អែកលើថាមពលប្រេងមានការរង្គោះរង្គើយ៉ាងខ្លាំង ហើយវិបត្តិនេះបានក្លាយទៅជាវិបត្តិសេដ្ឋកិច្ចពិភពលោកយ៉ាងធំនៅឆ្នាំ 1974 ។

## ៦.២. នយោបាយកាត់បន្ថយវិបត្តិសេដ្ឋកិច្ច

ការប្រយុទ្ធដើម្បីកាត់បន្ថយអតិផរណា ប្រទេសអង់គ្លេសមានអតិផរណា 13.4% នៅឆ្នាំ 1979 ហើយចុះមកត្រឹម 4.6% នៅឆ្នាំ 1984 ដែលបណ្តាលមកពីការកាត់បន្ថយចំណាយទៅលើមុខងារសាធារណៈ ។ ថវិកាសម្រាប់ចំណាយទៅលើក្រសួងផ្សេងៗ ដូចជាក្រសួងអប់រំបានកាត់បន្ថយ 6% ក្រសួងបរិស្ថាន 9% ក្រសួងអភិវឌ្ឍន៍ 45% (កាត់បន្ថយការសាងសង់លំនៅឋាន) ប៉ុន្តែដំឡើង 30% ទៅលើកកងកម្លាំងសណ្តាប់ធ្នាប់ 21% សម្រាប់សេវាសុខភាព [1] ។

---

(1). Histoire de la Grande Bretagne - p.368

## ៦.៣. នយោបាយឯកជនកម្ម

រដ្ឋាភិបាលបានរុះរើនយោបាយជាតូបនីយកម្មចោល ដោយប្រគល់កម្មសិទ្ធិផ្សេងៗ ដូចជា ក្រុមហ៊ុនប្រេង ទូរគមនាគមន៍ជាដើមទៅឱ្យក្រុមហ៊ុនឯកជន ។ នៅក្នុងរយៈពេល 4 ឆ្នាំដំបូងនៃនយោបាយនេះ រដ្ឋាភិបាលប្រមូលបានប្រាក់ចំនួន 1 ពាន់លានផោននៅឆ្នាំ 1984 និងកើនដល់ 2 ពាន់លានផោននៅឆ្នាំបន្ទាប់ ។ នយោបាយឯកជនកម្មបានធ្វើឱ្យប្រាក់ផោនអង់គ្លេសមានលំនឹង ហើយទីក្រុងឡុងដ៍ក្លាយទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏ធំ ។

នៅខែវិច្ឆិកា ឆ្នាំ 1990 មេដឹកនាំគណបក្សអភិរក្សនិយមយល់ឃើញថា ការដឹកនាំយូរនាំឱ្យមានវិបត្តិ ដូច្នេះគណបក្សអភិរក្សនិយមត្រូវផ្លាស់ប្ដូរមនុស្សថ្មី នោះគឺជាការឡើងកាន់តំណែងរបស់លោកចន មេជើ(John MaJor) ។ នៅក្នុងការដឹកនាំ លោកចន មេជើបានជួបប្រទះវិបត្តិសេដ្ឋកិច្ចមិនអាចដោះស្រាយបាន ។ នៅឆ្នាំ 1997 គណៈបក្សការងារបានចូលមកជំនួសគឺលោកតូនីប្លែរ(Tony Blair) ។ លោកប្លែរបានដោះស្រាយវិបត្តិនយោបាយផ្ទៃក្នុង គឺការធ្វើឱ្យមានសន្តិភាពរវាងអៀរឡង់ខាងជើងនិងអង់គ្លេស តាមរយៈកិច្ចចុះហត្ថលេខាសន្តិភាពនៅខែមេសា ឆ្នាំ 1998 ។ លោកបានដោះស្រាយបញ្ហាសង្គមដូចជាដំឡើងប្រាក់ខែឱ្យកម្មករ ដើម្បីឱ្យមានស្ថិរភាពក្នុងការរស់នៅ ។ ចំណែកនយោបាយអន្តរជាតិវិញ នៅក្រោយព្រឹត្តិការណ៍ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2001 អង់គ្លេសបានលើកទ័ពទៅអាហ្ហ្គានីស្ថានជាមួយសហរដ្ឋអាមេរិក នៅឆ្នាំ 2003 ក្នុងនាមជាសមាជិកនៃអង្គការអូតង់ ។

# 7. បញ្ហាអ៊ុលស្ទ័រ

ប្រទេសអៀរឡង់ស្ថិតនៅប៉ែកខាងលិចបំផុតនៃទ្វីបអឺរ៉ុប នៅក្នុងលំហមហាសាគរអាត្លង់ទិកគឺជាប្រទេសដែលមានជួរភ្នំព័ទ្ធជុំវិញ នៅប៉ែកកណ្ដាលលាតសន្ធឹងដោយវាលរាប ។ លក្ខខណ្ឌធម្មជាតិមិនសូវអំណោយផលដល់ជីវិតរស់នៅប៉ុន្មានឡើយពីព្រោះដីមានសំណើមជ្រុល ហើយគេពិបាកនឹងរកដីតំបន់ណាដែលមានជីជាតិណាស់ ។ ជនជាតិអៀរឡង់បានទទួលការឈឺចាប់ដោយសារប្រវត្តិសាស្ត្ររបស់ខ្លួនដ៏ជូរចត់ ។ ជនជាតិអៀរឡង់ភាគច្រើនជាអ្នកកាន់សាសនាគ្រិស្តនិកាយកាតូលិក បានតស៊ូការពារអត្តសញ្ញាណជាតិប្រឆាំងនឹងអង់គ្លេសដែលជាសត្រូវប្រចាំទសវត្សរ៍ ។ សាធារណរដ្ឋអៀរឡង់ខាងត្បូងបានក្លាយជារដ្ឋឯករាជ្យពីប្រទេសអង់គ្លេសនៅឆ្នាំ 1948 មានរដ្ឋធានីឈ្មោះ ឌុយប្លាំង (Dublin) ។ ជីវភាពប្រជាជនអៀរឡង់ខាងត្បូងពឹងផ្អែកលើវិស័យកសិកម្មមានដំឡូងបារាំង ការចិញ្ចឹមសត្វ និងនេសាទ ។

អៀរឡង់ខាងជើងហៅថា អ៊ុលស្ទ័រ មានរដ្ឋធានីបែលហ្វាស(Belfast) មានដែនដី 6រួមបញ្ចូលគ្នាជាទឹកដីអាណានិគមអង់គ្លេស មានប្រជាជនមួយភាគធំជានិគមជនមកពីប្រទេសអង់គ្លេស ។ ចំណែកប្រជាជនដើមកំណើតអៀរឡង់ប្រកាន់សាសនាកាតូលិក បានរងនូវការឈឺចាប់ដោយការរើសអើងអ្នកកាន់សាសនាពីពួកប្រូតេស្តង់ ។ នៅទសវត្សរ៍ឆ្នាំ 60 និង 70 មានផ្ទុះបាតុកម្មយ៉ាងខ្លាំងរហូតដល់មានអំពើហិង្សាដោយមានរបួស និងស្លាប់ក្រោមការបង្ក្រាបពីទ័ពអង់គ្លេស ។ ចាប់តាំងពីមានវិបត្តិបង្ហូរឈាមនេះមកមានមនុស្សស្លាប់ចំនួន 200 នាក់ និងរបួសជាច្រើននាក់ទៀត ។ វិបត្តិនៅអៀរឡង់ខាងជើងបានធ្វើឱ្យអង់គ្លេសមានការធុញទ្រាន់ជាខ្លាំង ។ វិបត្តិនយោបាយបានឈានរហូតដល់អង់គ្លេសព្រមទទួលស្គាល់សិទ្ធិជាពលរដ្ឋ និងបង្កើតរដ្ឋាភិបាល ។ នៅឆ្នាំ 1972 រដ្ឋាភិបាលអង់គ្លេសលុបបំបាត់ស្វ័យភាពអៀរឡង់ខាងជើង ជាហេតុបណ្តាលឱ្យកើតអំពើភេរវកម្មគួរឱ្យភ័យខ្លាចមួយនៅឆ្នាំ 1984 ។ ដើម្បីបញ្ចប់វិបត្តិនយោបាយនេះ រដ្ឋាភិបាលអង់គ្លេសបានបើកកិច្ចចរចាជាមួយចលនាកងទ័ពសាធារណរដ្ឋអៀរឡង់ (Irish Republic Army = IRA) ដើម្បីបញ្ចប់ជម្លោះនៅទីក្រុងបែលហ្វាសនៅឆ្នាំ 1998 ។ វិបត្តិនេះបានបញ្ចប់ដោយអង់គ្លេសបានបង្កើតរដ្ឋាភិបាលមួយដែលមានសមាជិកពីនិកាយទាំងពីររួមគ្នា(កាតូលិក និងប្រូតេស្តង់) ។

## ? សំណួរ

1. តើប្រទេសអង់គ្លេសជាប្រទេសឈ្នះ ឬជាប្រទេសចាញ់សង្គ្រាមលោកលើកទី 2 ? ព្រោះអ្វី ?
2. តើប្រទេសអង់គ្លេសមានគណបក្សសំខាន់ៗអ្វីខ្លះ ? តើគណបក្សមួយណាដែលដឹកនាំប្រទេសអង់គ្លេសបានល្អជាងគេ ?
3. តើលោកស្រី ម៉ាការេត ថាត់ឆឺ ជាប់ឆ្នោតជានាយករដ្ឋមន្ត្រីអង់គ្លេសពីឆ្នាំណា ? តើគាត់បានដោះស្រាយបញ្ហាអ្វីខ្លះ ?
4. វិបត្តិអ៊ុលស្ទ័រ ជាវិបត្តិធ្ងន់ធ្ងរសម្រាប់អង់គ្លេស តើអង់គ្លេសដោះស្រាយដូចម្តេច ?

មេរៀនទី

# 3 សាធារណរដ្ឋបារាំង

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីស្ថានភាពប្រទេសបារាំងចាប់ពីរដ្ឋាភិបាលបណ្ដោះអាសន្នរហូតដល់សាធារណរដ្ឋទី 5 ។
- វិភាគពីនយោបាយប្រទេសបារាំងពេលចុះចាញ់អាល្លឺម៉ង់ ។
- គោរពវីរភាពឧត្តមសេនីយ៍ សាលដឺហ្គោល ក្នុងការរំដោះប្រទេសបារាំង ។

នៅក្នុងសង្គ្រាមលោកលើកទី 2 កងទ័ពអាល្លឺម៉ង់បានវាយលុកចូលប្រទេសបារាំងដោយឆ្លងកាត់ប្រទេសហូឡង់ និងបែលហ្ស៊ិក ។ តែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ប្រទេសបារាំងទាំងមូលត្រូវទាហានអាល្លឺម៉ង់ចូលលុកលុយស្ទើរគ្រប់ទីកន្លែង ។ ប្រជាជនបារាំងបានភៀសខ្លួនចេញពីតំបន់អាល្លឺម៉ង់គ្រួតត្រា ។ នៅចំពោះមុខនៃការបាត់បង់តុល្យភាព បារាំងបានចុះសន្ធិសញ្ញាចាញ់សង្គ្រាមនៅថ្ងៃទី 22 ខែមិថុនា ឆ្នាំ 1940 ប៉ុន្តែឧត្តមសេនីយ៍ ដឺហ្គោលបានប្រកាសតាមប៉ុស្តិ៍វិទ្យុពីប្រទេសអង់គ្លេសនៅថ្ងៃទី 18 ខែមិថុនា ឆ្នាំ 1940 ឱ្យប្រជាជនបារាំងក្រោកតស៊ូ ។ ពេលនោះ នៅក្នុងប្រទេសបារាំងមានការបង្កើតរដ្ឋាភិបាលមួយ ដោយសហការជាមួយអាល្លឺម៉ង់ឈ្មោះ រដ្ឋាភិបាលវិស៊ី ដែលមានឧត្តមសេនីយ៍ប៉េតាំងជាអ្នកដឹកនាំ ។ បារាំងបានប្រមូលយកផលិតផលកសិកម្ម និងឧស្សាហកម្មទៅផ្គត់ផ្គង់កងទ័ពអាល្លឺម៉ង់ ថែមទាំងមានកម្មករបារាំងមួយភាគធំត្រូវជាប់កំណែនការងារនៅក្នុងប្រទេសអាល្លឺម៉ង់ទៀតផង ។

## 1. ការបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្ន

### 1.1. ការរីកសាយនៃសង្គ្រាមលោកលើកទី 2

នៅក្រោយពេលដែលប្រទេសនៅអឺរ៉ុបជាដៃគូចុះចាញ់កងទ័ពអាល្លឺម៉ង់ អង់គ្លេសជាប្រទេសតែមួយគត់ដែលទប់ទល់នឹងអាល្លឺម៉ង់ប្រកបដោយក្ដីអស់សង្ឃឹម ។ ក្រោយពីជល្មើមជ័យជម្នះបានដោយងាយនៅថ្ងៃទី22 ខែមិថុនា ឆ្នាំ1941 អាល្លឺម៉ង់បានបន្តវាតទីទៅដល់សហភាពសូវៀត ។ នៅអាស៊ីមហាអំណាចជប៉ុនបានបើកការវាយលុកនៅតំបន់ប៉ាស៊ីហ្វិកប្រឆាំងនឹងសហរដ្ឋអាមេរិកជាពិសេសទៅលើមូលដ្ឋានជើងទឹកនៅហាវ៉ៃ ថ្ងៃទី 7 ខែធ្នូ ឆ្នាំ 1941 ។ នៅឆ្នាំ 1942 កងទ័ពជប៉ុនលុកលុយទ្វីបអាស៊ីទាំងមូល ។

## 1.2. ចលនាតស៊ូប្រឆាំងអាល្លឺម៉ង់

ភាពសាហាវយង់ឃ្នងទៅលើប្រជាជននៅតាមតំបន់ដែលពួកអាល្លឺម៉ង់ត្រួតត្រា នាំឱ្យប្រជាជនភ័យខ្លាចមិនព្រមចុះចូល ។ ពួកគេនាំគ្នារត់ចូលព្រៃលាក់ខ្លួននៅតាមតំបន់ភ្នំ និងរាយការណ៍ជាសម្ងាត់ដល់ពួកសម្ព័ន្ធមិត្តអំពីសកម្មភាពកងទ័ពអាល្លឺម៉ង់ ។ ពួកអាល្លឺម៉ង់ក៏មានបណ្តាញស៊ើបការណ៍ (Gestapo) តាមដានដើម្បីចាប់ដាក់ជំរំប្រមូលផ្តុំនៅអូស្វីច(Auschwitz) ឬក៏យកទៅសម្លាប់ចោលនៅអូរ៉ាឌួ (Oradour) ។ នៅថ្ងៃទី 6 ខែមិថុនា ឆ្នាំ 1944 កងទ័ពសម្ព័ន្ធមិត្តបានបើកការវាយលុកយ៉ាងខ្លាំងទៅលើកងទ័ពអាល្លឺម៉ង់នៅតំបន់ ន័រម៉ង់ឌី(Normandy) ។ កងទ័ពភាគច្រើនជាទាហានសហរដ្ឋអាមេរិកនិងអង់គ្លេសបញ្ជាដោយឧត្តមសេនីយ៍ អេស៊ិនហាវ័រ(Dwight Eisenhower) ។ នៅថ្ងៃទី 15 ខែសីហា ឆ្នាំ 1944 កងទ័ពសហរដ្ឋអាមេរិកមួយផ្នែកបានចូលរួមជាមួយចលនាតស៊ូបារាំងនៅតំបន់ ប្រូវង់(Provence) ។ ចលនាតស៊ូបានវាយស្ទាក់ពួកសត្រូវគ្រប់ទីកន្លែង ហើយបានរុញច្រានព្រមទាំងចាប់ជាឈ្លើយសឹក ។ នៅថ្ងៃទី 8 ខែឧសភា ឆ្នាំ 1945 អាល្លឺម៉ង់បានប្រកាសដាក់អាវុធ ចំណែកនៅសមរភូមិប៉ាស៊ីហ្វិកវិញ ជប៉ុនទម្លាក់អាវុធនៅថ្ងៃទី 15 ខែសីហា ឆ្នាំ 1945 ។




ផែនទីប្រទេសបារាំង

## 1.3. ស្ថានភាពប្រទេសបារាំងក្រោយសង្គ្រាម

ក្រោយពីបញ្ចប់សង្គ្រាម ប្រទេសបារាំងបានបន្សល់នូវវិនាសកម្មដ៏គួរឱ្យអស់សង្ឃឹម ។ ទីក្រុង រោងចក្រ ផ្លូវថ្នល់ កំពង់ផែត្រូវខូចខាតស្ទើរអស់ទាំងស្រុងដោយការទម្លាក់គ្រាប់បែកនៅពេលសង្គ្រាម ហើយជីវិតប្រជាជនបារាំងត្រូវបាត់បង់ 750 ពាន់នាក់ ។ ក្រោយសង្គ្រាម សេដ្ឋកិច្ចបារាំងជួបឧបសគ្គ យ៉ាងធ្ងន់ធ្ងរ ការបោះក្រដាសប្រាក់ច្រើនជ្រុលបណ្ដាលឱ្យប្រាក់ហ្វ្រង់បាត់បង់តម្លៃ នាំមកនូវអតិផរណា ។ បារាំងត្រូវការទុនដើម្បីស្តារប្រទេសនៅក្រោយសង្គ្រាមឱ្យងើបឡើងវិញ ។ ដូច្នេះបើគ្មានជំនួយពីសហរដ្ឋ អាមេរិកទេ ប្រទេសបារាំង និងប្រទេសអឺរ៉ុបផ្សេងៗទៀតមិនអាចមានមូលដ្ឋានគ្រឹះដើម្បីស្តារសេដ្ឋកិច្ច បានឡើយពីព្រោះភាពត្រដាបត្រដួសនេះអាចនាំឥទ្ធិពលសង្គមនិយមរបស់សហភាពសូវៀតចូលមកគ្រប ដណ្តប់ទ្វីបអឺរ៉ុបទាំងមូល ដោយសហភាពសូវៀតជាប្រទេសមហាអំណាចទី ↑ ដែលបានឈ្នះលើពួក ណាស៊ីអាល្លឺម៉ង់ ។

## 1.4. រដ្ឋាភិបាលបណ្តោះអាសន្ន

នៅខែសីហា ឆ្នាំ 1944 នៅក្នុងរយៈពេលតែពីរបីសប្តាហ៍ប៉ុណ្ណោះ ឧត្តមសេនីយ៍ ដឺហ្គោល បាន បង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលមានសមាសភាពចម្រុះមកពីគណបក្សដែលតស៊ូ ក្នុង សម័យសង្គ្រាមរំដោះជាតិមានគណបក្សសង្គមនិយម (Social Party = SP) គណបក្សកុម្មុយនីស្ត (Communis Party=CP) និងគណបក្សចលនាសាធារណរដ្ឋប្រជាជន ។ នៅពេលកាន់អំណាច លោក ដឺហ្គោល មានទំនាស់ជាមួយមន្ត្រីរបស់លោកអំពីបញ្ហានយោបាយដឹកនាំប្រទេស ។ ពួកមន្ត្រីដែលមក ពីគណបក្សផ្សេងៗ ចង់បានរបបនយោបាយតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី 3 ដែលដួលរលំនៅ សម័យសង្គ្រាម(1940) ចំណែកលោកដឺហ្គោលចង់បាននយោបាយដែលប្រគល់តួនាទីទូលំទូលាយ ដល់ប្រធានាធិបតី រដ្ឋធម្មនុញ្ញទី 3 ទុកប្រធានាធិបតីជាតំណែងកិត្តិយស ។ ចំពោះការដឹកនាំនយោបាយ រដ្ឋជាតួនាទីនាយករដ្ឋមន្ត្រីដែលជ្រើសតាំងដោយសភា ។ នៅពេលនោះ ការដឹកនាំប្រទេសបារាំងជា តួនាទីរបស់គណបក្សបី គឺគណបក្សកុម្មុយនីស្ត (CP) គណបក្សសង្គមនិយម(SP) និងគណបក្ស ចលនាសាធារណរដ្ឋប្រជាជន ។

# 2. កំណើតសាធារណរដ្ឋទី 4

## 2.1. ការកកើត

របបសាធារណរដ្ឋទី 4 មានរដ្ឋធម្មនុញ្ញបង្កើតនៅឆ្នាំ 1946 ដែលប្រគល់អំណាចទៅឱ្យសភាជាអ្នកជ្រើសរើសនាយករដ្ឋមន្ត្រីដែលមានអាណត្តិ 5 ឆ្នាំ និងត្រួតពិនិត្យជាប្រចាំនូវសកម្មភាពនយោបាយដោយសភា ហើយសភាអាចដកហូតតំណែងគ្រប់ពេលវេលាបើសិនជាមានកំហុសឆ្គង ។ ដូចនេះរបបនេះប្រគល់អំណាចធំធេងដល់សភាក្នុងការកំណត់អំណាចនីតិប្រតិបត្តិ ចំណែកប្រធានាធិបតីក៏ជ្រើសតាំងដោយសភាដែរសម្រាប់អាណត្តិ 7 ឆ្នាំ ប៉ុន្តែពុំមានអំណាចទូលំទូលាយដូចសហរដ្ឋអាមេរិកដែលផ្តល់អំណាចដល់ប្រធានាធិបតីជាអ្នកចាត់ចែងផ្តាច់មុខនៅលើកិច្ចការទាំងមូលរបស់ប្រទេសជាតិ ។ ដឺហ្គោលបានចោទសភាសាធារណរដ្ឋទី 4 ថាជាសភាគណបក្ស ។

នៅឆ្នាំ 1947 សភាបានតែងតាំងប្រធានាធិបតីមកពីគណបក្សសង្គមនិយម វ៉ាំងសង់ អូរីយ៉ូល ( Vincent Auriole ) ដូចនេះសាធារណរដ្ឋទី 4 បានត្រូវបង្កើតឡើង ។

រដ្ឋាភិបាលខិតខំស្តារសេដ្ឋកិច្ច និងសង្គមដោយផ្តើមពីការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ស្ពាន និងការធ្វើឱ្យមានកំណើនខាងផលិតផលឧស្សាហកម្ម និងកសិកម្មប្រហាក់ប្រហែលមុនឆ្នាំ 1938 ។ ប៉ុន្តែទោះជាយ៉ាងណាកំណើនផលិតផលនេះនៅតែមិនទាន់សមល្មមនឹងតម្រូវការក្នុងប្រទេសឡើយ ។ម្យ៉ាងទៀតរដ្ឋាភិបាលបានធ្វើជាតូបនីយកម្មលើរោងចក្រឧស្សាហកម្មធ្យូងថ្ម និងឧស្ម័នរហូតដល់ធនាគារ ។ រដ្ឋាភិបាលបានបង្កើតអង្គការសង្គ្រោះសង្គម(Social Security) សម្រាប់ជួយឧបត្ថម្ភដល់អ្នកមានជំងឺមានគ្រោះថ្នាក់ក្នុងការងារ និងប្រាក់បំណាច់សម្រាប់គ្រួសារកម្មករទៀតផង ។

## 2.2. ការដួលរលំសាធារណរដ្ឋទី 4

នៅឆ្នាំ 1947 ជាឆ្នាំចាប់ផ្តើមនៃសង្គ្រាមត្រជាក់ និងសង្គ្រាមឥណ្ឌូចិនលើកទី 1 ។ ពួកកុម្មុយនីស្តបានចោទថារដ្ឋាភិបាលបារាំងនិយមទៅរកសហរដ្ឋអាមេរិកតាមរយៈផែនការម៉ាសាល់ និងធ្វើសង្គ្រាមដៀនបៀនភូដើម្បីកម្ចាត់ពួកកុម្មុយនីស្តដែលគាំទ្រដោយចិន និងសហភាពសូវៀត ។ ពួកកុម្មុយនីស្តបានដកខ្លួនចេញពីរដ្ឋាភិបាល ហើយធ្វើកូដកម្មឥតឈប់ឈរប្រឆាំងនឹងរដ្ឋាភិបាល ។ បញ្ហាមួយទៀតនៅពេលលោក ដឺហ្គោល ចុះចេញពីតំណែង គាត់បានបង្កើតគណបក្សមួយទៀតឈ្មោះ គណបក្សប្រមូលផ្តុំប្រជាជនបារាំង(The rally of the French People = RPF)ដោយធ្វើទស្សនកិច្ចនៅតាមខេត្តឃោសនាប្រឆាំងនឹងរដ្ឋាភិបាល ហើយក៏ចោទពួកកុម្មុយនីស្តថាចង់ផ្តាច់ខ្លួនបម្រើផលប្រយោជន៍របបកុម្មុយនីស្តដែលលំអៀងទៅរកសហភាពសូវៀត ។

នៅមុនសង្គ្រាម បារាំងជាប្រទេសមហាអំណាចអាណានិគមមួយយ៉ាងធំ បន្ទាប់ពីប្រទេសអង់គ្លេស ។ ឥទ្ធិពលបារាំងធ្លាក់ចុះយ៉ាងខ្លាំងនៅពេលបារាំងចាញ់សង្គ្រាមលោកលើកទី 2 ជាពិសេសប្រទេសមួយចំនួនធំនៅទ្វីបអាហ្វ្រិកទាមទារឯករាជ្យបានសម្រេចជោគជ័យ ប៉ុន្តែនៅអាល់ហ្សេរី សង្គ្រាមតស៊ូបានឆាបឆេះរវាងបារាំង និងចលនារំដោះជាតិបានអូសបន្លាយ ។ បារាំងបានគាំទ្រនិគមជនជាតិបារាំងជាងមួយលាននាក់នៅលើទឹកដីអាល់ហ្សេរី ។ សង្គ្រាមនេះបានអូសបន្លាយចាប់តាំងពីឆ្នាំ( 1945-1962 ) ។ សន្ធិសញ្ញា អេវីយ៉ង់ (Evian )បានបញ្ចប់សង្គ្រាមនេះ ។




*ជនភៀសខ្លួនបារាំងចេញពីប្រទេសអាល់ហ្សេរីមកដល់កំពង់ផែម៉ាសីក្នុងឆ្នាំ 1962*

សង្គ្រាមនៅអាល់ហ្សេរីបានបង្កើតវិបត្តិគណៈរដ្ឋមន្ត្រីជាច្រើនលើក ។ អសមត្ថភាពនៃសាធារណរដ្ឋទី 4 បានជំរុញលោក ដឺហ្គោល ដែលកំពុងត្រៀមខ្លួនដឹកនាំប្រទេសបន្តពីលោករ៉ាំងសង់ អូរីយ៉ូល បង្កើតរដ្ឋាភិបាលមួយដែលមានទម្រង់រដ្ឋធម្មនុញ្ញខុសគ្នា គឺតាមទម្រង់រដ្ឋធម្មនុញ្ញដែលលោក ដឺហ្គោល បានគិតទុកជាមុន ។ ដូចនេះ របបថ្មីមួយទៀតបានបង្កើតឡើងឈ្មោះ សាធារណរដ្ឋទី 5 នៅឆ្នាំ 1958 ។

## 3. កំណើតសាធារណរដ្ឋទី 5

### 3.1. សាលដឺហ្គោល (Charles de Gaulle 1958-1968)



*លោក សាលដឺហ្គោល*

#### ក. ផែនការសេដ្ឋកិច្ច

ចំពោះផែនការសេដ្ឋកិច្ចសាធារណរដ្ឋទី 5 បន្តស្នាដៃពីសាធារណរដ្ឋទី 4 ដោយរដ្ឋាភិបាលថ្មីបានធ្វើឱ្យប្រាក់ហ្វ្រង់មានលំនឹង រំសាយរោងចក្រឧស្សាហកម្មតូចៗ បង្កើតជាឧស្សាហកម្មធំខ្នាតអន្តរជាតិដើម្បីប្រកួតប្រជែងជាមួយសហរដ្ឋអាមេរិក ។ បារាំងបានបន្តការស្រាវជ្រាវវិស័យថាមពលបរមាណូ ការសិក្សាទីអវកាស ការកែតម្រូវនៃខ្សែទស្សន៍ពណ៌ ការបង្កើតសមត្ថភាពដឹកជញ្ជូនតាមផ្លូវអាកាស ដោយស្ថាបនាយន្តហោះយក្សរួមគ្នាជាមួយនិងចក្រភពអង់គ្លេសសម្រាប់ដឹកជញ្ជូន

លឿនជាងសំឡេងឈ្មោះ កុងគត (Concord) ។ ដូច្នេះប្រទេសបារាំងមានការរីកចម្រើនខាងបច្ចេកវិទ្យាទំនើប សង្គមបារាំងក៏ក្លាយជាសង្គមដែលនិយមសម្ភារៈតាមបែបសម័យនិយម ។

ទោះបីបារាំងរីកចម្រើនខាងវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាយ៉ាងនេះក៏ដោយ សង្គមបារាំងនៅតែជួបវិបត្តិធ្ងន់ធ្ងរ ពួកកសិករត្រីក្រលក់ផលិតផលមិនចេញ ពួកពាណិជ្ជករតូចតាចក្ស័យធន កម្មករបាត់បង់ការងារដោយសារការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងហាងទំនិញធំៗ ។ កម្មករឥតការងារធ្វើមានចំនួនកើនឡើងកាន់តែច្រើន សហគ្រាសតូចតាចត្រូវបាត់បង់មុខរបរ ។ នៅកណ្ដាលទីក្រុងប៉ារីសមានកម្មកររាប់សែននាក់ធ្វើកូដកម្ម ព្រោះបាត់បង់ការងារ និងប្រាក់ខែមិនគ្រប់គ្រាន់ អស់រយៈពេល 1 សប្ដាហ៍បណ្ដាលឱ្យរោងចក្រដទៃទៀតបិទទ្វារជាបន្តបន្ទាប់ ។ វិស័យដឹកជញ្ជូនឈប់ដំណើរការ វិស័យរដ្ឋបាលត្រូវរាំងស្ទះ ។ វិបត្តិនេះបានអូសបន្លាយពីខែឧសភាដល់ខែមិថុនា ឆ្នាំ 1968 រដ្ឋាភិបាលមិនអាចដោះស្រាយបានទើប ដឺហ្គោល លាឈប់នៅថ្ងៃទី 12 ខែមេសា ឆ្នាំ 1968 ។

## ២. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី 5

- តួនាទីរបស់ប្រធានាធិបតី

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី 5 ខុសគ្នាពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋមុនៗ ដោយរដ្ឋធម្មនុញ្ញនេះប្រគល់អំណាចដ៏ទូលំទូលាយដល់ប្រធានាធិបតី ។ ប្រធានាធិបតីជ្រើសតាំងដោយការបោះឆ្នោតមានអាណត្តិ 7 ឆ្នាំ អាចឈរបាន 2 អាណត្តិ មានសិទ្ធិរំលាយសភា រុះរើគណៈរដ្ឋមន្ត្រី ជាអគ្គមេបញ្ជាការកងទ័ពជាតិ ជាអ្នកជ្រើសតាំងនាយករដ្ឋមន្ត្រី និងមន្ត្រីផ្សេងៗ តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី ។ ក្រៅពីនេះប្រធានាធិបតីទទួលសារតាំង ចុះហត្ថលេខាលើសន្ធិសញ្ញា ក្រឹត្យ និងចេញបទបញ្ជាផ្សេងៗ ។

- តួនាទីសភា

សភាតំណាងរាស្ត្រមានអាណត្តិ 5 ឆ្នាំជ្រើសតាំងដោយការបោះឆ្នោតសកល មានតួនាទីអនុម័តច្បាប់ និងផែនការថវិកាជាតិសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រួតពិនិត្យការងាររបស់រដ្ឋាភិបាល មានសិទ្ធិរំលាយរដ្ឋាភិបាលដោយអនុលោមតាមសំឡេង $\frac{2}{3}$ ដាច់ខាត ។ ព្រឹទ្ធសភាមានអាណត្តិ ៩ ឆ្នាំ ចប់អាណត្តិមិនព្រមគ្នា (មិនស្របពេលគ្នា)ទេ សមាជិកចំនួន $\frac{1}{3}$ ត្រូវប្ដូរវៀងរាល់ 3 ឆ្នាំម្ដង ព្រឹទ្ធសភាមានភារកិច្ចចូលរួមតាក់តែងនិងអនុម័តច្បាប់ព្រមទាំងកញ្ចប់ថវិកាជាតិ ។

នៅទីបំផុតសាធារណរដ្ឋទី 5 បានយកគំរូតាមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកក្នុងការបង្កើតតុលាការជាន់ខ្ពស់ ឬក្រុមប្រឹក្សាធម្មនុញ្ញមានមាននាទីជានាការគោរពរដ្ឋធម្មនុញ្ញ ត្រួតពិនិត្យទៅលើការបោះឆ្នោត ។ តុលាការនេះមានសមាជិក ៩ រូប មានអាណត្តិ ៩ ឆ្នាំ តែងតាំងដោយប្រធានាធិបតី និងប្រធានសភាទាំងពីរ ។

## 3.2. សក ប៉ុមពីឌូ (Georges Pompidou 1968-1974)



*លោក សក ប៉ុមពីឌូ*

ការលាលែងមុនអាណត្តិរបស់លោក ដឺហ្គោល នៅឆ្នាំ 1968 តម្រូវឱ្យរបបសាធារណរដ្ឋទី 5 ជ្រើសរើសយកប្រធានាធិបតីមួយរូបទៀតដើម្បីបន្តតំណែង ។ នៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីមានបេក្ខជនពីររូបគឺ លោក ប៉ុមពីឌូ និងលោក អាឡាំងប៉ូអ៊ែ(Alain Poher) ។ ជាអ្នកនាំមុខនៅក្នុងការបោះឆ្នោត លោក ប៉ុមពីឌូ ដែលជាអ្នកដឺហ្គោលនិយម និងជាអតីតនាយករដ្ឋមន្ត្រីបានយកជ័យជម្នះដោយប្រមូលសំឡេងនាំមុខចំនួន 58% ។ លោក ប៉ុមពីឌូ បានតែងតាំងលោក សាបង់ដែលម៉ាស់(Charban Delmas) ជានាយករដ្ឋមន្ត្រី ។ ទិសដៅនយោបាយរបស់លោក សាបង់ដែលម៉ាស់ គឺការលើកស្ទួយវិស័យឧស្សាហកម្មទំនើបដើម្បីប្រកួតប្រជែងជាមួយប្រទេសមហាអំណាចសេដ្ឋកិច្ចមានសហរដ្ឋអាមេរិក អង់គ្លេស ជប៉ុន អាល្លឺម៉ង់ខាងលិច និង អ៊ីតាលី ។ ផលិតផលឧស្សាហកម្មនាំចេញមានកំណើន 5.5% ជារៀងរាល់ឆ្នាំ ប្រទេសបារាំងក្លាយជាមហាអំណាចទី 4 ផ្នែកនាំចេញផលិតផលទៅកាន់ទីផ្សារពិភពលោក ។ ការរីកលូតលាស់ខាងផ្នែកសេដ្ឋកិច្ចនេះបានលើកស្ទួយកម្រិតជីវភាពកម្មករបារាំងតាមរយៈការដំឡើងប្រាក់ខែ ។

នៅសម័យលោកប៉ុមពីឌូ ក៏មានចលនាទាមទារសិទ្ធិមួយចំនួនដូចជា ចលនាស្ត្រីទាមទារសិទ្ធិសេរីភាពក្នុងការពន្យារកំណើត និងលែងលះ ។ ចលនាតំបន់និយមសុំឱ្យផតំបន់មួយចំនួនដូចជា ប្រឺតុង គក បាស់ ដើម្បីបង្កើតជាតំបន់ស្វយ័តដោយរក្សានូវវប្បធម៌ដើមរបស់ពួកគេ ។

នៅក្នុងអាណត្តិលោក ប៉ុមពីឌូ បារាំងបានឆ្លងកាត់នូវវិបត្តិថាមពលពីរលើកគឺលើកទី ١ នៅឆ្នាំ 1973 នៅពេលដែលប្រទេសអង្គការអូប៉ិច(Organization of the petroleum Exporting Countrirs = OPEC) បានដំឡើងតម្លៃប្រេង បារាំងជាប្រទេសនាំប្រេងចូលចំនួន $\frac{3}{4}$ នៃថាមពលសរុបដែលគេត្រូវការ ។ ការបង្កើនតម្លៃប្រេងនេះធ្វើឱ្យបារាំងមានវិបត្តិថាមពល និងនាំមកនូវភាពមិននឹងនរនៃជញ្ជីងពាណិជ្ជកម្ម ។ លោក ប៉ុមពីឌូ មានជំងឺរ៉ាំរ៉ៃហើយទទួលមរណភាពនៅថ្ងៃទី 2 ខែមេសា ឆ្នាំ 1974 ។ នៅក្នុងអាណត្តិលោក ប៉ុមពីឌូ ទោះបីជាយ៉ាងនេះក្តីក៏គេចាត់ទុកជាយុគមាសសម្រាប់ប្រទេសបារាំងដែរ ។

### 3.3. វ៉ាលេរី ស៊ីស្កាដេស្តាំង (Valèry Giscard d' Estaing 1974-1981)



លោក វ៉ាលេរី ស៊ីស្កាដេស្តាំង

នេះជាលើកទី ɪ ហើយដែលប្រទេសបារាំងមានប្រធានាធិបតីថ្មី ដែលមិនមែនជាមនុស្សដឺហ្គោលនិយម មកពីគណបក្សកណ្តាល (Center) ជាអតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅអាណត្តិ លោក ប៉ុមពីឌូ ហើយតែងតាំងលោក សាក់ ស៊ីរ៉ាក់ (Jacque Chirac) ជានាយករដ្ឋមន្ត្រី ។

នៅក្នុងនយោបាយក្នុងប្រទេស លោកបានធ្វើកំណែទម្រង់សិទ្ធិពលរដ្ឋក្នុងការបោះឆ្នោតចាប់ពីអាយុ 18ឆ្នាំឡើងទៅ ។ ការផ្តល់ស្វយ័តភាពដល់ទីក្រុងប៉ារីស ក្នុងការបោះឆ្នោតជ្រើសរើសចៅហ្វាយក្រុងជាលើកដំបូង និងមានការផ្តល់ឯករាជភាពដល់ប្រព័ន្ធព័ត៌មានដូចជា វិទ្យុ និងទូរទស្សន៍ជាដើម ។ ក្រៅពីនេះ មានវិធានការមួយចំនួនទៀតទៅលើវិស័យសេដ្ឋកិច្ច និងសង្គមដូចជា ការដំឡើងពន្ធដារទៅលើដីធ្លី និងអចលនវត្ថុ បើកចំហឱ្យមានការលក់ដូរដោយសេរីនូវថ្នាំឬឱសថពន្យារកំណើត ។ នៅលើឆាកអន្តរជាតិវិញ សេដ្ឋកិច្ចបារាំងត្រូវរងគ្រោះរង្គើដោយវិបត្តិថាមពលលើកទីពីរនៅឆ្នាំ 1979 ដោយរដ្ឋាភិបាលបដិវត្តន៍អ៊ីរ៉ង់បានកាត់បន្ថយការនាំចេញប្រេងនៅ ។ នយោបាយស្តារសេដ្ឋកិច្ចមិនបានជោគជ័យចំនួនអ្នកឥតការងារធ្វើកើនឡើង ។ លោកស៊ីរ៉ាក់បានសុំលាលែងពីតំណែងហើយលោក រ៉ាយម៉ុងបា(Raymond Barre) បានឡើងជានាយករដ្ឋមន្ត្រីបន្តពីលោក ស៊ីរ៉ាក់ ។

### 3.4. លោក ហ្វ្រង់ស័រមីទែរ៉ង់ (François Mitterand 1981-1995)



លោក ហ្វ្រង់ស័រមីទែរ៉ង់

លោកជាប្រធានាធិបតីចេញពីគណបក្សសង្គមនិយមលើកទី ɪ នៅក្នុងសាធារណរដ្ឋទី 5 ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលគឺការលុបបំបាត់ទោសប្រហារជីវិត ការកាត់បន្ថយម៉ោងធ្វើការនៅត្រឹម 39 ម៉ោងក្នុងមួយសប្តាហ៍ និងកំណត់អាយុចូលនិវត្តន៍ 60ឆ្នាំ ។ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដឺហ្វែរ(G.Deferre) បានជំរុញឱ្យធ្វើវិមជ្ឈការអំណាចកណ្តាលមួយចំនួនផ្ទេរទៅខេត្ត និងតំបន់ ។ រដ្ឋបានបើកសេរីភាពទាំងស្រុងដល់ប្រព័ន្ធផ្សព្វផ្សាយ នោះជាការបើកផ្លូវនៃការចាប់កំណើតនៃវិទ្យុសេរី ។ នៅក្នុងអាណត្តិ លោក មីទែរ៉ង់ ចំនួនអ្នកឥតការងារធ្វើមានចំនួន 2 លាននាក់ក្នុងឆ្នាំ 1981 ។

## 4. នយោបាយក្រៅប្រទេសនៃសាធារណរដ្ឋទី 5

នៅសម័យដឺហ្គោលនយោបាយបារាំង គឺការគេចចេញពីឧត្តមភាពសហរដ្ឋអាមេរិកដូច្នេះបារាំងត្រូវតែមានកម្លាំងបរមាណូដោយខ្លួនឯង ។ បារាំងបានប្រើនយោបាយគាំទ្រចលនារើបម្រះពីនិមអាណានិគម ជាពិសេសប្រទេសមួយចំនួននៅអាហ្វ្រិកដូចជាបញ្ហាអាល់ហ្សេរី លោក ដឺហ្គោលធ្វើឱ្យមានការចរចាបញ្ចប់សង្គ្រាមដែលនៅទីបំផុតប្រជាជនបារាំងចំនួនមួយលាននាក់បានចាកចេញពីអាល់ហ្សេរីទៅរស់នៅប្រទេសបារាំងវិញ ។ លោកប្រធានាធិបតី ដឺហ្គោលក៏បានប្រឆាំងសមាជិកភាពរបស់អង់គ្លេសនៅក្នុងទីផ្សាររួមអឺរ៉ុប ដោយចាត់ទុកថាអង់គ្លេសជាប្រទេសនិយមសហរដ្ឋអាមេរិក លោក ដឺហ្គោល បានជំទាស់នឹងអង់គ្លេសមិនឱ្យចូលរួមជាសមាជិកនៃអង្គការនេះចំនួនពីរដងគឺនៅឆ្នាំ 1963 និង 1967 ប៉ុន្តែក្រោយមកអង់គ្លេសបានចូលជាសមាជិកនៃសហគមន៍នេះនៅក្នុងអាណត្តិ លោក ប៉ុមពីឌូ។



*ការចុះហត្ថលេខារវាងលោក ឡេអូនីត ប្រេស្នេវ (សហភាពសូវៀត) និងលោក ស៊ិស្កាដេស្តាំង (បារាំង) ស្តីពីការរំសាយសព្វាវុធ*

ក្នុងដំណើរទស្សនកិច្ចរបស់ លោក ដឺហ្គោល នៅទីក្រុងភ្នំពេញនៅឆ្នាំ 1966 លោកបានរិះគន់ដោយចំហថាសហរដ្ឋអាមេរិកធ្វើសង្គ្រាមនៅវៀតណាម ដើម្បីឧត្តមភាពនិយម ។ នៅឆ្នាំ 1964 បារាំងបានភ្ជាប់ទំនាក់ទំនងជាមួយចិន សហភាពសូវៀត និងប្រទេសអឺរ៉ុបខាងកើត ។ ប្រទេសបារាំងបានដក

ខ្លួនចេញពីអង្គការអូតង់នៅឆ្នាំ 1966 ដែរ ។ ដើម្បីពង្រីកតួនាទីមហាអំណាច បារាំងធ្វើការសាកល្បងអាវុធបរមាណូនៅលើកោះមូរ៉ូអា ទោះបីជាមានការហាមមិនឱ្យធ្វើការពិសោធបរមាណូរវាងមហាអំណាច និងមានការជំទាស់យ៉ាងខ្លាំងក្លាពីប្រទេសមួយចំនួននៅលើមាត់ច្រាំងប៉ាស៊ីហ្វិកក៏ដោយ ។ បារាំងក៏បានចូលរួមក្នុងសង្គ្រាមឈូងសមុទ្រពែក្សក្នុងនាមអង្គការសហប្រជាជាតិជាមួយសហរដ្ឋអាមេរិក ។ ចំពោះនយោបាយពិភពលោកវិញ បារាំងគឺជាមហាអំណាចមួយយ៉ាងសំខាន់នៅក្នុងក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិដែលមានសិទ្ធិប្រើច្បាប់ វេតូ ដែលប្រឆាំងនឹងដំណោះស្រាយណាមួយទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ក្នុងការដាក់ទណ្ឌកម្មខាងសេដ្ឋកិច្ច ឬអន្តរាគមន៍ខាងយោធានៅក្នុងរឿងចម្រូងចម្រាសណាមួយដូចជា ករណីប្រទេសអ៊ីរ៉ង់ ឬប្រទេសកូរ៉េខាងជើងជាដើម ។

ពិសេសជាងនេះទៀត បារាំងគឺជាមហាអំណាចធុនមធ្យមមួយដែលមានកម្លាំងការពារខ្លួនដោយផ្ទាល់ មិនចាំបាច់ពឹងលើសម្ព័ន្ធភាពនៅពេលមានអាសន្ន ។ កត្តានេះហើយដែលនាំឱ្យបារាំងសោះអង្គើយនឹងអង្គការអូតង់ ។ នៅក្នុងនយោបាយអឺរ៉ុបវិញបារាំងជាប្រទេសហត្ថលេខីនៅក្នុងសន្ធិសីទម៉ាស្ទ្រិក(Maastricht) នៅឆ្នាំ 1991 ដើម្បីបង្កើតរូបិយប័ណ្ណរួមឈ្មោះ អឺរ៉ូ (Euro) ។

## ? សំណួរ

1. តើប្រទេសបារាំងជាអ្នកឈ្នះ ឬជាអ្នកចាញ់សង្គ្រាមលោកលើកទី 2 ?
2. តើអ្នកណារំដោះប្រទេសបារាំងចេញពីហ្វាស៊ីសអាល្លឺម៉ង់ ?
3. ចូររៀបរាប់ពីរបបសាធារណរដ្ឋទី 4 និងទី 5 ។
4. ហេតុអ្វីបានជាលោក សាលដឺហ្គោល ធ្លាក់ពីតំណែងប្រធានាធិបតី ?
5. តើនយោបាយក្រៅប្រទេសរបស់បារាំងក្នុងសាធារណរដ្ឋទី 5 មានគោលដៅអ្វីខ្លះ ?

មេរៀនទី

# 4 សហព័ន្ធអាល្លឺម៉ង់ (1945-1991)

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីប្រទេសអាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី 2 និងការបែងចែកអាល្លឺម៉ង់ជា 4 ។
- យល់ដឹងពីបុព្វហេតុនៃការបែកបាក់ និងការរួបរួមអាល្លឺម៉ង់ទាំង 2 ។
- ពង្រីកសាមគ្គីភាព ពង្រឹងសន្តិភាព ធ្វើដំណោះស្រាយដោយសន្តិភាព ។

## 1. ប្រទេសអាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី 2

នៅក្នុងសង្គ្រាមលោកលើកទី 2 យើងឃើញមានមហាអំណាច 2 ដែលដើរតួនាទីសំខាន់នៅអឺរ៉ុបគឺសហភាពសូវៀត និងសហរដ្ឋអាមេរិក(ក្រៅទ្វីបអឺរ៉ុប) ដែលបានដណ្តើមគ្នាយកឧត្តមភាពក្រោយបរាជ័យនៃកងទ័ពណាស៊ី ។ នៅសមរភូមិប៉ែកខាងកើត កងទ័ពសូវៀតវាយបំបាក់ទ័ពអាល្លឺម៉ង់ឱ្យបរាជ័យជាបន្តបន្ទាប់ ហើយបានរំដោះយកប្រទេសយ៉ាងច្រើន និងបានធ្វើឱ្យពិភពលោកកោតស្ញប់ស្ញែង ជាពិសេសមជ្ឈដ្ឋាននៃពួកអឺរ៉ុបខាងលិចដែលត្រូវលុកលុយដោយទ័ពអាល្លឺម៉ង់ ។

នៅប៉ែកខាងលិច កងទ័ពសហរដ្ឋអាមេរិកបានគ្រប់គ្រងតំបន់ច្រាំងនៅន័រម៉ង់ឌីនៅថ្ងៃទី 6 ខែមិថុនា ឆ្នាំ 1944 និងធ្វើដំណើរទៅមុខយឺតៗ បណ្តាលមកពីការទប់ទល់យ៉ាងខ្លាំងពីពួកអាល្លឺម៉ង់ ។ កងទ័ពសម្ព័ន្ធមិត្តបានវាយចូលប្រទេសអាល្លឺម៉ង់ពីទិសខាងលិច ចំណែកកងទ័ពក្រហមបានវាយចូលទឹកដីអាល្លឺម៉ង់ពីទិសខាងកើតដែលជាអំពើសងសឹកត្រឡប់ទៅលើប្រជាជនអាល្លឺម៉ង់យ៉ាងសាហាវ ។ ទីក្រុងធំៗរបស់អាល្លឺម៉ង់ត្រូវខ្ទេចខ្ទាំដោយគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែក ។ អ៊ីត្លែបានធ្វើអត្តឃាតនៅពេលដែលទ័ពសម្ព័ន្ធមិត្តចូលដល់ទីក្រុងបែរឡាំង ។ នៅថ្ងៃទី 8 ខែឧសភា ឆ្នាំ 1945 អាល្លឺម៉ង់បានប្រកាសចាញ់សង្គ្រាមលោកលើកទី 2 ដោយឥតលក្ខខណ្ឌ ។ បួនខែក្រោយមក ជប៉ុនក៏ទម្លាក់អាវុធចុះចាញ់ដោយឥតលក្ខខណ្ឌដែរនៅថ្ងៃទី 15 ខែសីហា ឆ្នាំ 1945 បន្ទាប់ពីបានទទួលរងការវិនាសដោយអាវុធមហាប្រល័យ 2 គ្រាប់(បរមាណូ) នៅហ៊ីរ៉ូស៊ីម៉ា និងណាកាសាគី ។

បញ្ហាមួយទៀតដែលនាំឱ្យមានផលវិបាកវែងឆ្ងាយគឺនៅពេលដែលដឹងថាកងទ័ពអាល្លឺម៉ង់ពិតជាត្រូវចាញ់សង្គ្រាមនៅពេលខាងមុខ ពួកមហាអំណាចក្នុងសង្គ្រាមបាននាំគ្នាបង្កើតសន្និសីទអន្តរជាតិមួយនៅទីក្រុងយ៉ាល់តា ដែលជាទីក្រុងលំហែកាយនៅមាត់សមុទ្រខ្មៅដើម្បីកំណត់វាសនាប្រទេសអាល្លឺម៉ង់ក្រោយសង្គ្រាមដើម្បីផ្តាច់សរសៃឈាមប្រទេសនេះកុំឱ្យមានឱកាសបង្កសង្គ្រាមលោកជាថ្មីទៀត ។ សន្និសីទធ្វើឡើងដោយមហាអំណាចទាំង 3 មានសហភាពសូវៀត អាមេរិក និងចក្រភពអង់គ្លេស ។

នៅក្រោយសង្គ្រាម អាល្លឺម៉ង់ត្រូវបានបែងចែកជា2គឺអាល្លឺម៉ង់ខាងលិច និងអាល្លឺម៉ង់ខាងកើត ។ អាល្លឺម៉ង់ខាងលិច ត្រូវដាក់ពង្រាយដោយកងទ័ពសម្ព័ន្ធមិត្តដែលចែកជា 3 តំបន់មាន 11 រដ្ឋ(Landers) ជារដ្ឋសហព័ន្ធ ។ ចំណែកអាល្លឺម៉ង់ខាងកើតគ្រប់គ្រងដោយសហភាពសូវៀត ជារដ្ឋប្រជាធិបតេយ្យប្រជាមានិតដូចជាប្រទេសផ្សេងៗទៀតនៅអឺរ៉ុបខាងកើត ដែលរំដោះដោយកងទ័ពក្រហមដែរ ។ អាល្លឺម៉ង់ទាំង 2 នេះមានរដ្ឋធានីផ្សេងគ្នាអាល្លឺម៉ង់ខាងកើតមានរដ្ឋធានីបែរឡាំង និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់មានរដ្ឋធានីឈ្មោះ បោន(Bonn) ។

## 2. បញ្ហាអាល្លឺម៉ង់ជាស្នូលនៃសង្គ្រាមត្រជាក់

បញ្ហាអាល្លឺម៉ង់ធ្វើឱ្យអឺរ៉ុបមានភាពល្អក់កករតាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដើម្បីស្តារទ្វីបអឺរ៉ុបឡើងវិញនៅក្រោយសង្គ្រាមលោកលើកទី 2 គឺផែនការម៉ាសាលរបស់អាមេរិកដែលស្នើនៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 1947 នៅសកលវិទ្យាល័យហាវើត ។ ផែនការនេះបានញ៉ាំងឱ្យសហភាពសូវៀតមិនសប្បាយចិត្ត ពីព្រោះផែនការនេះមានទិសដៅទប់ស្កាត់ការរីកសាយនៃចលនាកុម្មុយនីស្តនៅតាមប្រទេសលោកខាងលិចមួយចំនួននៅក្រោយសង្គ្រាម ។

នៅខែមិថុនា ឆ្នាំ 1947 មានសន្និសីទនៅទីក្រុងឡុងដ៍ដែលចូលរួមដោយក្រុមសម្ព័ន្ធមិត្តទាំង 3 ដើម្បីពិភាក្សាពីបញ្ហាអាល្លឺម៉ង់ ការបង្រួបបង្រួមអាល្លឺម៉ង់ខាងលិចជាតំបន់តែមួយ និងការឯកភាពខាងរូបិយប័ណ្ណពីម៉ាក់(Mark) មកជាដឹតម៉ាក់( Deutsmark ) ។ ការសម្រេចប្រើរូបិយប័ណ្ណថ្មីដោយសម្ងាត់នេះធ្វើឱ្យសហភាពសូវៀតមិនសប្បាយចិត្ត ហើយបានចោទថាជារដ្ឋប្រហារហិរញ្ញវត្ថុដើម្បីរំលំសេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើត ។ នៅថ្ងៃទី 12 ខែមិថុនា ឆ្នាំ 1948 សហភាពសូវៀតប្រើវិធានការសងសឹកវិញតាមរយៈការបិទច្រកចូលក្រុងបែរឡាំងខាងលិច ។ ការកាត់ផ្តាច់អគ្គិសនីជាបញ្ហាធ្ងន់ធ្ងរ និងតម្រូវការចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ ។ ការផ្តាច់ភ្លើង និងបិទផ្លូវជាការមួយដែលធ្វើឱ្យប្រជាជននៅបែរឡាំងខាងលិចទ័លច្រកមិនអាចរកមធ្យោបាយមកដោះស្រាយបាន ពីព្រោះបែរឡាំងខាងលិចស្ថិត

នៅក្នុងទិកដីអាល្លឺម៉ង់ខាងកើត ។ វិបត្តិនេះគឺជាការរាំងខ្ទប់បែរឡាំងដែលជាវិធានការបិទផ្លូវសេដ្ឋកិច្ច ដែលពួកសម្ព័ន្ធមិត្តមានការខ្វល់ខ្វាយជាខ្លាំង ។ ពួកសម្ព័ន្ធមិត្តបានប្រថុយនូវគ្រោះថ្នាក់ដើម្បីដោះស្រាយវិបត្តិនេះ ។ ពួកគេគិតថានឹងមានសង្គ្រាមសាជាថ្មីអាចផ្ទុះឡើងក្នុងទឹកដីអាល្លឺម៉ង់ ប្រសិនជាសហភាពសូវៀតចាត់វិធានការម៉ឺងម៉ាត់ដើម្បីប្រឆាំង ។ នៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ 1948 ពួកសម្ព័ន្ធមិត្តបានប្រើយន្តហោះ 380 គ្រឿង ដើម្បីដឹកស្បៀង និងគ្រឿងផ្គត់ផ្គង់ចំនួន 1 500 000 តោន សម្រាប់ផ្គត់ផ្គង់បែរឡាំងខាងលិចតាមស្ពានអាកាស (Airlift) ។ ជាភ័ព្វសំណាង សកម្មភាពនេះបានប្រព្រឹត្តទៅដោយគ្មានការរំខានពីសហភាពសូវៀត ។ នៅខែមេសា ឆ្នាំ 1949 សន្ធិសិទ្ធិទីក្រុងវ៉ាស៊ីនតោនបានសម្រេចបង្កើតរដ្ឋាភិបាលអាល្លឺម៉ង់ថ្មី ។ នៅខែមិថុនា ឆ្នាំ 1949 ផ្លូវទៅកាន់បែរឡាំងខាងលិចត្រូវបានបើកឡើងវិញ ។ ដើម្បីឆ្លើយតប សហភាពសូវៀតក៏បានបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ឬអាល្លឺម៉ង់ខាងកើតនៅថ្ងៃទី 7 ខែតុលា ឆ្នាំ 1949 ។ អាល្លឺម៉ង់ខាងលិចត្រូវបំពាក់អាវុធឡើងវិញនិងដាក់បញ្ចូលជាសមាជិកទី 15 នៃអង្គការអាត្លង់ទិកខាងជើងហៅកាត់ថា **អូតង់**[1] ដើម្បីការពារអឺរ៉ុបខាងលិច ។ នៅថ្ងៃទី 14 ខែឧសភា ឆ្នាំ 1955 សហភាពសូវៀតបានបង្កើតបក្សវ៉ាសូវី ។ ក្រោមការដឹកនាំនៃរដ្ឋាភិបាលថ្មី សេដ្ឋកិច្ចរបស់អាល្លឺម៉ង់ខាងលិចរីកចម្រើនយ៉ាងខ្លាំង និងបានទាក់ទាញប្រជាជនអាល្លឺម៉ង់ខាងកើតហូរចូលមកអាល្លឺម៉ង់ខាងលិចជាច្រើន ។ ដើម្បីទប់ទល់នឹងបញ្ហានេះ សហភាពសូវៀតបានកសាងកំពែងមួយមានបណ្តោយ 42 km ។ នៅថ្ងៃទី 13 ខែសីហា ឆ្នាំ 1961 ជញ្ជាំងនេះបញ្ជាក់ថាទ្វីបអឺរ៉ុបមានប្លុក 2 គឺខាងកើត និងខាងលិច ជាពិសេសវាជានិមិត្តរូបនៃសង្គ្រាមត្រជាក់ ជំរុញឱ្យពិភពលោកស្ថិតនៅលើផ្លូវនៃសង្គ្រាមលោកលើកទី 3 ដោយសារការរត់ប្រណាំងសព្វាវុធមិនចេះហត់នឿយទំរាំដល់មានការដួលរលំនៃសហភាពសូវៀតនៅឆ្នាំ 1991 ។

## 3. ការចាប់បដិសន្ធិនៃអាល្លឺម៉ង់ខាងលិច

ការបោះឆ្នោតសកលលើកដំបូងត្រូវបានធ្វើឡើងនៅថ្ងៃទី 14 ខែសីហា ឆ្នាំ 1949 នៅអាល្លឺម៉ង់ខាងលិចតាមការសន្យារបស់សម្ព័ន្ធមិត្ត ពេលនោះគណៈបក្សកាតូលិកប្រជាធិបតេយ្យបានឈ្នះឆ្នោតដែលមានមេដឹកនាំឈ្មោះ កុងរ៉ាត់ អាដេណូអឺ (Konrad Adenauer 1949-1963) ។ នៅក្រោមការដឹកនាំរបស់លោក សហព័ន្ធអាល្លឺម៉ង់មានការរីកចម្រើនទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ជាពិសេសគឺការធ្វើឱ្យប្រទេសមានអធិបតេយ្យគឺបំពាក់អាវុធឡើងវិញ ។

---

(1). អូតង់ (NATO) North Atlantic Treaty Organization.

នៅថ្ងៃទី 16 ខែតុលា ឆ្នាំ 1963 លោកអធិការបតីអាដេណូអឺបានលាលែងពីតំណែង ហើយត្រូវបានជំនួសដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុ លូវីង អឺហាត( Luwing Erhard : 1963-1966) ដែលបានជំរុញសេដ្ឋកិច្ចអាល្លឺម៉ង់ក្រោមជំនួយនៃផែនការម៉ាសាល់ឱ្យក្លាយទៅជាមហាអំណាចសេដ្ឋកិច្ច ។ ចាប់ពីលោក **លូវីង អឺហាត** រហូតលោកអធិការបតីហេលមុតខូល( Helmut Kohl ) សុទ្ធតែបានធ្វើឱ្យសហព័ន្ធអាល្លឺម៉ង់ក្លាយជាប្រទេសគំរូខាងផ្នែកសេដ្ឋកិច្ចនៅអឺរ៉ុប ។ ប៉ុន្តែនៅក្នុងតំណែងរបស់លោកខូលត្រូវប្រឈមមុខនឹងបញ្ហារំជើបរំជួលដោយបញ្ហាចលនាសន្តិភាពដែលបានដង្ហែក្បួនបាតុកម្មប្រឆាំងនឹងការតាំងកាំជ្រួចផ្លោងពុនជីស៊ីង( Pershing) ដើម្បីប្រឆាំងនឹងប្រទេសប្លុកវ៉ាសូវីនៅសម័យសង្គ្រាមត្រជាក់ ។

# 4. ការបង្រួបបង្រួមប្រទេសអាល្លឺម៉ង់

ពិភពលោកទាំងមូលគិតថាការបែងចែកប្រទេសអាល្លឺម៉ង់ជា 2 នៅក្រោយសង្គ្រាមលោកលើកទី 2 គឺជាការរៀនខ្មាសបំផុត ។ ការបែងចែកនេះធ្វើឱ្យពិភពលោករស់នៅក្នុងភាពរំជើបរំជួលក្រោមព្យុះនៃសង្គ្រាមត្រជាក់អស់ជិតកន្លះសតវត្សដែលមានជញ្ជាំងបែរឡាំងជានិមិត្តរូប ដែលត្រូវគេផ្តួលរំលំនៅថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 1989 ។

ការកំណត់នៃការបញ្ចប់សង្គ្រាមត្រជាក់គឺការដួលរលំនៃអតីតសហភាពសូវៀត ហើយការប្រកួតប្រជែងដណ្តើមឧត្តមភាពគ្រប់គ្រងពិភពលោកត្រូវបញ្ចប់ ។ អាល្លឺម៉ង់ត្រូវបានបង្រួបបង្រួមគ្នាទៅជាប្រទេសតែមួយ ។

## 4.1. ការបង្រួបបង្រួមប្រទេសអាល្លឺម៉ង់មាន ៣ ដំណាក់កាល

**ដំណាក់កាលទី 1 :** នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1990 ធ្វើឱ្យរូបិយប័ណ្ណមានឯកភាពតែមួយគឺ ប្តូរប្រាក់ម៉ាក់ (ខាងកើត) មកជាដឺតម៉ាក់ (អាល្លឺម៉ង់ខាងលិច) វិញ ។

**ដំណាក់កាលទី 2 :** នៅថ្ងៃទី 3 ខែតុលា ឆ្នាំ 1990 ប្រកាសឱ្យមានឯកភាពផ្នែកនយោបាយ ហើយអតីតសាធារណរដ្ឋប្រជាធិតេយ្យអាល្លឺម៉ង់បានចូលរួមជាមួយសហព័ន្ធអាល្លឺម៉ង់ដោយរំលាយរដ្ឋទាំង 5 ។

**ដំណាក់កាលទី 3 :** តាមរយៈសន្ធិសញ្ញាថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1990 ពួកសម្ព័ន្ធមិត្តដែលបានឈ្នះសង្គ្រាមលោកលើកទី 2 ទាំង 4 រួមមានសហរដ្ឋអាមេរិក សហភាពសូវៀត ចក្រភពអង់គ្លេស និងសាធារណរដ្ឋបារាំងត្រូវដកកងទ័ពទាំងអស់ចេញពីទឹកដីអាល្លឺម៉ង់ទាំង 2 ដើម្បីដោះលែងប្រទេសអាល្លឺម៉ង់ឱ្យមានសេរីភាពខាងនយោបាយពោលគឺ អធិបតេយ្យ និងឯករាជ្យឡើងវិញ ។ ការរង់ចាំរហូតដល់ខែកញ្ញា ឆ្នាំ 1994 ទើបទ័ពសម្ព័ន្ធមិត្តដកអស់ពីទឹកដីអាល្លឺម៉ង់ជាស្ថាពរ ។ បញ្ហាដែលនៅសេសសល់គឺបញ្ហាព្រំដែនរវាងអាល្លឺម៉ង់ និងប៉ូឡូញ ។

## 4.2. វិស័យសេដ្ឋកិច្ច

ការរីកចម្រើនខាងសេដ្ឋកិច្ចអាស្រ័យលើកត្តាអនុគ្រោះមួយចំនួនដូចជា ៖

- តំបន់ធ្យូងថ្មដ៏ធំរបស់អាល្លឺម៉ង់គឺ តំបន់រូ( Rhur )ដែលជាប្រភពថាមពលសម្រាប់រោងចក្រធំៗ មានរោងចក្រស្លដែកជាដើម ។
- ភាពសម្បូរទៅដោយហត្ថករដោយមានប្រាក់កម្រៃថោក ដែលមានប្រភពជនភៀសខ្លួនមកពីអាល្លឺម៉ង់ខាងកើត និងអឺរ៉ុបប៉ែកខាងត្បូងមានក្រិក យូហ្គោស្លាវី និងតួកគីជាដើម ។ ប្រទេសអាល្លឺម៉ង់ត្រូវការពលករជាច្រើននាក់ក្នុងមួយឆ្នាំៗ ដើម្បីជំនួសជនជាតិអាល្លឺម៉ង់ដែលមានវ័យចាស់ ។ នៅទ្វីបអឺរ៉ុបមានតែអាល្លឺម៉ង់មួយគត់ដែលសម្បូរទៅដោយប្រជាជនមានវ័យចំណាស់ ពីព្រោះអត្រាកំណើនកុមារទាបពេកមានចំនួន $\frac{10}{1000}$ ក្នុងមួយឆ្នាំៗ ។



រោងចក្រដំឡើងរថយន្ត BMW

ចាប់ពីឆ្នាំ 1951 ការកសាងទ្វីបអឺរ៉ុបឡើងវិញគឺជាការបើកចំហទីផ្សារអាល្លឺម៉ង់ឱ្យកាន់តែធំទូលាយថែមទៀត ។ គេបានពង្រីកតំបន់ឧស្សាហកម្មធំៗជាច្រើនកន្លែងនៅទូទាំងប្រទេសដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ។ ឧស្សាហកម្មដ៏ល្បីល្បាញនាំមុខគេនៅទ្វីបអឺរ៉ុបរបស់អាល្លឺម៉ង់គឺរោងចក្រគ្រឿងអគ្គិសនី រោងចក្រគីមី រោងចក្រស្លដែក និងរោងចក្រផលិតគ្រឿងម៉ាស៊ីនធំៗ ។ អាល្លឺម៉ង់គឺជាប្រទេសនាំមុខគេខាងផ្នែកផលិតផលកសិកម្មផងដែរដូចជាស្ករ ទឹកដោះ សាច់ និងទទួលបានចំណាត់ថ្នាក់លេខ 2 សម្រាប់ការនាំចេញផ្លែឈើ និងដំឡូងបារាំង ។

ចំពោះវិស័យពាណិជ្ជកម្មក្រៅប្រទេស អាល្លឺម៉ង់បាននាំចេញនាំមុខគេទៅទ្វីបអឺរ៉ុបខាងផ្នែកផលិតផលគីមី ម៉ាស៊ីន និងរថយន្ត ចំណាត់ថ្នាក់លំដាប់ទី 3 នៅលើពិភពលោកបន្ទាប់ពីជប៉ុននិងអាមេរិក ។ បើគិតជាការទូទាត់ ជញ្ជីងពាណិជ្ជកម្មអាល្លឺម៉ង់បានចំណេញប្រាក់ច្រើនដោយការនាំចេញច្រើនជាងការនាំចូល ។

## 4.3. វិស័យសង្គម

សហព័ន្ធអាល្លឺម៉ង់ជាប្រទេសមួយដែលបានគិតនៅក្នុងវិស័យសង្គមល្អជាងគេនៅទ្វីបអឺរ៉ុបចាប់ពីប្រាក់ធានារ៉ាប់រងជំងឺការងារ អ្នកឥតការងារធ្វើ មនុស្សវ័យជរា ។ និយាយរួមគឺប្រជាជន 85% ទទួលបានប្រាក់ធានារ៉ាប់រងបើគិតជាទឹកប្រាក់សរុបមានចំនួន 5 741 ពាន់លានម៉ាក់នៅក្នុងឆ្នាំ 1985 ។ ស្ត្រីមានសិទ្ធិស្មើនឹងបុរសដែលមានចែងនៅក្នុងច្បាប់ជាមូលដ្ឋាន ស្ត្រីចំនួន $\frac{1}{2}$ ចាប់ពីអាយុ 15 ដល់ 50 ឆ្នាំ ទទួលបានការងារនៅខាងក្រៅផ្ទះ ។ តាមច្បាប់ស្ត្រីមានផ្ទៃពោះត្រូវបានឈប់សម្រាកនៅផ្ទះចំនួន 6 ខែ ក្រោយពេលឆ្លងទន្លេដើម្បីថែរក្សាទារក ។

ចំពោះផ្នែកសុខភាពវិញ តាមការធ្វើជំរឿនឆ្នាំ 1986 គេឃើញមនុស្សប្រុសមានអាយុមធ្យម 71 ឆ្នាំចំណែកមនុស្សស្រីវិញអាយុមាន 77 ឆ្នាំ ។ អត្រាមរណៈសម្រាប់កុមារមាន 9 នាក់ក្នុងចំនួន 1 000 នាក់ ។ នៅទូទាំងប្រទេសអាល្លឺម៉ង់មានគ្រូពេទ្យចំនួន 153 895 នាក់ គឺគ្រូពេទ្យម្នាក់សម្រាប់ប្រជាជន 376 នាក់មានទន្តពេទ្យចំនួន 34 415 នាក់ ឱសថការី 30 865 នាក់ និងគិលានុបដ្ឋាយិកាចំនួន 263 435 នាក់ (1986) ។

ចំពោះបញ្ហាជម្រកវិញ នៅក្នុងអំឡុងសង្គ្រាមលោកលើកទី 2 មានផ្ទះ 12 លានខ្នងត្រូវបានបំផ្លាញ ។ ចាប់ពីឆ្នាំ 1949 ដល់ 1972 រដ្ឋាភិបាលអាល្លឺម៉ង់បានសង់ផ្ទះថ្មីចំនួន 12 លានខ្នង ។ នៅក្នុងឆ្នាំ 1985 ការចំណាយប្រាក់សម្រាប់សាងសង់ផ្ទះសំបែងមានរហូតដល់ទៅ 40 ពាន់លានម៉ាក់ ។

ផ្នែកសិក្សាធិការជាការទទួលបន្ទុករបស់រដ្ឋនីមួយៗ( Lander) ចាប់ពីអាយុ 6 ដល់ 18 ឆ្នាំ ។ កុមារទាំងអស់ត្រូវចូលរៀននៅបឋមសិក្សាចាប់ពីអាយុ 6 ដល់ 10 ឆ្នាំ បន្ទាប់មកគេត្រូវចូលរៀននៅមធ្យមសិក្សាដែលជាសាលាតម្រង់ទិសវិជ្ជាជីវៈដែលជាគ្រឹះសម្រាប់បច្ចេកវិទ្យាជាន់ខ្ពស់សម្រាប់ចូលរៀននៅថ្នាក់មហាវិទ្យាល័យ ។ នៅក្នុងសហព័ន្ធអាល្លឺម៉ង់មានសាលាវិជ្ជាជីវៈ 5 847 កន្លែង សាកលវិទ្យាល័យ 59 (ជំរឿនឆ្នាំ 1986) ។ នៅអាល្លឺម៉ង់ សាកលវិទ្យាល័យដែលមានវ័យចំណាស់ជាងគេគឺហៃដេប៊ែរ ដែលចាប់កសាងតាំងពីឆ្នាំ 1356 មកម្ល៉េះ ។

### ? សំណួរ

1. ហេតុអ្វីបានជាអាល្លឺម៉ង់បែកបាក់ជាពីរ ? នៅថ្ងៃខែឆ្នាំណា ?
2. តើកត្តាអ្វីដែលធ្វើឱ្យប្រទេសអាល្លឺម៉ង់បង្រួបបង្រួមគ្នាវិញ ? នៅថ្ងៃខែឆ្នាំណា ?
3. ចូរនិយាយពីវិស័យសេដ្ឋកិច្ច និងសង្គមនៅអាល្លឺម៉ង់ខាងលិច ?

មេរៀនទី

# 5 ប្រទេសអ៊ីតាលី

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាព្រឹត្តិការណ៍សំខាន់ៗនៅប្រទេសអ៊ីតាលីក្រោយសង្គ្រាមលោកលើកទី 2 ។
- ❑ វិភាគពីការចាប់បដិសន្ធិនៃសាធារណរដ្ឋអ៊ីតាលី និងស្ថានភាពសេដ្ឋកិច្ច ។
- ❑ ចេះដកស្រង់បទពិសោធល្អៗពីការអភិវឌ្ឍជាតិនៅអ៊ីតាលី ។

អ៊ីតាលីស្ថិតនៅអឺរ៉ុបប៉ែកខាងត្បូង មានផ្ទៃក្រឡា 301 230 $km^2$ មានប្រជាជន 58 លាននាក់ (ឆ្នាំ 2006) ។ ប្រទេសអ៊ីតាលីលាតសន្ធឹងពីជើងទៅត្បូង សម្បូរទៅដោយភ្នំ ខ្ពង់រាប និងវាលទំនាប ចំនួន $\frac{3}{4}$ នៃផ្ទៃប្រទេស ។ អ៊ីតាលីមានកោះពីរសំខាន់គឺ កោះស៊ីស៊ីល និងសាដែង ស្ថិតនៅក្នុងលំហសមុទ្រមេឌីទែរ៉ានេ ។ ប្រទេសអ៊ីតាលីបែងចែកជាពីរសាធារណរដ្ឋគឺ សាន់ម៉ារីណូស្ថិតនៅភាគខាងកើតប៉ែកកណ្តាល និងបុរីវ៉ាទីកង់ស្ថិតនៅកណ្តាលទីក្រុងរ៉ូម ដែលជាលំនៅរបស់ស្តេចប៉ាបមេណាឌិចទី 16ជាប្រមុខនៃសាសនាកាតូលិកនៅលើពិភពលោក ។ អ៊ីតាលីជាឈ្មោះរ៉ូម៉ាំងហៅថា អ៊ីតាលីយ៉ា សំគាល់យកប៉ែកខាងត្បូងដែលមានន័យថាវាលស្មៅ ។ ប្រទេសនេះមានទីក្រុងល្បីល្បាញជាច្រើន ដូចជារ៉ូម គឺជាទីក្រុងនៃចក្រភពរ៉ូម ដែលមានអាយុជាង 2000ឆ្នាំមកហើយ ក្រុងហ្វូរ៉ង់ គឺជាទីក្រុងសិល្បៈដ៏ល្បីល្បាញបំផុតនៅលើពិភពលោក និងទីក្រុងល្បីល្បាញមួយទៀតគឺ វើនី ជាទីក្រុងទឹកដែលទាក់ទាញភ្ញៀវទេសចរគ្រប់ប្រទេសលើពិភពលោក ។

## 1. ការបង្កើតសាធារណរដ្ឋអ៊ីតាលី

ក្រោយការដួលរលំនៃចក្រភពរ៉ូម ទឹកដីនេះត្រូវបានគេបែងចែកជារដ្ឋតូចៗ ប៉ុន្តែនៅពេលដែលព្រះចៅណាប៉ូលេអុងចូលត្រួតត្រាលើតំបន់នេះ ក៏បានបញ្ចូលតំបន់នេះឱ្យនៅក្រោមចក្រភពបារាំង ។ នៅឆ្នាំ 1861 អ៊ីតាលីក្លាយជាប្រទេសឯករាជ្យនៅក្នុងរាជ្យព្រះចៅ វិចទ័រ អេម៉ានូអែលទី 2 (Victor Emanuel II) ហើយប្រែក្លាយជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ចាប់ពីឆ្នាំ 1920 ដល់ឆ្នាំ 1943 អ៊ីតាលីជារដ្ឋហ្វាស៊ីសមួយដែលដឹកនាំដោយលោក មូសូលីនី ដែលជាដៃគូណាស៊ី អាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី 2 ។ ក្រោយឆ្នាំ 1946 អ៊ីតាលីក្លាយជាសាធារណរដ្ឋសេដ្ឋកិច្ចពឹងផ្អែកលើវិស័យឧស្សាហកម្មនៅប៉ែកខាងជើង ហើយតំបន់ខាងត្បូងជាតំបន់កសិកម្ម ។

## 1.1. ទម្រង់រដ្ឋាភិបាល

នៅឆ្នាំ 1946 ប្រទេសអ៊ីតាលីបានប្តូរពីរាជានិយមទៅសាធារណរដ្ឋជាលើកដំបូងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងចំនួន 556 នាក់ ដែលជាសភាធម្មនុញ្ញដើម្បីសរសេររដ្ឋធម្មនុញ្ញមួយមុននឹងបង្កើតសាធារណរដ្ឋ ។ នៅឆ្នាំ 1947 រដ្ឋធម្មនុញ្ញបានអនុម័ត និងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 1948 ក្នុងនោះតម្រូវឱ្យមានប្រធានាធិបតី ព្រមទាំងមានព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ ។



ផែនទីប្រទេសអ៊ីតាលី

### ក. ប្រធានាធិបតី

ប្រធានាធិបតីនៃប្រទេសអ៊ីតាលី ត្រូវបោះឆ្នោតជ្រើសរើសដោយព្រឹទ្ធសភា និងសភាតំណាងរាស្ត្រមានអាណត្តិ 7 ឆ្នាំ ។ បេក្ខជនប្រធានាធិបតីទាំងពីរភេទត្រូវមានអាយុយ៉ាងតិច 50 ឆ្នាំ ។ ប្រធានាធិបតីមានតួនាទីជាអ្នកតែងតាំងនាយករដ្ឋមន្ត្រី និងមានសិទ្ធិរំលាយសភា ហើយរៀបចំឱ្យមានការបោះឆ្នោតសាជាថ្មី ។ សិទ្ធិពិសេសមួយទៀតគឺ ប្រធានាធិបតីជាមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពព្រមទាំងមានសិទ្ធិប្រកាសសង្គ្រាមទៀតផង ។ បញ្ហាគួរឱ្យកត់សំគាល់នោះគឺប្រទេសអ៊ីតាលីពុំមានតំណែងអនុប្រធានាធិបតីទេ បើសិនជាប្រធានាធិបតីមានជំងឺ តំណែងបណ្តោះអាសន្នត្រូវប្រគល់ទៅឱ្យប្រធានព្រឹទ្ធសភា ហើយប្រសិនបើប្រធានាធិបតីទទួលមរណភាព សភាទាំងពីរត្រូវបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មីមួយរូបទៀត ។

### ខ. នាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រី គឺជាមន្ត្រីសំខាន់ក្នុងរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីត្រូវបានតែងតាំងដោយប្រធានាធិបតី តាមរយៈការបោះឆ្នោតទុកចិត្តពីសភា ។ ជារឿយៗនាយករដ្ឋមន្ត្រីត្រូវជ្រើសតាំងពីសមាជិកសភា ។ នាយករដ្ឋមន្ត្រីគ្មានកំណត់អាណត្តិទេ សភាអាចដកនាយករដ្ឋមន្ត្រីពីតំណែងប្រសិនបើមានកំហុស ។ ចំណែកគណៈរដ្ឋមន្ត្រីត្រូវជ្រើសតាំងដោយនាយករដ្ឋមន្ត្រី ហើយត្រូវតែងតាំងដោយប្រធានាធិបតី តាមរយៈការសុំសេចក្តីទុកចិត្តពីសភា និងក្រោយការផ្តល់ការទុកចិត្តពីសភា នាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីជារដ្ឋាភិបាលស្របច្បាប់ ។

### គ. សភា

សភាទាំងពីរ គឺព្រឹទ្ធសភា និងសភាតំណាងរាស្ត្រមានសិទ្ធិក្នុងការអនុម័តច្បាប់ ។ សភាតំណាងរាស្ត្រមានសមាជិកចំនួន 630រូប ព្រឹទ្ធសភាមានសមាជិក 315រូប ដោយការបោះឆ្នោត និង 5រូបផ្សេងទៀត កាន់តំណែងអស់មួយជីវិតដែលជ្រើសតាំងដោយប្រធានាធិបតី សមាជិកទាំង 5រូបនេះគឺភាគច្រើនជ្រើសតាំងក្នុងចំណោមអតីតប្រធានាធិបតី ។ សភាតំណាងរាស្ត្របោះឆ្នោតដោយខណ្ឌទាំង 27 ខូទាំងប្រទេស ។ សភាតំណាងរាស្ត្រ និងព្រឹទ្ធសភាមានអាណត្តិ 5ឆ្នាំ ។ ប៉ុន្តែនៅពេលមានវិបត្តិប្រធានាធិបតីអាចរំលាយសភាមុនអាណត្តិ រួចជ្រើសតាំងបោះឆ្នោតសភាថ្មី ។

### ឃ. តុលាការ

ចៅក្រមនៃតុលាការអ៊ីតាលីប្រព្រឹត្តទៅតាមរយៈការតែងតាំង ។ តុលាការជាន់ខ្ពស់ហៅថាតុលាការធម្មនុញ្ញមានសមាជិក 15រូប ។ សមាជិក 5រូបតែងតាំងដោយប្រធានាធិបតី 5រូបតែងតាំងដោយសភា និង 5រូបទៀតតែងតាំងដោយចៅក្រមនៃក្រសួងយុត្តិធម៌ ។

### ង. ប្រជាជន

អ៊ីតាលីមានប្រជាជនកុះករនៅតំបន់ឧស្សាហកម្ម និងនៅទីក្រុងធំៗដូចជាទីក្រុងរ៉ូម មីឡង់ និងណាប ជាដើម ។ ទីក្រុងនីមួយៗមានប្រជាជនរាប់លាននាក់ ។ ប្រជាជនអ៊ីតាលីនៅប៉ែកខាងជើងមានជីវភាពខ្ពស់ជាងខាងត្បូង ។ ប្រជាជន $\frac{2}{3}$ ចូលចិត្តរស់នៅក្នុងក្រុង ពួកគេភាគច្រើនរស់នៅក្នុងផ្ទះល្វែង លើកលែងតែអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភទើបរស់នៅក្នុងភូមិគ្រឹះ និងមានបរិវេណធំទូលាយ ។ ចំពោះស្ត្រីដែលធ្វើការនៅឆ្ងាយពីផ្ទះ ច្រើនពឹងផ្អែកលើឪពុកម្តាយឱ្យជួយថែទាំចៅ ជួនកាលគេយកកូនទៅដាក់នៅក្នុងមជ្ឈមណ្ឌលកុមារ ។ ប្រជាជននៅក្នុងទីក្រុងភាគច្រើនមានរថយន្តផ្ទាល់ខ្លួនជាប្រការធ្វើឱ្យមានការកកស្ទះចរាចរណ៍ ដែលចោទជាបញ្ហាដល់ការយឺតយ៉ាវក្នុងដំណើរទៅបំពេញការងារ ។ ម្យ៉ាងទៀត បញ្ហាកង្វក់បរិស្ថានធ្វើឱ្យទីក្រុងពោរពេញដោយផ្សែងពុល ។ ជារឿយៗកង្វក់ទីក្រុងចោទជាបញ្ហាដល់សុខភាពប្រជាជន ។ ដើម្បីកាត់បន្ថយបញ្ហានេះ ប្រជាជនមួយភាគធំទៅធ្វើការដោយជិះរថយន្តក្រុង ។ ពួកកសិករមួយភាគធំរស់នៅទីក្រុង ពួកគេចេញទៅចម្ការនៅពេលព្រឹក ហើយពេលល្ងាចត្រឡប់ចូលក្រុងវិញ ។ ចំណែកប្រជាជនភាគខាងត្បូងចូលចិត្តរស់នៅជនបទ ។ គេឃើញមានលំនៅស្ថានបានកើនឡើងច្រើននៅតំបន់ភ្នំ ទោះបីជាតំបន់នោះជាកន្លែងលំហែកាយនៅចុងសប្តាហ៍ ឬក៏នៅរដូវក្តៅក៏ដោយ ។

ប្រជាជនអ៊ីតាលីចំនួន 95% ជាអ្នកកាន់សាសនាកាតូលិក ។ គេនិយមគោរពពិធីផ្សេងៗដូចជាការបំបួស បុណ្យសព និងអាពាហ៍ពិពាហ៍ជាដើម ។ ប្រជាជនអ៊ីតាលីប្រហែល 30% និយមសូត្រធម៌នៅតាមព្រះវិហារយ៉ាងខ្ជាប់ខ្ជួន ។ កាលពីសម័យដើម សាសនាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើច្បាប់ដូចជាការលែងលះគ្នា និងហាមការពន្លូតកូនជាដើម ។ នៅប្រទេសអ៊ីតាលី ក៏មានអ្នកកាន់សាសនាផ្សេងៗដែរដូចជានិកាយប្រូតេស្តង់ អ៊ីស្លាម និងជ្វីបជាដើម ។ បុរីវ៉ាទីកង់ជាទីតាំងរដ្ឋាភិបាលឯករាជ្យនៃសាសនាកាតូលិកមិនចំណុះឱ្យទីក្រុងរ៉ូមឡើយ ។

## 1.2. វិស័យអប់រំ

កុមារចាប់ពីអាយុ 6ឆ្នាំឡើង ត្រូវតែទៅរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ។ រដ្ឋាភិបាលជាអ្នកចេញគោលនយោបាយក្រសួងអប់រំជាអ្នកអនុវត្តគោលនយោបាយអប់រំ និងរៀបចំកម្មវិធីសិក្សានៅគ្រប់ភូមិសិក្សា ព្រមទាំងសៀវភៅសិក្សា ។ ក្រោយពីរៀនចប់មធ្យមសិក្សា សិស្សត្រូវបន្តការសិក្សានៅសាលាវិជ្ជាជីវៈ ។ សិស្សភាគច្រើនចាប់យកមុខវិជ្ជាបច្ចេកទេស ។ ក្រៅពីនេះ នៅប្រទេសអ៊ីតាលីមានសាលាមុខជំនាញបុរាណវត្ថុវិទ្យា និងភាសា ។ នៅទូទាំងប្រទេសអ៊ីតាលីមានសាកលវិទ្យាល័យរដ្ឋចំនួន 47 (ស្ថិតិឆ្នាំ 1948) ហើយក៏មានសាកលវិទ្យាល័យឯកជនមួយចំនួនទៀតផងដែរ ។ ប៉ុន្តែសាលាទាំងនោះគ្រប់គ្រងដោយសាសនា ។ ជារៀងរាល់ឆ្នាំ យ៉ាងហោចណាស់មាននិស្សិតចំនួន 1 លាននាក់ចូលរៀនក្នុងសាកលវិទ្យាល័យ ដែលមានរយៈពេលពី 5ឆ្នាំទៅ 6ឆ្នាំ ។ សាកលវិទ្យាល័យដែលមានវ័យចំណាស់ជាងគេគឺ ប៊ូឡូញ៉ា ដែលសាងសង់នៅឆ្នាំ 1100 នៃគ. ស. ។

## 1.3. ស្ថាបត្យកម្ម

អ៊ីតាលីជាប្រទេសមួយដែលរក្សាមរតកពីចក្រភពរ៉ូម នាំឱ្យប្រទេសនេះល្បីល្បាញខាងស្ថាបត្យកម្មល្បីៗក្នុងលោក ។ ក្រៅពីសំណល់ស្ថាបត្យកម្មរ៉ូម ជនជាតិអ៊ីតាលីមានស្នាដៃផ្ទាល់ខ្លួនដែរដូចជាវិហារ សាំងពីអ៊ែរ (Saint Peter's Church) នៅកណ្តាលក្រុងរ៉ូមដ៏ល្បីល្បាញដែលសាងសង់ឡើងនៅឆ្នាំ 330 នៃគ. ស. ដែលជាស្ថាបត្យកម្មដំបូងនៅមជ្ឈិមសម័យ ។ ក្រៅពីនេះ ប្រទេសអ៊ីតាលីក៏ជាអ្នកថែរក្សាកេរដំណែលពីចក្រភពប៊ីសង់តាំងផងដែរ ដូចជាព្រះវិហារ សាំងម៉ាក់ (Saint Mark) កសាងឡើងក្នុងឆ្នាំ 1000 នៃគ. ស. នៅក្នុងទីក្រុងវើនីស (Venise) ជាដើម ។

### 1.4. បណ្ណាល័យ និងសារមន្ទីរ

ប្រទេសអ៊ីតាលីសម្បូរទៅដោយបណ្ណាល័យ និងសារមន្ទីរជាច្រើននៅតាមទីក្រុងនានា ហើយសារមន្ទីរ និងបណ្ណាល័យទាំងអស់នោះគឺជាស្ថាបត្យកម្មដ៏ល្បីល្បាញដែលស្ថិតក្នុងវាំងស្តេច ឬនៅក្នុងអតីតវិមានរាជវង្សានុវង្ស ដែលបានបន្សល់ទុករាប់តំណាមនុស្សមកហើយ ។ បណ្ណាល័យនៅផ្លូរង់ (Florence) មានសៀវភៅចំនួន 4.5 លានក្បាល និងក្រុងរ៉ូមចំនួន 3.4 លានក្បាល ។ បណ្ណាល័យ និងសារមន្ទីរដើរតួសំខាន់បំផុតសម្រាប់វិស័យទេសចរណ៍ និងការស្រាវជ្រាវ ។ ជនជាតិអឺរ៉ុបភាគច្រើនគេនិយមអានសៀវភៅ ឬសារព័ត៌មានពេលផឹកកាហ្វេ ។

## 2. ចម្បូនភាពសេដ្ឋកិច្ចសង្គម

សេដ្ឋកិច្ចប្រទេសអ៊ីតាលីមានការរីកចម្រើនដោយពឹងផ្អែកទៅលើវិស័យជាច្រើនដូចជា ៖

### 2.1. កសិកម្ម

ប្រទេសអ៊ីតាលីមានផ្ទៃដីកសិកម្មចំនួន 40% នៃផ្ទៃប្រទេស កសិករមានដីកសិដ្ឋានតូចៗ ប៉ុន្តែមិនលើសពី 5 ហិចតា ។ ដីកសិកម្មអ៊ីតាលីមានលក្ខណៈទំនើប ប៉ុន្តែកសិករនៅភាគខាងត្បូងមានជីវភាពមិនទាន់ល្អនៅឡើយ ។ ដំណាំសំខាន់ជាងគេគឺទំពាំងបាយជូរ ។ គេយកទំពាំងបាយជូរធ្វើស្រាសម្រាប់នាំចេញ ។ ក្រៅពីនេះ គេនាំចេញប្រេងអូលីវ ។ ចំណែកដំណាំដទៃទៀតមាន ក្រូច ប៉េងប៉ោះ ផ្លែប៉ោម ដំឡូងបារាំង និងស្ករ ។ ធញ្ញជាតិសំខាន់គឺស្រូវសាលី អង្ករ និងពោត ។ កសិករអ៊ីតាលីសព្វថ្ងៃបានពង្រីកកសិដ្ឋានចិញ្ចឹមសត្វដូចជា ជ្រូក ចៀម និងគោ សម្រាប់បំពេញតម្រូវការក្នុងស្រុក ។ ជនជាតិអ៊ីតាលីនិយមបរិភោគសាច់ច្រើនបំផុត ដូច្នេះសាច់សត្វដែលគេចិញ្ចឹមក្នុងស្រុកមិនគ្រប់គ្រាន់សម្រាប់តម្រូវការទេ គេត្រូវនាំចូលបន្ថែមពីបរទេស ជាពិសេសប្រទេសអាហ្សង់ទីន ។

តំបន់ប៉ូ (Po) ជាតំបន់វាលរាបនៅភាគខាងជើងប្រទេសបានផ្តល់ផលិតផលកសិកម្មស្ទើរតែគ្រប់ប្រភេទសម្រាប់ចិញ្ចឹមប្រជាជនអ៊ីតាលី ។

### 2.2. រ៉ែ

ប្រទេសអ៊ីតាលីមានរ៉ែតិចតួចនៅតាមកោះដូចជា ស៊ីស៊ីល សាដែង និងមួយចំនួនទៀតស្ថិតនៅលើគោកដូចជា តូស្កាន ឡំបាឌី ជាដើម ។ រ៉ែទាំងនោះមានដូចជាក្រានីត ហ្វែលស្ប៉ាថ[1] និងថ្មម៉ាប ។ ចំណែកវិស័យថាមពល អ៊ីតាលីត្រូវនាំចូលពាក់កណ្តាលដើម្បីបំពេញតម្រូវការក្នុងស្រុក ។ អ៊ីតាលី

(1). ហ្វែលស្ប៉ាថ (feldspar) = ប្រភេទរ៉ែម្យ៉ាង

ត្រូវនាំចូលប្រេងនៅពីអារ៉ាប់ដូចជា លីប៊ី និងអ៊ីរ៉ង់ ។ ទឹកដីអ៊ីតាលីមានរ៉ែប្រេង និងឧស្ម័នបន្តិចបន្តួចនៅតំបន់ប៉ូ ។ ថាមពលអគ្គិសនីមាននៅប៉ែកខាងជើងដែរ ប៉ុន្តែថាមពលនេះមិនអាចចែកចាយទូទាំងប្រទេសបានឡើយ គឺប្រើសម្រាប់តែនៅប៉ែកខាងជើងប្រទេសតែប៉ុណ្ណោះ ។

## 2.3. វិស័យទេសចរណ៍

ទេសចរណ៍មានសក្តានុពលដ៏ធំធេង មរតកធម្មជាតិឆ្នេរខ្សាច់ភ្លឺផ្លេកលាតសន្ធឹងនៅក្រោមព្រះអាទិត្យនារដូវក្តៅជាច្រើនកន្លែង និងកេរដំណែលវប្បធម៌ក្រិកពរ៉ូម ព្រមទាំងសារមន្ទីរ ដែលមានឈ្មោះល្បីល្បាញក្នុងពិភពលោកស្ថិតក្នុងទីក្រុងប្រវត្តិសាស្ត្រមួយចំនួនបានទាក់ទាញពួកទេសចរឱ្យចូលមកទស្សនាដោយក្តីរំភើប ។ រូបិយប័ណ្ណហូរចូលតាមរយៈវិស័យទេសចរណ៍នេះ ជាជំនួយសម្រាប់ទូទាត់ជញ្ជីងពាណិជ្ជកម្មដែលខាតបង់មួយផ្នែក និងមួយផ្នែកទៀតសម្រាប់ជួយជំរុញសេដ្ឋកិច្ចអ៊ីតាលីឱ្យក្លាយជាប្រទេសអ្នកមាននៅក្នុងចំណោមប្រទេសមហាអំណាចឧស្សាហកម្មសេដ្ឋកិច្ចទាំង ៨ ។

## 2.4. ពាណិជ្ជកម្ម

នៅទសវត្សរ៍ឆ្នាំ 1990 អ៊ីតាលីជាប្រទេសឧស្សាហកម្មយ៉ាងសំខាន់ ដែលមានដៃគូពាណិជ្ជកម្មជាមួយអាល្លឺម៉ង់ បារាំង សហរដ្ឋអាមេរិក និងអង់គ្លេស ។ អ៊ីតាលីជាប្រទេសនាំចេញសម្លៀកបំពាក់ព្រមទាំងល្បីខាងច្នៃម៉ូតនាំមុខគេនៅលើពិភពលោក ។ ក្រៅពីនេះ មានស្បែកជើង រថយន្ត (Fiat) ម៉ាស៊ីនគ្រប់ប្រភេទ ដែកថែប គីមី និងផលិតផលកសិកម្ម ។ ផលិតផលនាំចូលមាន ប្រេងកាត រ៉ែ កំណាត់សំពត់ ស្រូវសាលី និងសាច់ ។

## ? សំណួរ

1. ចូរបង្ហាញស្ថានភាពភូមិសាស្ត្រប្រទេសអ៊ីតាលី ។
2. តើសាធារណរដ្ឋអ៊ីតាលីកើតឡើងនៅឆ្នាំណា ? មានរចនាសម្ព័ន្ធអ្វីខ្លះ ?
3. តើសេដ្ឋកិច្ចប្រទេសអ៊ីតាលីពឹងផ្អែកលើវិស័យអ្វីខ្លះ ? ចូររៀបរាប់ពីវិស័យទាំងនោះ ។
4. ប្រទេសអ៊ីតាលីសម្បូរខាងស្ថាបត្យកម្មបុរាណ តើបច្ចុប្បន្នវិស័យនេះរីកចម្រើនដែរ ឬទេ ? ព្រោះអ្វី ?
5. តើពាណិជ្ជកម្មអ៊ីតាលីមានអ្វីខ្លះ ?

មេរៀនទី

# 6 សហភាពសូវៀត (1945-1991)

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីស្ថានភាពសង្គមសេដ្ឋកិច្ចសហភាពសូវៀតក្នុងសង្គ្រាមត្រជាក់ ។
- ❑ វិភាគពីនយោបាយប៉េរ៉េស្ត្រូយការបស់លោកហ្គោបាឆូវ ។
- ❑ ស្រឡាញ់សន្តិភាពមានគំនិតច្នៃប្រឌិត និងអភិវឌ្ឍ ។

## 1. សហភាពសូវៀតក្រោយសង្គ្រាមលោកលើកទី 2

សហភាពសូវៀតជាមហាអំណាចមួយថ្មី ដែលកើតចេញពីសង្គ្រាមលោកលើកទី 2 ដោយសារប្រទេសនេះបានយកជ័យជម្នះយ៉ាងធំធេងសូម្បីតែប្រទេសនៅអឺរ៉ុបខាងលិចក៏មានការលើកសរសើរ និងមានជំនឿជឿជាក់យ៉ាងខ្លាំងលើមហាអំណាចថ្មីនេះ ។ ក្រោយសង្គ្រាមលោកលើកទី 2 រដ្ឋាភិបាលអឺរ៉ុបខាងលិចភាគច្រើនសុទ្ធតែមានសមាជិកជាគណបក្សកុម្មុយនីស្តនិយមសហភាពសូវៀត ។ ក្រោយបញ្ចប់សង្គ្រាមលោកលើកទី 2 ស្ថានភាពនយោបាយបានចែកចេញជាពីរប្លុកគឺមូលធននិយមមានសហរដ្ឋអាមេរិកជាមហាអំណាចក្រៅទ្វីបអឺរ៉ុប និងសហភាពសូវៀតនៅក្នុងប្លុកសង្គមនិយមស្ថិតក្នុងទ្វីបអឺរ៉ុប ។ ចាប់ពីឆ្នាំ 1947 ប្លុកទាំង 2 នេះ ប្រឈមមុខដាក់គ្នាជាប្រចាំបន្ទាប់ពីសហរដ្ឋអាមេរិកបានរំដោះអឺរ៉ុបខាងលិចឱ្យចេញពីក្រញាំសហភាពសូវៀតតាមរយៈផែនការម៉ាសាល់ ។ ដំណាក់កាលបង្ហាញកម្លាំងនេះហៅថាសង្គ្រាមត្រជាក់ដែលគំរាមគំហែងដល់ពិភពលោកដោយអាវុធមហាប្រល័យគឺសង្គ្រាមនុយក្លេអ៊ែរ ។

សហភាពសូវៀតបានទទួលជ័យជម្នះយ៉ាងធំធេងលើកងទ័ពអាល្លឺម៉ង់ដ៏ខ្លាំងដូចខ្យល់ព្យុះ ប៉ុន្តែរងនូវវិនាសកម្ម និងការខូចខាតច្រើនជាងគេដែរ ក្នុងការរុញច្រានទ័ពអាល្លឺម៉ង់ឱ្យដកថយមកទិសខាងលិច ។ ផ្លូវរថភ្លើងចំនួន $\frac{2}{3}$ ត្រូវបំផ្លាញរោងចក្រ កសិដ្ឋានរដ្ឋជាច្រើនកន្លែងរងការខូចខាតស្ទើរទាំងស្រុង ។ ជីវិតមនុស្សចំនួន 25 លាននាក់ត្រូវស្លាប់ដោយសារសង្គ្រាម ។

Berlin Wall today

សហភាពសូវៀតមានប្រៀបលើប្រទេសសម្ព័ន្ធមិត្តដោយសារតែគេរំដោះបានទឹកដីយ៉ាងធំទូលាយមានអឺរ៉ុបខាងកើត និងអឺរ៉ុបកណ្តាលរហូតដល់ក្រុងប៊ែរឡាំង ចំណែកទ័ពសម្ព័ន្ធមិត្តចូលតាមទ្វីបអឺរ៉ុបខាងលិចត្រូវរំកិលយ៉ាងយឺតៗ ដោយសារការប្រយុទ្ធរារាំងពីកងទ័ពអាល្លឺម៉ង់ជាពិសេសការវាយឡើងច្រាំងនៅន័រម៉ង់ឌី ។ សហភាពសូវៀតបានរំកិលព្រំដែនចូលប្រទេសប៉ូឡូញ ចំណេញបានទឹកដី 900 000 km$^2$ ហើយប៉ូឡូញក៏បានរុញព្រំដែនចូលទឹកដីព្រុស្សភាគខាងកើត ។ ដូចនេះ ទ័ពសម្ព័ន្ធមិត្តនៅរណសិរ្សខាងលិចបានចូលមកចាប់ដៃជាមួយរណសិរ្សខាងកើតដែលគ្រប់គ្រងដោយសហភាពសូវៀតកណ្តាលទីក្រុងប៊ែរឡាំង ។ លោកវិនស្តុន ឆឺឈីលបានលើកឡើងថា ព្រំដែនអឺរ៉ុបខាងលិចនិងអឺរ៉ុបខាងកើតខណ្ឌចែកដោយវាំងននដែក(Curtain Iron) ។ សហភាពសូវៀតមានឥទ្ធិពលគ្របដណ្តប់លើទ្វីបអឺរ៉ុបមួយចំហៀង ។ ចំណែកនៅអាស៊ី ប្រទេសចិនបានបង្ហាញឥទ្ធិពលរបស់ខ្លួន ដែលនាំឱ្យលោកខាងលិចមានការព្រួយបារម្ភយ៉ាងខ្លាំងដែរ ព្រោះជាប្រទេសធំលំដាប់ទី 4 ខាងទឹកដី និងឈរលំដាប់ទី 1 ខាងចំនួនប្រជាជនបានធ្លាក់ទៅក្នុងកណ្តាប់ដៃមេកុម្មុយនីស្តម៉ៅសេទុងនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 1949 ។

មេដឹកនាំចិនរូបនេះបានប្រកាសប្រទេសជាសាធារណរដ្ឋប្រជាមានិតដូចប្រទេសមួយចំនួននៅអឺរ៉ុបខាងកើត ដែលរួមគ្នាជាកម្លាំងមួយយ៉ាងរឹងមាំប្រឆាំងនឹងលទ្ធិមូលធននិយម ។

## 2. ការស្តារប្រទេសក្រោមការដឹកនាំរបស់ស្តាលីន

សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតមានទិសដៅតែមួយគឺ ការកសាងប្រទេសតាមឱ្យទាន់សហរដ្ឋអាមេរិកដែលជាគូបដិបក្ខធំប្រកបដោយគ្រោះថ្នាក់ និងឈានទៅឈរលំដាប់ទី 1 នៃមហាអំណាចពិភពលោក ។

ក្រោយសង្គ្រាមលោកលើកទី 2 គម្រោងការកសាងប្រទេសត្រូវផ្តើមពីជំហានដំបូង ដោយផ្អែកលើការកសាងផែនការសេដ្ឋកិច្ច ដោយចាប់បន្តអនុវត្តផែនការ 5 ឆ្នាំលើកទី IV និងទី V ដើម្បីស្តារភាពយឺតយ៉ាវនៅក្នុងសង្គ្រាមដោយសារការលុកលុយពីកងទ័ពអាល្លឺម៉ង់ ។

### 2.1. ផែនការ 5 ឆ្នាំលើកទី 4 (1945-1950)

ផែនការ 5 ឆ្នាំលើកទី 1 ក្នុងឆ្នាំ(1928-33) លើកទី 2 ក្នុងឆ្នាំ (1933-1938) បានជោគជ័យ គ្រោងនឹងធ្វើផែនការទី 3 ក្នុងឆ្នាំ(1939-1944) តែសង្គ្រាមលោកលើកទី 2 រំខានទើបលើកផែនការទី 4 ផែនការនេះធ្វើឱ្យមានកំណើនថាមពលទ្វេដងហើយជំរុញឱ្យមានការពង្រីកអណ្តូងប្រេងកាតថ្មីនៅតំបន់បាគូ(Bakou) និងការពង្រីកអណ្តូងរ៉ែធ្យូងថ្មនៅតំបន់ដុងប្រាស(Donbrass) ផ្តោះទៅរកការបង្កើនបរិមាណដែកថែបឱ្យបានទ្វេឡើង ដើម្បីពង្រីករោងចក្រ និងផ្លូវដែកឱ្យបានច្រើនខ្សែបន្ថែមទៀត ។

## 2.2. ផែនការ 5 ឆ្នាំលើកទី 5 (1951-1956)

មានការជំរុញយ៉ាងក្ដៅគគុកលើវិស័យបច្ចេកវិទ្យាជាន់ខ្ពស់ ជាពិសេសទៅលើវិស័យយោធា ។ នៅឆ្នាំ 1953 សូវៀតបានធ្វើឱ្យផ្ទុះគ្រាប់បរមាណូសាកល្បងលើកដំបូងរបស់ខ្លួនគឺ 8 ឆ្នាំក្រោយការទម្លាក់គ្រាប់បែកបរមាណូរបស់សហរដ្ឋអាមេរិកនៅហ៊ីរ៉ូស៊ីម៉ា និងណាកាសាគី ។ ក្រៅពីនេះ មានការពង្រីកវិស័យកសិកម្មរួមមានការដាំដើមឈើជាច្រើនកន្លែង និងពង្រីកផ្ទៃដីដាំស្រូវសាលីនៅភាគខាងត្បូងប្រទេស ។

# 3. លទ្ធិគោរពបុគ្គល

ជ័យជម្នះនៃសង្គ្រាមលោកលើកទី 2 ល្បីខ្ទរខ្ទារនៅលើពិភពលោកទាំងមូល ហើយអ្វីដែលពិសេសលើសនេះទៅទៀតគឺ នៅក្នុងមជ្ឈដ្ឋាននៃប្រជាជនសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត គេបានលើកសរសើរលោកស្តាលីនស្មើនឹងអាទិទេពមួយអង្គ ដែលបានជួយស្រោចស្រង់ប្រជាជនសូវៀតឱ្យរួចចាកផុតពីការកាប់សម្លាប់របស់ទាហានណាស៊ីដ៏សាហាវឃោរឃៅ ។ សេចក្ដីគោរពនេះត្រូវគេមើលឃើញតាមរយៈការប្ដូរឈ្មោះនៃអគារសាធារណៈ ផ្លូវថ្នល់ និងសាលារៀនសុទ្ធតែជាឈ្មោះស្តាលីនទាំងអស់ ហើយនៅតាមសួនច្បារសាធារណៈនៃទីក្រុងនានាទូទាំងសហភាពសូវៀតសុទ្ធតែមានរូបសំណាកលោកស្តាលីន ។ បុណ្យខួបទី 70 ជាមហាមិទិងមួយដែលប្រកាសថាលោកស្តាលីនជាបិតាសន្តិភាព និងជាអ្នករំដោះជីវិតប្រជាជន ។



*លោកស្តាលីន*

ការពង្រឹងអំណាចរបស់ស្តាលីន ធ្វើឡើងតាមរយៈការងារសន្តិសុខដែលដឹកនាំដោយដាណូវ (Danov) ជាអ្នកតាមដានជួរបញ្ញវន្តដូចជាពួកកវីនិពន្ធ ឬពួកសិល្បករល្បីៗ ដែលតែងតែប្រឆាំង ឬបញ្ចេញយោបល់រិះគន់របបស្តាលីន ។ អំណាចរបស់ស្តាលីនត្រូវពង្រឹងដោយការបង្កើតប៉ូលិសសម្ងាត់ដើម្បីបង្ក្រាបពួកប្រឆាំង ចាប់ជនសង្ស័យក្នុងជួរបុគ្គលិករដ្ឋ ឬសមាជិកបក្ស យកទៅដាក់គុក ឬនិរទេសទៅតំបន់ស៊ីបេរី ក្រោមទណ្ឌកម្មការងារជាទម្ងន់ និងអាកាសធាតុដ៏អាក្រក់បំផុត ។

នៅដំណាច់ឆ្នាំ 1952 សុខភាពរបស់ស្តាលីនបានចុះទន់ខ្សោយជាលំដាប់ ដែលនាំឱ្យមានការបះបោរពីសំណាក់ពួកប្រឆាំងចំពោះទង្វើដ៏ឃោរឃៅរបស់គាត់ ។ នៅថ្ងៃទី 13 ខែមករា កាសែតប្រាវដា (Pravda) បានចុះផ្សាយអំពីការបះបោររបស់ពួកគ្រូពេទ្យប្រឆាំងនឹងស្តាលីន ។

នៅថ្ងៃទី 5 ខែមីនា ឆ្នាំ 1953 ស្តាលីនបានស្លាប់ នៅក្នុងជន្មាយុ 73 ឆ្នាំដោយជំងឺកកឈាមក្នុងខួរក្បាល ។ ទោះបីជាយ៉ាងណាការក៏ដោយ ក៏ការបាត់បង់មេដឹកនាំកំពូលរូបនេះបានទទួលការសោកស្តាយនៅក្នុងមជ្ឈដ្ឋានប្រជាជនសូវៀតជាច្រើនលាននាក់ដែលតែងតែគិតថាលោកស្តាលីនជាអ្នកមានគុណ ។

# 4. លោកគ្រូតឆូវ (1953-1964)

## 4.1. ការរំសាយរបបស្តាលីន



លោកគ្រូតឆូវ

ប្រតិកម្មនឹងរបបស្តាលីនបានកើតឡើងយ៉ាងរហ័សនៅក្រោយមរណភាពរបស់លោក ។ ឥស្សរជនដែលកាន់កាប់តំណែងបន្តគឺលោកគ្រូតឆូវដែលមានតួនាទីជាអគ្គលេខាគណបក្ស និងជាប្រធានាធិបតីសូវៀត ។ ពួកអ្នកដែលបម្រើក្បាលម៉ាស៊ីនសំខាន់ៗនៅក្នុងរបបស្តាលីនដូចជា បេរីយ៉ាជាដើមត្រូវកាត់ទោសប្រហារជីវិត ។ លោកម៉ាឡង់កូវក៏ត្រូវធ្វើការរិះគន់ ហើយបណ្តេញចេញពីតំណែងរដ្ឋាភិបាល ។ សពលោកស្តាលីនដែលតម្កល់ទុកនៅលើទីលានក្រហមត្រូវគេយកចេញ សម្បត្តិសាធារណៈរបស់រដ្ឋមានឈ្មោះគាត់ត្រូវគេប្តូរឈ្មោះថ្មីឬត្រឡប់មកយកឈ្មោះពីដើមវិញ ។ អ្នកទោសនៅសម័យសង្គ្រាម ជាពិសេសជនជាតិភាគតិចដែលនិរទេសទៅតំបន់អាស៊ីត្រូវដោះលែងឱ្យមានសេរីភាព និងវិលមកកាន់ស្រុកកំណើតវិញ ។

## 4.2. មហាសន្និបាតលើកទី 20

នៅឆ្នាំ 1956 មហាសន្និបាតបក្សកុម្មុយនីស្តលើកទី 20 ដែលកោះហៅដោយលោកគ្រូតឆូវបានផ្តោតទៅលើការរៀបចំវិស័យនយោបាយថ្មី គឺត្រូវធ្វើឱ្យសម្រេចនៅក្នុងរយៈពេល 4 ឆ្នាំ ។

គ្រូតឆូវចាត់ទុកខ្លួនឯងថាជាអ្នកនយោបាយស្មោះត្រង់ចំពោះអ្នកដឹកនាំលេនីន ហើយចោទរបបស្តាលីនថាជារបបដើរខុសផ្លូវធ្វើឱ្យខូចខាតដល់សង្គម ។ លោកគ្រូតឆូវមានតួនាទីជាអ្នកកែប្រែកំហុសនយោបាយ សេដ្ឋកិច្ច និងយោធាដែលបន្សល់ទុកពីរបបស្តាលីន ។

## 4.3. កំណែទម្រង់សេដ្ឋកិច្ចនិងសង្គម

លោកគ្រូតឆូវជាប្រធានាធិបតីដ៏ល្បីល្បាញ ក្រោមការគ្រប់គ្រងអំណាចរបស់លោកមានការបាញ់បង្ហោះយានស្ពុតនិក (Spoutnik) 3 លើក (ពីឆ្នាំ 1957-1958) ដឹកអ្នកស្រាវជ្រាវទៅកាន់ទីអវកាសទទួលជោគជ័យយ៉ាងធំធេងដែលញ៉ាំងឱ្យសហភាពសូវៀតក្លាយជាមហាអំណាចទី1 ខាងផ្នែកបច្ចេកវិទ្យា ។

លោកគ្រូតឆូវបានបង្កើតផែនការលើកទី 6 នៅឆ្នាំ 1959 ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសហភាពសូវៀតតាមឱ្យទាន់សហរដ្ឋអាមេរិកនៅឆ្នាំ 1980 គឺមានរយៈពេល 20 ឆ្នាំ ។ គេបង្កើតកសិដ្ឋានរដ្ឋចំនួន 105 ទូទាំងប្រទេស បង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ចតំបន់ដែលដឹកនាំរោងចក្រ សហគ្រាស និងធ្វើផែនការនៅតាមតំបន់ ដើម្បីឱ្យផែនការនោះទទួលជោគជ័យ និងមានប្រសិទ្ធភាព ។

ចំពោះវិស័យកសិកម្មជាផ្នែកមួយដែលលោកគ្រូតឆូវយកចិត្តទុកដាក់ចាប់ពីឆ្នាំ 1953 មកម្ល៉េះ ។ គេបានពង្រីកផ្ទៃដីដាំដុះលើដីទំនេរ និងកាប់ឆ្ការដីថ្មីនៅតំបន់កាហ្សាក់ស្ថាន (Kasastan) ដើម្បីពង្រីកផលិតផលជាពិសេសលើផ្នែកដំណាំពោត ដែលជាដំបូងគឺសាកល្បងទៅលើផ្ទៃដី 60 លានហិចតា ។ នៅរដូវប្រមូលផលដែលទទួលបានលើកដំបូងជាបង្គួរមិនដូចការគ្រោងទុក ប៉ុន្តែនៅឆ្នាំក្រោយៗ មកទៀតទិន្នផលក៏កាន់តែធ្លាក់ចុះជាលំដាប់ ។ម្យ៉ាងទៀត ការប្រើជី និងថ្នាំសម្លាប់សត្វល្អិតហួសប្រមាណធ្វើឱ្យគុណភាពដីខូចស្ទើរទាំងស្រុង ព្រមទាំងបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់បរិស្ថានទៀតផង ។

### 4.4. ការធ្លាក់ពីតំណែង

ទោះបីជាមានស្នាដៃធំធេងក្នុងវិស័យអវកាសនៅក្នុងឆ្នាំ 1957 ក៏ដោយ ក៏គ្រូតឆូវមានចំណុចខ្សោយជាច្រើននៅលើផ្នែកសេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិដូចជាការបរាជ័យខាងសេដ្ឋកិច្ចដែលមិនបានលើកស្ទួយកម្រិតជីវភាពប្រជាជនឱ្យបានប្រសើរ និងប្រហាក់ប្រហែលអាមេរិក ។ ការបរាជ័យខាងវិស័យកសិកម្ម ការចំណាយខាងយោធានៅសម័យសង្គ្រាមត្រជាក់ជាបន្ទុកធ្ងន់របស់ថវិការដ្ឋ ។ ការបែកបាក់គ្នារវាងមហាមិត្តកុម្មុយនីស្តចិន និងវិបត្តិកាំជ្រួចដែលបណ្តាលឱ្យសូវៀតដកចេញពីប្រទេសគុយបានៅឆ្នាំ 1962 ដែលមតិពិភពលោកចាត់ទុកសហភាពសូវៀតជាគំរូក្នុងការថែរក្សាសន្តិភាព ប៉ុន្តែទង្វើនេះជាការអាប់ឱនកិត្យានុភាពរបស់សូវៀតចំពោះមុខអាមេរិកនៅឯនាយសមុទ្រ ។ នៅខែតុលា ឆ្នាំ 1964 គ្រូតឆូវបានធ្លាក់ពីតំណែង ដោយបាត់ការគាំទ្រពីសមាជិកបក្ស ។

## 5. អ្នកដឹកនាំដោយក្រុមវ័យចាស់

ក្រោយពីលោកគ្រូតឆូវទទួលមរណភាព អំណាចត្រូវធ្លាក់ទៅក្នុងដៃឥស្សរជនជាន់ខ្ពស់នៃបក្សកុម្មុយនីស្តសហភាពសូវៀតមានវ័យចាស់ៗដែលនិយមរបបអភិរក្សតែងតែខ្លាចអ្វីដែលជារបបកំណែទម្រង់ ជាពិសេសគឺរបបប្រជាធិបតេយ្យតាមបែបលោកខាងលិច ។ ដំណាក់កាលនេះគេឃើញប្រធានាធិបតីសហភាពសូវៀតផ្លាស់ប្តូរគ្នាពីមួយទៅមួយមានរយៈពេលខ្លីៗ ។ ការដឹកនាំដោយឥស្សរជនវ័យចំណាស់នេះពុំអាចធ្វើឱ្យសហភាពសូវៀតមានការរីកចម្រើនទៅមុខទេ ព្រោះពុំមានពេលវេលាគ្រប់គ្រាន់ និងមិនបានធ្វើកំណែទម្រង់ ។ ម្យ៉ាងទៀត ឥស្សរជនទាំងនេះជាមនុស្សដែលមានសុខភាពមិនសូវល្អ ពោរពេញដោយជំងឺប្រចាំកាយច្រើនស្លាប់នៅក្នុងតំណែង ។

## 5.1. វិស័យសេដ្ឋកិច្ច

នៅខែតុលា ឆ្នាំ1964 លោកប្រេស្នេវជាអ្នកកាន់តំណែងបន្តពីលោកគ្រុតឆូវ ។ លោកជាអ្នកដឹកនាំជំនាន់ក្រោយដែលប្រឈមមុខនូវវិបត្តិនយោបាយអន្តរជាតិ គឺសង្គ្រាមត្រជាក់ និងវិបត្តិផ្ទៃក្នុងគឺបញ្ហាឋិនភាពនៃសេដ្ឋកិច្ចសូវៀត ។ ចាប់ពីទសវត្សរ៍ឆ្នាំ 70មក សេដ្ឋកិច្ចសូវៀតគ្មានដំណើរការទៅមុខបើយោងទៅលើអត្រាកំណើនប្រចាំឆ្នាំ ។ បើផ្អែកលើផែនការ 5 ឆ្នាំលើកទី 11 (1980-1985) លទ្ធផលសេដ្ឋកិច្ចដែលទទួលបានតិចតួចណាស់មិនហួសពី 3.5% ។ កំណែទម្រង់សេដ្ឋកិច្ចដែលមានទិសដៅតាមឱ្យទាន់អាមេរិក វាមានតែក្នុងការសុបិនប៉ុណ្ណោះ ពីព្រោះអាមេរិកជាសង្គមសម្ភារនិយម មនុស្សរស់នៅពោរពេញដោយសម្ភារៈដែលរត់តាមចង្វាក់នៃល្បឿនបច្ចេកវិទ្យាទំនើប ។ សហភាពសូវៀតត្រូវការបច្ចេកវិទ្យាជាន់ខ្ពស់ថ្មីៗថែមទៀតដើម្បីតាមឱ្យទាន់លោកខាងលិច ប៉ុន្តែគេស្ថិតឆ្ងាយនៅឡើយ ។ ឥទ្ធិពលនៃសង្គមសម្ភារនិយមបានជំរុញឱ្យសូវៀតទិញសម្ភារៈទំនើបៗជាច្រើនពីអឺរ៉ុបខាងលិច ជាពិសេសគ្រឿងអគ្គិសនី និងអេឡិចត្រូនិចដូចជាចង្ក្រានបាយ ទូទឹកកក ម៉ាស៊ីនត្រជាក់ វិទ្យុ ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនបូមធូលី ម៉ាស៊ីនថត ទូរទស្សន៍។ល។ បន្ថែមពីលើនេះទៅទៀតសូវៀតបានជួបប្រទះវិបត្តិកសិកម្មយ៉ាងធ្ងន់ធ្ងរ ព្រោះផលិតផលមិនឆ្លើយតបនិងតម្រូវការក្នុងស្រុកដូចជាស្រូវសាលី សាច់ ទឹកដោះ បន្លែ និងផ្លែឈើ ដូចនេះសហភាពសូវៀតក្លាយជាទីផ្សារដ៏ធំរបស់អឺរ៉ុបខាងលិច ។

ដើម្បីបំពេញនូវការខាតបង់នៃជញ្ជីងពាណិជ្ជកម្ម សូវៀតត្រូវតែបង្កើនការនាំចេញនូវឧស្ម័នធម្មជាតិ និងប្រេងកាតដែលមានតម្លៃរហូតដល់ 12 ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ។ បើក្រឡេកមើលអង្គការកូមេកុង(COMECON) វិញដែលជាទីផ្សារអន្តរជាតិនៅអឺរ៉ុបខាងកើតបាននាំចេញផលិតផលគ្មានគុណភាពប្រើការមិនកើតបើប្រៀបធៀបទៅនឹងផលិតផលលោកខាងលិច និងជប៉ុន ។ សហភាពសូវៀតត្រូវខាតបង់មួយជាន់ទៀតនូវថវិកាដែលចំណាយចោលឥតប្រយោជន៍ ដើម្បីជួយជ្រោមជ្រែងឱ្យអង្គការនេះដំណើរការបាន ។ ការនាំចូលដ៏គំហុកនៃផលិតផលលោកខាងលិចបានធ្វើឱ្យមានអតិផរណាយ៉ាងធ្ងន់ធ្ងរ ជាពិសេសការចុះថោកនៃប្រាក់រូបបើធៀបនិងប្រាក់ដុល្លារ ។

## 5.2. វិស័យនយោបាយ


លោកប្រេស្នេវ

ក្រោយឡើងកាន់អំណាចរបស់លោកប្រេស្នេវមក គេមិនបានឃើញមានកំណែទម្រង់ម្តងណាឡើយ ជាពិសេសគឺបញ្ហាលទ្ធិប្រជាធិបតេយ្យ ។ មានការបង្ក្រាបទៅលើជួរបញ្ញវន្ត ជាពិសេសសេរីភាពក្នុងការបញ្ចេញមតិ ឬយោបល់ ប៉ុន្តែកម្រិតនៃការបង្ក្រាបស្រាលជាងនៅក្នុងសម័យស្តាលីន ។ លោកសុលសេនីស៊ីន ជាអ្នកនិពន្ធដ៏ល្បីល្បាញធ្លាប់

បានរិះគន់របបកុម្មុយនិស្ត និងអ្នកប្រាជ្ញរូបវិទ្យាលោក សាខារ៉ូវជាដើមសុទ្ធសឹងជាអ្នកប្រឆាំងដែលមានឈ្មោះល្បី ហើយធ្លាប់ទទួលពានរង្វាន់ណូបែលសន្តិភាពត្រូវគេនិរទេសទៅតំបន់ឆ្ងាយ ។ តាមធម្មតាអ្នកប្រឆាំងត្រូវគេចាប់ដាក់គុក ឬបញ្ជូនទៅមន្ទីរពេទ្យវិកលចរិតដើម្បីអប់រំកែប្រែ ។ ការដឹកនាំសហភាពសូវៀតគឺពឹងផ្អែកលើសមាជិកបក្សកុម្មុយនិស្តដែលមានចំនួនរហូតដល់ ១៧លាននាក់ទូទាំងប្រទេស មានតួនាទីសំខាន់បំផុតក្នុងវិស័យនយោបាយចាប់ពីឆ្នាំ ១៩១៧មក ។ ចាប់តាំងពីលោកប្រេស្នេវរហូតដល់លោកហ្គោបាឆូវ តំណែងប្រធានាធិបតីសូវៀតចេះតែផ្លាស់ប្តូរយ៉ាងឆាប់រហ័សបណ្តាលមកពីវ័យជរានៃអ្នកដឹកនាំកង្វះកំណែទម្រង់ឱ្យមានប្រសិទ្ធភាពស្របពេលដែលសហភាពសូវៀតកំពុងជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ។

## 6. នយោបាយស្តារឡើងវិញ ឬកំណែទម្រង់ប៉េរ៉េស្ត្រូយកា ( Perestroika)

សហភាពសូវៀតឈានដល់ដំណាក់កាលដែលយឺតពេលសម្រាប់ការធ្វើកំណែទម្រង់ ។ នៅឆ្នាំ 1985 លោកមិខាអ៊ិល ហ្គោបាឆូវជាប្រធានាធិបតីចុងក្រោយបង្អស់ដែលមានអាយុ 54ឆ្នាំ គឺជាការបើកសករាជថ្មីនៃមេដឹកនាំសហភាពសូវៀត បានបញ្ចប់របបដឹកនាំដោយព្រឹទ្ធាចារ្យនិយមដូចជា **យូរីអង់ត្រូប៉ូវ**(Youri Andropov 1982-1984) កុងស្តង់ទីន ឆេណិនកូ(Contantine Tchenenko 1984-1985) ជាដើម ។

នៅសម័យសង្គ្រាមត្រជាក់ សហភាពសូវៀតមានការនឿយណាយក្នុងការរត់ប្រណាំងគ្រឿងសព្វាវុធជាមួយអាមេរិកដែលជាបិតាខាងបច្ចេកវិទ្យា និងសេដ្ឋកិច្ចខ្លាំងជាងសហភាពសូវៀត ។



*ទស្សនកិច្ចរបស់លោក រីកេន (នៅទីក្រុងមូស្គូ)*

សហភាពសូវៀតបានជួយប្រទេសត្រីក្រមួយចំនួននៅទ្វីបអាស៊ី អាមេរិកខាងត្បូងនិងអាហ្វ្រិក ដើម្បីពង្រីកមនោគមន៍វិជ្ជាកុម្មុយនីស្ត ។ សហភាពសូវៀតបានផ្ដល់ជំនួយចំនួន 4 ពាន់លានដុល្លារក្នុងមួយឆ្នាំជាជំនួយយោធា និងសេដ្ឋកិច្ចដើម្បីពង្រឹងប្រទេសគុយបាឱ្យមានជំហររឹងមាំទប់ទល់ឥទ្ធិពលសហរដ្ឋអាមេរិក ។ មិនតែប៉ុណ្ណោះអនុញ្ញាតឱ្យប្រទេសគុយបានាំស្ករសចូលរហូតធ្វើឱ្យដួលរលំដល់ផលិតផលស្ករក្នុងស្រុក ។ នៅទ្វីបអឺរ៉ុបមានវិបត្តិផលិតផលស្ករសលើស ពីព្រោះគេបានប្រើមើមផៃថាវស្ករ ផលិតស្ករជំនួសការនាំចូលស្ករសធ្វើពីអំពៅ ។ ប្រទេសគុយបាជាប្រទេសតែមួយគត់ដែលពឹងផ្អែកលើដំណាំអំពៅ ។ ក្រៅពីនេះមាន ៖

- ការផ្ដល់ជំនួយដល់ប្រទេសអារ៉ាប់នៅឆ្នាំ 1967 ប្រឆាំងនិងអ៊ីស្រាអែលនៅក្នុងសង្គ្រាម 6 ថ្ងៃ ។
- ការលើកទ័ពចូលលុកលុយប្រទេសអាហ្វហ្គានីស្ថាននៅថ្ងៃទី 27 ខែធ្នូ ឆ្នាំ 1979 ជាការលូកដៃដ៏ធំមួយដើម្បីគាំទ្ររបបដឹកនាំថ្មីដែលមាននិន្នាការទោរកសហភាពសូវៀត ។
- ការផ្ដល់ជំនួយដល់ប្រទេសនៅអឺរ៉ុបខាងកើត ដើម្បីទ្រទ្រង់បក្សសម្ព័ន្ធវ៉ាសូវី និងអង្គការកូមេកុង ។

កត្តាផ្ទៃក្នុងការខិតខំពង្រីកខាងវិស័យកសិកម្មដោយប្រើជីគីមីនិងថ្នាំពុលហួសប្រមាណបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងធ្វើឱ្យខូចដីធ្លីនាំឱ្យជះឥទ្ធិពលអាក្រក់ដល់ការអភិវឌ្ឍវិស័យកសិកម្ម ។ ចំណែកឯវិបត្តិសង្គមវិញមានដូចជាការធ្លាក់ទឹកចិត្ត ការផឹកស្រា បញ្ហាពុករលួយចាប់ពីក្រោមដល់លើ ការថយចុះនៃអាយុ និងកំណើនអត្រាមរណៈកុមារទាំងអស់នេះជាកត្តាធ្លាក់ចុះ និងការបាត់ជំនឿលើនយោបាយរបស់បក្សកុម្មុយនីស្តសូវៀត ។


លោកហ្គោបាឆូវ

លោកហ្គោបាឆូវជាអ្នកធ្វើកំណែទម្រង់នយោបាយសេដ្ឋកិច្ច និងសង្គមដែលកំពុងទុំជោរនៅសហភាពសូវៀតដែលពីដើមមានជំហររឹងមាំតាំងពីឆ្នាំ 1917 មកម្ល៉េះ ។ ជាលើកដំបូង លោកហ្គោបាឆូវបានបើកឱ្យមានវិនិយោគទុនខាងវិស័យឧស្សាហកម្មមកពីខាងក្រៅ ហើយបំផុសឱ្យមានការប្រណាំងប្រជែងតាមទម្រង់សេដ្ឋកិច្ចរបបទីផ្សារសេរី ។

ក្នុងវិស័យនយោបាយវិញគឺបើកឱ្យពួកប្រឆាំងធ្វើការរិះគន់ជាចំហដល់របបមុន(សង្គមនិយម) ។ នៅក្នុងក្របខ័ណ្ឌនៃជួរគណបក្សផ្ដល់ឱ្យមានរបបប្រជាធិបតេយ្យនៅក្នុងបក្សពោលគឺឱ្យមានការជ្រើសរើសមន្ត្រីដោយការបោះឆ្នោត ដើម្បីសំដែងការទុកចិត្ត ។ នៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 1988 មានកំណែទម្រង់នៃរដ្ឋធម្មនុញ្ញដោយរៀបចំឱ្យមានការបោះឆ្នោតជ្រើសរើសសមាជិកសភាតាមរយៈពលរដ្ឋដែលមាន

គណបក្សច្រើនចូលរួម ។ កំណែទម្រង់នៃរដ្ឋធម្មនុញ្ញថ្មីនេះបានចែងពីអាណត្តិប្រធានាធិបតីដែលមានរយៈពេល 5 ឆ្នាំ ហើយលោកហ្គោបាឆូវជាប្រធានាធិបតីដំបូងដែលចូលកាន់តំណែងនៅឆ្នាំ 1990 ។ អ្នកទោសនយោបាយ និងអ្នកប្រឆាំងត្រូវដោះលែងពីមន្ទីរឃុំឃាំងឱ្យមានសេរីភាព និងត្រឡប់ជួបជុំគ្រួសារឯស្រុកកំណើតវិញ ។

## 7. ការដួលរលំសហភាពសូវៀត

ក្រោយពេលឡើងកាន់អំណាច ហ្គោបាឆូវបានប្រកាសថាលោកនឹងមិនអនុញ្ញាតឱ្យមានអន្តរាគមន៍ខាងវិស័យយោធាទៀតឡើយ ។ សំដីនេះបានដាស់ស្មារតីដល់ប្រទេសដែលនៅក្រោមរណបសហភាពសូវៀតក្រោយសង្គ្រាមលោកលើកទី 2 ដែលមានគំនិតដើរតាមលទ្ធិប្រជាធិបតេយ្យតាមបែបអឺរ៉ុបខាងលិច ប្រកាសជាប្រទេសឯករាជ្យបន្តបន្ទាប់គ្នា ដូចជាអាល្លឺម៉ង់ខាងកើត ឆេកូស្លូវ៉ាគី ហុងគ្រី ប៉ុលហ្គារី ប៉ូឡូញជាដើម ។ ចំណែកឯប្រទេសអាល្លឺម៉ង់ដែលខណ្ឌចែកដោយជញ្ជាំងបែរឡាំងត្រូវរួមគ្នាជាអាល្លឺម៉ង់តែមួយនៅថ្ងៃទី 3 ខែតុលា ឆ្នាំ 1990 ។ ទ័ពក្រហមដែលដាក់ពង្រាយនៅអឺរ៉ុបខាងកើតត្រូវដកចេញចាប់ពីឆ្នាំ 1991 ដល់ 1994 ពីព្រោះបក្សសម្ព័ន្ធវ៉ាសូវីជាបន្ទុកដ៏ធ្ងន់ធ្ងរដល់សូវៀត ។ នៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ 1991 អង្គការពាណិជ្ជកម្មកូមេកុងត្រូវបញ្ចប់ និងអង្គការសម្ព័ន្ធភាពវ៉ាសូវីត្រូវអស់ប្រសិទ្ធភាពចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1991 ។ អត្ថន័យនៃការបង្ហូរឈាមនៃកងទ័ពក្រហមចំនួន 35 លាននាក់ដែលរំដោះអឺរ៉ុបខាងកើតនៅសម័យសង្គ្រាមលោកលើកទី2 ឱ្យផុតពីក្រញាំពួកណាស៊ីអ៊ីត្រូវបានបញ្ចប់ ។

នៅក្នុងសហភាពសូវៀត រដ្ឋដែលនៅតាមមាត់សមុទ្របាល់ទិចបានទទួលឯករាជ្យជាបន្តបន្ទាប់ដោយពុំមានការបង្ហូរឈាម ។ រដ្ឋមួយចំនួននៅអាស៊ីកណ្តាលក៏ដណ្តើមឯករាជ្យ ហើយផ្តាច់ចេញពីសូវៀត ។ ចំណែករដ្ឋរុស្ស៊ីវិញក្លាយជារដ្ឋឯករាជ្យដោយមានប្រធានាធិបតីដំបូងគឺលោក បូរីស យេលស៊ីន (Boris Yeltsin) ។ បន្ទាប់មក ប្រទេសរុស្ស៊ីក៏បញ្ចូលទៅក្នុងសហព័ន្ធមួយទៀតជាមួយនិងអ៊ុយក្រែន បេឡារុស និងរដ្ឋឯករាជ្យមួយចំនួនទៀតហៅថាសហព័ន្ធរុស្ស៊ី ឬហៅថាសមាគមនៃរដ្ឋឯករាជ្យ ។ ការបង្កើតសហព័ន្ធរុស្ស៊ីធ្វើឱ្យលោកហ្គោបាឆូវដែលជាប្រធានាធិបតីនៃសហភាពសូវៀតត្រូវអស់តួនាទីនៅថ្ងៃទី 25 ខែធ្នូ ឆ្នាំ 1991 ។

## ? សំណួរ

1. ចូររៀបរាប់ពីការកសាងរបបសង្គមនិយមរបស់លោកស្តាលីន និងគ្រុស្ឆូវ ?
2. ចូរពណ៌នាពីស្ថានភាពសង្គម និងសេដ្ឋកិច្ចសហភាពសូវៀតក្រោយសង្គ្រាមលោកលើកទី 2 ?
3. តើលោកប្រេស្នេវបានជួយអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចសហភាពសូវៀតដូចម្តេចខ្លះ ?
4. ចូរវិភាគពីនយោបាយប៉េរ៉េស្ត្រូយការបស់លោកហ្គោបាឆូវ ?
5. ចូរធ្វើការប្រៀបធៀបវិស័យនយោបាយរបស់លោកស្តាលីន និងលោកប្រេស្នេវ ។
6. តើហេតុអ្វីបានជាសហភាពសូវៀតផ្តល់ជំនួយឱ្យអឺរ៉ុបខាងកើត ?
7. ចូរពន្យល់ពីបក្សសម្ព័ន្ធវ៉ាសូវី និងអង្គការកូមេកុង ។
8. តើកត្តាអ្វីខ្លះធ្វើឱ្យសហភាពសូវៀតទទួលបរាជ័យលើវិស័យកសិកម្ម ?
9. តើរដ្ឋណាខ្លះប្រកាសឯករាជ្យពីសហភាពសូវៀត ? ព្រោះអ្វី ?
10. មូលហេតុចម្បងអ្វីខ្លះ បណ្តាលឱ្យសភាពសូវៀតដួលរលំ ?

មេរៀនទី

# 7 សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់

**ចប់មេរៀននេះ សិស្សអាច**

- ❑ យល់ដឹងពីបុព្វហេតុនៃការពុះចែកប្រទេសអាល្លឺម៉ង់ជា 2 ។
- ❑ ពន្យល់ការលេចឡើងនៃរបបសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និងស្ថានភាពសេដ្ឋកិច្ចនយោបាយ ។
- ❑ និយាយពីវិបត្តិនៃការរួបរួមអាល្លឺម៉ង់ទាំងពីរ ។



ទីក្រុងប៊ែរឡាំងខាងកើត

សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ឬអាល្លឺម៉ង់ខាងកើត បង្កើតនៅថ្ងៃទី 7 ខែតុលា ឆ្នាំ 1949 មានផ្ទៃក្រឡា 108 333 $km^2$ មានប្រជាជន 17 លាននាក់ (1988) និងមានដង់ស៊ីតេ 154 នាក់ / $km^2$ រដ្ឋធានីគឺប៊ែរឡាំងខាងកើត ។ មានព្រំប្រទល់ខាងលិចជាប់នឹងសហព័ន្ធអាល្លឺម៉ង់ ខាងជើងទល់នឹងសមុទ្របាល់ទិច ខាងកើតជាប់ប្រទេសប៉ូឡូញ និងខាងត្បូងជាប់នឹងប្រទេសឆេកូស្លូវ៉ាគី ។ ដោយសារសង្គ្រាមលោកទាំង 2 លើកធ្វើឱ្យប្រជាជនអាល្លឺម៉ង់ភាគច្រើនជាស្ត្រី (53%) ចំណែកបុរសមានចំនួន 47% តែប៉ុណ្ណោះ (Encyclopedia of the Nations) ការព្រាត់ប្រាសគ្រួសារ គឺជាកត្តាដែលនាំឱ្យមានកំណើនប្រជាជនខ្សោយ ។

## 1. ការបង្កើតរដ្ឋអាល្លឺម៉ង់ខាងកើត

សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ជាប្រទេសដែលមានបន្ទាត់នយោបាយតាមបែបសហភាពសូវៀតដែលដឹកនាំដោយគណបក្សកុម្មុយនីស្ត ។ រដ្ឋាភិបាលបង្កើតឡើងតាមទម្រង់រដ្ឋធម្មនុញ្ញថ្ងៃទី 6 ខែមេសា ឆ្នាំ 1968 ដែលជំនួសរដ្ឋធម្មនុញ្ញថ្ងៃទី 7 ខែតុលា ឆ្នាំ 1949 ។ គណបក្សកុម្មុយនីស្តជា

គណបក្សតែមួយគត់ដែលកាន់កាប់ផ្នែកនយោបាយ សេដ្ឋកិច្ច និងផែនការ ។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី 18ឆ្នាំមានសិទ្ធិបោះឆ្នោតជ្រើសអ្នកតំណាងតែមួយគត់ក្នុងការដឹកនាំប្រទេសដែលមានតួនាទីជានាយករដ្ឋមន្ត្រី ។ សភានៅប្រទេសអាល្លឺម៉ង់ខាងកើតមានសមាជិក 500នាក់ សមាជិកសភាមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវមានអាយុពី 21ឆ្នាំឡើងទៅ ហើយសភាមានអាណត្តិ 7ឆ្នាំម្តង ។ ប្រទេសអាល្លឺម៉ង់ខាងកើតក្លាយជាសមាជិកទីផ្សាររួមអឺរ៉ុបនៅឆ្នាំ 1950 និងជាសមាជិកនៃបក្សសម្ព័ន្ធវ៉ាសូវីនៅឆ្នាំ 1955 ។



*សន្និសីទយ៉ាល់តា*

## 1.1. សន្និសីទយ៉ាល់តា (សហភាពសូវៀត)

សន្និសីទយ៉ាល់តាបង្កើតឡើងក្នុងគោលបំណងមិនឱ្យរបបយោធានិយមអាល្លឺម៉ង់រស់ឡើងវិញ ពីព្រោះអាល្លឺម៉ង់ជាប្រទេសតែមួយគត់ដែលជាអ្នកបង្កាត់ភ្លើងសង្គ្រាមលោកទាំង 2លើកក្នុងរយៈពេលចន្លោះតែ 21ឆ្នាំ ។ យ៉ាល់តាបានកំណត់ដោយមហាអំណាច 3គឺ សហភាពសូវៀត(ស្តាលីន) សហរដ្ឋអាមេរិក(រូស្វ៊ែល) និងចក្រភពអង់គ្លេស(ឆឺឈីល) ជាប្រទេសអ្នកឈ្នះសង្គ្រាមលោកលើកទី 2 ហើយក្នុងចំណោមប្រទេសទាំង 3នេះ សហភាពសូវៀតគឺជាអ្នកខ្លាំងជាងគេ ព្រោះសូវៀតបានរំដោះបរិមាណទឹកដីធំជាងគេមានអឺរ៉ុបខាងកើត និងអឺរ៉ុបកណ្តាល ចាប់ពីអឺរ៉ុបខាងកើតមកដល់ប៉ូឡូញ ។ ចំណែកពួកសម្ព័ន្ធមិត្តរំដោះនៅអឺរ៉ុបបានតែប្រទេសបារាំងមួយគត់ សូម្បីតែទីតាំងចុងក្រោយក្នុងការវាយលុកក៏មានដំណើរយឺតដែរ ពីព្រោះមានការទប់ទល់ខ្លាំងពីសំណាក់កងទ័ពអាល្លឺម៉ង់ ។ ទិសដៅនៃសន្និសីទយ៉ាល់តាមានដូចជា ៖

- ការរៀបចំប្រទេសអាល្លឺម៉ង់ជា ៤ តំបន់សម្រាប់ត្រួតត្រា ។
- នៅភាគខាងកើត សហភាពសូវៀតត្រួតត្រាលើតំបន់បាល់ទិច និងរំកិលព្រំដែនចូលប្រទេសប៉ូឡូញ ចំណែកប៉ូឡូញបានបង្វិតព្រំដែនបន្តចូលប្រទេសអាល្លឺម៉ង់ ។
- សហភាពសូវៀតបានសន្យានិងជួយវាយពួកជប៉ុនឱ្យបរាជ័យនៅក្រោយពេលដែលអាល្លឺម៉ង់ចុះចាញ់ចំនួន ៣ ខែ ។

ក្រោយសន្និសីទយ៉ាល់តា ក៏មានការកោះអញ្ជើញឱ្យមានសន្និសីទនៅសាន់ហ្វ្រាន់ស៊ីស្កូ ដើម្បីបង្កើតអង្គការសហប្រជាជាតិ ។

## 1.2. បញ្ហាអាល្លឺម៉ង់ឆ្ពោះទៅរកសង្គ្រាមត្រជាក់

នៅក្រោយសង្គ្រាមលោកលើកទី 2 ទ្វីបអឺរ៉ុបស្ទើរតែទាំងស្រុង ត្រូវគ្របដណ្តប់ដោយរបបកុម្មុយនីស្ត ដោយសារឥទ្ធិពលនៃជ័យជម្នះដ៏ធំធេងនៃកងទ័ពក្រហមរុស្ស៊ីព្រោះគេយល់ថាកងទ័ពក្រហមនេះហើយជាអ្នកជួយរំដោះប្រជាជនទ្វីបអឺរ៉ុបឱ្យផុតពីក្រញាំយង់ឃ្នងនៃកងទ័ពណាស៊ី ។ នៅក្នុងជួររដ្ឋាភិបាលនីមួយៗ ក៏មានគណបក្សកុម្មុយនីស្ត ដូច្នេះលទ្ធិមូលធននិយមមិនអាចមានកម្លាំងជ្រៀតចូលបានទេ ហើយនាំឱ្យមានវិបត្តិធ្ងន់ធ្ងរប្រសិនបើគេមិនជួយស្រោចស្រង់ឱ្យទាន់ពេលវេលា ។ ដំណោះស្រាយតាមរយៈជំនួយ 13 ពាន់លានដុល្លារសម្រាប់ជួយទ្វីបអឺរ៉ុបតាមផែនការម៉ាសាលសម្រាប់ប្រទេសអឺរ៉ុបខាងលិចអាចជួយប្រទេសទាំងនោះឱ្យងើបឈរបាន ឱ្យចាកផុតពីការដុនដាបនៅក្រោយសង្គ្រាម ប៉ុន្តែម៉ាសាលនេះហើយជាកំណើតនៃសង្គ្រាមត្រជាក់ ។ ឥទ្ធិពលចុងក្រោយនៃលទ្ធិកុម្មុយនីស្តគឺចម្បាំងនៅក្នុងប្រទេសក្រិក និងតួកគី អង់គ្លេសបានប្រយុទ្ធដើម្បីគាំទ្ររដ្ឋាភិបាលក្រិកឱ្យមានជីវិត ប៉ុន្តែដោយអង់គ្លេសបានចុះខ្សោយក្រោយសង្គ្រាមមិនអាចទប់ទល់បានក៏ប្រកាសដកថយ ដោយប្រគល់ឱ្យសហរដ្ឋអាមេរិកលើកទ័ពទៅរំដោះប្រទេសក្រិកជំនួសវិញ ។ ចាប់តាំងពីពេលនោះមកសហរដ្ឋអាមេរិកបានក្លាយជាប្រទេសមហាអំណាចដែលទទួលខុសត្រូវលើនយោបាយពិភពលោកខាងរបបមូលធននិយមចេញមុខជាមេប្រឆាំងទល់នឹងមហាអំណាចកុម្មុយនីស្តសហភាពសូវៀត ។ នៅឆ្នាំ 1948 មេទ័ពសូវៀត សូកូឡូវស្គី(Sokolovski) យល់ឃើញថាប៊ែរឡាំងស្ថិតនៅក្នុងទឹកដីអាល្លឺម៉ង់ខាងកើត ដូចនេះសហភាពសូវៀតត្រូវតែត្រួតត្រានូវរាល់ផ្លូវចេញចូលទៅកាន់ប៊ែរឡាំងខាងលិច(ផ្លូវរថភ្លើងនិងផ្លូវថ្នល់)គឺជាការបិទច្រកក្រុងប៊ែរឡាំងជាលើកដំបូង ។ លុះដល់ខែមិថុនា ឆ្នាំ 1949 មហាអំណាចមូលធនទាំង 3 បានកោះប្រជុំសន្និសីទនៅទីក្រុងឡុងដ៍ ដើម្បីរៀបចំបោះឆ្នោតសភា និងបង្កើតរដ្ឋធម្មនុញ្ញមួយនៅអាល្លឺម៉ង់ខាងលិច ។ កិច្ចការបន្តទៀតត្រូវរៀបចំបង្កើតក្រដាសប្រាក់ថ្មីឈ្មោះ ដឺតម៉ាក់(Deutsche Mark) ។ ការធ្វើកំណែទម្រង់ក្រដាសប្រាក់ថ្មីបានធ្វើឱ្យសហភាពសូវៀតមិនសប្បាយចិត្ត ពីព្រោះក្រដាសប្រាក់ថ្មីនេះធ្វើឱ្យខូចប្រយោជន៍សេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើត ។

ដោយសារតែហេតុនេះ សហភាពសូវៀតបានផ្តាច់ទឹក ភ្លើង ស្បៀង សម្រាប់ផ្គត់ផ្គង់អាល្លឺម៉ង់ខាងលិច ។ ដើម្បីបើកច្រកចេញចូលផ្តល់ការផ្គត់ផ្គង់សម្ភារៈបរិក្ខារ និងស្បៀងដល់អាល្លឺម៉ង់ សហរដ្ឋអាមេរិកបានបើកស្ពានអាកាសបញ្ចៀសឱ្យផុតពីវិបត្តិទ័លច្រក ។ ការបិទច្រកនេះមានរយៈពេល 1 ឆ្នាំ គឺចាប់ពីឆ្នាំ 1948 ដល់ ខែមិថុនា ឆ្នាំ 1949 ទើបសហភាពសូវៀតបានបើកផ្លូវរថភ្លើង និងផ្លូវហាយវេ (Highway) ទៅកាន់អាល្លឺម៉ង់ខាងលិចឡើងវិញ ។



*ការដឹកជញ្ជូនតាមផ្លូវអាកាស*

នៅឆ្នាំ 1950 ការប្រឈមមុខដាក់គ្នារវាងអាល្លឺម៉ង់ខាងលិច និងខាងកើត រឹតតែធ្ងន់ធ្ងរថែមទៀត នៅពេលដែលមហាអំណាចលោកខាងលិច បានចាប់ផ្តើមបំពាក់អាវុធដល់កងទ័ពអាល្លឺម៉ង់ខាងលិច និងការបញ្ចូលប្រទេសនេះជាសមាជិកទី 15 នៃអង្គការអូតង់នៅឆ្នាំ 1955 ។ ដោយខ្លាចមានសង្គ្រាមដណ្តើមទឹកដីដែលអាល្លឺម៉ង់បាត់បង់ដោយកាត់ទៅឱ្យប៉ូឡូញ តាមការកំណត់របស់សន្និសីទយ៉ាល់តា សូវៀតក៏បានបំពាក់អាវុធទៅឱ្យសាធារណរដ្ឋប្រជាមានិតអាល្លឺម៉ង់ខាងកើតដែរ ។ ចាប់តាំងពីការបែងចែកអាល្លឺម៉ង់ជា 2 មក សហព័ន្ធអាល្លឺម៉ង់មានសន្ទុះសេដ្ឋកិច្ចជឿនលឿន ហើយក៏ក្លាយជាមហាអំណាចសេដ្ឋកិច្ចលេខ 2 បន្ទាប់ពីសហរដ្ឋអាមេរិក ។ សក្តានុពលសេដ្ឋកិច្ចបានអូសទាញប្រជាជនអាល្លឺម៉ង់ខាងកើតឱ្យភៀសខ្លួនមកកាន់បែរឡាំងខាងលិចជាច្រើនពាន់នាក់ ដើម្បីស្វែងរកសុភមង្គលនិងមានជីវភាពកាន់តែប្រសើរឡើង ។ ការស្រេកឃ្លានសេរីភាពនេះ បង្កឱ្យសេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើតរឹតតែ

ធ្លាក់ចុះដោយសារពួកយុវជន បញ្ញវន្ត និងកម្មករជំនាញបានភៀសខ្លួនចេញទៅអាល្លឺម៉ង់ខាងលិច ។ នៅក្នុងរយៈពេល 15 ឆ្នាំនៃការបែកបាក់គ្នា អាល្លឺម៉ង់ខាងកើតត្រូវបាត់បង់មនុស្សជាង 3 លាននាក់ ដោយសារតែអ្នកទាំងនោះភៀសខ្លួនទៅខាងលិច ទោះបីជាមានការយាមកាម ឬត្រួតពិនិត្យយ៉ាងតឹងរ៉ឹងក៏ដោយ ក៏នៅតែមានជនភៀសខ្លួនតាមផ្លូវរថភ្លើងក្រោមដី ជួនកាលតាមរូងផ្លូវក្រោមដីទៀតផង ។

អាល្លឺម៉ង់ខាងកើតបានចាប់ផ្ដើមបិទព្រំដែនប្រទេសទាំង 2 ឱ្យជិតស្លុងនៅយប់ថ្ងៃទី 12 និង 13 ខែសីហា ឆ្នាំ 1961 តាមរយៈជញ្ជាំងបេតុងយ៉ាងក្រាស់ និងរាយលួសបន្លាពីលើប្រវែង 43 km ដើម្បីទប់ស្កាត់ជនភៀសខ្លួនអាល្លឺម៉ង់ខាងកើត ។ ជញ្ជាំងប៊ែរឡាំងជាការសុបិនដែលលោក ឆឺឈីលថ្លែងនៅហ្វុលតុនថា វាជាវាំងននដែកដែលបែងចែកទ្វីបអឺរ៉ុបជា 2 កាលពីឆ្នាំ 1946 ។ ក្រោយមក ការសាងសង់ជញ្ជាំងក្រុងប៊ែរឡាំងនេះហាក់ដូចជាបាត់បង់ប្រសិទ្ធភាពទៅវិញនៅពេលដែលប្រជាជនខាងកើតភៀសខ្លួនមកខាងលិចកាន់តែច្រើនឡើងរហូតដល់ 8 លាននាក់នៅឆ្នាំ 1989 ដោយប្រើផ្លូវផ្សេងៗដើម្បីជៀសជញ្ជាំងយ៉ាងរឹងមាំនេះ តាមប្រទេសសង្គមនិយមមួយចំនួនដូចប្រទេសឆេកូស្លូវ៉ាគីជាដើម ។




*ការកសាងជញ្ជាំងក្រុងប៊ែរឡាំង ( 1961 )*

# 2. សេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើត

## 2.1. វិស័យឧស្សាហកម្ម

ប្រទេសអាល្លឺម៉ង់ខាងកើតជាប្រទេសឈរនៅលំដាប់ទី 1 នៅអឺរ៉ុបខាងកើតខាងផ្នែកសេដ្ឋកិច្ច ។ បើគិតទាំងបរិមាណ និងគុណភាព ប្រទេសនេះជាអ្នកនាំចេញសំខាន់ជាងគេនៅក្នុងទីផ្សាររួមអឺរ៉ុបខាងកើត ហៅកាត់ថា កូមេកុង(COMECON) ។ បើនិយាយពីមូលដ្ឋានគ្រឹះឧស្សាហកម្មអាល្លឺម៉ង់ខាងកើតមានធ្យូងថ្ម(Lignite) ច្រើនជាងគេហើយនៅក្នុងរណ្ដៅរាក់ទៀតផង ចំណែកធនធានរ៉ែផ្សេងៗមិនសូវសម្បូរឡើយ ។

ឧស្សាហកម្មប្រើដោយប្រភពថាមពលភាគច្រើន ប្រើថាមពលធ្យូងថ្ម និងប្រេងកាតដែលជាប្រភពធ្វើឱ្យមានការខូចខាតច្រើនដល់ស្រទាប់អូសូន និងកង្វក់បរិស្ថាន ។ ឧស្សាហកម្មត្រូវប្រមូលផ្ដុំទៅតាមផ្នែកផលិតដែលមាន 132 កន្លែងខ្ទង់ប្រទេស ដែលបែងចែកជាផ្នែកធំៗមានគីមី គ្រឿងម៉ាស៊ីន អេឡិចត្រូនិច ព្រមទាំងរោងចក្រស្លដែកវាយនភ័ណ្ឌ អុបទិច និងរថយន្ត ។ នៅក្នុងរោងចក្រនីមួយៗ គេត្រូវប្រើមនុស្សយន្តជំនួសវិញ ដើម្បីបំពេញកង្វះខាតកម្មករជំនាញ ។

## 2.2. វិស័យកសិកម្ម



*ការប្រមូលផលដំឡូងបារាំង*

មានកសិដ្ឋានរដ្ឋចំនួន 471 ចែកចេញជា 3 900 សហករណ៍ បើគិតជាផ្ទៃដីកសិកម្មវិញស្មើនឹង 59% នៃផ្ទៃប្រទេសទាំងមូល ។ គេបានបែងចែកទឹកដីដំណាំជា 3 ប្រភេទគឺ ដីដែលមានជីជាតិ គេដាំស្រូវសាលី ដំឡូងសម្រាប់យកស្ករ ដីដែលមានគុណភាពអន់ គេដាំដំឡូងបារាំង និងដីសើមសម្រាប់ចិញ្ចឹមសត្វ ។ កសិកម្ម មានលក្ខណៈប្រពលវប្បកម្មដោយប្រើថ្នាំគីមីច្រើនលើសលប់ ។

សេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើតជាសេដ្ឋកិច្ចសមូហភាព ព្រោះមធ្យោបាយផលិតកម្មទាំងអស់ជារបស់រដ្ឋ ដូចជារោងចក្រ ដីធ្លី និងមធ្យោបាយដឹកជញ្ជូនជាដើម ជាពិសេសការអភិវឌ្ឍធ្វើតាមដំណាក់សេដ្ឋកិច្ចផែនការ 5ឆ្នាំម្តង ។

## 2.3. វិស័យពាណិជ្ជកម្ម

អាល្លឺម៉ង់ខាងកើតនាំចេញផលិតផលឧស្សាហកម្មច្រើនជាងគេទៅកាន់ទីផ្សារអឺរ៉ុបខាងកើតជាពិសេសទៅកាន់សហភាពសូវៀត ហើយនាំចូលមកវិញនូវវត្ថុធាតុដើមសម្រាប់បំពេញតម្រូវការចាំបាច់ក្នុងស្រុក ។ ប្រទេសអាល្លឺម៉ង់ខាងកើតមានឧស្សាហកម្មលូតលាស់បើប្រៀបធៀបទៅនឹងសកលលោកគឺឈរនៅលំដាប់ថ្នាក់ទី 10 ហើយបើប្រៀបនៅអឺរ៉ុបវិញគឺឈរនៅលំដាប់ថ្នាក់លេខ 5 ខ្ពស់ជាងសហភាពសូវៀត និងប្រទេសមួយចំនួនទៀត ។ ប្រទេសអាល្លឺម៉ង់ខាងកើតជាដៃគូពាណិជ្ជកម្មជាមួយអឺរ៉ុបខាងលិចផងដែរ ជាពិសេសជាមួយនឹងអាល្លឺម៉ង់ខាងលិច ។ សូម្បីតែនៅពេលដែលលោក ហ្គោបាឆូវបានទៅចូលរួមបុណ្យខួបនៃការបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់លើកទី 40 ក៏លោកមានប្រសាសន៍ថាអាល្លឺម៉ង់ខាងកើតមិនទាមទារឱ្យមាននយោបាយប៉េរ៉េស្រ្តូយកា ពីព្រោះប្រទេសនេះមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចទៅហើយ ។

# 3. វិស័យសង្គម

នៅឆ្នាំ 1965 ដោយកំណើនប្រជាជនយឺត រដ្ឋាភិបាលបានបើកសិទ្ធិឱ្យបុរសស្ត្រីមានសិទ្ធិស្មើគ្នា ព្រមទាំងលើកទឹកចិត្តស្ត្រីឱ្យចង់បានកូនច្រើនដោយរដ្ឋផ្តល់ថវិកា 1 000 ម៉ាក់ ចំពោះស្ត្រីមានកូនដំបូង ថែមទាំងទទួលសិទ្ធិសម្រាករយៈពេល 6ខែដោយមិនកាត់ប្រាក់ខែទៀតផង ហើយស្ត្រីមានកូនជាលើកទី 2 ត្រូវមានច្បាប់ឈប់សម្រាកចំនួនមួយឆ្នាំ និងកូនទី 3 ចំនួន 18ខែ ដោយរក្សាប្រាក់បៀវត្សពី 70% ទៅ 90% ។ គេសង្កេតឃើញមានការរៀបអាពាហ៍ពិពាហ៍នៅចន្លោះឆ្នាំ 1965 មានចំនួន $\frac{6.9}{1000}$ បានកើនឡើងដល់ $\frac{8.8}{1000}$ ក្នុងឆ្នាំ 1975 ។

ចំពោះបញ្ហាសិទ្ធិនៃការបញ្ចេញមតិវិញក៏មានចែងក្នុងច្បាប់ដែរ ។ នៅក្នុងឆ្នាំ 1970 ពួកអ្នកនិពន្ធនិងនិស្សិតមួយចំនួនដែលរិះគន់ប្រឆាំងនឹងរដ្ឋាភិបាលត្រូវបានគេបង្ខំឱ្យនិរទេស ឬត្រូវឃាត់ខ្លួន ។ តាមច្បាប់ឆ្នាំ 1997 ជនណាដែលបានរៀបចំឱ្យមានបាតុកម្មប្រឆាំងរដ្ឋាភិបាលត្រូវដាក់គុករយៈពេល 9ឆ្នាំ ។ នៅឆ្នាំ 1980 រដ្ឋាភិបាលចាប់អ្នកប្រឆាំងដាក់គុកមានចំនួនពី 6 500ទៅ 8 000នាក់ ។

## ១.1. វិស័យសុខាភិបាល

ការព្យាបាលជំងឺប្រជាជនត្រូវធ្វើឡើងដោយឥតបង់ថ្លៃ ។ នៅឆ្នាំ 1961 ជាឆ្នាំសាងសង់ជញ្ជាំងបែរឡាំង បុគ្គលិកសុខាភិបាលគ្រប់ជំនាញចំនួន 5 000 នាក់ បានរត់ភៀសខ្លួនទៅកាន់អាល្លឺម៉ង់ខាងលិច ។ ដើម្បីស្តារវិស័យនេះ គេបានបណ្តុះបណ្តាលពេទ្យគ្រប់ជំនាញ ។ នៅឆ្នាំ 1985 មានគ្រូពេទ្យថ្នាក់បណ្ឌិតចំនួន 37 943 នាក់ ទន្តពេទ្យ 11 757 នាក់ និងឱសថការី 3 785 នាក់ ។ ចំនួនគ្រែសរុបក្នុងមន្ទីរពេទ្យមាន 169 112 គ្រែ ។

## ១.2. វិស័យអប់រំ

កុមារត្រូវចូលរៀនចាប់ពីអាយុ 6 ឆ្នាំ សម្រាប់សិស្សថ្នាក់ទី 7-10 ត្រូវតែចំណាយ 1 ថ្ងៃក្នុងមួយសប្តាហ៍ដើម្បីធ្វើកម្មសិក្សានៅក្នុងសាលាពហុបច្ចេកទេសខាងមុខជំនាញ នៅក្នុងរោងចក្រ ឬ នៅក្នុងកសិដ្ឋាន ។ ចំណែកសិស្សចាប់ពីថ្នាក់ទី 10 ឡើងទៅ ត្រូវរៀនបន្ថែម 2 ឆ្នាំ សម្រាប់ថ្នាក់ហ្វឹកហ្វឺននៅមធ្យមសិក្សា 3 ឆ្នាំសម្រាប់សាលាមុខជំនាញ ។ ចំណែកនៅថ្នាក់ឧត្តមសិក្សាវិញ នៅទូទាំងប្រទេសមានសាកលវិទ្យាល័យចំនួន 7 និងវិទ្យាស្ថានជាន់ខ្ពស់ចំនួន 47 ផ្សេងទៀត ។

## ? សំណួរ

1. ហេតុអ្វីបានជាប្រទេសអាល្លឺម៉ង់បែកជាពីរ ?
2. តើសេដ្ឋកិច្ចអាល្លឺម៉ង់ខាងកើតពឹងផ្អែកលើអ្វីខ្លះ ?
3. ហេតុអ្វីបានជាសង្គមអាល្លឺម៉ង់ខាងកើតមានការរីកចម្រើន ?
4. តើកត្តាអ្វីខ្លះធ្វើឱ្យអាល្លឺម៉ង់រួបរួមគ្នាវិញ ?

មេរៀនទី

# 8 ប្រទេសឆេកូស្លូវ៉ាគី

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ព្រឹត្តិការណ៍សំខាន់ៗ នៅប្រទេសឆេកូស្លូវ៉ាគីក្រោយសង្គ្រាមលោកលើកទី 2 ។
- ❑ វិភាគការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងនយោបាយប្រទេសនេះ ។
- ❑ រៀនសូត្របទពិសោធល្អក្នុងការស្តារប្រទេសជាតិ ។

ប្រទេសឆេកូស្លូវ៉ាគីស្ថិតនៅក្នុងទ្វីបអឺរ៉ុបប៉ែកកណ្តាលដែលមានផ្ទៃក្រឡា 127 905 $km^2$ និងមានប្រជាជន 15 លាននាក់(1989) ហើយមានព្រំប្រទល់ខាងលិចជាប់នឹងប្រទេសអាល្លឺម៉ង់ ខាងជើងជាប់នឹងប្រទេសប៉ូឡូញខាងកើតជាប់ប្រទេសអ៊ុយក្រែន ខាងត្បូងជាប់នឹងប្រទេសអូទ្រីស និងហុងគ្រី ។ ទីក្រុងប្រាកជារដ្ឋធានី ។ ឆេកូស្លូវ៉ាគី រួមបញ្ចូលដោយទឹកដីឆែក និងស្លូវ៉ាក ។

## 1. ទិសំយនយោបាយ

### 1.1. ការបង្កើតរដ្ឋឆេកូស្លូវ៉ាគី

នៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទី I (1914-1918) លោក ម៉ាសារិកព្រមទាំងមេដឹកនាំឆែក និងស្លូវ៉ាកមួយចំនួនបានស្រុះស្រួលរៀបគម្រោងការបង្កើតរដ្ឋឆេកូស្លូវ៉ាគីមួយនៅក្នុងចក្រភពអូទ្រីស ហុងគ្រី ។ ប៉ុន្តែ គម្រោងនេះត្រូវបានលេចជារូបរាងឡើងនៅក្រោយសង្គ្រាមលោកលើកទី I ដោយចក្រភពអូទ្រីស ហុងគ្រី ត្រូវដួលរលំ ។ ប្រទេសដ៏ក្មេងខ្ចីនេះមានឈ្មោះថា សាធារណរដ្ឋឆេកូស្លូវ៉ាគី ។ លោក ម៉ាសារិក ជាប្រធានាធិបតីដំបូងដែលកាន់អំណាចពីឆ្នាំ 1918-1935 បន្ទាប់មកទៀតលោក បេណែស បានកាន់អំណាចបន្តក្នុងស្ថានភាពនយោបាយ និងសន្តិសុខពុំមានអ្វីប្រែប្រួល ។

នៅប្រទេសអាល្លឺម៉ង់ អ៊ីត្លែបានឡើងកាន់អំណាចទាំងស្រុងជាមួយមហិច្ឆតាត្រួតត្រាពិភពលោកតាមផែនការរបស់បក្សណាស៊ី ដែលតម្រូវឱ្យបង្កើតចក្រភពអាល្លឺម៉ង់មួយឡើង ដោយរួមបញ្ចូលទឹកដីដែលមានជនជាតិអាល្លឺម៉ង់រស់នៅមកជាចក្រភពអាល្លឺម៉ង់តែមួយ ។ ឆ្នាំ 1938 អ៊ីត្លែបានអនុវត្តនយោបាយ ដោយសម្លឹងមើលទៅតំបន់ស៊ុយដែត នៅប៉ែកពាយ័ព្យនៃប្រទេសឆេកូស្លូវ៉ាគីដែលមានជនជាតិអាល្លឺម៉ង់រស់នៅច្រើន ។ អ៊ីត្លែបានគំរាមប្រទេសឆេកូស្លូវ៉ាគីឱ្យប្រគល់ទឹកដីឱ្យខ្លួន

ដើម្បីធ្វើឱ្យសម្រេចនូវនយោបាយឈ្លានពាន ។ ដោយរាងចាលនឹងសង្គ្រាម ប្រទេសឆេកូស្លូវ៉ាគីក៏បង្ខំចិត្តព្រមប្រគល់ទឹកដីនេះឱ្យអាល្លឺម៉ង់តាមរយៈសន្ធិសញ្ញាក្រុងមុយនិច នៅថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 1938 ។ សន្ធិសញ្ញាមុយនិចមិនបានបញ្ចៀសសង្គ្រាមលោកឡើយ បន្ទាប់ពីអាល្លឺម៉ង់លើកទ័ពឆ្លងព្រំដែនចូលកាន់កាប់តំបន់ស៊ុយដែត រួចទន្ទ្រានចូលប្រទេសឆេកូស្លូវ៉ាគីតែម្តង ។ ពេលនោះលោក បេណែសបានលាលែងពីតំណែងប្រធានាធិបតី រួចភៀសខ្លួនទៅកាន់ទីក្រុងឡុងដ៍ដើម្បីបង្កើតរដ្ឋាភិបាលនិរទេសមួយដឹកនាំចលនាតស៊ូប្រឆាំងអាល្លឺម៉ង់ នៅក្នុងសង្គ្រាមលោកលើកទី 2 ។ ក្រោយពេលត្រួតត្រាប្រទេសឆេកូស្លូវ៉ាគី កងទ័ពអាល្លឺម៉ង់បានជិះជាន់គំរាមកំហែងប្រជាជនព្រមទាំងសម្លាប់ជនជាតិជ្វីបយ៉ាងរង្គាលស្ទើរតែផុតពូជ ។ នៅថ្ងៃទី 9 ខែមិថុនា ឆ្នាំ 1945 កងទ័ពសូវៀតបានរុញច្រានកងទ័ពអាល្លឺម៉ង់និងរំដោះបានទីក្រុងប្រាកទាំងស្រុង ។ ចំណែករដ្ឋាភិបាលនិរទេសបានត្រឡប់មករៀបចំរបៀបរៀបរយក្រុងប្រាកឡើងវិញ ។

## 1.2. រដ្ឋាភិបាលកុម្មុយនីស្ត

នៅក្រោយសង្គ្រាមលោកលើកទី 2 លោក បេណែស បានបង្កើតរដ្ឋាភិបាលចម្រុះមួយដែលមានសមាជិកគណបក្សកុម្មុយនីស្តភាគច្រើនកាន់កាប់ក្រសួងសំខាន់ៗ នៅក្នុងរដ្ឋាភិបាល ។ នៅឆ្នាំ 1946 មានការរៀបចំឱ្យមានការបោះឆ្នោតជាតិមួយ ។ ជាលទ្ធផលពួកកុម្មុយនីស្តបានទទួលសំឡេងឆ្នោតភាគច្រើន លោក បេណែស បានធ្លាក់ពីតំណែង មេដឹកនាំកុម្មុយនីស្ត ក្លេម៉ង់ ហ្គោតវ៉ៃត (Klément Gottwald) កាន់តំណែងប្រធានាធិបតីបន្ត ។ រដ្ឋាភិបាលកើតក្រោយការបោះឆ្នោតបានចម្លងតាមទម្រង់រដ្ឋាភិបាលក្រុងម៉ូស្គូទាំងស្រុង តាំងពីសេដ្ឋកិច្ចផែនការរហូតដល់ត្រួតពិនិត្យលើផលិតផលផ្សេងៗ ។ ក្រោយមកការរឹតបន្តឹងនិងអំពើផ្តាច់ការត្រូវគេយកមកអនុវត្តគាបសង្កត់ទៅលើសេរីភាពក្នុងការបញ្ចេញមតិព្រមទាំងបង្កើតប៉ូលិសសម្ងាត់ដើម្បីតាមឃ្លាំមើលចលនាប្រឆាំងនឹងរដ្ឋាភិបាល ។ នៅពេលនោះប្រទេសឆេកូស្លូវ៉ាគីជាមិត្តជិតស្និទ្ធនឹងសហភាពសូវៀត ។ នៅក្រោមការដឹកនាំរបស់ហ្គោតវ៉ៃត សេដ្ឋកិច្ចនៃប្រទេសឆេកូស្លូវ៉ាគីបានជាប់គាំង កម្រិតជីវភាពប្រជាជនធ្លាក់ចុះ កំណើនអ្នកគ្មានការងារធ្វើកាន់តែខ្ពស់ ។ បន្ទាប់ពីលោក ហ្គោតវ៉ៃត ធ្លាក់ពីតំណែង លោក ឌុបសិច(Dubcek) បានដឹកនាំរដ្ឋាភិបាលបន្តនៅឆ្នាំ 1968 ដោយនិយមគំនិតកែទម្រង់នយោបាយឱ្យមានភាពធូរស្រាលតាមរយៈការបញ្ចូលទស្សនៈលទ្ធិប្រជាធិបតេយ្យនៅក្នុងរបបកុម្មុយនីស្តដែលកំពុងថាក់ស្រេះ ។ ទស្សនៈនេះហៅថានិទាឃរដូវនៃក្រុងប្រាកដែលគាំទ្រសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិនយោបាយរបស់ពលរដ្ឋ ។ នយោបាយកែទម្រង់នៅប្រទេសឆេកូស្លូវ៉ាគីធ្វើឱ្យសហភាពសូវៀតនិងប្រទេសក្នុងប្លុកវ៉ាសូវីមានការព្រួយបារម្ភយ៉ាងខ្លាំងខ្លាចក្រែងគំរូនោះជ្រាបចូលទៅដល់ប្រទេសផ្សេងៗនៅអឺរ៉ុបខាង

កើត ។ នៅយប់ថ្ងៃទី 20-21 ខែសីហា ឆ្នាំ 1968 សហភាពសូវៀតបានលើកកងកម្លាំងរថក្រោះជាច្រើនគ្រឿងចូលលុកប្រទេសឆេកូស្លូវ៉ាគីដើម្បីផ្តួលរំលំរដ្ឋាភិបាលលោក ឌុបសិច ហើយលើកលោក ហ្គុស្តាវ ហ៊ូសាក់ (Gustav Husak) ឡើងជំនួស ។ ពេលនោះយ៉ាងហោចណាស់ក៏មានទ័ពបក្សសម្ព័ន្ធវ៉ាសូវី 80 ពាន់នាក់ដាក់ប្រចាំការនៅក្នុងប្រទេសឆេកូស្លូវ៉ាគីដែរ ។

## 1.3. ចលនាបដិវត្តន៍ឆេកូស្លូវ៉ាគី

នៅទសវត្សរ៍ឆ្នាំ 1980 ជីវភាពរបស់ប្រជាជនឆេកូស្លូវ៉ាគីធ្លាក់ចុះដុនដាបខ្លាំងដោយសារវិបត្តិសេដ្ឋកិច្ចរហូតដល់របបកុម្មុយនិស្តត្រូវរង្គោះរង្គើ ។ ចលនាបះបោរបានរីកសាយពាសពេញទីក្រុងប្រឆាំងនឹងរបបកុម្មុយនិស្ត ។ ពួកគេទាមទារឱ្យរំលាយរដ្ឋាភិបាល រួចយករបបប្រជាធិបតេយ្យតាមបែបអឺរ៉ុបខាងលិចមកជំនួសវិញ ។ តាំងពីពេលនោះ នយោបាយកែទម្រង់នៅសហភាពសូវៀតនៅក្នុងដំណែងលោក ហ្គោបាឆូវ ហាក់ដូចជួយជំរុញសភាពការណ៍នៅប្រទេសឆេកូស្លូវ៉ាគីឱ្យមានសំទុះកាន់តែខ្លាំងក្លាឡើងថែមទៀត ។

នៅខែវិច្ឆិកា ឆ្នាំ 1989 មានហ្វូងបាតុករដើរដង្ហែក្បួនច្រើនកុះករតាមដងវិថីនានានៃទីក្រុងប្រាកដែកាន់បដាស្រែកទាមទារឱ្យរដ្ឋាភិបាលកុម្មុយនិស្តចុះពីតំណែង ។ ក្នុងរយៈពេលមិនដល់មួយខែផងរដ្ឋាភិបាលកុម្មុយនិស្តបានលាលែងពីតំណែង ។ សភាជាតិបានបោះឆ្នោតជ្រើសមេដឹកនាំថ្មី គឺលោក វ៉ាក់ក្លាវ ហាវ៉ែល (Vaklav Havel) ដែលមាននិន្នាការទៅរករបបប្រជាធិបតេយ្យ ។ របបកុម្មុយនិស្តបានបញ្ចប់ជាស្ថាពរដោយគ្មានការបង្ហូរឈាម ដែលគេមិននឹកស្មានដល់ថាវាងាយស្រួលដូច្នេះសោះ ។

## 1.4. ការបែងចែករដ្ឋឆេកូស្លូវ៉ាគី

ក្រោយពីរបបកុម្មុយនិស្តដួលរលំ មានការខ្វែងគំនិតគ្នារវាងអ្នកដឹកនាំឆែក និងស្លូវ៉ាគី អំពីបញ្ហានយោបាយ និងសេដ្ឋកិច្ចដែលជាឧបសគ្គក្នុងការបង្កើតរដ្ឋធម្មនុញ្ញ និងនាំឱ្យមានភាពយឺតយ៉ាវក្នុងកំណែទម្រង់សេដ្ឋកិច្ច ។ នៅពាក់កណ្តាលឆ្នាំ 1993 មេដឹកនាំនៃរដ្ឋទាំងពីរបានពិភាក្សាអំពីការបង្កើតប្រទេសដាច់ដោយឡែកពីគ្នាគឺសាធារណរដ្ឋឆែក និងសាធារណរដ្ឋស្លូវ៉ាគី ។ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 1993 សាធារណរដ្ឋទាំងពីរបានកើតឡើងជាផ្លូវការ និងស្របច្បាប់ ។

### ក. សាធារណរដ្ឋឆែក

សាធារណរដ្ឋឆែកទទួលបានឯករាជ្យនៅថ្ងៃទី 1 ខែមករា ឆ្នាំ 1993 ជារដ្ឋប្រជាធិបតេយ្យមានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ។ រដ្ឋឆែកមានព្រំប្រទល់ខាងជើងជាប់នឹងប៉ូឡូញ ខាងកើតសហព័ន្ធរុស្ស៊ី ខាងត្បូងហុងគ្រី អូទ្រីស និងខាងលិចជាប់ប្រទេសអាល្លឺម៉ង់ ។ ស្ថិតនៅក្នុងទ្វីបអឺរ៉ុបប៉ែកកណ្តាល

មានផ្ទៃក្រឡា 78 864 $km^2$ មានប្រជាជន 10 លាននាក់ (ឆ្នាំ 1989)។ ប្រជាជនភាគច្រើនគឺអំបូរឆែក ក្រៅពីនោះមានជាតិពន្ធុចម្រុះជាមួយអាល្លឺម៉ង់ និងហុងគ្រី។ មុនសង្គ្រាមលោកលើកទី 2 មានជនជាតិជ្វីបរស់នៅច្រើន ប៉ុន្តែត្រូវពួកណាស៊ីសម្លាប់ស្ទើរផុតពូជ។ សព្វថ្ងៃនេះ មានជនជាតិជ្វីបរស់នៅទីក្រុងប្រាកមានចំនួន 15 ទៅ 18 ពាន់នាក់ប៉ុណ្ណោះ។ ប្រជាជនឆែកមានជំនឿទៅលើរ៉ូម៉ាំងកាតូលិក បន្ទាប់មកមានអ័រតូដុក និងប្រូតេស្តង់។ ជំនឿសាសនាត្រូវបើកចំហឡើងវិញនៅឆ្នាំ 1990 ក្រោយពេលរបបកុម្មុយនីស្តដួលរលំ។

## ១. សាធារណរដ្ឋស្លូវ៉ាក




*ផែនទីសាធារណរដ្ឋស្លូវ៉ាកនិងសាធារណរដ្ឋឆែក*

សាធារណរដ្ឋស្លូវ៉ាក ស្ថិតនៅអឺរ៉ុបប៉ែកកណ្តាល មានផ្ទៃក្រឡា 49 036 $km^2$ មានប្រជាជន 5.5 លាននាក់ មានទីក្រុងនយោបាយ ប្រាទីស្លាវ៉ា (Bratislava) និយាយភាសាស្លូវ៉ាក ហុងគ្រី និងរូម៉ានី និយមសាសនាកាតូលិក និងប្រូតេស្តង់។ ប្រធានាធិបតីដំបូងគឺ លោកកូវ៉ាក់។ ស្លូវ៉ាក បានចូលជាសមាជិកនៃអង្គការផ្សារួម និងអូតង់នៅឆ្នាំ 2004។ ស្លូវ៉ាកបានរឹតបន្តឹងចំណងមិត្តភាពនឹងសហរដ្ឋអាមេរិក ហើយគាំទ្រយ៉ាងពេញទំហឹងវត្តមានកងទ័ពអាមេរិក និងអូតង់នៅប្រទេសអ៊ីរ៉ាក់ និងអាហ្វហ្គានីស្ថាន។

## 2. វិស័យសង្គម

រដ្ឋយកចិត្តទុកដាក់ដល់កម្មករនិយោជិត និស្សិត អ្នកវិទ្យាសាស្ត្រ សិល្បករ សមាជិកសហករណ៍សុខទ្ធតែមានប្រាក់ធានាសុខភាពពីរដ្ឋ ។ បើសិនជាអ្នកណាម្នាក់មានជំងឺត្រូវបានទទួលប្រាក់ធានាក្នុងការព្យាបាលជំងឺចាប់ពី 50% នៃចំនួនប្រាក់ខែ ។ សម្រាប់ស្ត្រី នៅពេលឆ្លងទន្លេត្រូវបានឈប់សម្រាកមាតុភាពចំនួន 52 សប្តាហ៍ និងប្រាក់ឧបត្ថម្ភចំនួន 90% នៃប្រាក់ខែ ។

នៅឆ្នាំ 1985 ប្រទេសឆេកូស្លូវ៉ាគីមានមន្ទីរពេទ្យ 229 កន្លែង ស្មើនឹង 123 151 គ្រែ ។ មន្ទីរសម្ភពមានចំនួន 141 និងមន្ទីរពេទ្យកុមារ 43 កន្លែង ក្រៅពីនេះមានយុទ្ធនាការចុះចាក់ថ្នាំបង្ការជំងឺឆ្លងមានដូចជាជំងឺរបេង ខាន់ស្លាក់ ស្វិតដៃជើង ជំងឺខួរក្បាលជាដើម ។ ការចុះចាក់ថ្នាំបង្ការនេះបានធ្វើឱ្យអត្រាមរណៈនៃកុមារចុះមកនៅត្រឹម 10% នៅឆ្នាំ 1985 ។ ដោយសារការយកចិត្តទុកដាក់របស់រដ្ឋាភិបាលអំពីសុខភាព គេឃើញថាអាយុមធ្យមរបស់ប្រជាជនឆេកូស្លូវ៉ាគី បុរសជាមធ្យមអាយុ 66ឆ្នាំ និងស្ត្រីអាយុ 74ឆ្នាំ ប៉ុន្តែបើប្រៀបធៀបនឹងអឺរ៉ុបខាងលិចអត្រានេះនៅមានកម្រិតទាបនៅឡើយ ។

នៅក្នុងប្រព័ន្ធអប់រំឆេកូស្លូវ៉ាគីពុំមានថ្នាក់រៀនបង់ថ្លៃឡើយចាប់ពីមត្តេយ្យរហូតដល់ឧត្តមសិក្សា ។ ក្រោយពីរៀនចប់ថ្នាក់មូលដ្ឋានរយៈពេល 9ឆ្នាំមក សិស្សអាចបន្តយកមុខជំនាញនៅតាមសាលាមុខរបរផ្សេងៗទៀត ។ និស្សិតឆេកូស្លូវ៉ាគីបានទទួលអាហារូបករណ៍ដល់អាយុ 25ឆ្នាំ ។ នៅទូទាំងប្រទេសឆេកូស្លូវ៉ាគីមានសកលវិទ្យាល័យចំនួន 36 ក្នុងចំណោមនោះមានសកលវិទ្យាល័យល្បីឈ្មោះចំនួន 5 កន្លែងគឺ សកលវិទ្យាល័យសាល(Charles University )កសាងឡើងនៅឆ្នាំ 1348 សកលវិទ្យាល័យកុំមេនុស(Comenius University )កសាងឡើងនៅឆ្នាំ 1919 សកលវិទ្យាល័យប៉ាឡាគី(Palacky University) កសាងឡើងនៅឆ្នាំ 1576 សកលវិទ្យាល័យសាហ្វារីក(Safarik University ) កសាងឡើងនៅឆ្នាំ 1959 និងសកលវិទ្យាល័យពូគីន(Purkine University )កសាងឡើងនៅឆ្នាំ 1919 ។ នៅឆ្នាំសិក្សា 1985-1986 មាននិស្សិតបរទេស 4 160នាក់ បានសិក្សានៅក្នុងប្រទេសឆេកូស្លូវ៉ាគី ។

## 3. វិស័យសេដ្ឋកិច្ច

### 3.1. ឧស្សាហកម្ម

នៅឆ្នាំ 1948 នៅក្នុងសម័យកុម្មុយនីស្តឡើងកាន់អំណាច រោងចក្រសហគ្រាស និងកសិដ្ឋានត្រូវកាន់កាប់ដោយរដ្ឋ ។ លុះមកដល់ឆ្នាំ 1989 ពួកកុម្មុយនីស្តបាត់បង់អំណាច រោងចក្រ និងកសិដ្ឋានទាំងអស់ត្រូវផ្លាស់ប្តូរមកជាកម្មសិទ្ធិឯកជនវិញ ។

វិស័យឧស្សាហកម្មបានស្រូបយកកម្មករ 40% នៃចំនួនប្រជាជនសកម្ម ។ ផលិតផលឧស្សាហកម្មមានគ្រឿងកំណាត់ កញ្ចក់ ម៉ាស៊ីន ចំណីអាហារ រថយន្តក្រុង រថយន្តទេសចរណ៍ រថយន្តដឹកទំនិញធុនធំ ដែលផលិតចេញពីរោងចក្រស្កូដា(Skoda) ដ៏ល្បីឈ្មោះ និងធ្លាប់ប្រណាំងប្រជែងជាមួយរថយន្តរីណូរបស់បារាំង ឬ វ៉ុលវ៉ាហ្គែនរបស់អាល្លឺម៉ង់ជាដើម ។ ទឹកដីឆេកូស្លូវ៉ាគីសម្បូរដែរស្ទើរគ្រប់ប្រភេទដូចជា បុកស៊ីត ធ្យូងថ្ម ប្រេងកាត ម៉ង់កាណែស ដែមាស និងអុយរ៉ានីញ៉ូម ដែលជាប្រភពថាមពលខ្ពស់បំផុត សម្រាប់ប្រើប្រាស់ទាំងវិស័យស៊ីវិល និងយោធា ។

## ១.២. ប្រភពថាមពល

ប្រទេសឆេកូស្លូវ៉ាគីមានរោងចក្រថាមពលមួយដ៏ធំនៅជិតទីក្រុង វូសនី(Vojni) ដែលប្រើថាមពលធ្យូងថ្ម ។ ប្រទេសនេះក៏មានថាមពលដែលប្រើដោយកម្លាំងទឹក(វារីអគ្គិសនី) ប៉ុន្តែមិនទាន់ឆ្លើយតបនឹងតម្រូវការក្នុងស្រុកនៅឡើយ ។

ដោយសារភាពសម្បូរទៅដោយរ៉ែអ៊ុយរ៉ានីញ៉ូម ប្រទេសឆេកូស្លូវ៉ាគីបានកសាងរោងចក្រដើរដោយថាមពលបរមាណូនៅឆ្នាំ 1968 នៅបូហូនីល(Bohonile) ។ នៅឆ្នាំ 1986 បានសម្រេចដាក់ឱ្យប្រើរេអាក់ទ័រចំនួន 5 គ្រឿង ដែលក្នុងមួយគ្រឿងមានកម្លាំងរហូតដល់ 440 មេកាវ៉ាត់ ។ ឆេកូស្លូវ៉ាគីមានអណ្តូងប្រេងកាតមួយនៅជិតព្រំប្រទល់ប្រទេសអូទ្រីសដែលផ្តល់ការផ្គត់ផ្គង់ចំនួន 2 000 បារ៉ែលក្នុងមួយថ្ងៃ ។ ក្រៅពីនេះ ឆេកូស្លូវ៉ាគីក៏បាននាំចូលឧស្ម័នធម្មជាតិពីប្រទេសរុស្ស៊ីបន្ថែមទៀតផងដែរ ។

## ១.៣. កសិកម្ម

ប្រទេសឆេកូស្លូវ៉ាគីមានផ្ទៃដីកសិកម្មចំនួន 40% នៃផ្ទៃប្រទេស ។ ដំណាំទាំងនោះមានដំឡូងបារាំង ពោត បន្លែ និងផ្លែឈើ ។ ក្រៅពីនេះ ក៏មានកសិដ្ឋានចិញ្ចឹមសត្វធំៗដូចជា មាន់ ជ្រូក ចៀម និងគោ ។ ប្រទេសឆេកូស្លូវ៉ាគីមានដៃគូពាណិជ្ជកម្មជាមួយប្រទេសអូទ្រីស បារាំង អាល្លឺម៉ង់ ហុងគ្រី ប៉ូឡូញ អ៊ីតាលី និងសហរដ្ឋអាមេរិក ។ ផលិតផលនាំចេញមានធ្យូងថ្ម សម្លៀកបំពាក់ ដែកថែប ម៉ាស៊ីន រថយន្ត ។ ផលិតផលក្នុងស្រុកឆេកូស្លូវ៉ាគីមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជនចំនួន 15 លាននាក់បានឡើយ ត្រូវនាំចូលពីបរទេសនូវ ប្រេងកាត ឧស្ម័នធម្មជាតិ រថយន្ត ស្រូវសាលី ។

## ? សំណួរ

1. ក្រោយសង្គ្រាមលោកលើកទី 2 តើប្រទេសឆេកូស្លូវ៉ាគីប្រកាន់នយោបាយបែបណា ?
2. ហេតុអ្វីបានជាក្រោយឆ្នាំ 1991 ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរ ?
3. តើសេដ្ឋកិច្ចប្រទេសឆេកូស្លូវ៉ាគីមានការរីកចម្រើន ឬទេ ? ព្រោះអ្វី ?

មេរៀនទី

# 9 ប្រទេសប៉ូឡូញ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាព្រឹត្តិការណ៍នយោបាយ សេដ្ឋកិច្ច និងសង្គមប៉ូឡូញក្រោយសង្គ្រាមលោកលើកទី 2 ។
- វិភាគបញ្ហាប្រទេសប៉ូឡូញជាកម្មវត្ថុរបស់មហាអំណាចអាល្លឺម៉ង់ និងសូវៀត ។
- បណ្ដុះស្មារតីស្រឡាញ់សន្តិភាព និងការអភិវឌ្ឍ ។

ប្រទេសប៉ូឡូញស្ថិតនៅក្នុងទ្វីបអឺរ៉ុបប៉ែកកណ្ដាល មានផ្ទៃក្រឡា 312 683 គីឡូម៉ែត្រការ៉េមានប្រជាជន 38 505 000 នាក់ (ឆ្នាំ 2006) មានរដ្ឋធានីឈ្មោះ វ៉ាសូវី ប្រទេសនេះចែកចេញជា 16 ខេត្ត ។ ប្រទេសប៉ូឡូញមានព្រំប្រទល់ខាងជើងជាប់សមុទ្របាល់ទិក ខាងលិចជាប់និងសហព័ន្ធអាល្លឺម៉ង់ ខាងត្បូងជាប់និងសាធារណរដ្ឋឆែក និងសាធារណរដ្ឋស្លូវ៉ាគី ខាងកើតទល់និងសហព័ន្ធរុស្ស៊ី ។ ពួកណាស៊ីបានបំភ្លៃព្រឹត្តិការណ៍ប៉ូឡូញជាបុព្វហេតុនៃការផ្ទុះសង្គ្រាមលោកលើកទី 2 ។




*ផែនទីប្រទេសប៉ូឡូញ*

# 1. ប្រទេសប៉ូឡូញក្នុងសង្គ្រាមលោកលើកទី2

## 1.1. មូលហេតុនៃសង្គ្រាម



កងទ័ពអាល្លឺម៉ង់ឈ្លានពានប្រទេសប៉ូឡូញ (ថ្ងៃទី 01 ខែកញ្ញា ឆ្នាំ 1939)

សន្ធិសញ្ញាវែរសៃ(Versailles) (បារាំង) ឆ្នាំ 1919 បានធានាដល់ឯករាជ្យនៃប្រទេសប៉ូឡូញ ប៉ុន្តែមុនសង្គ្រាមលោកលើកទី 2 ប្រទេសនេះបានក្លាយជាទិសដៅនៃមហិច្ឆតារវាងមហាអំណាចជិតខាងទាំងពីរគឺចក្រភពអាល្លឺម៉ង់ និងសហភាពសូវៀត ។ នៅថ្ងៃទី 23 ខែសីហា ឆ្នាំ 1939 ប្រទេសអាល្លឺម៉ង់ និងសូវៀតបានចុះសន្ធិសញ្ញាជាសម្ងាត់ ដើម្បីបែងចែកទឹកដីប៉ូឡូញ ។

សង្គ្រាមលោកលើកទី 2 បានផ្ទុះឡើងនៅពេលដែល អ៊ីត្លែ លើកទ័ពចូលលុកប្រទេសប៉ូឡូញនៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 1939 ។ អាល្លឺម៉ង់បានល្មើសរំលោភឯករាជ្យនៃប្រទេសប៉ូឡូញដែលស្ថិតនៅក្រោមការធានាអះអាងនៃពួកមហាអំណាច ។ នៅខែមិថុនា ឆ្នាំ 1941 អាល្លឺម៉ង់បានលើកទ័ពចូលលុកសហភាពសូវៀត ដោយរំលោភសន្ធិសញ្ញាសម្ងាត់នៃប្រទេសទាំងពីរនៅថ្ងៃទី 23 ខែសីហា ឆ្នាំ1939 ។ ដើម្បីប្រឆាំងនឹងពួកណាស៊ី ប៉ូឡូញបានបង្កើតចលនាតស៊ូជាពីរក្រុម ក្រុមទី 1 មានទ័ពចំនួន 200 ពាន់នាក់ ច្បាំងនៅសមរភូមិខាងលិចដើម្បីគាំទ្ររដ្ឋាភិបាលបណ្តោះអាសន្នដែលមានទីស្នាក់ការនៅទីក្រុងឡុងដ៍ និងក្រុមទី 2 មានទ័ពចំនួន 400 ពាន់នាក់ រួមកម្លាំងជាមួយទ័ពសូវៀត ។

នៅខែមេសា ឆ្នាំ 1943 ចំណងមិត្តភាពរវាងប៉ូឡូញ និងសូវៀតត្រូវបានប្រេះឆាដោយសារទាហានអាល្លឺម៉ង់បានរកឃើញរណ្តៅកប់ខ្មោចនាយទាហានប៉ូឡូញចំនួន 4 500 នាក់នៅកាទីន(Katine) ដែលត្រូវតម្រួតសូវៀតសម្លាប់ ប៉ុន្តែសូវៀតបានចោទថាអាល្លឺម៉ង់ជាអ្នកសម្លាប់រង្គាលទៅវិញ ។ ក្រោយពីផ្ទុះរឿងឧក្រិដ្ឋកម្មនេះ សូវៀតបានលើកទ័ពចូលប្រទេសប៉ូឡូញនៅខែកក្កដា ឆ្នាំ 1944 រួចបង្កើតរណសិរ្សរំដោះជាតិមួយដោយឡែកពីរដ្ឋាភិបាលបណ្តោះអាសន្ននៅទីក្រុងឡុងដ៍ ។ ពួកទាហានណាស៊ីបានដកទ័ពចេញពីប្រទេសប៉ូឡូញនៅអំឡុងខែមករា ឆ្នាំ 1945 ។

### 1.2. ភាពហិនហោចដោយសារសង្គ្រាម

មានប្រជាជនប៉ូឡូញប្រហែល 6 លាននាក់បានស្លាប់នៅក្នុងសង្គ្រាមលោកលើកទី 2 និងមានចំនួន 2.5 លាននាក់ ត្រូវជំរុញឱ្យធ្វើការជាទម្ងន់នៅប្រទេសអាល្លឺម៉ង់ ។ យ៉ាងហោចណាស់មានប្រជាជនប៉ូឡូញជិត 1 លាននាក់ត្រូវគេសម្លាប់នៅក្នុងជំរំប្រមូលផ្ដុំនៅអូស្វិច នៅទីក្រុងឡាំងកា និងម៉ាសដាណែក ។ តាមការប៉ាន់ស្មាន ការខូចខាតជាទ្រព្យសម្បត្តិមានរហូតដល់ 50 ពាន់លានដុល្លារ ។

## 2. ប្រទេសប៉ូឡូញនៅក្រោយសង្គ្រាមលោកលើកទី2

### 2.1. វិស័យនយោបាយ

នៅក្រោយសន្និសីទយ៉ាល់តា សូវៀតបានបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នឯកភាពជាតិប៉ូឡូញមួយនៅខែមិថុនា ឆ្នាំ 1945 ។ ក្រោយមកទៀត ដោយមានការព្រមព្រៀងពីមហាអំណាច គេឃើញមានការចាត់ចែងឱ្យធ្វើការបោះឆ្នោតដោយសេរីមួយនៅខែមករា ឆ្នាំ 1947 ដែលពេលនោះ ពួកកុម្មុយនីស្តជាអ្នកក្ដាប់អំណាចនៅក្នុងរដ្ឋាភិបាលនេះ ។ ការគ្រប់គ្រងនៃរបបកុម្មុយនីស្តលើកដំបូងបង្កើតឱ្យមានភាពតានតឹងជាមួយសាសនារ៉ូម៉ាំងកាតូលិកដោយមានការចាប់ខ្លួនមន្ត្រីសង្ឃដាក់គុកជាដើម ។ ប្រជាជនប៉ូឡូញជាអ្នកមានជំនឿមោះមុត និងជាអ្នកប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនខាងសាសនាខ្លាំងជាងគេក្នុងចំណោមប្រជាជននៅអឺរ៉ុប ។ ម្យ៉ាងទៀត ការតែងតាំងឧត្តមសេនីយ៍សូវៀតកុងស្តង់ទីន រូកូសូវស្គី (Konstantin Rokossovsky) ជាមន្ត្រីការពារជាតិ ហើយក្រោយមកទៀតមានតំណែងជានាយករដ្ឋមន្ត្រីអស់រយៈពេល 4 ឆ្នាំ ដោយវិបត្តិសេដ្ឋកិច្ចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពកម្មករ ។ គំនិតជាតិនិយម វិបត្តិសាសនា វិបត្តិសេដ្ឋកិច្ច បានកន្ត្រាក់ស្មារតីពួកកាតូលិក និងពួកកម្មករឱ្យធ្វើបាតុកម្មនៅប៉ូណាន (Poznan) នៅខែមិថុនា ឆ្នាំ 1956 នាំមកដល់ការតែងតាំង លោក កូមុលកា (Gomulka) ជាអតីតមេដឹកនាំគណបក្សកម្មករធ្វើជានាយករដ្ឋមន្ត្រីដើម្បីធ្វើការកែទម្រង់ ។ វិបត្តិសង្គម និងសេដ្ឋកិច្ចចេះតែរីករាលដាលធំឡើងៗ នាំឱ្យបាតុកម្មកើតមាននៅតាមទីក្រុងមួយចំនួនដូចជានៅតាមទីក្រុងដង់ និងសាប៉ូជាដើម ។ ដោយសារសម្ពាធបាតុកម្មបានធ្វើឱ្យរដ្ឋាភិបាលលោកកូមុលកាធ្លាក់ពីតំណែងនៅឆ្នាំ 1970 ។ លោក ស៊ីរ៉េច (Cierek) ជាអ្នកកាន់តំណែងបន្ត បានធ្វើការបង្ក្រាបទៅលើចលនាបាតុកម្មរបស់កម្មករយ៉ាងខ្លាំងធ្វើឱ្យចលនានេះប្រមូលផ្ដុំបង្កើតជាសហជីពកម្មករ ដែលហៅថាអង្គការសាមគ្គីភាព ដឹកនាំដោយឡិចវ៉ាលេសា (lech Valesa) ។ អង្គការនេះមានឥទ្ធិពលខ្លាំងដោយសារមានការចូលរួមពីពួកកាតូលិកធ្វើការតវ៉ាទាមទារសិទ្ធិកម្មករក្នុងការបង្កើតសហជីព និងសិទ្ធិធ្វើបាតុកម្មពីរដ្ឋាភិបាល ។ ក្រោយពីចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលរួចមក ចលនានេះបានរីកដុះដាលពាសពេញផ្ទៃប្រទេស ។

នៅខែកញ្ញា ឆ្នាំ 1981 ពេលអង្គការសហជីពកម្មករបើកសមាជរបស់ខ្លួន សហភាពសូវៀតធ្វើអន្តរាគមន៍ដើម្បីប្រឆាំងនិងសហជីពកម្មករ ។ នៅខែធ្នូ ឆ្នាំ 1981 ច្បាប់អាជ្ញាសឹកបានប្រកាសដាក់ប្រទេសជាតិក្នុងស្ថានភាពមានសង្គ្រាមជាមួយឡិចវ៉ាលេសា ។ ក្រោយមកមេដឹកនាំអង្គការសហជីពកម្មករត្រូវចាប់ខ្លួន ។ ព្រឹត្តិការណ៍ដែលគួរឱ្យកត់សំគាល់គឺ ការចាប់ធ្វើឃាតមន្ត្រីសង្ឃនាម ប៉ូពីឡូស្កូ ។ នៅអំឡុងឆ្នាំ 1990 ទើបចលនាកម្មករទទួលជោគជ័យ គឺនៅពេលដែលលោក វ៉ាលេសាបានជាប់ឆ្នោតជាប្រធានាធិបតី ។ នៅឆ្នាំ 1997 រដ្ឋធម្មនុញ្ញថ្មីនៃប្រទេសប៉ូឡូញ បានបញ្ញត្តិប្រទេសនេះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យដែលប្រធានាធិបតីមានអាណត្តិ 5 ឆ្នាំ អមដោយនាយករដ្ឋមន្ត្រី ។ ប្រធានាធិបតីជាអ្នកជ្រើសរើសមន្ត្រីតាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី រួចសុំសេចក្តីអនុម័តពីសភាដោយមតិភាគច្រើន ។ នៅក្រោយការដួលរលំអតីតសហភាពសូវៀត ប៉ូឡូញបានក្លាយជាសមាជិកអង្គការអូតង់ និងជាសមាជិកនៃទីផ្សាររួមអឺរ៉ុបទៀតផង ។

## ២.២. វិស័យសង្គម

រដ្ឋាភិបាលបានគិតគូរដល់មនុស្សចាស់ជរា មនុស្សពិការ និងជាពិសេសមនុស្សបាត់បង់សមត្ថភាពពលកម្មដោយផ្តល់ប្រាក់ចូលនិវត្តន៍យ៉ាងទៀងទាត់ ។ ចំណែកមន្ត្រីរដ្ឋការគ្រប់ជាន់ថ្នាក់នៃក្រសួងមន្ទីរនានាមាន គ្រូបង្រៀន ពេទ្យ អ្នកបើកយន្តហោះ នាវាចរ ឬកម្មករគ្រប់ប្រភេទត្រូវរដ្ឋគិតគូរពីការចូលនិវត្តន៍ 60 ឆ្នាំ សម្រាប់បុរស និងស្ត្រីគឺអាយុត្រឹម 55 ឆ្នាំ ។

នៅឆ្នាំ 1986 សេវាសុខាភិបាល ទូទាំងប្រទេសប៉ូឡូញមាន គ្រូពេទ្យសរុប 72 900 នាក់ ត្រូវជា 19 នាក់សម្រាប់ប្រជាជន 10 ពាន់នាក់ និងមានមន្ទីរពេទ្យចំនួន 702 បើគិតចំនួនគ្រែមាន 245 ពាន់ ទទួលព្យាបាលអ្នកជំងឺបាន 4 571 ពាន់នាក់ ។ ក្រសួងសុខាភិបាលប៉ូឡូញមានការខ្វះខាតឱសថព្យាបាល ហើយត្រូវនាំចូលថ្នាំពេទ្យមួយចំនួនធំពីបស្ចិមប្រទេស ។ បើគិតពីអាយុមធ្យមនៅប៉ូឡូញ បុរសមានអាយុ 66 ឆ្នាំ និងស្ត្រី 75 ឆ្នាំ ។

ប្រព័ន្ធអប់រំនៅប៉ូឡូញមាន 9 ឆ្នាំសម្រាប់បឋមសិក្សា 4 ឆ្នាំសម្រាប់មធ្យមសិក្សាចំណេះទូទៅ 5 ឆ្នាំសម្រាប់សាលាបច្ចេកទេស ឬ 3 ឆ្នាំសម្រាប់សាលាខាងមុខរបរ ។ នៅឆ្នាំសិក្សា 1985-1986 ទូទាំងប្រទេសប៉ូឡូញមានសាលាបឋមសិក្សាចំនួន 17 013 ដែលមានសិស្សចូលរៀនចំនួន 383 ពាន់នាក់និងគ្រូចំនួន 277 900 នាក់ ។ សាលាមធ្យមសិក្សាចំណេះទូទៅមានចំនួន 1 131 មានសិស្ស 383 ពាន់នាក់ និងគ្រូចំនួន 22 300 នាក់ ។ មាននិស្សិតចំនួន 15 435 ពាន់នាក់កំពុងរៀននៅក្នុងសាលាមុខរបរ ចំនួន 913 នាក់សម្រាប់មុខវិជ្ជាកសិកម្ម សេដ្ឋកិច្ច ព្រៃឈើ សុខាភិបាល សិល្បៈ និងបច្ចេកវិទ្យា ។

ចំពោះផ្នែកឧត្តមសិក្សាគឺស្ថិតនៅក្រោមការគ្រប់គ្រងនៃក្រសួងឧត្តមសិក្សា ។ ប្រទេសប៉ូឡូញមានសកលវិទ្យាល័យចំនួន 11 សាលាពហុបច្ចេកទេសចំនួន 17 ឱសថសាស្ត្រ 10 និងបណ្ឌិតសភាទេវវិទ្យា 2 ។ សកលវិទ្យាល័យដែលមានវ័យចំណាស់ជាងគេនៅប្រទេសប៉ូឡូញគឺ សកលវិទ្យាល័យហ្សាសេឡូនៀន (Jagellonian) បង្កើតឡើងតាំងពីឆ្នាំ 1364 ។ នៅពេលដែលប្រទេសប៉ូឡូញបង្កើតច្បាប់អាជ្ញាសឹក សកលវិទ្យាល័យទាំងអស់ត្រូវបិទទ្វារអស់រយៈពេលជាច្រើនខែ ក្រុមសកលវិទ្យាធិការនិងព្រឹទ្ធបុរសចំនួន 70 នាក់ ត្រូវរដ្ឋាភិបាលឃោឃាំមើលយ៉ាងជិតដល់ ។

## 2.3. វិស័យសេដ្ឋកិច្ច

សេដ្ឋកិច្ចប្រទេសប៉ូឡូញមានសន្ទុះរីកចម្រើនមិនចាញ់ប្រទេសមួយចំនួននៅអឺរ៉ុបខាងកើតប៉ុន្មានឡើយ ។

### ក. ផ្នែកឧស្សាហកម្ម

នៅមុនសង្គ្រាមលោកលើកទី 2 ប្រទេសប៉ូឡូញជាប្រទេសកសិកម្ម ប៉ុន្តែក្រោយសង្គ្រាមលោកលើកទី 2 ប៉ូឡូញបានក្លាយជាប្រទេសឧស្សាហកម្ម ដោយពឹងផ្អែកលើរ៉ែក្រោមដីជាច្រើនប្រភេទនៅប៉ែកនិរតីនៃប្រទេស ហើយជាតំបន់ប្រមូលផ្តុំទីក្រុងធំៗមាន វ៉ាសូវី ដង់ ឡូត និងប៉ូណាង់ជាដើម ។ នៅក្នុងការពង្រីកឧស្សាហកម្ម ប៉ូឡូញត្រូវការប្រាក់កម្ចី និងបច្ចេកវិទ្យាពីលោកខាងលិច ។ ប្រទេសប៉ូឡូញមានកម្មករ 5 លាននាក់ធ្វើការក្នុងសហគ្រាសរដ្ឋទាំង 5 500 ។ រោងចក្រដែលប្រើសព្វថ្ងៃធ្វើឱ្យមានកង្វក់បរិស្ថានយ៉ាងខ្លាំង ព្រោះគ្រប់ផ្នែកនៃរោងចក្រចាស់គំរិលពេកមិនទាន់សម័យ រីឯផលិតផលមិនសូវមានគុណភាព បើប្រៀបធៀបទៅនឹងផលិតផលលោកខាងលិច ។ ទំនិញដែលផលិតបានត្រូវបង្ហូរទៅក្នុងទីផ្សារកូមេកុង ។ ចាប់ពីឆ្នាំ 1980 រដ្ឋាភិបាលបានប្រឹងប្រែងស្តារវិស័យឧស្សាហកម្មឡើងវិញ ។ ប៉ុន្តែរដ្ឋត្រូវជំពាក់បំណុលលោកខាងលិចកាន់តែច្រើនឡើងថែមទៀត ។ ការស្តារផ្នែកឧស្សាហកម្មនេះតម្រូវឱ្យរុះរើរោងចក្រ កាត់បន្ថយកម្មករ បណ្តុះបណ្តាលបច្ចេកវិទ្យាទំនើប និងរកប្រាក់កម្ចីពីប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិក អាល្លឺម៉ង់ ស៊ុយអែត អ៊ីតាលី និងបារាំងជាដើម ។ នៅឆ្នាំ 1990 ប្រទេសប៉ូឡូញមានអ្នកឥតការងារធ្វើចំនួន 1 លាននាក់ នៅអំឡុងពេលនោះមានពលរដ្ឋជាច្រើនបានធ្វើចំណាកស្រុកដើម្បីរកការងារនៅអឺរ៉ុបខាងលិច ។

## ១. វិស័យកសិកម្ម

ដីកសិកម្មនៅប៉ូឡូញត្រូវគេរៀបចំទៅតាមប្រភេទ នៅតំបន់ខាងជើងដីសើម ពុំសូវមានជីជាតិ ជាវាលទំនាបមួយផ្នែកគ្របដណ្តប់ដោយព្រៃ និងមួយផ្នែកទៀតអំណោយផលដល់ដំណាំដំឡូងបារាំង និងចិញ្ចឹមជ្រូក។ នៅផ្នែកខាងត្បូង សម្បូរទៅដោយដីមានជីជាតិល្អ គេដាំស្រូវសាលី នៃថាវស្គរ និង បន្លែ។ បើគិតតាមជញ្ជីងពាណិជ្ជកម្មវិញប៉ូឡូញមានការនាំចូលច្រើនជាងការនាំចេញ។ ការនាំចេញ ភាគច្រើនជាផលិតផលកសិកម្ម។

## ? សំណួរ

1. ហេតុអ្វីបានជាគេថា ប្រទេសប៉ូឡូញជាប្រភពនៃសង្គ្រាមលោកលើកទី 2 ?
2. តើប្រទេសប៉ូឡូញបានខូចខាតអ្វីខ្លះដោយសារសង្គ្រាមលោកលើកទី 2 ?
3. នៅក្រោយសង្គ្រាមលោកលើកទី 2 តើប្រទេសប៉ូឡូញបានស្តារប្រទេសជាតិដោយផ្តោតលើវិស័យអ្វីខ្លះ ? ចូរពន្យល់ពីវិស័យនីមួយៗ។
4. ហេតុអ្វីបានជាសហភាពសូវៀតមិនជួយសង្គ្រោះប្រទេសប៉ូឡូញឱ្យទាន់ពេលវេលាពីក្រញាំដៃអាល្លឺម៉ង់ ?
5. តើវិស័យនយោបាយរបស់ប្រទេសប៉ូឡូញបានស្តារមុខមាត់ដូចម្តេចខ្លះ ក្រោយការដួលរលំសហភាពសូវៀត ?

# 10 សហព័ន្ធយូហ្គោស្លាវី

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីទីតាំងភូមិសាស្ត្រទឹកដីប្រទេសយូហ្គោស្លាវី ។
- រៀបរាប់ពីនយោបាយរបស់យូហ្គោស្លាវីក្នុងសង្គ្រាមលោកទាំង 2 ។
- រកមូលហេតុនៃការបែកបាក់សហព័ន្ធយូហ្គោស្លាវីក្នុងសង្គ្រាមត្រជាក់ ។




*ផែនទីប្រទេសយូហ្គោស្លាវី*

## 1. ការចិតក្តនៃយូហ្គោស្លាវី

នៅថ្ងៃទី 01 ខែធ្នូ ឆ្នាំ 1918 មានឈ្មោះថាសហព័ន្ធស្លូវេនី ក្រូអាត និងរាជាណាចក្រសែប៊ី ។ ក្រោយមកតាមរយៈសន្ធិសញ្ញាការខូតនៅទីក្រុងប៉ារីស សហព័ន្ធនេះត្រូវបានគេទទួលស្គាល់នៅថ្ងៃទី 13 ខែកក្កដា ឆ្នាំ 1922 ។ នៅឆ្នាំ 1941 ប្រទេសនេះទទួលការលុកលុយពីពួកសម្ព័ន្ធភាពត្រីភាគីយ៉ាងធ្ងន់ធ្ងរនៅក្នុងអំឡុងដើមសង្គ្រាមលោកលើកទី 2 ហើយត្រូវបាត់ឈ្មោះពីផែនទីពិភពលោកនៅ

ឆ្នាំ 1943-1945 ។ នៅឆ្នាំ 1943 មានចលនារំដោះជាតិដែលដឹកនាំដោយពួកកុម្មុយនីស្តហើយបានប្តូរឈ្មោះទៅជាសាធារណរដ្ឋប្រជាមានិត ហើយកាន់អំណាចនៅឆ្នាំ 1946 ។ លុះដល់ឆ្នាំ 1963 ប្រទេសនេះបានប្តូរឈ្មោះទៅជាសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវី ( S.F.R.Y ) បានក្លាយជាប្រទេសមួយដែលមានទឹកដីធំជាងមុនព្រោះគេបានបញ្ចូលទឹកដីអ៊ីស្ទ្រា ( Istria ) និងរីចិកា ( Rejeka ) បន្ថែមទៀត ។

នៅក្រោយសង្គ្រាមលោកលើកទី 2 ប្រទេសជារដ្ឋសហព័ន្ធដែលមានរដ្ឋ 6 គឺរដ្ឋសង្គមនិយមបូស្នីអែសេកូវីន ក្រូអាត ម៉ាសេដ្វាន ស្លូវេនី ម៉ុងតេណេហ្គ្រោ និងស៊ែប៊ីដែលរួមបញ្ចូលទាំងខេត្តស្វយ័ត 2 គឺវ៉ូសវ៉ូឌីន និងកូសូវូដែលមានសិទ្ធិស្មើគ្នានិងរដ្ឋផ្សេងៗ ទៀតនៅក្នុងសហព័ន្ធដែរ ។ លុះដល់ឆ្នាំ 1991 រដ្ឋសហព័ន្ធមួយនេះបានធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមនៅក្នុងឧបទ្វីបបាល់កង់ក្រោយការដួលរលំនៃអតីតសហភាពសូវៀត ។

# 2. នយោបាយ

## 2.1. សង្គ្រាមលោកលើកទី1



*រជ្ជទាយាទនៃចក្រភពអូទ្រីស-ហុងគ្រី (ហ្វ្រង់ស្វ័រហ្វែឌីណង់និងមហេសី)*

ការសម្លាប់រជ្ជទាយាទប្រង់ស្វ័រហ្វែឌីណង់នៅ សារ៉ាសីវ៉ូ [1] ( Sarajevo ) ដោយនិស្សិតស៊ែប៊ីម្នាក់ជាការបើកទ្វារនៃសង្គ្រាមលោកលើកទី 1 ។ ចក្រភពអូទ្រីស-ហុងគ្រីបានប្រកាសសង្គ្រាមជាមួយប្រទេសស៊ែប៊ីនៅថ្ងៃទី 28 ខែកក្កដា ឆ្នាំ 1914 តែស៊ែប៊ីគាំទ្រដោយប្រទេសរុស្ស៊ី ។ នេះជាបុព្វហេតុ

(1). ថ្ងៃទី 28 ខែមិថុនា ឆ្នាំ 1914

បង្កើតរដ្ឋស្លាវខាងត្បូង ។ នៅក្រោយសង្គ្រាមលោកលើកទី ១ សន្ធិសញ្ញាអន្តរជាតិស្តីពីការបំបែកចេញពីចក្រភពអូទ្រីសដើម្បីបង្កើតប្រទេស 2 គឺឆេកូស្លូវ៉ាគី និងយូហ្គោស្លាវី ឬហៅថាស្លាវខាងត្បូង ។ ប្រទេសយូហ្គោស្លាវីគឺជារាជាណាចក្រដែលសោយរាជ្យដោយព្រះចៅភីទ័រទី ១ បន្ទាប់មកប្រទេសម៉ុងតេណេហ្គ្រោ ក៏ត្រូវបានបញ្ចូលទៅក្នុងប្រទេសស៊ែប៊ី ហើយក៏ប្រកាសជារាជាណាចក្រស៊ែប៊ី ក្រូអាត និងស្លូវ៉ែនីនៅខែធ្នូ ឆ្នាំ 1918 ។

## 2.2. សង្គ្រាមលោកលើកទី២



*អាល្លឺម៉ង់ចូលលុកលុយប្រទេសយូហ្គោស្លាវី*

នៅអំឡុងសង្គ្រាមលោកលើកទី 2 នៅពេលដែលអាល្លឺម៉ង់ចូលលុកលុយប្រទេសយូហ្គោស្លាវី នៅឯទីក្រុងឡុងដ៍ប្រទេសអង់គ្លេសបានបង្កើតរដ្ឋាភិបាលនិរទេសបណ្ដោះអាសន្នមួយនៅឯនាយសមុទ្រ ដើម្បីប្រឆាំងនឹងអាល្លឺម៉ង់ ។ រដ្ឋាភិបាលនេះដឹកនាំដោយព្រះចៅភីទ័រទី 2 ដែលគាំទ្រដោយចលនាតស៊ូពីរក្រុមសំខាន់ៗ ។ ក្រុមទី ១ ដឹកនាំដោយលោកឈីតនីក(Chetniks) និងក្រុមមួយទៀតដឹកនាំដោយលោកទីតូ ។ នៅឆ្នាំ 1943 ក្រុមទាំង 2 នេះបែកបាក់គ្នានាំឱ្យផ្ទុះសង្គ្រាមស៊ីវិល ក្រុមដែលដឹកនាំដោយទីតូមានការគាំទ្រពីទ័ពក្រហមរបស់សូវៀតទទួលជោគជ័យ ។ នៅចុងខែតុលា ឆ្នាំ 1944 កងទ័ពអាល្លឺម៉ង់បានដកថយពីយូហ្គោស្លាវី ហើយចូលជំនួសដោយកងទ័ពក្រហមសូវៀត ។ នៅខែវិច្ឆិកា ឆ្នាំ 1944 ចលនារំដោះជាតិរបស់ទីតូបានលេចរូបរាងឡើង ហើយលោកទីតូបានឡើងជានាយករដ្ឋមន្ត្រីទី ១ នៃរដ្ឋាភិបាលយូហ្គោស្លាវីនៅខែមីនា ឆ្នាំ 1945 ។ ក្រោយការបោះឆ្នោតជាតិ គណបក្សកុម្មុយនីស្តដែលដឹកនាំដោយលោកទីតូឈ្នះឆ្នោតទទួលបានអាសនៈច្រើនក្នុងសភា ។ រដ្ឋធម្មនុញ្ញបានប្រកាសយូហ្គោស្លាវីទៅជាសហព័ន្ធសាធារណរដ្ឋប្រជាមានិតយូហ្គោស្លាវីដែលមានទីតូជាប្រធានាធិបតី ។

## 3. សេនាប្រមុខទីតូ



លោកទីតូ

នៅឆ្នាំ 1946 រដ្ឋធម្មនុញ្ញថ្មី បានផ្តល់ស្វយ័តភាពដល់រដ្ឋដទៃទៀតទាំង 6 នៅក្នុងសហព័ន្ធដូចៗគ្នា ប៉ុន្តែការពិតអំណាចទាំងអស់គឺស្ថិតក្នុងកណ្តាប់ដៃរបស់ប្រធានាធិបតីទីតូ និងអ្នកដឹកនាំគណបក្សកុម្មុយនីស្ត ។

នៅពេលដែលបានគ្រប់គ្រងប្រទេសពេញលេញ រដ្ឋាភិបាលលោកទីតូបានចាប់ផ្តើមធ្វើនយោបាយការបរទេសឯករាជ្យមួយដោយបើកការទាក់ទងជាមួយលោកខាងលិចជាពិសេសទំនាក់ទំនងខាងសេដ្ឋកិច្ច និងយោធា ដោយចុះសន្ធិសញ្ញាបក្សសម្ព័ន្ធយោធាជាមួយប្រទេសក្រិក និងតួកគី ដែលប្រទេសទាំង 2 នេះសុទ្ធតែស្ថិតក្នុងសន្ធិសញ្ញាការពារនៃអង្គការអូតង់( OTAN ) ។ ដូច្នេះអ្វីដែលជាទំនាក់ទំនងស្អិតរមួតជាមួយសហភាពសូវៀតបានត្រូវចុះខ្សោយជាបន្តបន្ទាប់ និងកាត់ផ្តាច់ជាស្ថាពរនៅឆ្នាំ 1955 នៅក្រោយមរណភាពស្តាលីន ។ ទំនាក់ទំនងការបរទេសរបស់យូហ្គោស្លាវីនិងសូវៀតធ្វើឱ្យពិភពលោកព្រួយបារម្ភ ព្រោះប្រទេសអឺរ៉ុបខាងកើតនឹងយកតម្រាប់តាម ប្រសិនបើគ្មានវិធានការទប់ស្កាត់ឱ្យទាន់ពេលវេលា ។អ្វីដែលធ្វើឱ្យពិភពលោកមានការភ្ញាក់ផ្អើលគឺការធ្វើអន្តរាគមន៍ជាទ្រង់ទ្រាយធំដើម្បីគំរាមដោយកម្លាំងទ័ព និងយុទ្ធនាការយោធាចូលទៅក្នុងប្រទេសហុងគ្រីឆ្នាំ 1956 និងឆេកូស្លូវ៉ាគីដោយប្រើរទេះគង់ និងយន្តហោះប្រតិកម្មរាប់រយគ្រឿង ដើម្បីសម្លុតប្រទេសឆេកូស្លូវ៉ាគីនៅឆ្នាំ 1968 ។ ព្រឹត្តិការណ៍នេះបានគំរាមដល់ប្រទេសយូហ្គោស្លាវីផងដែរ ប៉ុន្តែសហភាពសូវៀតហាក់ដូចជារារែកចិត្តនៅពេលដែលលោកទីតូស្រែកថាប្រទេសយូហ្គោស្លាវីមិនមែនជាប្រទេសហុងគ្រី និងឆេកូស្លូវ៉ាគីទេ ។

ជាការពិតនយោបាយរបស់លោកទីតូហាក់ដូចជាមិនសូវមានសម្ពាធធ្ងន់ធ្ងរមកលើប្រជាជនដូចប្រទេសនៅអឺរ៉ុបមួយចំនួនទៀតដែលបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ឬសរសេររបស់ក្រុមបញ្ញវន្តឡើយ ។

នៅដើមឆ្នាំ 1970 នៅក្នុងសហព័ន្ធមានការរំជើបរំជួលនៃចលនាជាតិនិយម ពិសេសគឺពួកក្រូអាត និងពួកបញ្ញវន្ត ។ ក្រោយមក ដោយសារមានការកកស្ទះនូវដំណើរការសេដ្ឋកិច្ច ទើបលោកទីតូបានបន្ធូរឱ្យមានសេរីភាពខ្លះទៅលើសមាជិកទាំង 6 របស់រដ្ឋសហព័ន្ធ លោកទីតូបានទទួលមរណភាពនៅថ្ងៃទី 4 ខែមិថុនា ឆ្នាំ 1980 ដោយបន្សល់ទុកនូវបញ្ហាធ្ងន់ធ្ងរមួយចំនួនគឺ បញ្ហាសេដ្ឋកិច្ច បញ្ហាជនជាតិ និងបំណុលបរទេសជាដើម ។

បញ្ហាជនជាតិ ជាការព្រួយបារម្ភខ្លាំងនិងការបង្ហូរឈាមនៅក្នុងរដ្ឋសហព័ន្ធនេះ ព្រោះការស្លាប់របស់លោកទីតូជាការដួលរលំអំណាចកណ្តាល ។ រដ្ឋសមាជិកនៅក្នុងសហព័ន្ធត្រូវបែកបាក់ ។ ស្ទើរតែគ្រប់រដ្ឋសមាជិកទាំងអស់បានទាមទារស្វ័យភាពរៀងៗខ្លួន ហើយក្រោយមកបានប្រកាសជារដ្ឋឯករាជ្យ ។ ក្រោយមកមានជនជាតិអំបូរស៊ែប៊ីបានខិតខំពង្រឹងឧត្តមភាពអំបូរជនជាតិខ្លួន បានខិតខំស្តារយូហ្គោស្លាវីដែលចាស់ហើយរង្គោះរង្គើស្ទើរដួលរលំឱ្យងើបឡើងវិញ ។

# 4. ប្រជាជាតិបរិស្ថានទូទៅ

## 4.1. ជំនឿសាសនា

យូហ្គោស្លាវីមិនត្រឹមតែជាទឹកដីមួយដែលរស់នៅដោយអំបូរពូជសាសន៍ជាច្រើនប៉ុណ្ណោះទេថែមទាំងមានជំនឿសាសនាផ្សេងៗគ្នាទៀតផងដូចជាអ៊ីស្លាម កាតូលិក ជូដា(Judaism) ប្រូតេស្តង់ និងអ័រតូដុក(Orthodox) ។



*យូហ្គោស្លាវីគោរពសាសនាគ្រិស្តនិកាយអ័រតូដុក*

បើតាមស្ថិតិឆ្នាំ 1921 និង 1948 បានបង្ហាញថាជនជាតិយូហ្គោស្លាវីជាអ្នកជាប់ជំពាក់លើជំនឿសាសនា និងប្រតិបត្តិយ៉ាងជ្រាលជ្រៅគឺមានរហូតដល់ 99% ។ នៅក្រោយពេលដែលរបបកុម្មុយនីស្តកាន់អំណាចនៅឆ្នាំ 1964 ស្ថិតិមួយទៀតបញ្ជាក់ថាមានប្រជាជន 70% ជាអ្នកជឿសាសនា ។មជ្ឈមណ្ឌលដែលគោរពសាសនាខ្លាំងបំផុតគឺនៅខេត្តកូសូវ៉ូ(Kosovo) មានសាសនិកជនចំនួន 91% និងនៅអែសេកូវីន 83.8% ។ កន្លែងដែលមានសាសនិកជនទាបជាងគេស្លូវេនី 65.4% នៅស៊ែប៊ី 63.7% និង

នៅក្រូអាត 63.6% ។ ជំនឿសាសនាផ្សេងៗគ្នាដែលមាននៅពាសពេញសហព័ន្ធយូហ្គោស្លាវីជាការបន្ថែមទៅលើបញ្ហាជនជាតិផ្សេងគ្នា ដូចជាពួកស៊ែប៊ីប្រកាន់សាសនាគ្រិស្ត អ័រតូដុក ក្រូអាតប្រកាន់សាសនាកាតូលិក និងបូស្នីប្រកាន់សាសនាអ៊ីស្លាម ។ កត្តាទំនាស់ទាំង 2 នេះហើយបានបង្កើតឱ្យមានការផ្ទុះសង្គ្រាមជនជាតិដែលនាំទៅដល់ការរលំរលាយសហព័ន្ធយូហ្គោស្លាវី ។

## 4.2. សេដ្ឋកិច្ច

នៅទសវត្សរ៍ឆ្នាំ 70 ប្រទេសយូហ្គោស្លាវីបានជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដែលបណ្ដាលមកពីកំហុសរដ្ឋាភិបាលលោកទីតូដែលគ្រោងនឹងធ្វើឱ្យយូហ្គោស្លាវីក្លាយទៅជាប្រទេសមួយរីកចម្រើនខាងសេដ្ឋកិច្ចនៅលើឧបទ្វីបបាល់កង់ដូចជាប្រទេសនានានៅអឺរ៉ុបខាងលិចដែរ ។ យូហ្គោស្លាវីចាំបាច់ខ្ចីប្រាក់ចំនួនច្រើនលើសលុបដើម្បីកសាងសេដ្ឋកិច្ចគ្រប់វិស័យដោយពឹងផ្អែកលើការនាំចេញ ។ នៅទសវត្សរ៍ឆ្នាំ 70 អឺរ៉ុបខាងលិចជួបវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ជាពិសេសវិបត្តិថាមពលបានចោទជាបញ្ហាដល់ផលិតផលនាំចេញ និងធ្វើឱ្យរាំងស្ទះដង្ហើមសេដ្ឋកិច្ចយូហ្គោស្លាវី ហើយជាលទ្ធផល មនុស្សរាប់លាននាក់ត្រូវបាត់បង់ការងារ និងបាត់បង់ប្រាក់កំរៃប្រចាំថ្ងៃ ។ រដ្ឋាភិបាលត្រូវខ្ចីប្រាក់ពីអង្គការរូបិយប័ណ្ណអន្តរជាតិ (IMF) ដើម្បីទប់ទល់នឹងបញ្ហានេះ ។



*កសិដ្ឋានចិញ្ចឹមចៀមនៅយូហ្គោស្លាវី*

នៅឆ្នាំ 1989 តាមស្ថិតិជាផ្លូវការមានកសិដ្ឋានចំនួន 148 ត្រូវប្រកាសរឹបអូសដោយសារជំពាក់បំណុលធនាគារ និងមនុស្ស 89 400 នាក់ត្រូវបាត់បង់ការងាររហូតមកដល់រយៈពេល 9 ខែ ដំបូងនៃឆ្នាំ 1990 ។ តាមស្ថិតិរបស់អង្គការរូបិយប័ណ្ណអន្តរជាតិមានកសិដ្ឋាន 889 ត្រូវរឹបអូស និងមានមនុស្ស 52 500 នាក់ឥតការងារធ្វើ ។ ចំណែកឯរោងចក្រកែច្នៃវិញមានមនុស្ស 600 000 នាក់បាត់បង់ការងារ ។ នៅក្នុងអំឡុងនៃវិបត្តិនេះមានប្រជាជនប្រហែល 2.5 លាននាក់ខ្វះការងារធ្វើ ។ តំបន់មានកសិដ្ឋានច្រើនដូចជានៅស៊ែប៊ី ម៉ាសេដ្វាន បូស្នី កូសូវ៉ូ និងអ៊ែសេកូវីនទទួលរងការរឹបអូសច្រើនបំផុតក្នុងប្រទេសយូហ្គោស្លាវី ។

## ៤.៣. ការបែកបាក់សហព័ន្ធយូហ្គោស្លាវី

នៅឆ្នាំ 1987 លោកស្លូបូដានមីឡូសេវិចដែលមានដើមកំណើតជាជនជាតិស៊ែប៊ីបានឡើងជាប្រធានគណបក្សកុម្មុយនីស្តបានគិតទៅដល់វិសាលភាពនៃអំបូរជនជាតិស៊ែប៊ីដែលធ្លាប់មានឥទ្ធិពលគ្របដណ្តប់ទៅលើរដ្ឋស៊ែប៊ីខេត្តបូស្នី វ៉ូសវ៉ូឌីណា ក្រូអាស៊ី អ៊ែសេកូវីន និងម៉ាសេដ្វាន ។ នៅដើមឆ្នាំ 1989 កងទ័ពស៊ែប៊ីបានចូលលុកលុយលើអធិបតេយ្យភាពនៃរដ្ឋកូសូវ៉ូដែលប្រជាជនភាគច្រើនជាអំបូរអាល់បានីកាន់សាសនាអ៊ិស្លាម ។

ចំណែករដ្ឋស៊ែប៊ីវិញគិតថាគេមិនអាចឈរនៅស្ងៀមប្រសិនបើរដ្ឋក្នុងអតីតយូហ្គោស្លាវីត្រូវបែកបាក់ហើយបង្កើតជារដ្ឋឯករាជ្យ ។ គេបានកោះប្រជុំសភាកុម្មុយនីស្តលើកទី 14 ដែលមានសមាជិកនៃរដ្ឋទាំង 6 នៅក្នុងអតីតយូហ្គោស្លាវីមកប្រជុំក្រោមការគាបសង្កត់របស់មេដឹកនាំស៊ែប៊ីដើម្បីដោះស្រាយវិបត្តិនេះ ។ ស្លូបូដាន មេឡូសេវិចចង់បង្កើតសាធារណរដ្ឋឯករាជ្យរបស់ស្លូវេនី និងក្រូអាតត្រូវទទួលបរាជ័យ ។ អ្នកតំណាងនៃរដ្ឋទាំង 2 នេះបានដើរចេញពីសភា នៅទីបំផុតគណបក្សកុម្មុយនីស្តនៃអតីតយូហ្គោស្លាវីត្រូវរំសាយ ។ នៅពេលដែលស៊ែប៊ីបានប្រឹងប្រែងពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើរដ្ឋយូហ្គោស្លាវីដទៃទៀត ប្រទេសស្លូវេនី និងក្រូអាតក៏បានធ្វើឱ្យសម្រេចនូវឯកភាពរបស់ខ្លួនដែរនៅថ្ងៃ 25 ខែមិថុនា ឆ្នាំ 1991 ។

ពួកស៊ែប៊ីខិតខំពង្រីកឥទ្ធិពលរបស់ខ្លួនដើម្បីស្តារវិសាលភាពនៃអតីតយូហ្គោស្លាវីឡើងវិញស្របពេលជំនោរនៃលទ្ធិប្រជាធិបតេយ្យបានបោកបក់យ៉ាងខ្លាំងទៅលើស្ថាប័នកុម្មុយនីស្តនៅអឺរ៉ុបខាងកើត ។ រដ្ឋ 2 គឺក្រូអាស៊ីនិងស្លូវេនីបានបោះឆ្នោត ហើយបង្កើតរដ្ឋធម្មនុញ្ញដែលដឹកនាំដោយរដ្ឋាភិបាលពហុបក្ស ហើយធ្វើឱ្យគណបក្សកុម្មុយនីស្តលុបបំបាត់ដោយស្វ័យប្រវត្តិ និងគ្មានការបង្ហូរឈាម ហើយរដ្ឋទាំង 2 នេះក្លាយជារដ្ឋឯករាជ្យនៅលើទឹកដីយូហ្គោស្លាវីដែលកំពុងមានភាពរំជើបរំជួល ។ មេដឹកនាំពួកស៊ែប៊ីមេឡូសេវិចមិនសប្បាយចិត្តនឹងរដ្ឋប្រជាធិបតេយ្យទាំង 2 បានរឹតបន្តឹងតាមផ្លូវសេដ្ឋកិច្ចដូចជាដំឡើងពន្ធគយទៅលើផលិតផលនាំចូលពីសាធារណរដ្ឋទាំង 2 ជាដើម ។ ប្រទេសស៊ែប៊ី និង

ម៉ុងតេណេហ្គ្រោបានបង្កើតជារដ្ឋស្ថិតក្នុងប្រទេសយូហ្គោស្លាវីជាមួយគ្នាដើម្បីប្រឈមមុខនិងរដ្ឋឯករាជ្យទាំង 2 ប៉ុន្តែពួកជនជាតិភាគតិចស៊ែប៊ីរស់នៅក្នុងក្រូអាស៊ីបានប្រឆាំងនិងអធិបតេយ្យនៃរដ្ឋនេះបង្កើតជាកម្លាំងប្រឆាំង ពីព្រោះរដ្ឋធម្មនុញ្ញនៃប្រទេសនេះបានកាត់បន្ថយសិទ្ធិរបស់ជនជាតិស៊ែប៊ី ។ នៅខែសីហា ឆ្នាំ 1990 គេបានដាក់ពង្រាយកងប៉ូលិសនៅតំបន់ក្រាស៊ីណា(Krajina) ដែលមានជនជាតិស៊ែប៊ីរស់នៅ ។

ការបើបតស៊ូរវាងអំបូរស៊ែប៊ីនៅក្រាស៊ីណា ទល់និងប៉ូលិសក្រូអាស៊ីជាហេតុនាំឱ្យអតីតយូហ្គោស្លាវីក្លាយជាភ្នក់ភ្លើងសង្គ្រាម ។ បញ្ហាមួយទៀតគឺការដាក់ពង្រាយកងប៉ូលិសស្លូវេនីនៅតាមព្រំប្រទល់ស៊ែប៊ីជំនួសប៉ូលិសអតីតយូហ្គោស្លាវីបានបង្កឱ្យមានការបង្ហូរឈាមដីខ្លីមួយទៀតជាមួយពួកស៊ែប៊ី ។ នៅខែសីហា ឆ្នាំ 1991 កងទ័ពយូហ្គោស្លាវីដែលភាគច្រើនជាជនជាតិស៊ែប៊ី និងម៉ុងតេណេហ្គ្រោបានលុកលុយចូលប្រទេសក្រូអាស៊ីដែលគ្មានកងទ័ពការពារ មានតែកងប៉ូលិស ។



*ទាហានស៊ែប៊ីចូលលុកលុយទីក្រុងវូកូវ៉ា ( VUKOVAR )*

កងទ័ពយូហ្គោស្លាវីមានប្រៀបទាំងចំនួនមនុស្ស និងអាវុធគឺពលទាហានចំនួន 30 000 នាក់និងរទេះតង់ 3 000 គ្រឿង ហើយបានបំបាក់កងទ័ពក្រូអាស៊ីឱ្យនៅក្រៅរង្វង់ប្រយុទ្ធ មិនតែប៉ុណ្ណោះកងទ័ពយូហ្គោស្លាវីថែមទាំងប្រើទ័ពជើងអាកាសទម្លាក់គ្រាប់បែកទៅលើក្រុងហ្សាគ្រឹប(Zagreb) ទៀតផង ។ ប្រទេសក្រូអាស៊ីរងនូវវិនាសកម្មយ៉ាងធំធេង ពិសេសនៅទីក្រុងវូកូវ៉ា(Vukovar) ដោយកងទ័ពយូហ្គោស្លាវីបានគ្រប់គ្រងទឹកដីក្រូអាស៊ី 30% ។ ដោយមិនអាចទប់ទល់បានតទៅទៀត រដ្ឋាភិបាលក្រូអាស៊ីបានចុះសន្ធិសញ្ញាបញ្ចប់សង្គ្រាមជាមួយពួកស៊ែប៊ី ។

នៅពេលកាន់កាប់ប្រទេសនេះ ពួកស៊ែប៊ីបានធ្វើការរើសអើងពូជសាសន៍ដោយបណ្តេញពួកក្រូអាតយកផ្ទះឱ្យអំបូរជនជាតិស៊ែប៊ីរស់នៅ ។ គេឃើញពួកក្រូអាស៊ីមករស់នៅកណ្តាលវាលតាមឆ្នេរសមុទ្រចាល់ទិករាប់ពាន់គ្រួសារ ។

នៅខែកញ្ញា ឆ្នាំ 1991 សាធារណរដ្ឋម៉ាសេដ្វានបានប្រកាសឯករាជ្យដោយពុំមានការបង្ហូរឈាម ឬការប្រឆាំងពីពួកស៊ែប៊ីឡើយ ។ ដើម្បីការពារសាធារណរដ្ឋក្មេងខ្ចីនេះ ក៏មានការដាក់ពង្រាយកងទ័ពសហរដ្ឋអាមេរិកចំនួន 500 នាក់ ក្រោមទង់ជាតិអង្គការសហប្រជាជាតិជាអ្នកថែរក្សាសន្តិភាពនៅតាមបណ្តោយព្រំដែនប៉ែកខាងជើងជាមួយសាធារណរដ្ឋស៊ែប៊ី (យូហ្គោស្លាវី) ។ ប្រធានាធិបតីដំបូងគឺលោកគីរ៉ូគ្លីកូរ៉ូវ( KIRO GLIGOROV ) បានរក្សាចំណងទាក់ទងល្អជាមួយស៊ែប៊ី និង-សាធារណរដ្ឋផ្សេងទៀតដែលនៅជិតខាងគ្នា ។

នៅទសវត្សរ៍ឆ្នាំ 1990 ខេត្ត កូសូវ៉ូ ជាខេត្តស្វយ័តនៅក្នុងប្រទេសស៊ែប៊ីបានប្រឹងប្រែងតស៊ូបង្កើតខេត្តឯករាជ្យមួយ ។ លុះដល់ឆ្នាំ 1996 ជនជាតិអំបូរអាល់បានីភាគតិចកាន់សាសនាអ៊ីស្លាមក្នុងខេត្តកូសូវ៉ូបានបង្កើតកងទ័ពរំដោះនៅពេលនោះកងទ័ពយូហ្គោស្លាវីបានប្រើវិធានការក្តៅមកលើអំបូរអាល់បានី បង្កការភ័យខ្លាចដល់ជនស៊ីវិលនាំគ្នាភៀសខ្លួនចេញពីលំនៅឋាន ។ ក្រោយពីការស្វះស្វែងរកសន្តិភាពដែលផ្តួចផ្តើមដោយអង្គការណាតូ និងស៊ែប៊ីនៅឆ្នាំ 1990 មិនបានសម្រេច អង្គការណាតូបានសម្រេចទម្លាក់គ្រាប់បែកចំនួន 2 ខែទៅលើប្រទេសស៊ែប៊ី និងម៉ុងតេណេហ្គ្រោបង្ខំឱ្យស៊ែប៊ីដកទ័ពចេញពីកូសូវ៉ូ ។ លុះដល់ឆ្នាំ 1999 ខេត្តកូសូវ៉ូទាំងមូលត្រូវដាក់ពង្រាយដោយកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ នៅឆ្នាំ 2008 កូសូវ៉ូត្រូវប្រកាសជារដ្ឋឯករាជ្យមួយដែលទទួលស្គាល់ដោយប្រទេសចំនួន 60 ប៉ុន្តែមិនទាន់បានចូលជាសមាជិកអង្គការសហប្រជាជាតិនៅឡើយ ។

## 5. សេចក្តីសន្និដ្ឋាន

ការដួលរលំនៃអតីតសហភាពសូវៀតធ្វើឱ្យប្រទេសដែលកាន់របបសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតបានបែកខ្ញែក ហើយបង្កើតជាប្រទេសកាន់របបនយោបាយតាមលទ្ធិប្រជាធិបតេយ្យនិងរបបសេដ្ឋកិច្ចទីផ្សារសេរីតាមបែបលោកខាងលិច ។ ឥទ្ធិពលនេះបានឆ្លងទៅដល់សាធារណរដ្ឋប្រជាមានិតយូហ្គោស្លាវីដែលជាប្រទេសបង្កើតឡើងដោយលោកទីតូនៅក្រោយសង្គ្រាមលោកលើកទី 2 ត្រូវបែកខ្ញែក ហើយបង្កើតជាសាធារណរដ្ឋឯករាជ្យទោះជាសហព័ន្ធយូហ្គោស្លាវីដែលដឹកនាំដោយប្រទេសស៊ែប៊ី និងម៉ុងតេណេហ្គ្រោទិតខំទប់ស្កាត់យ៉ាងណាក៏ដោយ ។ នៅទីបំផុតរដ្ឋសមាជិកទាំងនោះត្រូវបានដាក់ចូលទៅក្នុងសហគមន៍អឺរ៉ុបជាបន្តបន្ទាប់ដើម្បីបញ្ចៀសសង្គ្រាមនៅពេលអនាគតដែលនឹងធ្វើឱ្យអន្តរាយទ្វីបអឺរ៉ុបដោយសារសង្គ្រាមឧបទ្វីបបាល់កង់សាជាថ្មីទៀត ។

ម្យ៉ាងទៀត នៅក្រោយសង្គ្រាមលោកលើកទី 2 ពួកមេដឹកនាំផ្តាច់ការដូចជារបបណាស៊ីអាល្លឺម៉ង់ និងជប៉ុនដែលប្រព្រឹត្តអំពើកាប់សម្លាប់ប្រជាជនស៊ីវិលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម និងប្រឆាំងមនុស្សជាតិបានបញ្ចប់ដោយសាលក្រមតុលាការអន្តរជាតិ ។ ច្បាប់អន្តរជាតិនៅតែមានសុពលភាពជារៀងរហូតមកដល់សព្វថ្ងៃ សូម្បីតែមេដឹកនាំស៊ែប៊ី ស្លូបូដាន មេឡូសេវិចក៏ត្រូវកាត់ទោសនៅតុលាការអន្តរជាតិក្រុងឡាអេដែរ ។ ថ្មីៗនេះនៅប្រទេសកម្ពុជាតុលាការកូនកាត់មួយបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងកម្ពុជាកំពុងធ្វើការកាត់ទោសមេដឹកនាំក្នុងរបបខ្មែរក្រហមមួយចំនួនដែលជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## ? សំណួរ

1. ចូរបង្ហាញពីមូលហេតុដែលនាំឱ្យកើតរដ្ឋស្លាវខាងត្បូង ។
2. តើក្នុងសហព័ន្ធយូហ្គោស្លាវីមានរដ្ឋជាសមាជិកចំនួនប៉ុន្មាន ? អ្វីខ្លះ ?
3. តើមូលហេតុអ្វីបានជារដ្ឋទាំងនោះរួបរួមគ្នា? ហេតុអ្វីបានជាបែកបាក់គ្នាទៅវិញ ?
4. តើសេដ្ឋកិច្ចយូហ្គោស្លាវីមានគម្រោងអ្វីខ្លះ ?
5. ហេតុអ្វីបានជាប្រទេសយូហ្គោស្លាវីជួបប្រទះវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ?

មេរៀនទី

# 11 បញ្ហាទូទៅក្នុងពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- ស្គាល់បម្រែបម្រួលនយោបាយសង្គម និងសេដ្ឋកិច្ចជាសកល ។
- យល់ដឹងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ។
- ទទួលយកបទពិសោធល្អៗពីប្រទេសអភិវឌ្ឍដើម្បីជួយដល់ប្រទេសខ្លួន ។

អស់រយៈកាលដ៏យូរមកហើយដែលគេតែងតែគិតថា បញ្ហាសង្គ្រាម និងសន្តិភាពជាបញ្ហាដ៏ស្រួចស្រាល់ប្រឈមនឹងការរស់នៅដោយសុខក្សេមក្សាន្តរបស់ប្រជាជនលើសកលលោក ។ មកដល់ទសវត្សរ៍ឆ្នាំ 80 នៃសតវត្សទី 20 គេបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារបញ្ហារួមលើសកលលោកបានលេចឡើងជាច្រើនទៀត ដែលគំរាមកំហែងដល់ការរស់នៅរបស់ប្រជាជនលើសកលលោកទាំងមូល ។ បញ្ហាទាំងនោះមានដូចជា បញ្ហាបរិស្ថាន បញ្ហាកំណើនប្រជាជន បញ្ហាជនអន្តោប្រវេសន៍ បញ្ហាសន្តិសុខស្បៀង បញ្ហាភេរវកម្មអន្តរជាតិ ។ល ។

## 1. បញ្ហាបរិស្ថាន

រយៈពេលកន្លងទៅជាច្រើនសតវត្សមកហើយ មនុស្សលោកចិញ្ចឹមជីវិតដោយសារការទទួលបានភោគផលពីធម្មជាតិ ប៉ុន្តែគេពុំបានគិតអំពីផលលំបាកនៅពេលដែលសម្បត្តិដ៏ស្តុកស្តម្ភនេះត្រូវបាត់បង់នោះឡើយ ។ ទីបំផុតបញ្ហានេះបានក្លាយជាបញ្ហាមួយដ៏ស្រួចស្រាល់គំរាមកំហែងដល់ជីវិតសត្វលោកទាំងមូល នេះបណ្តាលមកពី "មហន្តរាយបរិស្ថាន" ។ រឹតតែស្មុគស្មាញថែមទៀត ធម្មជាតិខ្លួនឯងមិនអាចនឹងស្តារឡើងវិញនូវអ្វីដែលបានបាត់បង់ទៅហើយនោះទេ ។



គ្រោះទឹកជំនន់ប្រទេសបាគីស្ថាន (ខែកញ្ញា ឆ្នាំ 2010)

គ្រោះធម្មជាតិបណ្តាលមកពីការខូចខាតធម្មជាតិដែលពីមុនមកគេសឹងតែមិនដែលឃើញមានទេ ដូចជា ការរញ្ជួយផែនដី កំណើនកម្តៅផែនដី ទឹកជំនន់ ភាពរាំងស្ងួត ។ល។ បាតុភូតបែបនេះលេចឡើងដោយសារកម្លាំងធម្មជាតិ និងសកម្មភាពរបស់មនុស្សដែលធ្វើឱ្យខូចខាតដល់ធម្មជាតិ ។ ជាការពិតណាស់ កំណើនមនុស្សកាន់តែច្រើន សេចក្តីត្រូវការសម្ភារៈក៏កាន់តែច្រើនផងដែរ ដូច្នេះដើម្បីបម្រើសេចក្តីត្រូវការរបស់ខ្លួន មនុស្សត្រូវការកែច្នៃទាញយកប្រយោជន៍ពីប្រភពធម្មជាតិកាន់តែខ្លាំង ប៉ុន្តែទំហំនៃលទ្ធភាពធម្មជាតិមានកម្រិត ។

ការធ្លាក់ចុះនៃបរិស្ថានធម្មជាតិទាក់ទងយ៉ាងស្អិតរមួតទៅនឹងធាតុសំខាន់មួយចំនួនគឺ បរិយាកាស និងអាកាសធាតុ ធនធានទឹក និងមហាសមុទ្រ ដី ស្រទាប់ផែនដី(សម្រាប់ដំណាំនិងព្រៃឈើ) រុក្ខជាតិ និងសត្វ ។

សារធាតុបំពុលអាកាសដែលកកើតឡើងដោយសារកាកសំណល់ពីរោងចក្រ និងផ្សែងយានយន្ត មានឥទ្ធិពលទៅលើបរិស្ថាន និងមានគ្រោះថ្នាក់បំផុត ។ គេបានរកឃើញសារធាតុពុលជាង 200 មុខក្នុងតំបន់ឧស្សាហកម្មស្លដែក ចម្រាញ់ប្រេងកាត ផលិតកម្មគីមី រោងចក្រផលិតជី ។ សារធាតុពុលមានកម្រិតគ្រោះថ្នាក់កាន់តែខ្ពស់ថែមទៀតនៅក្នុងតំបន់ឧស្សាហកម្មថាមពលបរមាណូ ។ សារធាតុពុលទាំងអស់នេះអាចនាំគ្រោះថ្នាក់មិនត្រឹមតែទៅលើសុខភាព និងជីវិតមនុស្សប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យខាតបង់ដល់រុក្ខជាតិ ជីវិតសព្វសត្វក្នុងតំបន់ទាំងមូល ។ ឥទ្ធិពលនៃភាពកខ្វក់នៅក្នុងបរិយាកាសពុំមានព្រំដែនឡើយ ។

គ្រោះថ្នាក់មួយទៀតកើតឡើងដោយសារការបាត់បង់ស្រទាប់អូសូននៅក្នុងបរិយាកាសដែលបណ្តាលមកពីសារធាតុពុលពីកាកសំណល់រោងចក្រ ។ នៅឆ្នាំ 1986 បានលេចឡើងនូវ "ការធ្លុះស្រទាប់អូសូន" នៅតំបន់អង់តាក់ទិក ហើយរំលងបាន 10ឆ្នាំមកនៅតំបន់យ៉ាគុត(រុស្ស៊ី) មានលេចឡើងនូវបាតុភូតមួយដែលអាចសន្មតថាជាការធ្លុះស្រទាប់អូសូន ។ ស្រទាប់អូសូនកាន់តែស្តើងទៅៗនៅតំបន់ប៉ូលខាងជើង និងប៉ូលខាងត្បូងអាចធ្វើឱ្យសីតុណ្ហភាពផែនដីកើនឡើងដែលបង្កគ្រោះថ្នាក់បំផុតដល់ភាវៈរស់នៅលើផែនដី ដោយកាំរស្មីស្វាយអ៊ុលត្រារបស់ព្រះអាទិត្យ ។ សារធាតុបំពុលបរិយាកាសគឺអាចនាំឱ្យមានកង្វក់អាកាស ភ្លៀងអាស៊ីតបំពុលរុក្ខជាតិ និងជីវិតសត្វលោកផងដែរ ។

ក្រៅពីអ្វីដែលបានរៀបរាប់ខាងលើ សារធាតុបំពុលដែលចេញពីរោងចក្រនាំឱ្យបរិយាកាសកខ្វក់ ។ បច្ចុប្បន្ន គេសង្កេតឃើញមានសារធាតុបំពុលកើនដោយសារទង្វើរបស់មនុស្សដូចជា កាបូនឌីអុកស៊ីត ($CO_2$) កើតពីការដុតព្រៃ សារធាតុក្លរ៉ូភ្លុយអរ៉ូកាបូន (*CFCS*) កើតពីហ្គាសទូទឹកកក ម៉ាស៊ីនត្រជាក់រថយន្តជាដើម ។

បញ្ហាកង្វះទឹកស្អាតបានក្លាយជាបញ្ហាចោទយ៉ាងធ្ងន់ធ្ងរនៅពេលបច្ចុប្បន្ន ។ គេសង្កេតឃើញទឹកទន្លេស្រកចុះ បឹង និងទឹកស្ទឹងមួយចំនួនចាប់ផ្តើមរីងស្ងួត ។ សេចក្តីត្រូវការទឹកកាន់តែកើនឡើង ប៉ុន្តែប្រភពទឹកកាន់តែថយចុះ ។ ដោយសារសេចក្តីត្រូវការលើវិស័យកសិកម្ម គេបានបូមទឹកស្រោចស្រពអស់យ៉ាងច្រើនបណ្តាលឱ្យបឹង ស្ទឹង ទន្លេតូចៗរីងស្ងួតហួតហែង ។ សព្វថ្ងៃនេះ មានប្រទេសចំនួនជាង 80ដែលមានប្រជាជន 40% នៃប្រជាជនពិភពលោកពុំមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ ។

ការចោលសំរាមជាកាកសំណល់ពីរោងចក្របានធ្វើឱ្យខូចបរិស្ថានទាំងនៅក្នុងទឹក និងលើគោកដែលជាស្រទាប់ដីដាំដំណាំ ។ មហាសមុទ្របានក្លាយជាអាងស្តុកជាតិពុលដែលជាសារធាតុគីមីវិទ្យុសកម្មបន្សល់ពីការសាកល្បងអាវុធបរមាណូនៃប្រទេសអភិវឌ្ឍ ។ ជាពិសេស តាមឆ្នេរសមុទ្រកាកសំណល់ពីការធ្លាយប្រេងពីនាវាដឹកប្រេងដែលក្នុងមួយឆ្នាំៗមិនតិចជាង 1.5លានតោនឡើយ ។ គេពុំទាន់បានសិក្សាលើមហន្តរាយដោយសារបញ្ហានេះឱ្យបានដិតដល់នៅឡើយទេ ។

បញ្ហាដ៏គួរឱ្យព្រួយបារម្ភបំផុតនាពេលបច្ចុប្បន្ននេះ គឺការរេចរិលស្រទាប់ដីដាំដំណាំ ។ គ្រាន់តែរយៈពេល 3ទសវត្សរ៍ចុងក្រោយនេះ ដីដាំដំណាំ ដីព្រៃឈើប្រែក្លាយជាវាលល្ហល្ហេវគ្មានដំណាំ គ្មានព្រៃឈើ ខ្សោះប្រើការវែងកើតបានកើនឡើង 30ដង ។ នេះជាគ្រោះអាសន្នមួយយ៉ាងធំដែលគេឱ្យឈ្មោះថា "គ្រោះអាសន្នផែនដី" នេះគេមិនបានរាប់បញ្ចូលក្នុងខណៈដែលមានសង្គ្រាមបរមាណូផ្ទុះឡើងផងទេ ។

ប្រភពពីរយ៉ាងដ៏សំខាន់ដែលនាំឱ្យខូចស្រទាប់ផែនដី(នេះបើយើងមិននិយាយអំពីឥទ្ធិពលនៃបរិយាកាស) គឺការប្រើជីសរីរាង្គ និងថ្នាំពុលក្នុងការដាំដំណាំ និងប្រភពមួយទៀតដ៏សំខាន់គឺការកាប់ទន្ទ្រានព្រៃឈើ ។ ព្រៃឈើមិនត្រឹមតែជាប្រភពស្រូបយក និងស្តុក $CO_2$ ដ៏សំខាន់ប៉ុណ្ណោះទេ វាក៏ជាប្រភពសម្របសម្រួលឱ្យមានលំនឹងអាកាសធាតុដ៏ល្អប្រសើរ ថែរក្សាអាកាសធាតុមិនឱ្យក្តៅពេក មិនឱ្យត្រជាក់ពេក ។ ក្រៅពីនេះព្រៃឈើជាប្រភពផ្តល់ឱ្យមនុស្សលោកនូវវត្ថុធាតុដើមជាច្រើនដូចជាថ្នាំសង្កូវ រុក្ខផល ក្តារ ជម្រកសត្វ ។ល ។ ផលិតផលដែលបានមកពីប្រភពព្រៃឈើជាទំនិញដ៏ប្រសើរបំផុតនៅលើទីផ្សារអន្តរជាតិ ។ មួយសតវត្សចុងក្រោយនៅលើភពផែនដីបានបាត់បង់ព្រៃឈើអស់ $\frac{1}{3}$ ។ ក្នុងចំណោមនេះនៅក្នុងទ្វីបអាហ្វ្រិកអស់ជាងពាក់កណ្តាល ទ្វីបអាស៊ីអស់ $\frac{2}{3}$ អាមេរិកឡាទីនអស់ $\frac{1}{3}$ ធៀបទៅនឹងព្រៃឈើដែលធ្លាប់មាន ។ ក្រៅពីការកាប់យកឈើបែបអនាធិបតេយ្យ ព្រៃឈើត្រូវបាត់បង់ដោយការកាប់ធ្វើអុស (នៅក្នុងប្រទេសអន់ថយ) ។ ដោយសារការកាប់បំផ្លាញព្រៃឈើត្រូវខូចខាតជារៀងរាល់ឆ្នាំមិនតិចជាង 10លានហិចតានោះទេ ។

ការបាត់បង់ព្រៃឈើបានធ្វើឱ្យបាត់បង់ជីវៈចម្រុះនៅលើដី ។ នេះជាឥទ្ធិពលមួយយ៉ាងអាក្រក់ប៉ះពាល់ទៅដល់ការរស់រានមានជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិទាំងអស់ក្នុងធម្មជាតិទាំងមូល ។ គ្រាន់តែមួយសតវត្សចុងក្រោយ សត្វព្រៃបានបាត់បង់ និងផុតពូជអស់ជាង 1 លានប្រភេទ រុក្ខជាតិអស់ជាង25 ពាន់ប្រភេទ ។ មិនត្រឹមតែប៉ុណ្ណោះ ពូជសត្វស្រុករាប់រយប្រភេទ ក៏ត្រូវបានបាត់បង់ផងដែរ ។ ការបាត់បង់ជីវៈចម្រុះនឹងក្លាយទៅជាមហន្តរាយមួយយ៉ាងធំសម្រាប់មនុស្សជាតិទាំងមូល ។ ការវាយតម្លៃរបស់អ្នកឯកទេសបានឱ្យដឹងថាដល់ឆ្នាំ 2018 ជីវៈចម្រុះនឹងត្រូវបាត់បង់ពី 10-15% ថែមទៀត ។ នេះជាបញ្ហាដ៏លំបាកដែលត្រូវទាមទារឱ្យមានការចូលរួមដោះស្រាយទាំងអស់គ្នា គឺរិះរកវិធីយ៉ាងណាដើម្បីកែប្រែឥរិយាបថមនុស្សក្នុងទំនាក់ទំនងរបស់ពួកគេជាមួយធម្មជាតិ ។

## 2. បញ្ហាកំណើនប្រជាជន និងបញ្ហាជនអន្តោប្រវេសន៍

កំណើនប្រជាជនបានក្លាយជាបញ្ហារួមមួយយ៉ាងស្រួចស្រាល់ នៅក្នុងដំណាក់កាលចុងសតវត្សទី 20 និងបន្តរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ។ នៅចុងសតវត្សទី 20 ប្រជាជនពិភពលោកបានកើនឡើងរហូតដល់ទៅ 6 ពាន់លាននាក់ ។ កំណើនប្រជាជនបានលេចឡើងនូវបញ្ហាស្មុគស្មាញជាច្រើនដូចជា បញ្ហាឧបត្ថម្ភថាមពល សុវត្ថិភាពស្បៀងអាហារ បញ្ហាជនអន្តោប្រវេសន៍ ។ល ។

បញ្ហាកំណើនប្រជាជនរឹតតែក្លាយជាបញ្ហាកាន់តែស្រួចស្រាល់ថែមទៀតនៅប្រទេសដែលមានកំណើនប្រជាជនខ្លាំង (ភាគច្រើនជាប្រទេសអន់ថយដែលទើបតែចប់សង្គ្រាម ឬទើបទទួលបានឯករាជ្យ) ។ ក្នុងស្ថានភាពបែបនេះ បញ្ហាកំណើនប្រជាជននៅក្នុងប្រទេសអន់ថយអាចបង្កើតជាបញ្ហាស្មុគស្មាញ និងពិបាកកំណត់ជាច្រើនទៀត ។ នៅក្នុងបណ្តាប្រទេសជឿនលឿនមានប្រជាជនរស់នៅប្រមាណ $\frac{1}{7}$ នៃប្រជាជនពិភពលោក ប៉ុន្តែផលិតផលសរុបស្មើនឹង $\frac{1}{5}$ នៃផលិតផលសរុបពិភពលោក បានន័យថាមាន 20ដងលើសប្រទេសតតិយលោក ។ ប្រទេសជឿនលឿនទាំងនេះមានលទ្ធភាពដោះស្រាយបញ្ហាសុខាភិបាល សិក្សាធិការ ការថែទាំបរិស្ថានធម្មជាតិបានល្អ ដែលជាកត្តាមួយអាចធ្វើឱ្យប្រជាជនមានអាយុវែងជាងប្រជាជននៃបណ្តាប្រទេសតតិយលោក ។

ទោះបីសព្វថ្ងៃមានប្រទេសអន់ថយមួយចំនួនបានក្លាយទៅជាប្រទេសកំពុងអភិវឌ្ឍ ឬក៏ក្លាយទៅជាប្រទេសដែលមានចំណាត់ថ្នាក់ក្នុងក្រុមនៃប្រទេសជឿនលឿនក៏ដោយ ក៏គម្លាតរវាងបណ្តាប្រទេសឧស្សាហកម្មជឿនលឿននិងបណ្តាប្រទេសកំពុងអភិវឌ្ឍនៅតែមានកម្រិតខុសឆ្ងាយពីគ្នា ដោយសារតែបម្រែបម្រួលនៃកំណើនប្រជាជន ។ ក្នុងស្ថានភាពបែបនេះ បំលាស់ប្តូរទីលំនៅរបស់ប្រជាជនបានក្លាយជាបញ្ហាដ៏ស្រួចស្រាល់ទន្ទឹមនឹងបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ការជួញដូរមនុស្ស គ្រឿងញៀន ការរំលោភលើពលកម្មកុមារ ។ល។ បញ្ហាទាំងនេះជាវិបត្តិរួម ហើយត្រូវដោះស្រាយទាំងអស់គ្នា។ ហេតុដូច្នេះទើបមានសំណួរដែលមិនអាចរកចម្លើយបានគឺ តើនៅពេលណាទើបគេអាចបញ្ចប់គម្លាតរវាងប្រទេសឧស្សាហកម្មជឿនលឿន និងប្រទេសតតិយលោកបាន ? ក្នុងខណៈនេះតើគេគួរជួយកសាងសេដ្ឋកិច្ចប្រទេសអន់ថយដើម្បីកាត់បន្ថយបញ្ហាជនអន្តោប្រវេសន៍ ឬមួយក៏គេបន្តធ្វើការកេងប្រវ័ញ្ចលើតម្លៃពលកម្មទាបរបស់ជនអន្តោប្រវេសន៍តទៅទៀត ?

## ១. បញ្ហាសន្តិសុខស្បៀង

កង្វះគ្រឿងឧបភោគបរិភោគ ជាញឹកញាប់បាននាំមកនូវគ្រោះទុរ្ភិក្សដល់ប្រជាជនរាប់លាននាក់លើពិភពលោក ។ តាមធម្មតា ផលិតកម្មម្ហូបអាហារមិនអាចបំពេញសេចក្តីត្រូវការរបស់មនុស្សដែលមានកំណើនយ៉ាងខ្ពស់លើពិភពលោកបានទេ ។ កន្លងមកគេធ្លាប់បានកាត់បន្ថយកង្វះស្បៀងខ្លះនាពាក់កណ្តាលទសវត្សរ៍ឆ្នាំ 70 នៃសតវត្សទី 20 ។ នេះជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រនៃយន្តការដំណោះស្រាយផលិតកម្មគ្រឿងបរិភោគ ជាពិសេសផលិតផលធញ្ញជាតិដែលមានទំហំធំធេងជាងកំណើនប្រជាជនពិភពលោក ។ នៅលើវិស័យកសិកម្មគេបានប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗក្នុងការ

រៀបចំដី ជ្រើសរើសពូជ ការបង្កើតប្រព័ន្ធស្រោចស្រពធំៗ និងការប្រើប្រាស់ឱ្យអស់លទ្ធភាពដី ។ ម្យ៉ាងទៀតគេបានបង្កើតឧបករណ៍នេសាទធំៗ មានលទ្ធភាពពង្រីកផលិតផលនេសាទសមុទ្រ ដើម្បីជួយកាត់បន្ថយបញ្ហាកង្វះម្ហូបអាហារ ។

ទោះជាយ៉ាងណាក៏ដោយក្នុងពេលបច្ចុប្បន្ន ប្រជាជនចំនួន 840 លាននាក់នៅតែប្រឈមនិងគ្រោះទុរ្ភិក្សនៅឡើយ ។ គេនៅតែឃើញមានវិសមាមាត្រយ៉ាងខ្លាំងនៅក្នុងកម្រិតនៃការប្រើប្រាស់គ្រឿងបរិភោគនៅក្នុងបណ្ដាប្រទេសជឿនលឿន និងបណ្ដាប្រទេសអន់ថយ ។ ចំពោះទ្វីបអាហ្វ្រិកភាពក្រីក្រនៅតែជាបញ្ហាចោទ ហើយប្រជាជនជួបប្រទះនឹងបញ្ហាទុរ្ភិក្សខ្លាំងជាងគេ ។

ចាប់ពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 80 ដើមទសវត្សរ៍ឆ្នាំ 90 ដំណើរអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារលើពិភពលោកជាបញ្ហាសំខាន់ដែលគំរាមកំហែងដល់សន្តិសុខស្បៀង និងកង្វះខាតអាហារ ។

នៅលើពិភពលោកជាលើកទីមួយហើយដែលផលិតផលស្បៀងចាប់ផ្ដើមស្រុតចុះយ៉ាងលឿន ទោះបីជាតម្រូវការទីផ្សារនៅមានទំហំធំក៏ដោយ ។ នៅដំណាក់កាលចុងក្រោយ ទន្ទឹមនឹងកំណើនប្រជាជនពិភពលោក របកគំហើញបច្ចេកវិជ្ជា និងធនធានធម្មជាតិថ្មីៗអាចជួយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅក្នុងបណ្ដាប្រទេសតតិយលោក ជាពិសេសនៅក្នុងទ្វីបអាស៊ីដែលកំពុងមានការរីកចម្រើនលើវិស័យឧស្សាហកម្ម ។ បច្ចុប្បន្នប្រទេសអាស៊ីជាច្រើន(ជាពិសេសប្រទេសចិន)កំពុងតែជួបនឹងកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា (នៅអាស៊ីមានប្រជាជនរស់នៅ 3 500 លាននាក់គឺ ជាងពាក់កណ្ដាលប្រជាជនពិភពលោក)។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃសេចក្ដីត្រូវការគ្រឿងបរិភោគគេ ទាមទារឱ្យមានរចនាសម្ព័ន្ធផលិតកម្មឱ្យកាន់តែប្រសើរឡើង ឱ្យមានការពង្រីកផលិតកម្មចិញ្ចឹមសត្វដើម្បីបង្កើនការផ្គត់ផ្គង់ សាច់ ទឹកដោះគោ ស៊ុត... និងផលិតផលសមុទ្រជាដើម ។ តាមការទស្សន៍ទាយថានៅឆ្នាំ 2030 ប្រសិនបើតម្រូវការស្បៀងអាហារមានកម្រិតកាន់តែខ្ពស់ នោះនឹងនាំឱ្យមានកង្វះខាតគ្រឿងឧបភោគកាន់តែខ្លាំង ។ សេចក្ដីត្រូវការធញ្ញជាតិទាមទារឱ្យធ្វើការនាំចូលកើនឡើងបីដងលើសពីមុន ។

កង្វះគ្រឿងបរិភោគធ្វើឱ្យតម្លៃរបស់វាកាន់តែកើនឡើង ។ តាមការទស្សន៍ទាយរបស់រដ្ឋាភិបាលជប៉ុននៅឆ្នាំ 2010 តម្លៃស្រូវសាលី និងអង្ករនឹងកើនឡើងពីរដង ។ ជាគោលការណ៍ស្ថានភាពបែបនេះអាចទាក់ទាញអ្នកវិនិយោគនៅលើវិស័យកសិកម្មក្នុងការផលិត និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធផលិតដោយសង្កត់ធ្ងន់លើដំណាំស្បៀង ។ ក៏ប៉ុន្តែគេនៅតែមិនទាន់យកចិត្តទុកដាក់លើមធ្យោបាយនេះឱ្យបានទូលំទូលាយនៅឡើយទេ ។

ដោយសារតែ ៖

- ទីមួយគេមិនអនុញ្ញាតឱ្យធ្វើអាជីវកម្មស្រែចម្ការនៅលើផ្ទៃដីឱ្យលើសពី 15% នៃផ្ទៃដីទាំងអស់ ។
- ទីពីរគឺ បញ្ហាបាត់បង់ធនធានទឹកនៅក្នុងការស្រោចស្រពលើដីដាំដំណាំ ដែលបណ្ដាលឱ្យមានការអស់ទឹកពីទន្លេ ព្រែក បឹង ។ល ។
- ទីបីគឺ ដីឆាប់ខ្សោះដោយការប្រើជីគីមី ហើយទីបំផុតដីកសិកម្មទាំងនោះនឹងក្លាយទៅជាទីរហោស្ថាន និងត្រូវគេបោះបង់ចោល ។

ដោយសារកត្តាខាងលើ "បដិវត្តន៍បៃតង" លែងមានផលល្អដូចពេលមុនទៀតហើយ មិនត្រឹមតែប៉ុណ្ណោះ វានាំមកនូវចំណុចអវិជ្ជមានជាច្រើនថែមទៀតនៅក្នុងដំណើរការវិវត្តផលិតកម្មកសិកម្ម ។ ដូចគ្នានេះដែរការបង្កើតឧបករណ៍នេសាទធំៗនៅក្នុងសមុទ្រ និងមហាសមុទ្រពិតមែនតែបានលើកកម្ពស់កំណើនផលិតផលនេសាទ តែក៏ជាការគំរាមកំហែងដល់ការបាត់បង់ធនធានត្រីសមុទ្រផងដែរ ។

ជាលទ្ធផលការរីកចម្រើនបែបនេះនាំឱ្យស្ថានភាពឧបត្ថម្ភគ្រឿងបរិភោគធ្លាក់ចុះទៅវិញ ។ ជារៀងរាល់ឆ្នាំ ទិន្នផលស្រូវសាលីកាន់តែថយចុះ បើប្រៀបធៀបទិន្នផលឆ្នាំ 1990 ហើយការធ្លាក់ចុះមានចំនួនពីរដងបើប្រៀបធៀបទៅនឹងទិន្នផលឆ្នាំ 1950 ( 1.1 តោន / ហ. ត. ទល់នឹង 2.1 តោន / ហ. ត. ) ។ ការប្រមូលផលស្រូវសាលី ស្រូវ (ធញ្ញជាតិ) រហូតដល់ឆ្នាំ 1984 បានធ្លាក់ចុះ 9% ។ ការនេសាទត្រីសម្រាប់មនុស្សម្នាក់ពីឆ្នាំ (1950-1984) បានកើនឡើងចំនួនពីរដង ប៉ុន្តែលុះដល់ឆ្នាំ 1996 ត្រូវបានថយចុះចំនួន 9% ។ ផលិតផលស្រូវសាលី(ធញ្ញជាតិ) នៅក្នុងទសវត្សរ៍ឆ្នាំ 90 បានធ្លាក់ចុះដល់ចំណុចអប្បបរមា មិនអាចផ្គត់ផ្គង់ប្រជាជនឱ្យបានគ្រប់គ្រាន់ចំនួន 50 ថ្ងៃ ។ ក្នុងពេលនេះដែរ ថវិកាអន្តរជាតិសម្រាប់ផ្គត់ផ្គង់សេចក្ដីត្រូវការគ្រឿងបរិភោគបានធ្លាក់ចុះចំនួនពីរដង ។ តម្លៃស្រូវសាលីបានកើនឡើងពីរដងនៅលើទីផ្សារអន្តរជាតិក្នុងឆ្នាំ 1996 ។

តួលេខខាងលើគ្រាន់តែជាសូចនាករ (Indicator) សំខាន់ៗដែលជាទឡ្ហីករណ៍មួយបង្ហាញឱ្យឃើញនូវការគំរាមកំហែងដល់ស្ថិរភាពសង្គមនាចុងសតវត្សទី 20 ។

## 4. បញ្ហាសង្គ្រាម និងអស្ថិរភាពសន្តិសុខសង្គម

យើងបាននិយាយរួចមកហើយអំពីបញ្ហារួម ឬបញ្ហាសកលដែលបានកើតឡើងនៅក្នុងបរិបទនៃទំនាក់ទំនងសង្គមមនុស្សទៅនឹងធម្មជាតិនិងផលិតកម្ម ។ ប៉ុន្តែ នៅជុំវិញមនុស្សមិនមែនមានត្រឹមតែធម្មជាតិប៉ុណ្ណោះទេ តែគេក៏រាប់បញ្ចូលទាំងមធ្យោបាយដំណើរការវិវត្តសង្គមផងដែរ ។ ទៅលើបញ្ហានេះ រដ្ឋ និងសង្គមមានលទ្ធភាពការពារសន្តិសុខជូនប្រជាពលរដ្ឋបាន អាស្រ័យទៅលើសមត្ថភាព និងសកម្មភាពនៃជីវិតរបស់មនុស្សម្នាក់ៗប៉ុណ្ណោះ ។

នៅពាក់កណ្ដាលសតវត្សទី 20 ជាដំបូងគេឃើញថារដ្ឋ និងសង្គមហាក់ដូចជាគ្មានសមត្ថភាពបង្កើតប្រព័ន្ធសន្តិសុខណាមួយឱ្យមានប្រសិទ្ធភាពដើម្បីការពារសន្តិសុខមនុស្សជាតិបានទេ ។ ជាលទ្ធផល សង្គ្រាមលោកបានផ្ទុះឡើងរហូតដល់ទៅពីរលើក ។ លុះដល់ទសវត្សរ៍ឆ្នាំ 70 ឥទ្ធិពលអាវុធមហាប្រល័យត្រូវបានគេរារាំង ព្រោះជាការគំរាមកំហែងដល់សន្តិភាពពិភពលោក ។ ប៉ុន្តែអាវុធមហាប្រល័យជាច្រើនប្រភេទនៅមានអត្ថិភាពនៅឡើយដូចជា អាវុធណឺត្រុង អាវុធគីមី និងអាវុធជីវសាស្ត្រដែលមានលទ្ធភាពកម្ទេចភាវៈរស់ទាំងអស់នៅលើភពផែនដីយ៉ាងងាយ ។ ទន្ទឹមនឹងនេះ គេនៅតែបន្តផលិតអាវុធថ្មីៗកាន់តែទំនើបៗថែមទៀត ។ នេះជាបញ្ហាពិបាកដោះស្រាយមួយ ពីព្រោះក្នុងការផលិតអាវុធទាំងអស់នេះ គេបានចំណាយថវិកាផលិតមួយផ្នែកធំ ឯការថែរក្សាទុកដោយសុវត្ថិភាព និងការកម្ទេចវាចោលក៏ត្រូវចំណាយថវិកាយ៉ាងច្រើនដូចគ្នាដែរ ។

ក្នុងអំឡុងពេលក្រោយសង្គ្រាមត្រជាក់ យើងទាំងអស់គ្នាហាក់ដូចជាបានធូរស្រាលពីការប្រឈមមុខដាក់គ្នារវាងកំពូលមហាអំណាចមូលធននិយម និងកុម្មុយនីស្ត ។ ប៉ុន្តែបញ្ហាជម្រួចស្រាលថ្មីៗបានលេចឡើងនៅតាមតំបន់នានាដែលអាចឈានទៅដល់ការផ្ទុះឡើងនូវទំនាស់ដោយប្រើកម្លាំងយោធា ។

ស្ថិរភាពសន្តិសុខសង្គមទទួលការគំរាមកំហែងកាន់តែខ្លាំងឡើងៗដោយសារសកម្មភាពឧក្រិដ្ឋ ។ ចាប់ពីទសវត្សរ៍ឆ្នាំ 80មកសកម្មភាពឧក្រិដ្ឋបានកើតឡើងចំនួន 5% ជារៀងរាល់ឆ្នាំ ។ សកម្មភាពឧក្រិដ្ឋមិនត្រឹមតែបំផ្លិចបំផ្លាញដល់សម្ភារៈរបស់ប្រជាជនប៉ុណ្ណោះទេ តែវាបានធ្វើឱ្យប្រជាជនភ័យខ្លាចយ៉ាងខ្លាំងជាមួយនឹងការបាត់បង់ជីវិត ។ សព្វថ្ងៃយើងឃើញថាពួកឧក្រិដ្ឋជនភាគច្រើន សុទ្ធតែមានអង្គការចាត់តាំងច្បាស់លាស់ និងមានប្រព័ន្ធគ្រប់គ្រងយន្តការដឹកនាំម៉ឺងម៉ាត់ បំពាក់ទៅដោយអាវុធទំនើបៗមានប្រព័ន្ធការពារ និងការឱ្យសញ្ញាជាស្វ័យប្រវត្តិ ប្រព័ន្ធចាប់សំឡេង ទំនាក់ទំនងតាមវិទ្យុ ទូរទស្សន៍ កុំព្យូទ័រ ។ល ។ ក្នុងស្ថានភាពបែបនេះ ពួកឧក្រិដ្ឋជនអាចរៀបចំសកម្មភាពរបស់ខ្លួនទុកជាមុន ។ ពួកឧក្រិដ្ឋជនធ្វើសកម្មភាពដោយគ្មានព្រំដែនដែលគេឱ្យឈ្មោះថា "ភេរវកម្មអន្តរជាតិ" ។ មេដឹកនាំមហាអំណាចសេដ្ឋកិច្ចទាំង 7 ក្នុងឱកាសនៃកិច្ចប្រជុំនៅទីក្រុងឌេនវ័រនាថ្ងៃទី 22 ខែមិថុនា ឆ្នាំ 1997 បានទទួលស្គាល់ថា "ក្រុមភេរវករអន្តរជាតិ ជានិច្ចជាកាលបានផ្សារភ្ជាប់ទៅនឹងស្ថានភាពប្រែប្រួលនៃពិភពលោកបានលឿនជាងរដ្ឋាភិបាលទៅទៀត" ។

ដោយស្នាដៃភេរវករ ឥស្សរជនជាច្រើនបានបាត់បង់ជីវិតដូចជា លោក ចនកេណ្ណឺឌី លោក រ៉ូបឺត កេណ្ណឺឌី អ្នកស្រីឥន្ទ្រាគន្ធី លោក រ៉ាជីហ្វគន្ធី លោក ម៉ាទីនលូធ័រឃីង ។ល ។ ប្រជាជនស្លូតត្រង់រាប់ម៉ឺននាក់ក៏ត្រូវស្លាប់ដោយសារស្នាដៃភេរវករផងដែរ ។ នៅដើមសតវត្សទី 21 ភេរវករអន្តរជាតិ

បានធ្វើសកម្មភាពយ៉ាងធំធេងមួយដោយបើកយន្តហោះបំបុកបំផ្លាញមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិនៅទីក្រុងញូវយ៉ក ។ ក្នុងរយៈពេល 10ឆ្នាំ(1990-2000) ពួកភេរវករអន្តរជាតិបានធ្វើសកម្មភាពចំនួន 6 500លើកដែលក្នុងនោះបានសម្លាប់មនុស្សអស់ 5 000នាក់ និងរងរបួសពិការអស់ចំនួន 11 ពាន់នាក់ ។

ជានិច្ចជាកាលពួកភេរវករអន្តរជាតិក្រៅពីការធ្វើឱ្យផ្ទុះគ្រាប់បែកសម្លាប់ជីវិតមនុស្ស ពួកគេតែងតែធ្វើសកម្មភាពពាក់ព័ន្ធជាមួយនឹងការជួញដូរថ្នាំញៀន ជួញដូរមនុស្ស ធ្វើចរាចរណ៍លុយក្លែងក្លាយ ក្លែងឯកសារលុយពីធនាគារ ។ល ។

ដូច្នេះយើងឃើញថា ទោះបីសង្គ្រាមត្រជាក់បានបញ្ចប់ហើយក្តី ប៉ុន្តែបញ្ហាសង្គ្រាម និងអស្ថិរភាពសង្គមនៅតែជាបញ្ហាមួយយ៉ាងស្រួចស្រាល់ ហើយដើម្បីបញ្ចប់បញ្ហាកង្វល់ទាំងនេះយើងទាំងអស់គ្នាត្រូវរកគ្រប់មធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីបញ្ឈប់សកម្មភាពឃោរឃៅរបស់ពួកភេរវជនអន្តរជាតិគ្រប់រូបភាព បង្កើនសាមគ្គីភាព រឹតចំណងសហប្រតិបត្តិការអន្តរជាតិ ដើម្បីរក្សាសន្តិភាពលើពិភពលោក ។

## 5. មូលហេតុចម្បងនៃការលេចឡើងនូវបញ្ហារួមលើពិភពលោក

យើងបានបង្ហាញរួចមកហើយនូវបញ្ហារួមដែលគំរាមកំហែងដល់ការរស់នៅរបស់ប្រជាជនលើពិភពលោក ដែលក្នុងនោះយើងក៏បានបង្ហាញអំពីមូលហេតុមួយចំនួនរួចទៅហើយដែរ ។ ឥឡូវនេះយើងពិនិត្យមើលប្រភពបញ្ហាមួយចំនួនទៀតដើម្បីស្វែងយល់អំពីប្រភពបញ្ហារួមលើពិភពលោកឱ្យកាន់តែស៊ីជម្រៅថែមទៀត ។

- ប្រភពទី 1 : កំណើន និងទំហំសេដ្ឋកិច្ចពិភពលោកមិនស៊ីចង្វាក់ទៅនឹងលទ្ធភាពពិតប្រាកដដែលផ្តល់ពីធនធាននៅលើដី ។
- ប្រភពទី 2 : កើតចេញពីការរីកចម្រើននៃបដិវត្តន៍វិទ្យាសាស្ត្របច្ចេកទេស ។ ជោគជ័យនៃប្រវត្តិវិទ្យាសាស្ត្របច្ចេកទេសនាំមកនូវផលវិជ្ជមាន និងអវិជ្ជមានព្រមគ្នាក្នុងពេលតែមួយ ។ គេអាចផលិតរថយន្ត នាវាធំៗកាន់តែច្រើន ប៉ុន្តែកាកសំណល់ពីយានយន្តទាំងនេះបានបំផ្លាញបរិយាកាសយ៉ាងខ្លាំង ជាពិសេស ចំពោះម៉ាស៊ីនប្រើថាមពលអាតូមិកដែលមិនត្រឹមតែជាម៉ាស៊ីនមានកម្លាំងខ្លាំងសម្រាប់សម្រួលការងារសង្គមមនុស្សប៉ុណ្ណោះទេ តែកាកសំណល់របស់ម៉ាស៊ីននេះធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស បរិស្ថាន ហើយទីបំផុតក្លាយជាក្តីព្រួយបារម្ភដល់សុវត្ថិភាព និងជាហានិភ័យចំពោះសង្គមមនុស្សទាំងមូល ។

- ប្រភពទី 3 ៖ កំណើនប្រជាជនទាមទារឱ្យមានការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគកាន់តែច្រើន ដោយប្រើប្រាស់ធម្មជាតិដែលចេះតែរេចរិលទៅៗ ។ សព្វថ្ងៃប្រជាជនរាប់ពាន់នាក់ទទួលការគំរាមកំហែងដោយគ្រោះទុរ្ភិក្ស 1 200 លាននាក់ជាអនក្ខរជន 1 600 លាននាក់ពុំមានទឹកស្អាតប្រើ 2 000 លាននាក់គ្មានអគ្គិសនីប្រើ ។
- ប្រភពទី 4 ៖ ការចំណាយធនធានយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើសព្វាវុធ និងកងទ័ព ។
- ប្រភពទី 5 ៖ ភាពយឺតយ៉ាវរបស់ស្ថាប័នអំណាចជាតិក្នុងការឆ្លើយតប និងរកវិធីដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា ។

សរុបសេចក្តីមក យើងឃើញថា ទោះបីនៅមានរដ្ឋមួយចំនួននៅមានភាពយឺតយ៉ាវក្នុងការចូលរួមដោះស្រាយបញ្ហារួមនៅលើពិភពលោកពិតមែន ក៏ប៉ុន្តែបញ្ហានេះត្រូវបានគេលើកយកមកពិភាក្សាសឹងតែនៅគ្រប់កិច្ចប្រជុំអន្តរជាតិ ។ ព្រះរាជាណាចក្រកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងការស្វែងរកដំណោះស្រាយបញ្ហានេះ ។ ជាការពិតណាស់ បញ្ហារួមលើពិភពលោក ទាមទារឱ្យមានការចូលរួមរបស់ប្រទេសទាំងអស់ ជាពិសេសពីសំណាក់ប្រទេសឧស្សាហកម្មជឿនលឿនដែលជាប្រទេសមានលទ្ធភាពច្រើនជាងគេ ។

## ? សំណួរ

1. តើបញ្ហាអ្វីទៅដែលគេចាត់ទុកជាបញ្ហារួមលើពិភពលោក ? ចូររាប់បញ្ហារួមលើពិភពលោកឱ្យបានយ៉ាងតិចប្រាំ ?
2. តើស្ថានភាពបរិស្ថានធម្មជាតិលើពិភពលោកទទួលការគំរាមកំហែងអ្វីខ្លះ ?
3. តើអ្វីជាប្រភពមូលដ្ឋានដែលនាំឱ្យលេចឡើងនូវបញ្ហារួមលើពិភពលោក ?

វិទ្យាល័យហ៊ុនសែនអន្លង់ស្នួល
បណ្ណាល័យព្រាបស
លេខ........ថ្ងៃទី........ខែ........ឆ្នាំ........

មេរៀនទី

# 12 ដំណើរការវិវត្តសកលភាវូបនីយកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាអំពីដំណើរការវិវត្តសកលភាវូបនីយកម្ម ។
- ❑ពន្យល់ពីអ្វីដែលហៅថាសកលភាវូបនីយកម្ម ការលេចឡើង និងការវិវត្តរបស់វា ។
- ❑ គាំទ្រប្រទេសកម្ពុជាក្នុងចលនាសកលភាវូបនីយកម្ម ។

## 1. សេចក្តីផ្តើម

សកលភាវូបនីយកម្ម គឺជាដំណើរការវិវត្តនៅក្នុងចរន្តនៃការបង្កើតឡើងនូវប្រព័ន្ធតែមួយនៅលើពិភពលោក ។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ 60 នៃសតវត្សទី 20 មកយើងសង្កេតឃើញថានៅលើពិភពលោកមានលេចឡើងនូវទំនោរទៅរកការធ្វើសមាហរណកម្មលើវិស័យនយោបាយ និងសេដ្ឋកិច្ច ។ នៅក្នុងចំណោមកត្តាថ្មីៗជាច្រើនដែលបានលេចឡើង ហាក់ដូចជាមានឥទ្ធិពលយ៉ាងខ្លាំងទៅរកការកសាងប្រព័ន្ធអន្តរជាតិថ្មីមួយទៀត ក្នុងនោះយើងអាចធ្វើការកត់សំគាល់ដូចតទៅ ៖

- កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចពិភពលោកដែលជំរុញឱ្យកាន់តែលេចឡើងនូវអស្ថិរភាពនិងផលវិបាកចំពោះបញ្ហាផ្ទៃក្នុងប្រទេស និងទំនាក់ទំនងរវាងប្រទេសលើសពិភពលោក ។ នេះជាសញ្ញាមួយទាមទារឱ្យមានការបង្កើតប្រព័ន្ធថ្មីមួយប្រកបដោយប្រសិទ្ធភាព ។
- កំណើនយ៉ាងខ្លាំងនូវបំលាស់ប្តូរទីលំនៅរស់នៅរបស់ប្រជាពលរដ្ឋនៅលើពិភពលោក ។
- ការរីកចម្រើនយ៉ាងខ្លាំងនូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ ។
- ការរីកសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាទំនើបដែលជានិច្ចកាលបានក្លាយជាឧបករណ៍នយោបាយសកលលោក ។
- បញ្ហារួមជាច្រើនបានកើតឡើងដែលទាមទារឱ្យមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំរដ្ឋាភិបាល អង្គការអន្តរជាតិ សហគមន៍អន្តរជាតិជាដើម ។

យើងឃើញការលេចឡើងនូវរូបភាពនៃដំណើរការវិវត្តសមាហរណកម្មនយោបាយ និងសេដ្ឋកិច្ចពិភពលោក ដែលចាំបាច់ត្រូវតែមានសហគមន៍ និងអង្គការអន្តរជាតិផ្សេងៗ ចូលរួមដោះស្រាយបញ្ហាខាងលើនេះ ។ ទិន្នន័យដែលយើងទទួលបានពីអង្គការសហប្រជាជាតិ(1999) ឃើញថានាពាក់កណ្តាលទសវត្សរ៍ឆ្នាំ 80 នៅលើពិភពលោកមានអង្គការអន្តរជាតិចំនួនមួយពាន់ ។

ក្រោយសង្គ្រាមលោកលើកទី 2 ក្នុងរយៈពេលមួយយ៉ាងខ្លី គេបានបង្កើតអង្គការអន្តរជាតិជាច្រើនដែលមានតួនាទីសំខាន់ក្នុងការធ្វើសកម្មភាពសមាហរណកម្មពិភពលោក ។ អង្គការទាំងនោះមានអង្គការសហប្រជាជាតិ(United Nations = UN) អង្គការរូបិយវត្ថុអន្តរជាតិ(International Monetary Fund = IMF) ធនាគារពិភពលោក(World Bank) ។ ក្រៅពីនេះ គេឃើញមានអង្គការអន្តរជាតិកម្រិតតំបន់ដូចជាអង្គការរដ្ឋនៃទ្វីបអាមេរិក(Organization of American States = OAS) អង្គការនាំចេញប្រេងកាត(Organization of Petroleum Exporting Countries = OPEC) អង្គការឯកភាពអាហ្វ្រិក (Organization of African Unity = OAU) អង្គការសន្និសីទប្រទេសអ៊ីស្លាម(Organization of the Islamic Conference = OIC) សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ អាស៊ាន(Association of Southeast Asian Nations = ASEAN) សហគមន៍អឺរ៉ុប(European Union = EU) ។ល ។

បច្ចុប្បន្ននេះ គេសង្កេតឃើញអង្គការអន្តរជាតិជាច្រើនទាំងកម្រិតសកល ទាំងកម្រិតតំបន់និងកម្រិតអនុតំបន់ បានធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងទិសដៅនយោបាយសមាហរណកម្ម ប៉ុន្តែអង្គការដែលទទួលបានជោគជ័យជាងគេគឺ សហគមន៍អឺរ៉ុប ។ ក្រៅពីនេះ មានស្ថាប័នសំខាន់ពីរទៀតដែលខំប្រឹងប្រែង ដើម្បីជំរុញចរន្តសកលភាវូបនីយកម្មរបស់ខ្លួនគឺ

1. ក្រុមប្រទេសឧស្សាហកម្មជឿនលឿន G-8 (សហរដ្ឋអាមេរិក អង់គ្លេស បារាំង អ៊ីតាលី កាណាដា អាល្លឺម៉ង់ ជប៉ុន និងរុស្ស៊ី) (ដំបូងឡើយមានឈ្មោះថា G-7 ដោយគេមិនទាន់បញ្ចូលប្រទេសរុស្ស៊ី) ។ ក្រុម G-7 ជួបប្រជុំគ្នាជាដំបូងនៅឆ្នាំ 1975 ក្នុងទីក្រុងតូចមួយក្បែរទីក្រុងប៉ារីសឈ្មោះថា រ៉ាមប៊ូយេ ពេលខ្លះគេហៅថា G-7 " ក្លឹបរ៉ាមប៊ូយេ " ។

2. ស្ថាប័នមួយទៀតគឺ G-20 ដែលបានបង្កើតឡើងក្នុងដំណាក់កាលវិបត្តិហិរញ្ញវត្ថុឆ្នាំ 1997-1998 ។

# 2. ការវិវត្តសកលភាវូបនីយកម្ម

## 2.1. ការប្រែប្រួលតួនាទីអធិបតេយ្យភាពរបស់រដ្ឋ

ការវិវត្តសកលភាវូបនីយកម្ម មានការប៉ះពាល់យ៉ាងខ្លាំងចំពោះតួនាទីរដ្ឋជាតិ(Nation State) ជាពិសេសទៅលើប្រទេសតូចហើយទន់ខ្សោយ ។ នៅក្នុងរយៈពេលប្រហែល 20 ឆ្នាំកន្លងទៅ នយោបាយ

ក្នុងប្រទេស និងនយោបាយការបរទេសត្រូវបានគេចាត់ទុកជាតួនាទី និងមុខងារដាច់ខាតរបស់រដ្ឋក្នុងការធ្វើទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋដើម្បីផលប្រយោជន៍រៀងៗខ្លួន ។ នៅក្នុងដំណាក់កាលបច្ចុប្បន្ន មានកត្តាជាច្រើនដូចជា កត្តាបច្ចេកវិទ្យា នយោបាយសេដ្ឋកិច្ច បរិស្ថាន ជំងឺរាតត្បាត ភេរវកម្មជាដើម ដែលទាមទារឱ្យប្រទេសទាំងអស់ដោះស្រាយរួមគ្នា ព្រោះវាអាចគំរាមកំហែងដល់អាយុជីវិត ឬផ្តល់នូវការរីកចម្រើនរួមមួយលើពិភពលោកមិនចំពោះតែរដ្ឋណាមួយនោះឡើយ ។ ផលប៉ះពាល់ចៀសមិនផុតពីអធិបតេយ្យភាពរបស់រដ្ឋនៅក្នុងសកលភាវូបនីយកម្ម ។

បញ្ហាជាច្រើនដែលលេចឡើងនៅលើពិភពលោកបានទាមទារឱ្យមានសេចក្តីសម្រេចចិត្តមួយដែលអាស្រ័យដោយរដ្ឋជាច្រើនរួមគ្នាធ្វើការដោះស្រាយជាឯកច្ឆន្ទ ។ បញ្ហារួមលើពិភពលោកទាមទារឱ្យមានដំណោះស្រាយរួម ព្រោះរដ្ឋមួយពុំមានលទ្ធភាពដោះស្រាយបានដោយឯកឯងដោយមិនគិតថាបញ្ហាទាំងនោះជាបញ្ហាសកល និងគំរាមកំហែងចំពោះប្រជាជនលើពិភពលោកទាំងមូលនោះបានឡើយ ។ម្យ៉ាងទៀត ដំណើរការអភិវឌ្ឍបច្ចេកវិទ្យាសេដ្ឋកិច្ច នយោបាយ កំពុងធ្វើសកម្មភាពក្នុងលក្ខណៈជាសកល ហើយចេញពីរង្វង់អធិបតេយ្យរដ្ឋ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រដ្ឋនៅតែមានឥទ្ធិពលយ៉ាងខ្លាំងលើសកម្មភាពអង្គការ សហគ្រាសពហុជាតិ(Multinational Corporations) ហើយរដ្ឋដើរតួយ៉ាងសំខាន់ក្នុងនាមជាប្រធានវិស័យភាពទៅលើអង្គការ ស្ថាប័នពហុជាតិនៅក្នុងតំបន់ និងនៅលើពិភពលោក ។ *ឧទាហរណ៍* ការកំណត់តម្លៃប្រេង និងឧស្ម័ន ជាបញ្ហាយ៉ាងសំខាន់មិនមែនរដ្ឋជាម្ចាស់ប្រេងណាមួយអាចកំណត់ជាអត្តនោម័តិឡើយ ។ បញ្ហានេះត្រូវតែដោះស្រាយក្នុងកម្រិតអន្តរជាតិដូចជាដោះស្រាយតាមរយៈ OPEC EU ជាដើម ។ ផ្ទុយទៅវិញ គេតែងជួបភាពមិនចុះសម្រុងគ្នារវាងរដ្ឋ និងរដ្ឋជាញឹកញាប់ ។

ជាលទ្ធផល នៅក្នុងចរន្តសកលភាវូបនីយកម្មលើដំណើរសមាហរណកម្មសេដ្ឋកិច្ច ហិរញ្ញវត្ថុជាក្រិត្យក្រមពិភពលោកធ្វើឱ្យតួនាទី និងអធិបតេយ្យភាពរបស់រដ្ឋធ្លាក់ចុះ ពីព្រោះសហគ្រាសពហុជាតិ ឬសហគ្រាសអន្តរជាតិធ្វើសកម្មភាពភាគច្រើនអាស្រ័យទៅលើដំណើរការវិវត្តនៃទីផ្សារពិភពលោក ហើយគេធ្វើយ៉ាងណាឱ្យមានឯករាជភាពពីនយោបាយរបស់រដ្ឋ ។

ចំពោះចរន្តសកលភាវូបនីយកម្មនៅលើវិស័យនយោបាយវិញ រឹតតែធ្វើឱ្យមានភាពស្មុគស្មាញថែមទៀតទៅនឹងអធិបតេយ្យភាពរដ្ឋ ។ ជាការពិតណាស់ ចរន្តសកលភាវូបនីយកម្មពាក់ព័ន្ធនឹងបញ្ហាពិភពលោក ដូច្នេះអាចពាក់ព័ន្ធទៅនឹងកម្មវិធីនយោបាយបរទេសរបស់រដ្ឋអធិបតេយ្យមួយ ។ ជាធម្មតា គោលនយោបាយការបរទេសត្រូវបង្កើតឡើងដោយអាស្រ័យទៅនឹងស្ថានភាពនយោបាយក្នុងប្រទេសរួចបញ្ច្រាសមកវិញ ។ ក្នុងពេលបច្ចុប្បន្ននេះគឺជាការលំបាកមួយ ក្នុងការធ្វើឱ្យចរន្តសកលភា

វូបនីយកម្មមានការវិវត្តដោយឯករាជ្យពីអធិបតេយ្យភាពរដ្ឋ ។ ម្យ៉ាងទៀត ចរន្តសកលភាវូបនីយកម្មអាចវិវត្តក្រោមឥទ្ធិពលនៃប្រទេសមហាអំណាចណាមួយដែលខ្លាំងជាងគេ ។

បញ្ហាខាងលើនេះពិតជាស្មុគស្មាញ ហើយទាមទារឱ្យពិនិត្យមើលដោយយកចិត្តទុកដាក់ជាទីបំផុតទៅលើស្ថានភាពជាក់ស្តែងដើម្បីឱ្យចរន្តសកលភាវូបនីយកម្មអាចដំណើរការទៅបានដោយមិនកាត់ផ្តាច់រវាងនយោបាយក្នុងប្រទេស និងនយោបាយការបរទេសរបស់រដ្ឋអធិបតេយ្យភាពណាមួយ ។

ជាលទ្ធផលនៃការអនុវត្តជាក់ស្តែង ប្រទេសអន់ខ្សោយ(តតិយលោក) កាន់តែបាត់បង់អធិបតេយ្យភាពរបស់ខ្លួននៅក្នុងការចូលមកនៃចរន្តសកលភាវូបនីយកម្មនេះ ដោយសារតែលទ្ធភាពនៃនយោបាយការបរទេសរបស់ប្រទេសទាំងនេះត្រូវរួញតូចក្រោមសម្ពាធឥទ្ធិពលនយោបាយការបរទេសរបស់ប្រទេសមហាអំណាចជាពិសេសវិស័យព័ត៌មានវិទ្យា និងទូរគមនាគមន៍រឹតតែធ្វើឱ្យតួនាទីរដ្ឋទន់ខ្សោយកាន់តែចុះទន់ខ្សោយថែមទៀត ។ ប្រព័ន្ធផ្កាយរណបក៏អាចជាប្រភពបង្កើតបញ្ហាដូច-ខាងលើនេះដែរ ដែលធ្វើឱ្យរដ្ឋាភិបាលរឹតតែបាត់បង់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានថែមទៀត ។

ភាពរង្គោះរង្គើនៃប្រព័ន្ធសង្គមនិយមកើតឡើងក្នុងដំណាក់កាលចុងក្រោយនៃសតវត្សទី 20 ។ យើងសង្កេតឃើញថារដ្ឋដែលចាកចេញពីប្រព័ន្ធសង្គមនិយមតែងតែលើកពាក្យស្លោកថា "អបអរសាទរលទ្ធិប្រជាធិបតេយ្យ" ។ ក្នុងខណៈនោះមានអ្នកនយោបាយជាច្រើនបានចាត់ទុកថា ការកសាងលទ្ធិប្រជាធិបតេយ្យ ជាការដើរក្នុងចរន្តសកលភាវូបនីយកម្ម ។ ជាការឆ្លើយតបទៅនឹងស្ថានភាពបែបនេះ ក្រុមប្រឹក្សាជាតិទទួលបន្ទុកការងារការបរទេសសហរដ្ឋអាមេរិកបានធ្វើសេចក្តីសម្រេចចិត្តថាត្រូវបង្កើតជាចាំបាច់ក្រុមសិក្សាស្រាវជ្រាវមួយដែលជាមូលដ្ឋាននៃគោលនយោបាយការបរទេសសហរដ្ឋអាមេរិកជុំវិញការអភិវឌ្ឍស្ថាប័នប្រជាធិបតេយ្យពិភពលោក ។ ពីអតីតកាល យើងឃើញនយោបាយការបរទេសសហរដ្ឋអាមេរិកក្នុងដំណាក់កាលសង្គ្រាមត្រជាក់មានទិសដៅជួយដល់ប្រទេសណាដែលគាំទ្រនយោបាយការបរទេសរបស់ខ្លួន ប៉ុន្តែក្នុងពេលបច្ចុប្បន្ន ការទទួលជំនួយពីសហរដ្ឋអាមេរិកតែងតែផ្សារភ្ជាប់នឹងលក្ខខណ្ឌនៃការកសាងសង្គមប្រជាធិបតេយ្យ ។ ជាលទ្ធផល ប្រទេសជាច្រើនដែលចាកចេញពីប្លុកសង្គមនិយមប្រកាសថា ខ្លួនកសាងលទ្ធិប្រជាធិបតេយ្យបែរជាជួបនឹងភាពអនាធិបតេយ្យផ្ទុះឡើង ហើយបង្កជាសង្គ្រាមស៊ីវិលបង្ហូរឈាមគ្នាទៅវិញ ។ ជាការលំបាកណាស់ នៅពេលដែលកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសមួយគ្មានមូលដ្ឋានសង្គមប្រជាធិបតេយ្យ ដែលប្រជាជនភាគច្រើនជាអនក្ខរជន និងមានសេដ្ឋកិច្ចអន់ខ្សោយ ។ ការកសាងលទ្ធិប្រជាធិបតេយ្យដើម្បីត្រឹមតែបានទទួលការគាំទ្រពីសហរដ្ឋអាមេរិកបែបនេះមិនខុសអ្វីពីសហភាពសូវៀតដែលដឹកនាំមនោគមន៍វិជ្ជាកុម្មុយនីស្តយកទៅសាបព្រោះក្នុងប្រទេសតតិយលោកក្នុងដំណាក់កាលសង្គ្រាមត្រជាក់នោះទេ ។

ក្នុងដំណាក់កាលចុងក្រោយ ប្រទេសតតិយលោកបានចងក្រងជាសមាគមរដ្ឋដើម្បីបញ្ចៀសនូវការលូកដៃពីសំណាក់កំពូលមហាអំណាច ។ ទន្ទឹមនឹងនេះសមាគមពហុជាតិក្នុងតំបន់បានធ្វើសកម្មភាពដោះស្រាយបញ្ហាជាច្រើនតួរឱ្យកត់សំគាល់គឺ បញ្ហានយោបាយ បញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម បញ្ហាវប្បធម៌ បញ្ហាបរិស្ថាន បញ្ហាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម បញ្ហាអភិវឌ្ឍន៍បច្ចេកវិទ្យា ។ល ។

## 2.2. សហគមន៍រដ្ឋអធិបតេយ្យ ឬពិភពលោកពហុជាតិតែមួយ

ពិភពលោកពហុជាតិមានន័យថា ពិភពលោកទាំងមូលនឹងពុំមានព្រំប្រទល់ជាទឹកដីតែមួយរស់នៅដោយប្រជាជនដែលមានសញ្ជាតិផ្សេងៗគ្នានោះទេ ។ នេះជាទិសដៅចុងក្រោយនៃដំណើរការវិវត្តសកលភាវូបនីយកម្ម ។ ប៉ុន្តែទស្សនៈមួយទៀតបានគិតថាពិភពលោកទាំងមូលនឹងក្លាយទៅជាសហគមន៍រដ្ឋអធិបតេយ្យ ។ នេះជាចក្ខុវិស័យរបស់អ្នកសកលភាវូបនីយកម្មនិយមតែប៉ុណ្ណោះ ។ ចំពោះសំណួរថា តើគេត្រូវប្រើមធ្យោបាយបែបណា និងពេលណាទើបសម្រេចគោលដៅនេះ ? ចម្លើយនិងសំណួរនេះនៅមានភាពស្រពេចស្រពិល និងមិនប្រាកដប្រជានៅឡើយ ។

យើងបាននិយាយពីខាងលើរួចមកហើយអំពីកត្តាជំរុញឱ្យមានការធ្វើសមាហរណកម្មបណ្តាប្រទេសពិភពលោកដើម្បីស្វែងរកដំណោះស្រាយបញ្ហារួមចំពោះមុខផង និងដើម្បីស្វែងរកនូវជំហរអភិវឌ្ឍរួមផង ។ យើងឃើញថារដ្ឋនីមួយៗហាក់ដូចជាចុះអន់ថយនូវអធិបតេយ្យភាពរបស់ខ្លួនក្នុងនាមជាឧបករណ៍ផ្តាច់ការក្នុងការធ្វើសកម្មភាពនានាដើម្បីផលប្រយោជន៍ជាតិ ។

ដើម្បីពិភាក្សាលើបញ្ហានេះ យើងពិនិត្យមើលតួនាទីរបស់រដ្ឋសិនក្នុងការស្វែងរកជំហរអភិវឌ្ឍជាតិ ប្រកបដោយចីរភាព ស្ថិរភាព សន្តិភាព កិត្តិយស និងសេចក្តីថ្លៃថ្នូរ ។

- ជំហរដ៏សំខាន់របស់រដ្ឋគឺ អធិបតេយ្យភាពដែលជាគោលការណ៍កំណត់នូវអំណាចដ៏ខ្ពស់បំផុតនៅលើទឹកដី និងប្រជាជនដែលរដ្ឋគ្រប់គ្រង ។ ត្រង់នេះរដ្ឋជាឧបករណ៍ផ្តាច់ការក្នុងការការពារបូរណភាពទឹកដីខ្លួន ។
- រដ្ឋជាផ្នែកមួយនៃសហគមន៍អន្តរជាតិ ប៉ុន្តែរដ្ឋនីមួយៗមានព្រំដែនសកម្មភាពរបស់ខ្លួនច្បាស់លាស់ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ និងក្នុងការប្រកួតប្រជែងគ្នាដើម្បីផលប្រយោជន៍ជាតិរៀងៗខ្លួន ។
- រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរ បញ្ជូនកម្លាំងពលករទៅបំពេញការងារនៅក្រៅប្រទេស និងការពារពួកគេគ្រប់ពេលវេលាស្របទៅតាមច្បាប់ ។ នៅក្នុងប្រព័ន្ធទីផ្សារសេរីមានលេចឡើងជាញឹកញាប់នូវភាពមិនចុះសម្រុងគ្នាលើបញ្ហានេះ ។ ជាលទ្ធផល គេមិនអាចដោះស្រាយបញ្ហាអ្វីមួយបានទេ បើគ្មានអន្តរាគមន៍ពីរដ្ឋ ទោះបីជាក្នុងពេលបច្ចុប្បន្ន ដំណើរការវិវត្តនៃសមាហរណកម្មពាណិជ្ជកម្ម ផលិតកម្មពិភពលោកគ្មានព្រំដែនយ៉ាងណាក៏ដោយ ។

- ជានិច្ចកាលរដ្ឋតែងតែរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ចសេរីអន្តរជាតិជាមួយនឹងសេដ្ឋកិច្ចជាតិ ។ ត្រង់នេះចង់បញ្ជាក់អំពីការសម្របសម្រួល ឬការរារាំងនយោបាយអនុត្តរភាពសេដ្ឋកិច្ចរបស់ប្រទេសដែលមានសេដ្ឋកិច្ចខ្លាំងជាង ។ យើងទទួលស្គាល់ដែរថា រដ្ឋក៏មានការចាប់អារម្មណ៍ទៅលើដំណើរសកលភាវូបនីយកម្មលើវិស័យសេដ្ឋកិច្ចបច្ចេកវិទ្យាទំនើបផងដែរ ដោយធ្វើសកម្មភាពពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ប៉ុន្តែជាភ័ព្វសំណាងអាក្រក់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិបែបនេះ រដ្ឋទន់ខ្សោយតែងតែទទួលសម្ពាធពីរដ្ឋខ្លាំង ។
- កិច្ចសហប្រតិបត្តិការអន្តរជាតិរវាងធនាគារឯកជនក្តី ឬធនាគារជាតិក្តីត្រូវគេទទួលស្គាល់ថាជាកិច្ចព្រមព្រៀងពហុជាតិ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវតែទទួលស្គាល់នូវតួនាទីគ្រប់គ្រងរបស់រដ្ឋផងដែរ ដែលក្នុងនោះមានការទទួលខុសត្រូវក្នុងការសម្របសម្រួល និងត្រួតពិនិត្យពីស្ថាប័នហិរញ្ញវត្ថុជាតិដែលបំពេញការងារសម្រាប់រដ្ឋាភិបាលជាដើម ។

ដោយតួនាទីរដ្ឋនៅតែសំខាន់និងត្រូវតែពង្រឹង រដ្ឋត្រូវតែរៀបចំនូវគោលនយោបាយសមស្របសម្រាប់ឧបត្ថម្ភដល់ដំណើរការប្រព័ន្ធហិរញ្ញវត្ថុ ផលិតកម្មពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការពិភពលោកនៅក្នុងរង្វង់មួយដែលសហគ្រាសអាចធ្វើសកម្មភាពទៅបាន ។

សព្វថ្ងៃនេះថ្វីត្បិតតែក្រុមហ៊ុន សហគ្រាស សាជីវកម្ម សហគមន៍ពហុជាតិកាន់តែមានចំនួនច្រើនឡើងៗយ៉ាងណាក្តី ប៉ុន្តែអង្គការទាំងនេះភាគច្រើន ពុំមានអធិបតេយ្យទេ លើកលែងតែឬកយោធា ។ អង្គការទាំងនោះពុំមានទឹកដីដែលត្រូវការពារនោះឡើយ ដោយសារតែព្រំដែនសីមារបស់គេពុំមានភាពច្បាស់លាស់ គឺអាស្រ័យតែទៅលើឯកទេសរបស់ស្ថាប័នទាំងនេះ ដូចជា បរិស្ថាន សេដ្ឋកិច្ច ឬទំនាក់ទំនងសង្គមកិច្ច ។ល ។ ទោះបីស្ថាប័នទាំងនេះគ្មានអធិបតេយ្យភាព ប៉ុន្តែគេអាចធ្វើឱ្យអំណាចរដ្ឋចុះទន់ខ្សោយ ដូច្នេះហើយបានជាពួកគេទទួលរងការវាយលុកពីកម្លាំងនយោបាយរដ្ឋជារឿយៗ ។ ក្នុងខណៈគេចង់គេចចេញពីការគ្រប់គ្រងរបស់រដ្ឋ គេអាចធ្វើបានតាមរយៈសំបុត្រអនាមិក ឬការលាក់ខ្លួនមិនទទួលខុសត្រូវចំពោះមុខសង្គម និងចំពោះមុខប្រជាពលរដ្ឋ ។ ជាលទ្ធផលគ្មានអ្វីក្រៅពីធ្វើឱ្យសង្គមបែកបាក់ និងអនាធិបតេយ្យតែប៉ុណ្ណោះ ។

សរុបសេចក្តីមក ទោះបីជាអ្នកសកលភាវូបនីយកម្មមើលឃើញការកសាងពិភពលោកតាមបែបពហុជាតិ ឬសហគមន៍រដ្ឋអធិបតេយ្យយ៉ាងណាក៏ដោយ ក៏ក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហានេះនៅតែជារឿងមួយស្មុគស្មាញ ហើយក៏គ្មានអ្វីឱ្យប្រាកដប្រជាឡើយ ។ ពាក្យសកលភាវូបនីយកម្ម ដែលគេប្រើសព្វថ្ងៃនេះគ្រាន់តែជាពាក្យសម្រាប់អ្នកនយោបាយប្រើជាមធ្យោបាយដើម្បីកសាងពិភពលោកមួយប្រកបដោយការចុះសម្រុងគ្នា ការយោគយល់គ្នា និងដើម្បីកិច្ចសហប្រតិបត្តិការតែប៉ុណ្ណោះ ។

## 2.3. តួនាទីយោធានៅក្នុងចរន្តសកលភាវូបនីយកម្ម

បញ្ហាដ៏ស្មុគស្មាញបំផុតនៅក្នុងសកម្មភាពនយោបាយអន្តរជាតិ គឺទាក់ទងនឹងការប្រើប្រាស់កម្លាំងទ័ព ច្បាប់ និងសិទ្ធិក្នុងការប្រើប្រាស់កម្លាំងទ័ព ដើម្បីដោះស្រាយទំនាស់នៅក្នុងប្រទេស ឬតំបន់ណាមួយ ។ គេពិបាកនឹងវិនិច្ឆ័យទៅលើអត្ថន័យនៃការប្រើប្រាស់កម្លាំងទ័ពក្នុងប្រទេសឬតំបន់ណាមួយ ប្រសិនបើគេពឹងផ្អែកទៅលើមាត្រាទី 2 នៃលក្ខន្តិកៈអង្គការសហប្រជាជាតិដែលចែងអំពីការមិនអនុញ្ញាតឱ្យលូកដៃចូលបញ្ហាផ្ទៃក្នុងរបស់ប្រទេសមួយ លើកលែងតែក្នុងខណៈណាដែលស្ថានការណ៍នៅក្នុងប្រទេសនោះអាចគំរាមកំហែងដល់សន្តិភាព និងស្ថិរភាពអន្តរជាតិ ។

គេចាត់ទុកមធ្យោបាយប្រើប្រាស់កម្លាំងទ័ពអន្តរជាតិដើម្បីរារាំងការគំរាមកំហែងស្ថិរភាពនិងសន្តិភាពពិភពលោកថាជាអន្តរាគមន៍ដើម្បីសន្តិភាព ។ ការប្រើប្រាស់មធ្យោបាយបែបនេះត្រូវបានគេហៅថា "សិទ្ធិក្នុងការលូកដៃ" ដែលអនុញ្ញាតឱ្យប្រទេសមួយ ឬក្រុមប្រទេសមួយចំនួនមានសិទ្ធិលូកដៃចូលបញ្ហាផ្ទៃក្នុងរបស់ប្រទេសផ្សេងទៀត ក្រោមលេសថាជាការរារាំងដល់សកម្មភាពទាំងឡាយណាដែលនាំឱ្យមានអស្ថិរភាព និងសង្គ្រាម ។

នៅក្នុងបរិបទដូចខាងលើនេះ គេឃើញមានបញ្ហាស្មុគស្មាញមួយចំនួនទាក់ទងទៅនឹងសកម្មភាព "លូកដៃដើម្បីមនុស្សធម៌" ដែលនៅក្រោមការដឹកនាំរបស់អង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិផ្សេងៗទៅលើប្រទេសណាមួយ ឬក្រុមប្រទេសណាមួយ ។ *ឧទាហរណ៍* នៅក្នុងប្រទេសស៊ូដង់ អង្គការអន្តរជាតិបានធ្វើសកម្មភាពមនុស្សធម៌ជួយដល់ប្រជាជនស៊ូដង់ ។ ប្រតិបត្តិការនោះធ្វើឡើងទៅបានដោយមានការយល់ព្រមពីរដ្ឋាភិបាលកាន់អំណាច និងមេដឹកនាំពួកឧទ្ទាមផងដែរ ។ ប៉ុន្តែចំពោះប្រទេសសូម៉ាលីវិញកិច្ចប្រតិបត្តិការរបស់កងកម្លាំងអន្តរជាតិពុំបានទទួលកិច្ចព្រមព្រៀងណាមួយពីរដ្ឋាភិបាលសូម៉ាលីឡើយ ដោយរដ្ឋាភិបាលសូម៉ាលីប្រឆាំងនឹងអន្តរាគមន៍នេះ ។

អ្វីដែលបានលើកឡើងខាងលើ ទាមទារឱ្យមានការពិភាក្សាឡើងវិញអំពីសិទ្ធិរបស់សហគមន៍អន្តរជាតិនៅក្នុងអន្តរាគមន៍នឹងការលូកដៃចូលក្នុងបញ្ហាប្រទេសដទៃក្នុងពេលដែលពុំមានការយល់ព្រមពីសំណាក់រដ្ឋាភិបាលប្រទេសនោះ ។ ដោយទទួលស្គាល់អំពីគោលការណ៍ដែលត្រូវបានអនុម័តដោយសហគមន៍អន្តរជាតិបានបង្កទំនាស់ទៅនឹងអធិបតេយ្យភាពជាតិ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក ប៉េរេដឺ គូអេឡាបានថ្លែងថានៅក្នុងច្បាប់នៃសហគមន៍អន្តរជាតិត្រូវតែបញ្ចូលទស្សនទានថ្មីនៃសហគមន៍អន្តរជាតិដោយផ្សារភ្ជាប់រវាង "ច្បាប់ និងសីលធម៌" ។

ដំណាក់កាលចុងក្រោយ នៅក្នុងពិភពលោកមានការកើនឡើងនូវចលនាជាតិនិយម(Nationalism) សាសនានិយម និងការប្រកាន់វប្បធម៌ជ្រុលនិយម ។ល ។ ព្រឹត្តិការណ៍នេះសឱ្យឃើញថាគួរតែពិនិត្យ និងវាយតម្លៃជាថ្មីទៅលើគោលនយោបាយរបស់អ្នកកាន់អំណាចរដ្ឋ ហើយក៏ត្រូវធ្វើការកំណត់សាជាថ្មី និងបែងចែកឱ្យបានត្រឹមត្រូវអំពីអធិបតេយ្យភាពរបស់រដ្ឋនៅក្នុងចរន្តសកលភាវូបនីយកម្ម ។ ជាការពិតណាស់ ចលនាជាតិនិយមជាកម្លាំងមួយដ៏ខ្លាំងក្លាក្នុងការរារាំងដល់ដំណើរការវិវត្តចរន្តសកលភាវូបនីយកម្ម ។ ប៉ុន្តែប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា ក្រោយពីសង្គ្រាមលោកលើកទី 1 និងលើកទី 2 មក មហាជនមានការយល់ដឹងពីវប្បធម៌សន្តិភាព ដោយបន្ថយការគាំទ្រមនោគមន៍វិជ្ជាជាតិនិយមហើយបែរជាមកចែករំលែកការយល់ដឹង និងចេះឱ្យតម្លៃគ្នាទៅវិញទៅមក ។

## 3. សន្និដ្ឋាន

សរុបសេចក្តីមកយើងឃើញថា ការរស់នៅរបស់មហាជនលើពិភពលោកទាមទារឱ្យមានកិច្ចសហប្រតិបត្តិការជាចាំបាច់ដោយសារតែមានបញ្ហាច្រើនដែលគ្មានប្រទេសណាមួយអាចដោះស្រាយតែឯកឯងបានទេ ។ ប៉ុន្តែ កិច្ចសហប្រតិបត្តិការនេះមិនមែនមានន័យថា រដ្ឋដកថយពីអធិបតេយ្យភាពរបស់ខ្លួនក្នុងការថែរក្សាឯករាជភាព និងសិទ្ធិរបស់ខ្លួនក្នុងការសម្រេចបញ្ហារបស់ខ្លួនដោយខ្លួនឯង ឬការពង្រឹងតួនាទីរបស់ខ្លួនក្នុងសហគមន៍រដ្ឋនោះឡើយ ។ ដូច្នេះ អាទិភាពនៃដំណើរសកលភាវូបនីយកម្មនៅតែជាបញ្ហានៅឡើយ ។

## ? សំណួរ

1. តើកត្តាអ្វីខ្លះដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ (សកលភាវូបនីយកម្ម) ?
2. តើរដ្ឋមានតួនាទីយ៉ាងណាក្នុងនយោបាយអន្តរជាតិ ? តើចរន្តសកលភាវូបនីយកម្មអាចមានផលប៉ះពាល់យ៉ាងណាដល់តួនាទីរដ្ឋ ?
3. ហេតុដូចម្តេចបានជាកម្លាំងទ័ពអន្តរជាតិតែងតែជួបនឹងភាពស្មុគស្មាញនៅក្នុងការធ្វើសកម្មភាពមនុស្សធម៌ ឬរារាំងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសណាមួយលើពិភពលោក ?

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

1. តើប្រធានាធិបតីសហរដ្ឋអាមេរិករូបណាដែលបង្កើតកម្មវិធី New Deal ?

☐ ក. រូស្វែល ☐ ខ. និចសុន ☐ គ. ចនសុន ☐ ឃ. រីហ្គែន ។

2. តើនាយករដ្ឋមន្ត្រីចក្រភពអង់គ្លេសរូបណាដែលសង្គ្រោះប្រទេសអង់គ្លេសក្នុងសង្គ្រាមលោកលើកទី 2 ?

☐ ក. សំប៊ែឡាំង ☐ ខ. ឆឺឈីល ☐ គ. អេដែន ☐ ឃ. ថាត់ឆឺ ។

3. តើមេដឹកនាំសហភាពសូវៀតរូបណាដែលសង្គ្រោះប្រទេសឱ្យរួចពីសង្គ្រាមលើកទី 2 ?

☐ ក. លេនីន ☐ ខ. ស្តាលីន ☐ គ. គ្រូតឆូវ ☐ ឃ. ហ្គោបាឆូវ ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. នៅឆ្នាំ 1944 លោកឧត្តមសេនីយ៍បារាំង .................... បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ន ។

2. ក្រោយសង្គ្រាមលោកលើកទី 2 ប្រទេសអាល្លឺម៉ង់បែកជាពីរគឺ .................... និង .................... ។

3. នៅឆ្នាំ 1946 រដ្ឋធម្មនុញ្ញថ្មីរបស់សហព័ន្ធយូហ្គោស្លាវីបានផ្តល់ស្វ័យភាពដល់រដ្ឋទាំង 6 តែធាតុពិតអំណាចក្នុងកណ្តាប់ដៃ .................................... ។

III. ចូរគូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស ។

| ឈ្មោះប្រធានាធិបតី | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1 កេណ្ណឺឌី | ក. សហភាពសូវៀត | 1. → ..... |
| 2 ខ្រូស្ចូវ | ខ. សហរដ្ឋអាមេរិក | 2. → ..... |
| 3 មីតេរ៉ង់ | គ. បារាំង | 3. → ..... |
| 4. ទីតូ | ឃ. អង់គ្លេស | 4. → ..... |
| 5 ប្រេស្នែវ | ង. យូហ្គោស្លាវី | 5. → ..... |

IV. សំណួរត្រិះរិះ

1. តើកត្តាអ្វីខ្លះដែលជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ(សកលភាវូបនីយកម្ម) ?

2. តើបញ្ហាបរិស្ថានធម្មជាតិបានគំរាមកំហែងពិភពលោកដូចម្តេចខ្លះ ?

3. ហេតុអ្វីបានជាក្រោយឆ្នាំ 1991 ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរ ?

4. ហេតុអ្វីបានជាគេថាប្រទេសប៉ូឡូញជាប្រភពនៃសង្គ្រាមលោកលើកទី 2 ?

# ជំពូកទី 2 ប្រវត្តិសាស្ត្រប្រទេសកម្ពុជា



ប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមនិយមបារាំងអស់រយៈពេលជិត 1 សតវត្ស(90ឆ្នាំ)(1863-1953) ហើយបានទទួលឯករាជ្យដោយសារប្រជារាស្ត្រខ្មែរ ពិសេសសម្តេចព្រះនរោត្តមសីហនុបានបង្កើតចលនាតស៊ូទាមទារឯករាជ្យបានពេញបរិបូរពីពួកបារាំង និងកសាងសង្គមថ្មីមួយសំបូររុងរឿង "សម័យសង្គមរាស្ត្រនិយម"។ នៅឆ្នាំ 1970 ប្រទេសកម្ពុជាបានរងនូវឥទ្ធិពលនៃសង្គ្រាមត្រជាក់ ហើយកើតឡើងនូវសង្គ្រាមស៊ីវិលកាប់សម្លាប់ជីវិតមនុស្ស និងបំផ្លិចបំផ្លាញធនធានជាតិដល់ឬសគល់ ជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ថ្ងៃទី 7 ខែមករា ឆ្នាំ 1979 ប្រទេសកម្ពុជាត្រូវបានរំដោះឱ្យរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែសង្គ្រាមនៅតែបន្តទៀត។ ដើម្បីសន្តិភាព សម្តេចព្រះនរោត្តម សីហនុ និង សម្តេច ហ៊ុន សែន បានរកឃើញនូវមាគ៌ាមួយដែលអាចបញ្ចប់សង្គ្រាមរវាងខ្មែរនិងខ្មែរតាមរយៈការជួបចរចារវាងភាគីទំនាស់ដើម្បីធ្វើការបង្រួបបង្រួមជាតិខ្មែរឡើងវិញ។

មេរៀនទី

# 1 ប្រទេសកម្ពុជាក្រោមអាណានិគមបារាំង (1863-1953)

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាព្រឹត្តិការណ៍នៅសម័យអាណានិគមបារាំង ។
- វិភាគលទ្ធផលវិជ្ជមាន និងអវិជ្ជមាននៃរបបគ្រប់គ្រងរបស់អាណានិគមបារាំង ។
- បង្កើនមនសិការស្នេហាជាតិ សាមគ្គីភាពផ្ទៃក្នុង ការពារផលប្រយោជន៍ជាតិ ។

ពួកសៀម និងយួនបានធ្វើជាអាណាព្យាបាលលើខ្មែរអស់រយៈពេលយ៉ាងយូរ ហើយពេលនោះខ្មែរត្រូវបាត់បង់ទឹកដី និងទ្រព្យធនជាតិអស់ជាច្រើនថែមទៀត ។ ដោយសារតែហេតុនេះព្រះបាទអង្គឌួងមានព្រះរាជបំណងពឹងបារាំងដើម្បីជួយការពារទឹកដីខ្មែរឱ្យរួចពីកណ្ដាប់ដៃប្រទេសជិតខាងទាំងពីរនេះ ។

## 1. មូលហេតុនៃវត្តមានបារាំង

តើបារាំងចូលមកគ្រប់គ្រងប្រទេសកម្ពុជានៅពេលណា ? ដោយរបៀបណា ?

### 1.1. រជ្ជកាលព្រះបាទអង្គឌួង (1841-1860)

ព្រះបាទអង្គឌួងជាបុត្រព្រះបាទអង្គអេង បានស្នាក់នៅរៀនសូត្រឯប្រទេសសៀម ។ ព្រះអង្គជាព្រះរាជាមួយអង្គដែលមានទឹកព្រះទ័យស្នេហាជាតិមោះមុត ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។(ព្រះអង្គមានស្នាព្រះហស្ថខាងអក្សរសាស្ត្រ កំណែទម្រង់ផ្នែករដ្ឋបាល បង្កើតប្រាក់ថ្មី និងកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី មានផ្លូវពីឧដុង្គទៅកំពតកាត់តាមស្រុកឈូកតភ្ជាប់ទៅដល់កំពង់ផែសមុទ្រថ្មី ។ ការកសាងកំពង់ផែនេះដើម្បីជំនួសកំពង់ផែចាស់ដែលប្រទេសអណ្ណាមលេបយក និងស្ដារមុខមាត់ប្រទេសកម្ពុជាក្នុងវិស័យទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិតាមផ្លូវសមុទ្រឡើងវិញ ។) ព្រះបាទអង្គឌួងទ្រង់មានព្រះតម្រិះថា ប្រទេសកម្ពុជាកាន់តែធ្លាក់ដុនដាបទៅៗនឹងឈានទៅដល់ការបែងចែកទឹកដីតាមមហិច្ឆតាឈ្លានពានរបស់ប្រទេសទាំងពីរគឺយួន និងសៀម ដោយគ្រោងយកទន្លេមេគង្គជាព្រំប្រទល់[1]ហើយពេលនោះប្រទេសកម្ពុជានឹងត្រូវបាត់ឈ្មោះពីផែនទីពិភពលោក ។ ដើម្បីបញ្ចៀសប្រទេសកម្ពុជាឱ្យរួចផុតពីការលេបត្របាក់របស់សៀម និងយួន ដំណោះស្រាយតែមួយគត់គឺ ត្រូវមានប្រទេសមហាអំណាចណាមួយជាបង្អែក ។

(1). Le Cambodge de Sihanouk Pa. 67

នៅខែវិច្ឆិកា ឆ្នាំ 1853 ព្រះបាទអង្គឌួងបានពឹងបព្វជិតកាតូលិកមួយអង្គនាម មីស(Miche) ដែលបានចូលមកផ្សព្វផ្សាយសាសនានៅប្រទេសកម្ពុជាតាំងពីឆ្នាំ 1848មកម្ល៉េះ ឱ្យជួយទាក់ទងប្រទេសបារាំងដើម្បីសុំការការពារពីប្រទេសមហាអំណាចមួយនេះ ។ បព្វជិតអង្គនេះបាននាំលោកជាមួយមន្ត្រីខ្មែរពីរនាក់ទៀតឈ្មោះ កុលដឺម៉ុងតេរ៉ូ និងប៉ែន និងនាំសារព្រមទាំងសួយសារអាករផង ដើម្បីថ្វាយព្រះចៅណាប៉ូលេអុងទី 3 តាមរយៈអគ្គកុងស៊ុលបារាំងប្រចាំក្រុងសិង្ហបុរី ។ លុះដល់ឆ្នាំ 1855 ទើបបានចម្លើយពីព្រះចៅអធិរាជបារាំងដែលផ្តល់ការទទួលស្គាល់ប្រទេសកម្ពុជាត្រឹមតែជាដៃគូពាណិជ្ជកម្មប៉ុណ្ណោះ ។ លទ្ធផលដែលទទួលបានគឺផ្ទុយពីបំណងប្រាថ្នារបស់ព្រះមហាក្សត្រខ្មែរ ។ ក្រោយមក ព្រះបាទអង្គឌួងបានផ្ញើសារលិខិតពីរលើកទៀត ដោយទទូចសុំឱ្យបារាំងជួយធ្វើអន្តរាគមន៍យកទឹកដីកូសាំងស៊ីនដែលបាត់បង់នៅឆ្នាំ 1841 ព្រមទាំងពន្យល់បារាំងថា កោះត្រឡាចគឺជាទឹកដីរបស់ខ្មែរដែរ ចំណែកទឹកដីមួយផ្នែកធំទៀតនៅត្រើយខាងកើតទន្លេមេគង្គ ដែលប្រទេសអណ្ណាមប្រវិញ្ចយកជាយូរមកហើយនោះ ព្រះអង្គមិនតវ៉ាយកមកវិញឡើយ [1] ។ លទ្ធផលនៃទំនាក់ទំនងទាំងពីរលើកចុងក្រោយមិនបានចេញជាផ្លែផ្កាអ្វីឡើយ ។

នៅថ្ងៃទី 01 ខែកញ្ញា ឆ្នាំ 1858 មានបេសកកម្មរួមគ្នាមួយរបស់កងទ័ពបារាំង និងអេស្ប៉ាញបានចូលមកដល់ទីក្រុងដាណាងដើម្បីជួយស្រោចស្រង់ជីវិតពួកអ្នកផ្សព្វផ្សាយសាសនាកាតូលិក ដែលនៅសេសសល់ពីការសម្លាប់របស់ស្តេចអណ្ណាម ។ ក្រោយពីទ័ពអណ្ណាមបរាជ័យខាងយោធា កងទ័ពបារាំងចូលកាន់កាប់ទីក្រុងព្រៃនគរ និងតំបន់ជិតខាងនៅថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 1859 [2] ។ ក្រោយទទួលបានដំណឹងនេះ ព្រះបាទអង្គឌួងបានបញ្ជូនទ័ពខ្មែរមួយកងទៅកាន់ខេត្ត មាត់ជ្រូកក្នុងបំណងបង្ហាញថាទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ប៉ុន្តែគួរឱ្យស្តាយ បំណងនេះត្រូវអាក់ខានដោយព្រះអង្គចូលទិវង្គតនៅថ្ងៃទី 18 ខែតុលា ឆ្នាំ 1860 នារាជធានីឧដុង្គ ។

ក្រោយចូលកាន់កាប់ទីក្រុងព្រៃនគរបារាំងមានបំណងឡើងតាមទន្លេមេគង្គចូលទៅកាន់កាប់ប្រទេសចិនប៉ែកខាងត្បូង ប៉ុន្តែបេសកកម្មរបស់ក្រុមនាវិកបារាំងទទួលបរាជ័យ ដោយសារទន្លេមេគង្គមានឧបសគ្គច្រើនដែលមិនអាចឱ្យធ្វើដំណើរបានដូចការគ្រោងទុក ។ នៅពេលធ្វើដំណើរតាមដងទន្លេមេគង្គ ពួកបារាំងបានចាប់ចិត្តនឹងទេសភាពដ៏ស្រស់ត្រកាលនៅអមច្រាំងទន្លេទាំងសងខាងមានដំណាំរដូវដ៏ខៀវស្រងាត់ដូចជា សណ្តែក ល្ង ពោត និងបន្លែលាយឡំនឹងដើមឈើហូបផ្លែជាច្រើនប្រភេទ ។ បារាំងយល់ថាប្រទេសកម្ពុជាជាប្រទេសសម្បូរទៅដោយទន្លេ ដែលជាផ្លូវគមនាគមន៍យ៉ាងសំខាន់សម្រាប់ដឹកជញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារនៅអឺរ៉ុប ។ កម្ពុជាមានផ្ទៃដីកសិកម្មច្រើនហើយប្រជាជនតិច ពួកបារាំងនឹងអាចបង្កើតជាដីដាំដំណាំកសិកម្មបានផលច្រើន ។ម្យ៉ាងទៀតប្រទេស

(1). Le Cambodge de Sihanouk Pa. 68

(2). Le Cambodge la Colonie FranÇaise Pa. 5

កម្ពុជាជាប្រទេសសម្បូរដោយព្រៃ និងភ្នំប្រកបដោយឈើដែលមានគុណភាពខ្ពស់ ។ នៅក្រោមដីសម្បូរទៅដោយរ៉ែជាច្រើនប្រភេទ ។ ទោះបីពេលនោះបារាំងមិនទាន់មានមធ្យោបាយទាញយកផលពីប្រទេសកម្ពុជាក៏ដោយ ក៏បារាំងនៅតែប៉ុនប៉ងយកធនធានរ៉ែទាំងនេះ ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់បម្រើក្នុងវិស័យឧស្សាហកម្មប្រទេសខ្លួន ។

## 1.2. ព្រះបាទនរោត្តម (1860-1904)



*ព្រះបាទនរោត្តម*

បន្ទាប់ពីព្រះបាទអង្គឌួងសុគតនៅឆ្នាំ 1860 ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានលើកក្សត្រអង្គវតីឱ្យសោយរាជ្យបន្ត ។ ក៏ប៉ុន្តែ ដោយក្សត្រអង្គនេះពុំមានប្រជាប្រិយភាពផង ហើយថែមទាំងមានការច្រណែនពីព្រះអនុជពីរព្រះអង្គទៀតគឺ អង្គសូនិងស៊ីវត្ថាផង ក៏បង្កឱ្យមានចលនាបះបោរពេញផ្ទៃប្រទេសប្រឆាំងនិងការលើកទ្រង់ឱ្យសោយរាជ្យ ។ ក្សត្រអង្គវតីភិតភ័យក៏រត់ចេញទៅបាងកកឆ្លងកាត់តាមបាត់ដំបងនៅខែសីហា ឆ្នាំ 1861 ដោយនាំយកទាំងគ្រឿងសម្រាប់គ្រងរាជ្យទៅជាមួយផង ។ ពេលនោះ អង្គសូ(ព្រះបាទស៊ីសុវត្ថិ) ក៏ទទួលរ៉ាប់រងកិច្ចការប្រទេសជាតិជំនួសអង្គវតី និងបានរុញច្រានចលនាបះបោរដឹកនាំដោយស៊ីវត្ថាឱ្យថយទៅប៉ែកខាងជើងប្រទេស ។ បព្វជិតកាតូលិកមួយអង្គបានផ្ញើសារទៅកុងស៊ុលបារាំងនៅបាងកកឱ្យជួយធ្វើអន្តរាគមន៍ដើម្បីឱ្យក្សត្រអង្គនេះត្រឡប់មកមាតុប្រទេសវិញ ។ ក្សត្រអង្គវតីបានវិលត្រឡប់មកដល់ក្រុងឧដុង្គនៅខែមីនា ឆ្នាំ 1862 តាមផ្លូវទឹកកាត់តាមខេត្តកំពត ។ នៅពេលដែលដឹងថាក្សត្រអង្គវតីបានគង់នៅទីក្រុងឧដុង្គ អគ្គទេសាភិបាលបារាំងប្រចាំកូសាំងស៊ីន ដឺឡាក្រង់ឌីយែរ( De la Grandière) បានចាត់មេបញ្ជាការជើងទឹក ឌូដាដឺឡាគ្រេ ( Doudart de lagré ) ឱ្យចូលមកធ្វើទំនាក់ទំនង និងជួយធ្វើអន្តរាគមន៍យកគ្រឿងសម្រាប់គ្រងរាជ្យពីប្រទេសសៀមមកវិញដើម្បីអភិសេកព្រះអង្គឡើងសោយរាជ្យតាមប្រពៃណី ។ សម្រាប់ប្រទេសកម្ពុជា បារាំងចង់ជួយការពារប្រទេសនេះឱ្យផុតពីនឹមត្រួតត្រារបស់សៀមមកវិញនិងយួនដោយធានាថានិងជួយយកទឹកដីកូសាំងស៊ីនមកឱ្យខ្មែរវិញ ។ ទោះបីជាមានការធានាអះអាងរបស់បារាំងក៏ដោយ ក៏ព្រះបាទនរោត្តមនៅតែមានការព្រួយបារម្ភថានៅពេលណាមួយ បារាំងដកលែងត្រួតត្រាដែនកូសាំងស៊ីននោះប្រទេសយួននិងសៀមអាចមកត្រួតត្រាប្រទេសកម្ពុជាសាជាថ្មីឡើងវិញ ។

នៅខែមីនា ឆ្នាំ 1863 ឧត្តមនាវី ដឺឡាក្រង់ឌីយែរ បានមកកាន់ក្រុងឧដុង្គដោយផ្ទាល់ដើម្បីចុះសន្ធិសញ្ញាមិត្តភាពជាមួយប្រទេសកម្ពុជាជាសម្ងាត់ ។ ខ្លឹមសារនៃសន្ធិសញ្ញានេះមានចែងអំពីការជួយ

ការពារប្រទេសកម្ពុជាដោយរក្សាទឹកដីមិនឱ្យមានការបាត់បង់តទៅទៀត ។ ជាថ្នូរមកវិញ ប្រទេសកម្ពុជាត្រូវប្រគល់បុព្វសិទ្ធិពិសេសដល់បារាំងក្នុងការបោះទីតាំង និងការបង្កើតសាលាក្ដីនៅក្នុងប្រទេស ហើយថែមទាំងចាត់ឱ្យមានរ៉េស៊ីដង់បារាំងនៅអមព្រះមហាក្សត្រ ។ ក្រោយមក សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយការគ្រប់គ្រងរាជសម្បត្តិក៏មិនមានអ្វីជាឧបសគ្គទៀតឡើយ ។ ក្សត្រអង្គវតីបានធ្វើពិធីអភិសេកឡើងសោយរាជ្យនៅទីក្រុងឧដុង្គនៅថ្ងៃទី 03 ខែមិថុនា ឆ្នាំ 1864 ដោយមាននាមសម្រាប់រាជ្យថា " ព្រះបាទនរោត្តម " ។

# 2. នយោបាយកំណែទម្រង់សង្គមខ្មែរ

## 2.1. កំណែទម្រង់ឆ្នាំ 1877

### ក. មូលហេតុ

កត្តាពីរសំខាន់ៗដែលជំរុញឱ្យបារាំងដាក់កម្មវិធីកំណែទម្រង់សង្គមនៅក្នុងឆ្នាំ 1877 គឺកត្តាសេដ្ឋកិច្ចពាណិជ្ជកម្ម និងនយោបាយ ។

- កត្តាសេដ្ឋកិច្ចពាណិជ្ជកម្ម : អស់រយៈពេល 14 ឆ្នាំមកហើយ ពាណិជ្ជករបារាំងពុំអាចពង្រីកសកម្មភាពរកស៊ីនៅក្នុងប្រទេសកម្ពុជាបានឡើយ ដោយសារប្រជាជនកម្ពុជារស់នៅតាមបែបប្រពៃណីសក្តិភូមិ មិនចាប់អារម្មណ៍នឹងប្រព័ន្ធទីផ្សារ ។
- កត្តានយោបាយ : នៅលើកត្តានយោបាយ បារាំងរំពឹងថាអាចពង្រឹងអំណាចគ្រប់គ្រងរបស់ខ្លួននៅក្នុងឥណ្ឌូចិន ។ ឥណ្ឌូចិនត្រូវមានប្រព័ន្ធឯកភាពបែបបារាំងទាំងនៅក្នុងតំបន់ និងទាំងនៅក្នុងរចនាសម្ព័ន្ធសង្គម ។

### ខ. ទិសដៅ

ដោយសារមូលហេតុខាងលើនេះ ទើបបារាំងមានទិសដៅចង់កែប្រែសង្គមប្រពៃណីទំនៀមទម្លាប់សក្តិភូមិខ្មែរឱ្យទៅជាសង្គមមូលធននិយម ដែលជាប្រព័ន្ធទីផ្សារសេរី ដូចសង្គមបារាំងដែរ ។

### គ. កម្មវិធី

ដើម្បីសម្រេចទិសដៅនេះ បារាំងបានរៀបចំកម្មវិធី និងធ្វើសកម្មភាពនយោបាយដូចខាងក្រោម ៖

- នៅក្នុងសង្គមកម្ពុជា ចាំបាច់ត្រូវមានកម្មវិធីនយោបាយថ្មីមួយដើម្បីកាត់បន្ថយអំណាចស្ដេចត្រាញ់ មន្ត្រីសក្តិភូមិ និងលុបបំបាត់វណ្ណៈខ្ញុំគេ បង្កើនចំនួនម្ចាស់កម្មសិទ្ធិ ដែលជាកម្លាំងចលករជួយជំរុញកម្មវិធីកំណែទម្រង់បារាំងឱ្យបានជោគជ័យ ។ បារាំងបានដាក់ចុះនូវកម្មវិធីបង្កើតតុលាការជាន់ខ្ពស់គ្រប់គ្រងលើតុលាការមូលដ្ឋាន បង្កើតប្រព័ន្ធពន្ធដារថ្មី ។

• បញ្ហាជាមួយរាជាណាចក្រសៀម បារាំងបានរៀបចំជាហូរហែ ឲ្យឡិតតែគ្មានចែងក្នុងកម្មវិធីកំណែទម្រង់ឆ្នាំ 1877 ក៏ពិតមែន ។ នេះជាការមួយមានសារៈសំខាន់ណាស់ ដើម្បីកសាងប្រព័ន្ធឯកភាពមួយក្នុងសហព័ន្ធឥណ្ឌូចិនបារាំង ។ ក្រោយពីបានធ្វើឱ្យរាជាណាចក្រសៀមទទួលស្គាល់ការគ្រប់គ្រងរបស់បារាំងលើប្រទេសកម្ពុជារួចមក បារាំង-សៀមបានចរចាអំពីបញ្ហាព្រំប្រទល់ដែនប្រទេសទាំងពីរ ។ ជាលទ្ធផល នៅក្នុងឆ្នាំ 1904 សៀមបានប្រគល់ទឹកដីភាគខាងជើងគឺមូលព្រៃ ស្ទឹងត្រែងមកឱ្យខ្មែរវិញ ។ ឆ្នាំ 1907 សន្ធិសញ្ញាបារាំង-សៀមស្តីពីការប្រគល់ខេត្តបាត់ដំបង សៀមរាប សេរីសោភ័ណមកឱ្យខ្មែរជាបន្តទៀត ។ នៅឆ្នាំ 1908 បារាំងបានធ្វើផែនទីមួយមានឈ្មោះថា ផែនទីដងរែកដែលទទួលស្គាល់ដោយតំណាងបារាំង-សៀមនិងនៅលើឆាកអន្តរជាតិរហូតដល់ពេលបច្ចុប្បន្ន ។

## 2.2. កំណែទម្រង់ឆ្នាំ 1884

ភាពមិនអើពើរបស់មន្ត្រីរាជការ ស្តេចត្រាញ់ សក្តិភូមិខ្មែរចំពោះកម្មវិធីដែលបារាំងបានដាក់ចុះក្នុងឆ្នាំ 1877 បានធ្វើឱ្យអាជ្ញាធរបារាំងក្រេវក្រោធយ៉ាងខ្លាំង ។ នៅឆ្នាំ 1884 អំណាចអាណាព្យាបាលបារាំងបានប្រឹងប្រែងទាញស្ថាប័នរដ្ឋបាលកម្ពុជាទាំងអស់ដាក់ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ ដូច្នេះកំណែទម្រង់ឆ្នាំ 1884 ជាការមួយដែលបារាំងចង់ប្រែក្លាយប្រទេសកម្ពុជាពីប្រទេសក្រោមអាណាព្យាបាលឱ្យទៅជាប្រទេសក្រោមអាណានិគមរបស់ខ្លួនវិញ ។

កម្មវិធីកំណែទម្រង់ឆ្នាំ 1884 បានបន្តខ្លឹមសារនៃកម្មវិធីឆ្នាំ 1877 ប៉ុន្តែអ្វីដែលបន្ថែមពីលើនេះគឺការដាក់ប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់បារាំងផ្ទាល់ ។ ឈរលើកិច្ចព្រមព្រៀងឆ្នាំ 1884 បារាំងបានរៀបចំថ្នាក់ដឹកនាំខេត្តដោយបារាំងផ្ទាល់គឺ (មាត្រា 3) ។ ខេត្ត 58 ត្រូវបង្រួមបញ្ចូលគ្នាមកត្រឹម 8 ខេត្ត ឱ្យស្ថិតនៅក្រោមអំណាចរ៉េស៊ីដង់ ។ រ៉េស៊ីដង់ត្រូវមានការតែងតាំងពី រ៉េស៊ីដង់ សេណេរ៉ាល់ (ថ្នាក់ដឹកនាំបារាំងលើសហព័ន្ធឥណ្ឌូចិន)តាមសេចក្តីស្នើសុំពីរ៉េស៊ីដង់ស៊ុបពែរីយ័រ ។ រ៉េស៊ីដង់ស៊ុបពែរីយ័រ(ថ្នាក់ដឹកនាំបារាំងលើប្រទេសកម្ពុជា) ធ្វើការគ្រប់គ្រងការងារពេញផ្ទៃប្រទេសកម្ពុជា ក្រោមបញ្ជាផ្ទាល់ពីរ៉េស៊ីដង់សេណេរ៉ាល់(កូសាំងស៊ីន) ។ ពេលនោះ ព្រះមហាក្សត្រកម្ពុជាលែងមានសិទ្ធិសម្រេចអ្វីទៀតហើយ ក្រៅពីចាំទទួល និងយល់ព្រមរាល់សេចក្តីសម្រេចចិត្តរបស់រ៉េស៊ីដង់ស៊ុបពែរីយ័រ ។ ក្នុងការបំពេញការងារដឹកនាំ រ៉េស៊ីដង់ស៊ុបពែរីយ័រមានក្រុមប្រឹក្សាដែលមានតួនាទីជាអ្នកជំនួយការងារដែលក្នុងនោះមានសមាជិកចំនួន 12 នាក់គឺ 6 នាក់ជាមន្ត្រីពាណិជ្ជកម្មបារាំង ដែលតែងតាំងដោយរ៉េស៊ីដង់សេណេរ៉ាល់ និងជនជាតិខ្មែរ 3 នាក់ ចិនម្នាក់ ចាមម្នាក់ យួនម្នាក់ ដែលតែងតាំងដោយព្រះមហាក្សត្រដោយមានការអនុម័តយល់ព្រមពីរ៉េស៊ីដង់សេណេរ៉ាល់នៅកូសាំងស៊ីន ។

## 2.3. ការបះបោររបស់ប្រជាជនកម្ពុជាឆ្នាំ 1886

ដោយបានមើលឃើញថា "កិច្ចព្រមព្រៀងឆ្នាំ 1884" ធ្វើឱ្យពួកគេបាត់បង់សិទ្ធិអំណាចដែលធ្លាប់មានពីមុនមក ពួកមន្ត្រីសក្តិភូមិខ្មែរបានបំបះបំបោរប្រជាជនឱ្យចូលរួមធ្វើការប្រឆាំងតវ៉ា ។ នៅឆ្នាំ 1885 ការបះបោរដែលបានរៀបចំឡើងដោយមន្ត្រីរាជការបានផ្ទុះឡើង ហើយបានរីករាលដាលយ៉ាងលឿនពាសពេញផ្ទៃប្រទេស ។ បាតុករបានលើកបដាទាមទារឱ្យបារាំងប្រគល់អំណាចថ្វាយព្រះមហាក្សត្រខ្មែរវិញ ។ ការបះបោររបស់ពួកបាតុករ ពុំមានឥរិយាបថជាការទាមទារឯករាជ្យទេ ចំណុចដែលសំខាន់គឺ គេទាមទារឱ្យបារាំងដកអំណាចគ្រប់គ្រងដោយផ្ទាល់របស់ខ្លួនចេញពីប្រព័ន្ធរដ្ឋបាលខ្មែរ ។

ដោយមិនចង់ឱ្យការបះបោរនេះប្រែក្លាយជាការបះបោរទាមទារឯករាជ្យជាតិ បារាំងបានសម្របសម្រួលនិងមន្ត្រីរាជការដើម្បីធ្វើការចរចារកដំណោះស្រាយ ។ នៅឆ្នាំ 1886 កិច្ចព្រមព្រៀងបានឈានដល់ការចុះហត្ថលេខាទ្វេភាគីបារាំង-ខ្មែរ ។ ក្រោយការចុះហត្ថលេខា ប្រជាជនបានបញ្ឈប់ការបះបោរយ៉ាងឆាប់រហ័ស ។

ដោយអាស្រ័យទៅនឹងកិច្ចព្រមព្រៀងឆ្នាំ 1886 ព្រះមហាក្សត្រ និងមន្ត្រីរាជការខ្មែរបានទទួលមកវិញនូវតួនាទីក្នុងរដ្ឋបាល ។ ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 1887 ប្រព័ន្ធរដ្ឋបាលកម្ពុជាត្រូវបានស្តារឡើងវិញ ។ រ៉េស៊ីដង់ស៊ុបពែរីយ័របារាំងនៅក្នុងប្រទេសកម្ពុជា បានបន្តការងារជាទីប្រឹក្សាព្រះមហាក្សត្រខ្មែរដូចមុនដដែល ។

ដូច្នេះការប៉ុនប៉ងរបស់បារាំងដើម្បីកែប្រែសង្គមខ្មែរពីសង្គមប្រពៃណីទំនៀមទម្លាប់ឱ្យទៅជាសង្គមមួយ ដែលមានបែបផែនផលិតកម្មមូលធននិយម ប្រព័ន្ធទីផ្សារសេរីបានទទួលបរាជ័យជាលើកទី 2 ។

## 2.4. មធ្យោបាយថ្មីរបស់បារាំងក្នុងទិសដៅធ្វើកំណែទម្រង់សង្គមកម្ពុជា

យោងតាមកិច្ចព្រមព្រៀងឆ្នាំ 1886 បារាំងបានផ្អាកសកម្មភាពទិសដៅក្នុងការធ្វើកំណែទម្រង់សង្គមខ្មែរជាបណ្តោះអាសន្ន ។ ប៉ុន្តែ គេមិនបានបោះបង់ផ្លូវនេះចោលទាំងស្រុងនោះឡើយ ។ បារាំងបានជ្រើសរើសយកមធ្យោបាយថ្មីដោយប្រើទឹកប្រាក់ដើម្បីទម្លុះទម្លាយភាពរាំងស្ទះគម្រោងការរបស់គេ ។ នៅក្នុងដំណាក់កាលឆ្នាំ 1888-1889 រដ្ឋបាលបារាំងបានចុះហត្ថលេខាជាមួយព្រះមហាក្សត្រព្រះនរោត្តម លើកិច្ចព្រមព្រៀងមួយចំនួនដែលមានរូបភាពជាសេចក្តីប្រកាសរបស់ព្រះមហាក្សត្រប្រគល់អំណាចទៅឱ្យបារាំងវិញ ។ លទ្ធផលនៃសេចក្តីសម្រេចព្រះទ័យរបស់ព្រះមហាក្សត្រក្នុងការផ្តល់អំណាចឱ្យបារាំងគឺ ៖

• អនុញ្ញាតឱ្យខ្មែរស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលបារាំង ជាថ្នូរនិងការលើកកម្ពស់ការផ្គត់ផ្គង់ដល់ព្រះបរមរាជវាំង និងសេចក្តីត្រូវការសំខាន់ៗ (ក្នុងឆ្នាំ 1890) ។
• បង្កើតក្រុមការងារពិសេសដែលស្ថិតក្រោមការដឹកនាំរបស់រដ្ឋបាលបារាំង (ចាប់ពីខែមករា ឆ្នាំ 1892) ។ រាល់ការបង់ពន្ធទាំងអស់ដែលប្រមូលដោយមន្ត្រីខ្មែរ ត្រូវប្រគល់ទៅឱ្យក្រុមការងារពិសេស ។ បារាំងធ្វើដូចនេះ ដើម្បីលុបបំបាត់អំពើពុករលួយនៅក្នុងជួរមន្ត្រីពន្ធដារខ្មែរ ។

ចំពោះបញ្ហាជាមួយនិងមន្ត្រីរាជការខ្មែរ បារាំងក៏បានយកប្រាក់មកធ្វើជាមធ្យោបាយដោះស្រាយដែរ ។ បារាំងបានអនុម័តច្បាប់ស្តីពីប្រាក់បៀវត្សមន្ត្រីរាជការ ។ មន្ត្រីរាជការខ្មែរអាចទទួលប្រាក់បៀវត្សខ្ពស់ ។ ជាការឆ្លើយតបគេឱ្យមន្ត្រីរាជការខ្មែរត្រូវតែធ្វើការដោយភក្តីភាពនិងអស់ពីសមត្ថភាព បើពុំដូច្នេះទេ គេនឹងត្រូវបាត់បង់ការងារ ។ បារាំងបានបង្កើតសាលារដ្ឋបាលសម្រាប់មន្ត្រីខ្មែរ ។ ជាលក្ខខណ្ឌមន្ត្រីរាជការទាំងអស់ត្រូវឆ្លងកាត់សាលានេះ ។ មន្ត្រីរាជការដែលធ្លាប់តែជំទាស់តវ៉ាប្រឆាំងកំណែទម្រង់របស់បារាំង ក៏ប្រែជាស្ងប់ស្ងាត់ទៅវិញ ។

ដូច្នេះទោះបីបារាំងបានផ្អាកសកម្មភាពបន្តិចនៅឆ្នាំ 1886 ក៏ពិតមែន ប៉ុន្តែក្នុងរយៈពេលយ៉ាងខ្លីប៉ុណ្ណោះ បារាំងក៏អាចឈ្លមយកអំណាចមកវិញទាំងអស់ ជាពិសេសអំណាចគ្រប់គ្រងទាំងស្រុងលើប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធពន្ធដារខ្មែរ ។

## 2.5. លទ្ធផលកំណែទម្រង់សង្គមរបស់បារាំង

ការធ្វើកំណែទម្រង់រដ្ឋបាលរបស់អាណានិគមនិយមបារាំងនៅក្នុងប្រទេសកម្ពុជាឈានចូលទៅដល់ការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ និងជំរុញឱ្យសង្គមមានការអភិវឌ្ឍ ។ បើប្រៀបធៀបក្នុងរយៈកាល 25ឆ្នាំមុន(1884-1910) ហេដ្ឋារចនាសម្ព័ន្ធសង្គមទាំងអស់ត្រូវបានកែប្រែមុខមាត់ថ្មី ។

នៅក្នុងវិស័យរដ្ឋបាលដែលធ្លាប់តែមានភាពអនាធិបតេយ្យ អសមត្ថភាព និងគ្មានប្រសិទ្ធភាពត្រូវបានជំនួសដោយរបៀបគ្រប់គ្រងរដ្ឋបាលថ្មីរបស់អាណានិគមនិយមបារាំងដែលដឹកនាំដោយ រ៉េស៊ីដង់នៅរាជធានីភ្នំពេញ និងនៅតាមខេត្ត ។

ដោយសារកំណែទម្រង់នៅលើប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធិដីធ្លី និងការលុបបំបាត់របបទាសភាព វិស័យចិត្តសាស្ត្រសង្គមក៏មានការប្រែប្រួលច្រើនណាស់ដែរ ។ ការបង្កើតឡើងនូវការចុះបញ្ជីដីធ្លី ផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់របៀបបុរាណ បង្កើតកម្មសិទ្ធិលើដីធ្លី ការបង្កើតប្រព័ន្ធច្បាប់ថ្មី គឺជាជំនួយផ្នែកស្មារតីនៃសង្គមខ្មែរឱ្យរស់នៅប្រកបដោយឯករាជ្យ និងស្ថិរភាពជាពិសេសម្ចាស់ដីតូចតាច ។

វិស័យពាណិជ្ជកម្មនៅក្នុងសង្គមខ្មែរបានលេចឡើងជាសកម្មភាពពាណិជ្ជកម្មយ៉ាងសកម្មក្នុងការទិញដូរអចលនវត្ថុ ការដាក់បញ្ចាំស្របពេលនឹងការធ្វើជំនួញស្រូវ-អង្ករនៅក្នុងទីក្រុង ។ ស្ថានភាពបែបនេះបានលេចឡើងនូវទំនាក់ទំនងប្រព័ន្ធ "ទីផ្សារ" ថ្មីដែលជាទំនាស់ទៅនឹងទំនៀមទម្លាប់ប្រពៃណីនៅក្នុងសង្គមខ្មែរ ។ ជាលទ្ធផលមានលេចឡើងនូវពួកអ្នកមានដែលភាគច្រើនជាជនជាតិចិននិងយួន ។ រីឯប្រជាកសិករខ្មែរភាគច្រើនក៏បានក្លាយជាជនរងគ្រោះអស់ដីធ្លីដោយសារការលក់បញ្ចាំ ។

ក្នុងវិស័យកសិកម្មមានការបង្កើតប្រព័ន្ធកសិកម្ម "កសិដ្ឋាន" ។ ចំពោះប្រព័ន្ធសេដ្ឋកិច្ចកសិកម្មបែបនេះ កសិករខ្មែរពុំបានត្រៀមខ្លួនទុកជាមុនទេ ទាំងការយល់ដឹង ទាំងផ្នែកសម្ភារៈ(អវត្តមានកម្លាំង និងមធ្យោបាយផលិតកម្ម និងការសម្របសម្រួលឱ្យមានស្ថិរភាពសេដ្ឋកិច្ចទីផ្សារ) ។

ដូច្នេះលទ្ធផលនៃកំណែទម្រង់ទៅលើវិស័យកសិកម្មធ្វើឱ្យកម្ពុជាមានមុខមាត់នៅលើទីផ្សារអន្តរជាតិ ។ សង្គមកម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធផ្គត់ផ្គង់ផលិតផលលើទីផ្សារដែលកម្លាំងផលិតកម្មរស់នៅបែបធម្មជាតិរបស់កសិករខ្មែរភាគច្រើន ។ ទន្ទឹមនឹងនេះសង្គមខ្មែរបានប្រឈមនឹងបញ្ហាថ្មីបន្ថែមទៀតនៅក្នុងសេដ្ឋកិច្ចកសិកម្មគឺ ដំណើរការវិវត្តភាពខុសគ្នានៃស្ថានភាពកសិករនៅតាមទីជនបទ ដែលប្រែក្លាយជាកសិករស៊ីឈ្នួលធ្វើស្រែ (ដោយសារបាត់បង់ដីធ្លី) និងម្ចាស់ដីធំៗជាអ្នកគ្រប់គ្រងដីផលិតកម្មទាំងនោះ ។ គម្លាតរវាងអ្នកមាន និងអ្នកក្របានបង្កើតជាបញ្ហាទំនាស់យ៉ាងស្រួចស្រាល់បន្ទាប់ពីបារាំងប្រគល់ឯករាជ្យឱ្យប្រទេសកម្ពុជានៅឆ្នាំ 1953 ។ ពួកអាណានិគមបានបន្សល់បញ្ហាទាំងនេះសម្រាប់អ្នកកាន់អំណាចកម្ពុជាធ្វើការដោះស្រាយ ។

## ៣. ការតស៊ូដើម្បីឯករាជ្យជាតិ និងសន្និសីទក្រុងហ្សឺណែវ 1954

នៅក្នុងប្រទេសកម្ពុជា ចលនាតស៊ូដើម្បីឯករាជ្យជាតិ បានចែកចេញជាពីរផ្នែកផ្សេងគ្នាគឺ

- ការតស៊ូដោយអាវុធ ដឹកនាំដោយកម្លាំងនៃចលនាតស៊ូខ្មែរឥស្សរៈ ដែលមានការជួយគាំទ្រពីសំណាក់កងកម្លាំងវៀតមិញ ។
- ការតស៊ូដោយសន្តិវិធី ដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ (នយោបាយការទូត) ។

### ៣.១. រណសិរ្សខ្មែរឥស្សរៈ

នៅចុងឆ្នាំ 1944 បក្សកុម្មុយនីស្តឥណ្ឌូចិនបានចាប់ផ្តើមបង្កើតកងទ័ពជាតិនៅប្រទេសវៀតណាម ។ នានិទាឃរដូវឆ្នាំ 1945 បានចាប់ផ្តើមធ្វើបាតុកម្មនៅក្នុងតំបន់រំដោះនៃប្រទេសកម្ពុជា ។

នៅខែសីហា ឆ្នាំ 1945 នៅប្រទេសវៀតណាមក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ការបះបោរបានផ្ទុះយ៉ាងខ្លាំង ។ នៅថ្ងៃទី2 ខែកញ្ញា ឆ្នាំ 1954 គេបានបង្កើតរដ្ឋឯករាជ្យមួយឈ្មោះ "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" ។

ពួកចិនជាតិនិយមដែលកាន់កាប់ភូមិភាគខាងជើងនៃប្រទេសវៀតណាម និងពួកអង់គ្លេសបារាំងដែលបានកាន់កាប់ភូមិភាគខាងត្បូងបានប្រយុទ្ធគ្នាដើម្បីទឹកដីអាណានិគមនិយមរបស់ខ្លួន ។ វៀតណាមត្រូវការចាំបាច់សម្ងំបង្កើតកម្លាំងរដ្ឋអំណាចថ្មីរបស់ខ្លួន ។ នៅឆ្នាំ 1946 សង្គ្រាមទាមទារឯករាជ្យជាតិបានផ្ទុះឡើង និងរាលដាលគ្រប់ទីកន្លែងក្នុងប្រទេសវៀតណាម ហើយចលនានេះរាលដាលទៅក្នុងទឹកដីកម្ពុជា ។ ក្រោយមកទើបលេចចេញចលនាតស៊ូប្រដាប់អាវុធរបស់ខ្មែរឥស្សរៈនៅកម្ពុជា ។

រណសិរ្ស "ខ្មែរឥស្សរៈ" ដំបូងពុំទាន់បានកសាងមូលដ្ឋានរបស់ខ្លួនទេ ។ ទោះជាយ៉ាងណាក៏ដោយ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន រណសិរ្ស "ខ្មែរឥស្សរៈ" បានធ្វើសកម្មភាពយ៉ាងសកម្ម ។ កងទ័ពជាតិវៀតណាមខាងជើងបានចូលមកដល់ប្រទេសកម្ពុជា ដែលធ្វើឱ្យការប្រយុទ្ធប្រឆាំងនឹងពួកអាណានិគមបារាំងកាន់តែខ្លាំងគ្នាឡើង ។ នៅអំឡុងឆ្នាំ 1947-1948 ដោយបានទទួលការគាំពារពីកម្លាំងកងទ័ពវៀតណាម រណសិរ្ស "ខ្មែរឥស្សរៈ" បានកសាងមូលដ្ឋានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ នៅចុងឆ្នាំ 1949 កងទ័ពខ្មែរឥស្សរៈ បានពង្រីកតំបន់កាន់កាប់របស់ខ្លួន នៅលើផ្ទៃដី $\frac{1}{3}$ នៃផ្ទៃប្រទេសទាំងមូល ដែលមានប្រជាជនចំនួនប្រហែល 1 លាននាក់រស់នៅ ។ ដោយពើបប្រទះនូវព្រឹត្តិការណ៍យ៉ាងនេះសម្តេចព្រះនរោត្តមសីហនុ និងបារាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅឆ្នាំ 1949 ដែលមានអត្ថន័យថា ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យមួយស្ថិតនៅក្នុងសហព័ន្ធឥណ្ឌូចិនបារាំង ។

## ១.2. ព្រះរាជដំណើរទៅកាន់ប្រទេសបារាំង

នៅថ្ងៃទី 09 ខែកុម្ភៈ ឆ្នាំ 1953 ព្រះអង្គបានយាងចេញពីប្រទេសកម្ពុជាឆ្ពោះទៅកាន់ប្រទេសបារាំង ដោយប្រគល់កិច្ចការប្រទេសជាតិឱ្យព្រះរាជបិតា ព្រះបាទសុរាម្រិត និងឯកឧត្តម ប៉ែននុត ជាឧបនាយករដ្ឋមន្ត្រី ។ នៅប្រទេសបារាំងព្រះអង្គទ្រង់គង់នៅទីក្រុងណាពួលក្នុងតំបន់អាល់ខាងក្រោម ( Alpes Maritimes ) ហើយក៏បានផ្ញើសារទៅលោក វ៉ាំងសង់ អូរីយ៉ូល នៅថ្ងៃទី 05 ខែមីនា ឆ្នាំ 1953 ដោយមានសេចក្តីថា "នៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំមកប្រទេសបារាំង ខ្ញុំមានជំនឿថាបារាំងនឹងសន្យាផ្តល់នូវអ្វីដែលខ្ញុំបានសន្យាជូនប្រជាជនរបស់ខ្ញុំ គឺការនាំមកនូវឯករាជ្យពេញលេញជូនមាតុភូមិ ។ នៅក្នុងន័យនេះ បើប្រទេសកម្ពុជាមិនបានទទួលអំណាចខាងតុលាការ យោធា ហិរញ្ញវត្ថុ និង

សេដ្ឋកិច្ចទេនោះ ឈ្មោះថាប្រទេសកម្ពុជាមិនបាននូវឯករាជ្យពេញលេញនៅឡើយ ។ អស់រយៈពេលពីរសប្តាហ៍ក្នុងការរង់ចាំចម្លើយពីប្រធានាធិបតីបារាំងដោយពុំបានទទួលផ្លែផ្កាមក ព្រះអង្គបានផ្ញើសារលិខិតជាលើកទីពីរ ដោយសុំឱ្យបារាំងឆ្លើយនឹងសំណើនេះឱ្យឆាប់បំផុត ។ ចម្លើយដែលព្រះអង្គបានទទួលគឺបដិសណ្ឋារកិច្ចរបស់លោកអូរីយ៉ូលក្នុងពិធីលៀងសាយភោជន៍មួយនៅវិមាន អេលីហ្សេ នៅថ្ងៃពុធទី 25 ខែមីនា ឆ្នាំ 1953 ប៉ុន្តែមិនមានន័យអ្វីសម្រាប់បញ្ហានយោបាយឡើយ ។

## ៣.៣. ព្រះរាជដំណើរទៅកាន់ប្រទេសកាណាដា និងសហរដ្ឋអាមេរិក

ការយាងទៅប្រទេសកាណាដាដោយសង្ឃឹមថាប្រទេសនេះជាប្រទេសនិយាយភាសាបារាំង ទទួលអរិយធម៌បារាំង ហើយអាចមានឥទ្ធិពលក្នុងការទាក់ទាញរដ្ឋាភិបាលបារាំងឱ្យយល់អំពីបញ្ហារបស់ប្រទេសនៅក្រោមអាណានិគម ។ នៅថ្ងៃទី 12 ខែមេសា ឆ្នាំ 1953 ព្រះអង្គបានធ្វើសន្និសីទកាសែតមួយតាមរយៈវិទ្យុកាណាដា ដោយបញ្ជាក់ថាការផ្សព្វផ្សាយរបស់ពួកឥស្សរៈ និងកុម្មុយនីស្តមានឥទ្ធិពលខ្លាំងក្នុងការទាក់ទាញប្រជាជន ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពនៃប្រទេសកម្ពុជា ។ នៅទីក្រុងតូរ៉ុងតូ ព្រះអង្គបានប្រកាសថាលទ្ធផលនៅតែអវិជ្ជមានដដែល បើប្រជាជននៃប្រទេសជឿនលឿនមិនចូលរួមក្នុងបុព្វហេតុនៃការតស៊ូដ៏ត្រឹមត្រូវនេះ ។ ព្រះអង្គបានចាកចេញពីប្រទេសកាណាដាមកសហរដ្ឋអាមេរិក ដំណឹងនេះបានធ្វើឱ្យមេដឹកនាំសំខាន់របស់ខ្មែរឥស្សរៈឈ្មោះ ពុត ឆាយ និងនិល ពេជ្យ បាននាំទ័ពមកចុះចូលនឹងកងទ័ពខេមរភូមិន្ទ ។ នៅសហរដ្ឋអាមេរិក ព្រះអង្គបានជួបជាមួយរដ្ឋលេខាធិការក្រសួងការបរទេស ចន ហ្វូស្ទ័រឌូល(John Foster Dulles) នៅទីក្រុងវ៉ាស៊ីនតោន ដើម្បីពន្យល់នូវគំនិតខាងលើ ។ ក្នុងពេលនោះ លោករដ្ឋមន្ត្រីការបរទេសបាននិយាយថាសហរដ្ឋអាមេរិកក៏មានការពេញចិត្តចំពោះការផ្តល់ឯករាជ្យដល់កម្ពុជាដែរ ប៉ុន្តែនៅពេលនេះ សហរដ្ឋអាមេរិកកំពុងជួបប្រទះនូវបញ្ហាមួយដែលមិនទាន់បានដោះស្រាយគឺបញ្ហាសង្គ្រាមឥណ្ឌូចិនលើកទីមួយដែលមិនទាន់បានទទួលលទ្ធផលឈ្នះឬចាញ់[1] ។ ប៉ុន្តែ សហរដ្ឋអាមេរិកសន្យាថានឹងជួយកម្ពុជាឱ្យទទួលឯករាជ្យពេញលេញនៅពេលណាដែលសង្គ្រាមឥណ្ឌូចិនបានចប់សព្វគ្រប់ ។ លទ្ធផលនៃជំនួបនេះបានធ្វើឱ្យព្រះអង្គខកព្រះទ័យជាខ្លាំង ប៉ុន្តែព្រះអង្គនៅតែមានក្តីសង្ឃឹមក្នុងការទាក់ទាញអ្នកនយោបាយបរទេសដើម្បីឱ្យយល់ពីបញ្ហារបស់ខ្មែរ ។ នៅទីក្រុងញូយ៉ក ព្រះអង្គផ្តល់បទសម្ភាសន៍មួយជាមួយភ្នាក់ងារកាសែតញូវយ៉កថែម(New York Times) ។ នៅថ្ងៃអាទិត្យទី 19 ខែមេសា ឆ្នាំ 1953 កាសែតនេះបានចុះផ្សាយលើទំព័រមុខរបស់ខ្លួននូវអត្ថបទដែលមានឥទ្ធិពលដូចគ្រាប់បែកមួយគ្រាប់ ។ អត្ថបទនោះបញ្ជាក់ថាប្រសិនបើប្រទេសនៅឥណ្ឌូចិនមិនបានទទួលឯករាជ្យពីបារាំងទេនោះ ប្រជាជនខ្មែរនៅទូទាំងប្រទេស

---

(1). Que sais-je . les Guerres Indochinoises, P. 98

និងក្រោកឡើងធ្វើការប្រឆាំងនឹងអាណានិគម នៅពេលនោះ ជោគជ័យរបស់ពួកកុម្មុយនីស្តនឹងកើតមានជាស្វ័យប្រវត្តិ ។ ប្រសិទ្ធភាពនៃការសែតញូវយ៉កថែមបានជំរុញឱ្យបារាំងទទួលយកការចរចាជាថ្មីនៅទីក្រុងប៉ារីសនៅថ្ងៃ 23 ខែមេសាឆ្នាំ 1953 ដែលមានឯកឧត្តមប៉ែន នុត និងព្រះអង្គម្ចាស់មុនីរ៉េតតំណាងប្រតិភូខ្មែរ ។ នៅថ្ងៃទី 09 ខែឧសភា ឆ្នាំ 1953 បារាំងបានប្រគល់ទ័ពផ្នែកអន្តរាគមន៍ដាក់ក្រោមបញ្ជាការរបស់ខ្មែរ និងផ្នែកផ្សេងៗទៀតជាបន្តបន្ទាប់ ប៉ុន្តែផ្នែកខ្លះប្រគល់ឱ្យហើយ តែនាំឱ្យខូចផលប្រយោជន៍ខ្មែរដូចជា បញ្ហាហិរញ្ញវត្ថុជាដើម [1] ។

## ៤.៤. ដំណើរយាងទៅរាជាណាចក្រថៃ

ព្រះបាទ នរោត្តម សីហនុ ទ្រង់បានរៀបចំព្រះរាជដំណើរទស្សនកិច្ចទៅកាន់ប្រទេសថៃ ដោយសំចតសម្រាកព្រះកាយនៅខេត្តសៀមរាបមុននឹងឆ្ពោះទៅកាន់ប្រទេសថៃតាមប៉ោយប៉ែត ។ នៅថ្ងៃទី 12 ខែមិថុនា ឆ្នាំ 1953 ព្រះអង្គបានប្រកាសយ៉ាងឱឡារិកនៅខេត្តសៀមរាបថា ប្រជាជាតិខ្មែរទាំងមូលបានសម្តែងនូវទឹកចិត្តដ៏មោះមុតក្នុងការទាមទារឯករាជ្យពីបារាំងឱ្យបានដាច់ខាត ទោះបីជាបារាំងពុំមានឆន្ទៈក្នុងការប្រគល់ឯករាជ្យឱ្យយើងក៏ដោយ ។

នៅថ្ងៃទី 14 ខែមិថុនា ឆ្នាំ 1953 ព្រះអង្គបានយាងទៅកាន់ទីក្រុងបាងកកជាមួយរាជវង្សានុវង្សមួយចំនួន ប៉ុន្តែដំណើរទស្សនកិច្ចនេះត្រូវបាននាយករដ្ឋមន្ត្រីថៃ ហ្លួង វិបុល សង្គ្រាមទទួលយ៉ាងសោះអង្គើយ ។

នៅប្រទេសកម្ពុជាឯណោះវិញ ពួកប្រជាធិបតេយ្យដែលនិយមស្តាំបានឈប់បង្កជម្លោះ ហើយបានរួបរួមនឹងរាជរដ្ឋាភិបាល ។ ប្រជាជនខ្មែរទាំងប្រុសទាំងស្រីចំនួន 400 000 នាក់បានស្ម័គ្រចិត្តចូលបម្រើក្នុងកងជីវពលនារីក្លាហានដោយទទួលការហ្វឹកហាត់យ៉ាងសកម្ម ដោយប្តេជ្ញាថានឹងដង្ហែតាមព្រះបាទនរោត្តមសីហនុដើម្បីដណ្តើមយកឯករាជ្យជូនមាតុភូមិឱ្យបានទោះបីជាត្រូវបូជាជីវិតក៏ដោយ ។

នៅក្នុងសេចក្តីប្រកាសមួយចុះថ្ងៃ 07 ខែកក្កដា ឆ្នាំ 1953 ប្រទេសកម្ពុជាបានផ្ញើសារទៅកាន់ប្រទេសបារាំងពីអំណាចទាំងឡាយដែលខ្មែរទាមទារពីបារាំង ។ ក្រោយមក រដ្ឋាភិបាលបារាំងបានផ្ញើសារតបមកវិញថាបារាំងបានយល់ព្រមប្រគល់អំណាចទាំងអស់ឱ្យខ្មែរវិញជាបន្ទាន់ ។ ព្រះបាទនរោត្តមសីហនុបានយាងនិវត្តន៍ពីប្រទេសថៃមកវិញនៅថ្ងៃទី 21 ខែមិថុនា ឆ្នាំ 1953 ហើយព្រះអង្គក៏គង់នៅខេត្តសៀមរាប ជាតំបន់ស្វយ័តពុំមានវត្តមានកងទ័ពបារាំង ដើម្បីស្តាប់ការចរចានៅទីក្រុងភ្នំពេញ ។ នៅទីក្រុងភ្នំពេញថ្ងៃទី 29 ខែសីហា ឆ្នាំ 1953 មានការចុះហត្ថលេខានៃការព្រមព្រៀងបារាំង-ខ្មែរ ផ្ទេរ

(1) Le Cambodge de Sihanouk Pa. 19

ផ្នែកយុត្តិធម៌ និងប៉ូលិសមកឱ្យខ្មែរ ។ លុះដល់ថ្ងៃ 17 ខែតុលាមានការចុះហត្ថលេខាមួយទៀតស្តីពីការប្រគល់អធិបតេយ្យភាពខាងផ្នែកយោធាកម្ពុជាទាំងមូល ។ សម្តេចព្រះនរោត្តម សីហនុបានយាងចូលទីក្រុងភ្នំពេញនៅថ្ងៃទី 08 ខែវិច្ឆិកា ឆ្នាំ 1953 ប្រកបដោយស្នូរទះដៃ និងសំឡេងជ័យឃោសន៍យ៉ាងកងរំពង អបអរចំពោះការទាមទារឯករាជ្យជាតិជូនមាតុភូមិតាមការសន្យាពិតប្រាកដរបស់ទ្រង់ ដែលសក្តិសមជាព្រះបិតាឯករាជ្យជាតិ និងមហាវីរបុរសជាតិ ។ នៅថ្ងៃទី 09 ខែវិច្ឆិកា ឆ្នាំ 1953 មានប្រារព្ធធ្វើពិធីផ្ទេរអំណាចមួយនៅពីមុខព្រះបរមរាជវាំង ដោយឧត្តមសេនីយ ឡង់ ក្លាត ថ្វាយព្រះមហាក្សត្រខ្មែរយ៉ាងឱឡារិក ។ ចាប់ពីពេលនោះមក នៅថ្ងៃទី 09 ខែវិច្ឆិកា ត្រូវបានប្រកាសជាថ្ងៃឯករាជ្យនៃប្រទេសកម្ពុជាដែលខ្មែរយើងតែងតែប្រារព្ធធ្វើបុណ្យរំលឹកខួបនេះជារៀងរាល់ឆ្នាំ ។

## 3.5. ប្រតិបត្តិការបណ្តេញពួកវៀតមិញ

ពួកវៀតមិញបានចូលមកលាក់ខ្លួនដោយខុសច្បាប់ក្នុងទឹកដីខ្មែរតាំងពីឆ្នាំ 1949 ដោយមានការគាំទ្រពីពួកខ្មែរឥស្សរៈ ។ នៅថ្ងៃ 20 ខែកុម្ភៈ ឆ្នាំ 1954 មេដឹកនាំក្រុមខ្មែរឥស្សរៈសំខាន់ៗដូចជា សាវ៉ាង វង្ស និងទ្រង់ចន្ទ រង្សី បានចុះចូលជាមួយសង្គមជាតិវិញនៅខេត្តកំពង់ស្ពឺ ។ ព្រះបាទនរោត្តមសីហនុទ្រង់ធ្វើជាអគ្គមេបញ្ជាការកងទ័ពជាតិដឹកនាំប្រតិបត្តិការឈ្មោះមហាសាមគ្គីដើម្បីបណ្តេញពួកវៀតមិញឱ្យចេញពីទឹកដីខ្មែរចាប់ពីខេត្តបាត់ដំបងរហូតដល់ខេត្តក្រចេះ និងស្ទឹងត្រែង ។ នៅក្នុងខេត្តក្រចេះកងខេមរភូមិន្ទបានប្រយុទ្ធខ្លួនទល់នឹងខ្លួនប្រកបដោយវីរភាពស្នេហាជាតិ កម្ទេចកងទ័ពវៀតមិញនៅសមរភូមិចុងក្រោយ ដោយធ្វើឱ្យពួកកុម្មុយនីស្តវៀតមិញបរាជ័យយ៉ាងធ្ងន់ធ្ងរជាទីបំផុត ។

## 3.6. សន្និសីទក្រុងសឺណែវ

ថ្ងៃទី 26 ខែមេសា ឆ្នាំ 1954 សន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសបានចាប់ផ្តើម ដែលក្នុងនោះចូលតំណាងប្រទេសចំនួន 19 បានចូលរួមដូចជា ចក្រភពអង់គ្លេស សហភាពសូវៀត សហរដ្ឋអាមេរិក បារាំង សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសពាក់ព័ន្ធមួយចំនួនទៀត ។ នៅក្នុងឱកាសពិភាក្សាបញ្ហាឥណ្ឌូចិនមានមន្ត្រីការបរទេសអង់គ្លេស បារាំង សហភាពសូវៀត សហរដ្ឋអាមេរិក សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រាជាណាចក្រលាវ រាជាណាចក្រកម្ពុជា និងអំណាចបាវដាយវៀតណាមបានចូលរួម ។

នៅក្នុងដំណើរប្រព្រឹត្តិទៅនៃសន្និសីទនាទីក្រុងសឺណែវ គេបានចុះហត្ថលេខាលើឯកសារមួយចំនួន ដែលក្នុងនោះទាក់ទងនឹងកម្ពុជាដូចតទៅ ៖

- កិច្ចព្រមព្រៀងស្តីពីការបញ្ឈប់បទបាញ់គ្នានៅក្នុងប្រទេសកម្ពុជា ។
- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ និងការបោះឆ្នោត ។
- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនិងសម្ព័ន្ធភាពយោធា ការតាំងមូលដ្ឋានទ័ពបរទេស និងការជួយឧបត្ថម្ភកម្លាំងយោធាពីបរទេស ។
- សេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំងស្តីពីការដកកងទ័ពបារាំងចេញពីទឹកដីប្រទេសឥណ្ឌូចិន និងគោរពដល់ឯករាជ្យ អធិបតេយ្យភាពនៃប្រទេសនៅក្នុងឥណ្ឌូចិន ។
- សេចក្តីថ្លែងការណ៍របស់សន្និសីទទាក់ទងនិងកិច្ចព្រមព្រៀងសឺណែវ ។
- សេចក្តីថ្លែងការណ៍បិទសន្និសីទ ។

នៅក្នុងសេចក្តីប្រកាសបិទសន្និសីទសឺណែវ សមាជិកទាំងអស់បានប្រកាសស្តីអំពីកាតព្វកិច្ចរបស់ខ្លួន គោរពនូវឯករាជ្យ និងអធិបតេយ្យភាពរបស់ប្រទេសកម្ពុជានៅក្នុងឥណ្ឌូចិន ។

ដោយយោងទៅតាមកិច្ចព្រមព្រៀងនេះ សកម្មភាពយោធា ត្រូវបញ្ឈប់ទាំងស្រុងនៅលើទឹកដីកម្ពុជាចាប់ពីថ្ងៃទី 7 ខែសីហា ឆ្នាំ 1954 ។ កិច្ចព្រមព្រៀងបាននិយាយអំពីការដកទ័ពបរទេសចេញពីទឹកដីកម្ពុជាឱ្យអស់នៅក្នុងអំឡុង 90 ថ្ងៃ ។ ចំពោះកម្លាំងកងទ័ពខ្មែរឥស្សរៈត្រូវរំសាយក្នុងអំឡុង 30 ថ្ងៃ ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសស្តីពីការធានាដល់អតីតអ្នកចូលរួមក្នុងចលនាតស៊ូ ធានាដល់សិទ្ធិពលរដ្ឋ ការពារជីវិត ទ្រព្យសម្បត្តិ និងធានាដល់សិទ្ធិក្នុងការអនុវត្តសេរីភាពប្រជាធិបតេយ្យ ។ រាជរដ្ឋាភិបាលបានអះអាងចំពោះសេចក្តីសម្រេចចិត្តរបស់ខ្លួនថា "ប្រជាពលរដ្ឋកម្ពុជាទាំងអស់រួមរស់នៅក្នុងសហគមន៍ជាតិតែមួយ ដោយមិនប្រកាន់ពូជសាសន៍ និងធានាដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួនដូចមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ" ។ ដោយយោងទៅតាមមាត្រាអភិវឌ្ឍន៍សន្តិភាពូបនីយកម្ម ដែលមានចែងក្នុងសន្និសីទនាទីក្រុងសឺណែវ ការបោះឆ្នោតជាសកលនៅប្រទេសកម្ពុជាបានប្រព្រឹត្តទៅនៅឆ្នាំ 1955 ។

# 4. ចំណុចវិជ្ជមាននិងអវិជ្ជមាននៃអាណាព្យាបាលបារាំង

## 4.1. លទ្ធផលវិជ្ជមាន

នៅពេលត្រួតត្រាប្រទេសកម្ពុជា ពួកអាណានិគមបារាំងបានយល់ដឹងច្រើនអំពីអរិយធម៌ដ៏រុងរឿងរបស់ខ្មែរនៅក្នុងអតីតកាល ជាពិសេសក្នុងសម័យអង្គរ ។ ដោយជក់ចិត្តក្នុងការស្រាវជ្រាវរកឫសគល់នៃអរិយធម៌ខ្មែរ និងដោយសារការស្រាវជ្រាវមានទំហំធំធេង បារាំងបានបង្កើតវិទ្យាស្ថានមួយ

ដើម្បីសិក្សាស្រាវជ្រាវអំពីអតីតចក្រភពខ្មែរ ជាពិសេសសិល្បៈចម្លាក់ខ្មែរតាមជញ្ជាំងប្រាសាទដែលមានច្រើនស្មុគស្មាញនៅក្នុងប្រទេសសៀម វៀតណាម និងឡាវសព្វថ្ងៃ។ ក្រោមការផ្តួចផ្តើមរបស់លោក ប៉ូល ឌូមែរ(Paul Doumer) អគ្គទេសាភិបាលឥណ្ឌូចិន សាលាបារាំងចុងបូព៌ាប្រទេសត្រូវបានគេបង្កើតឡើងនៅទីក្រុងហាណូយ នៅថ្ងៃទី 15 ខែធ្នូ ឆ្នាំ 1898 ។ សាលានេះប្រមូលផ្តុំអ្នកប្រាជ្ញបារាំងដែលមានជំនាញខុសៗគ្នា ជាពិសេសជំនាញបុរាណវត្ថុវិទ្យា និងសិលាចារឹក ប៉ុន្តែគេត្រូវរង់ចាំការងារនេះរហូតដល់ឆ្នាំ 1907 គឺជាឆ្នាំដែលសៀមបានប្រគល់ទឹកដីខេត្តបាត់ដំបង សិរីសោភ័ណ និងមហានគរ (សៀមរាប)មកឱ្យខ្មែរវិញ ទើបចាប់ផ្តើមការងារជួសជុលប្រាសាទ និងធ្វើការសិក្សាស្រាវជ្រាវ ។ អ្នកប្រាជ្ញបារាំងដែលល្បីឈ្មោះដូចជាហ្សង់ កូមៃ(Jean Comaill)ស្លាប់នៅក្នុងឆ្នាំ 1906 នៅអង្គរដោយអំពើប្លន់ លោក ប៊ែរណាត ហ្វីលីព(Bernad Philippe) លោក ហ្សក សឺដែស(George Coedès1886-1969) លោក ហ្វីលីព ស្ទែន(Philippe Stern) និងលោក ហង្សរី ម៉ាសាល(Henri Marchal 1886-1969) ធ្វើការនៅប្រទេសកម្ពុជាក្នុងតួនាទីជារ៉េស៊ីដង់បារាំងប្រចាំតំបន់ខ្ពង់លើអស់រយៈពេល 25 ឆ្នាំក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ និងព្រះបាទនរោត្តមសីហនុ។ លោក អាដេម៉ាឡឺក្លែរ(Adhémard Leclère) បានសម្រេចនូវស្នាដៃដ៏ធំធេង តាមរយៈការនិពន្ធសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីសម័យកាលកកើតរដ្ឋដំបូង ឬអាណាចក្រភ្នំរហូតដល់សម័យក្រោយអង្គរ ។ លោករ៉េស៊ីដង់រូបនេះបានទុកប្រទេសកម្ពុជាជាមាតុភូមិទីពីររបស់លោកបន្ទាប់ពីប្រទេសបារាំង ។ លោកបានជីកកកាយនូវមរតកអតីតកាលរបស់ខ្មែរដែលកប់បាត់ឱ្យរស់ឡើងវិញ ប្រយោជន៍ឱ្យខ្មែរមានទំនុកចិត្ត និងមោទនភាពជាតិតាមរយៈភាពរុងរឿងនៃចក្រភពអង្គរ និងពញ្ញាក់ស្មារតីខ្មែរឱ្យចេះសាមគ្គីភាពគ្នាឡើងវិញតាមរយៈមេរៀនប្រវត្តិសាស្ត្រសម័យអង្គរ និងការធ្លាក់ចុះដោយសារការជណ្តើមគ្នាគ្រួតត្រាប្រទេសខ្មែរអំពីសំណាក់សៀម និងយួន ។

តាមរយៈសន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី 23 ខែមីនា ឆ្នាំ 1907 បារាំងបាននាំយកខេត្តបាត់ដំបង និងមហានគរដែលជាបេះដូងនៃប្រទេសកម្ពុជាមកវិញ ។ ខេត្តនេះមានស្រុកប្រាំគឺ សិរីសោភ័ណ មង្គលបុរី សៀមរាប និងត្នោត ចំណែកឯស្រុកចុងក្រោយគឺស្រុកអារញ្ញ និងខេត្តផ្សេងៗទៀតត្រូវបាត់បង់ជាស្ថាពរ ។

នៅក្នុងឆ្នាំ 1904 ក្រោមការគាបសង្កត់របស់បារាំង សៀមបានប្រគល់ខេត្តម្លូព្រៃ ទន្លេរពៅ និងខេត្តកោះកុងមកឱ្យខ្មែរវិញ ។

នៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ 1904-1927 វិស័យសិក្សាធិការបានចាប់ផ្តើមឡើងដោយលើកស្ទួយវប្បធម៌ជាតិខ្មែរ និងដាក់ទោសដល់ឪពុកម្តាយណាដែលមិនបញ្ជូនកូនឱ្យទៅរៀន ។ នៅពេលនោះ មានការយកចិត្តទុកដាក់បង្កើតសាលាវត្ត សាលាតាមឃុំ និងសាលាបឋមសិក្សាបារាំង ចំណែកសាលាមធ្យមសិក្សាបង្កើតដំបូងគឺមានតែវិទ្យាល័យព្រះស៊ីសុវត្ថិមួយគត់នៅឆ្នាំ 1904 ។ នៅឆ្នាំ1915 គណៈកម្មការរៀបចំវចនានុក្រមខ្មែរត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យភាសាជាតិមានលក្ខណៈប្រាកដនិយម ។


ព្រះបាទស៊ីសុវត្ថិ

វិស័យសេដ្ឋកិច្ចមានកសិកម្ម និងដំណាំកសិ-ឧស្សាហកម្មមួយចំនួនដូចជាម្រេច ក្រចៅ ថ្នាំជក់ដែលដាំលើច្រាំងទន្លេមេគង្គមានការរីកចម្រើនគួរឱ្យកត់សំគាល់ ។ នៅឆ្នាំ 1924 នៅជប់ខេត្តកំពង់ចាមបារាំងបាននាំយកពូជដើមកៅស៊ូពីប្រទេសប្រេស៊ីលមកដាំលើផ្ទៃដី 125 ពាន់ហិចតា ។ ការបង្កើតដំណាំកៅស៊ូ បានលើកស្ទួយជីវភាពកម្មករតាមរយៈផ្តល់ផ្ទះមួយខ្នងសម្រាប់គ្រួសារកម្មករនីមួយៗ នៅជុំវិញផ្ទះមានច្បារដំណាំ និងអាចចិញ្ចឹមសត្វដើម្បីបំពេញសេចក្តីត្រូវការក្នុងជីវភាពគ្រួសារទៀតផង ។បារាំងបានបង្កើតមន្ទីរពេទ្យទំនើបដ៏ធំមួយនៅជិតរោងចក្រចម្រាញ់ជ័រសម្រាប់ព្យាបាលកម្មករ ជាពិសេសទៅទៀត នៅរៀងរាល់ល្ងាចថ្ងៃអាទិត្យ កម្មករទាំងអស់ត្រូវបានដឹកជញ្ជូនដោយរថយន្តទៅទស្សនាខ្សែភាពយន្តកម្សាន្ត ។

នៅក្នុងរជ្ជកាលព្រះបាទមុនីវង្ស 1927-1941 អាណានិគមបារាំងបានចាប់ផ្តើមកសាងគមនាគមន៍ ។ ផ្លូវភាគច្រើនដែលបារាំងកសាងសុទ្ធសឹងជាផ្លូវដែលគេប្រើប្រាស់នៅក្នុងសម័យចក្រភពខ្មែរ ។ នៅឆ្នាំ 1932 បារាំងបានកសាងផ្លូវរថភ្លើងមួយខ្សែប្រវែង 275 គីឡូម៉ែត្រតភ្ជាប់ពីទីក្រុងភ្នំពេញទៅអារញ្ញប្រទេសសៀមឆ្លងកាត់តាមប៉ោយប៉ែត ។ ខេត្តប៉ែកខាងកើតមានព្រៃវែង និងស្វាយរៀងជាដើម មានទំនាក់ទំនងងាយស្រួលជាមួយរាជធានីភ្នំពេញ តាមរយៈស្ពានទំនើបមួយឆ្លងកាត់ទន្លេបាសាក់នៅឆ្នាំ 1928 មានប្រវែង 292 ម៉ែត្រ ហៅថាស្ពានព្រះមុនីវង្ស ។


ព្រះបាទមុនីវង្ស

## 4.2. លទ្ធផលអវិជ្ជមាន

ទោះបីបារាំងបានលុបបំបាត់នូវរបបទាសភាពនៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិក៏ដោយ ក៏មិនបានធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានការធូរស្រាលឡើយ ផ្ទុយទៅវិញបារាំងបានធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រឡើង តាមរយៈទម្ងន់ពន្ធដារច្រើនប្រភេទចាប់ពីពន្ធស្រូវ ពន្ធខ្លួន រហូតដល់ពន្ធលើសត្វពាហនៈ។ ការគាបសង្កត់តាមរយៈពន្ធដារបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរងើបបះបោរឡើង។ មិនតែប៉ុណ្ណោះ បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឱ្យបម្រើយោធាបារាំងក្នុងសង្គ្រាមលោកលើកទី 1 និងលោកលើកទី 2 ឱ្យទៅស្លាប់ក្នុងសមរភូមិទៀតផង។ នៅឆ្នាំ 1949 បារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោម និងតំបន់ដាច្បាត់ឱ្យទៅស្តេចយួនបាវដាយ។ ខេត្តត្រាចក៏ត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមទៀត ព្រមទាំងប្រមូលយកវត្ថុកេតនភណ្ឌរបស់ខ្មែរទៅស្រុកបារាំងថែមទៀត។

## ? សំណួរ

1. ហេតុដូចម្តេចបានជាកិច្ចព្រមព្រៀងបារាំង-កម្ពុជាឆ្នាំ 1863 មានចរិតលក្ខណៈជាការដាក់ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង ?
2. តើកំណែទម្រង់ឆ្នាំ 1877 និង 1884 មានកម្មវិធីខុសគ្នាដូចម្តេចខ្លះ ?
3. តើបារាំងប្រើមធ្យោបាយដូចម្តេច ដើម្បីសម្រេចទិសដៅនយោបាយកំណែទម្រង់របស់ខ្លួន ?
4. តើកំណែទម្រង់បារាំងបាននាំមកដល់សង្គមខ្មែរនូវអ្វីខ្លះ ?
5. តើចលនាតស៊ូដើម្បីឯករាជ្យជាតិក្នុងប្រទេសកម្ពុជាបានប្រព្រឹត្តទៅបែបណា ?
6. តើសន្និសីទក្រុងសឺណែវឆ្នាំ 1954 បានអនុម័តលើកិច្ចព្រមព្រៀងអ្វីខ្លះសម្រាប់កម្ពុជា ?
7. តើវត្តមានបារាំងនៅលើទឹកដីខ្មែរផ្តល់ផលវិជ្ជមាន និងអវិជ្ជមានដូចម្តេចខ្លះ ?

មេរៀនទី

# 2 របបសង្គមរាស្ត្រនិយម (1955-1970)

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីការលេចឡើងនៃរបបសង្គមរាស្ត្រនិយម និងលទ្ធផល ។
- ❑ វិភាគពីនយោបាយអព្យាក្រឹតរបស់សង្គមរាស្ត្រនិយម ។
- ❑ ពង្រីកស្មារតីសាមគ្គីភាពពង្រឹងឯកភាព និងការអភិវឌ្ឍជាតិ ។

បារាំងបានមកធ្វើអាណានិគមលើទឹកដីខ្មែរអស់រយៈពេលជិត 1 សតវត្ស ។ ព្រះបាទនរោត្តម សីហនុបានទាមទារឯករាជ្យពីបារាំងនៅឆ្នាំ 1953 ។

## 1. ការលេចឡើងនៃរបបសង្គមរាស្ត្រនិយម



សម្ដេចព្រះ នរោត្តម សីហនុ

ក្រោយសន្ធិសញ្ញាទីក្រុងសីណែវឆ្នាំ 1954 កម្ពុជាបានទទួលសន្តិភាពពេញលេញ ។ តាមព្រះរាជតម្រិះរបស់សម្ដេចព្រះ នរោត្តម សីហនុ ថាប្រសិនបើបញ្ហាផ្ទៃក្នុងនៅតែប្រេះស្រាំ គ្មានឯកភាពជាតិនោះយើងមិនអាចកសាងជាតិដែលទើបតែងើបពីនឹមត្រួតត្រានេះបានទេ ។ ព្រះរាជតម្រិះ គឺចង់ឱ្យគណបក្សនយោបាយ មហាជនរួមរស់ជុំវិញព្រះមហាក្សត្រ ។ ប៉ុន្តែរដ្ឋធម្មនុញ្ញឆ្នាំ 1947 បានបញ្ញត្តក្រិត្យអំណាចនៃព្រះមហាក្សត្រ ។ រាល់ទស្សនៈនយោបាយរបស់ព្រះមហាក្សត្រត្រូវធ្វើសេចក្ដីស្នើទៅសភាទើបមានសុពលភាព ។ គណបក្សដែលអង្គុយក្នុងសភាជារបាំងមួយរាំងជានិច្ច ទោះជាកម្មវិធីរបស់ព្រះមហាក្សត្រល្អយ៉ាងណាក៏ដោយ ។

ថ្ងៃទី 2 ខែមីនា ឆ្នាំ 1955 សម្ដេចព្រះ នរោត្តម សីហនុ បានផ្សព្វផ្សាយសេចក្ដីថ្លែងការណ៍អំពីការចុះចេញពីរាជបល្ល័ង្ក ហើយថ្វាយរាជបល្ល័ង្កទៅព្រះបិតា នរោត្តម សុរាម្រិត ។ នៅថ្ងៃទី 22 ខែមីនា ឆ្នាំ 1955 សម្ដេចព្រះ នរោត្តម សីហនុ បានប្រកាសបង្កើតអង្គការនយោបាយ "សង្គម" ។ អង្គការនយោបាយ "សង្គម" នឹងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជាសកលនៅខែកញ្ញាឆ្នាំ 1955 ដែលជាមធ្យោបាយតែមួយក្នុងការដឹកនាំរដ្ឋាភិបាល ដើម្បីប្រជែងអំណាចជាមួយគណបក្សនយោបាយផ្សេងៗ ។

អង្គការនយោបាយ "សង្គមរាស្ត្រនិយម" ហៅកាត់ថា "សង្គម" ត្រូវបានបង្កើតឡើងនៅថ្ងៃទី 22 ខែមីនា ឆ្នាំ 1955 ។ ថ្វីត្បិតតែអង្គការ "សង្គម" ទើបតែបង្កើតឡើងក៏ដោយ ប៉ុន្តែជំនឿជាក់លើរបបនេះបានក្លាយជាកម្លាំងនយោបាយមួយយ៉ាងធំសម្បើម ។ ការជឿជាក់នេះបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនគឺ ៖

## 1.1. ប្រជាប្រិយភាពប្រធាន

សម្តេចព្រះ នរោត្តម សីហនុ ជាស្ថាបនិក និងជាប្រធានអង្គការ "សង្គម" ។ ព្រះអង្គមានប្រជាប្រិយភាពខ្លាំងណាស់ ពីព្រោះប្រជាពលរដ្ឋខ្មែរទទួលស្គាល់ព្រះអង្គជាបិតាឯករាជ្យជាតិ និងសន្តិភាពជាតិ ។ ទន្ទឹមនឹងនេះ ទោះបីព្រះអង្គបានចុះចេញពីរាជបល្ល័ង្កក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរនៅតែគោរព និងមានជំនឿជាក់លើព្រះអង្គថាជាព្រះមហាក្សត្រដដែល ។

## 1.2. ភាពរឹងមាំនៃរចនាសម្ព័ន្ធដឹកនាំអង្គការ "សង្គម" ថ្នាក់មូលដ្ឋាន

អង្គការនយោបាយសង្គមរាស្ត្រនិយម ជាប្រភេទអង្គការមហាជន ដូច្នេះការគាំទ្រពីមហាជនថ្នាក់មូលដ្ឋានជាកត្តាចាំបាច់ និងជាកម្លាំងចលករមួយជួយឱ្យអង្គការមានជ័យជម្នះក្នុងការបោះឆ្នោត ។ មន្ត្រីរាជការ ប្រជាជនទូទៅបានចូលជាសមាជិកអង្គការសង្គមរាស្ត្រនិយមយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

## 1.3. ក្បាលម៉ាស៊ីនដឹកនាំ

នៅក្នុងក្បាលម៉ាស៊ីនដឹកនាំអង្គការសង្គមរាស្ត្រនិយម ក្រៅពីសម្តេចព្រះ នរោត្តម សីហនុ មានឥស្សរជននយោបាយជាច្រើនរូបទៀត ចូលរួមក្នុងអង្គការនេះ ។ ក្នុងចំណោមអ្នកនយោបាយទាំងនេះមានខ្លះជាថ្នាក់ដឹកនាំគណបក្សដទៃទៀតដូចជា លោក ស៊ឹមវ៉ារ លោក សឺន សាន ព្រះអង្គម្ចាស់ នរិន្ទដេត លោក យ៉ែម សំបួរ លោក សម សារី ជាដើមដែលបង្ខំចិត្តរំលាយគណបក្សខ្លួនចោលដោយគ្មានសង្ឃឹមថាអាចប្រកួតប្រជែងនឹងអង្គការសង្គមរាស្ត្រនិយមបាន ។

## 1.4. វិស័យហិរញ្ញវត្ថុ

គណបក្សសង្គមរាស្ត្រនិយម ជាគណបក្សដែលមានហិរញ្ញវត្ថុរឹងមាំ ។ ប្រជាប្រិយភាពរបស់ប្រធានគណបក្ស និងភាពរឹងមាំរបស់បក្សឡើយ មហាជនមានការចាប់អារម្មណ៍ ។ ក្នុងស្ថានភាពបែបនេះ អង្គការសង្គមរាស្ត្រ និយមទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុពីគ្រប់មជ្ឈដ្ឋាន តាមរយៈការបរិច្ចាគពីសំណាក់សមាជិកនិងអ្នកមានទ្រព្យសម្បត្តិភាគច្រើនក្នុងស្រុក ។

ដោយសារតែអង្គការនយោបាយសង្គមរាស្ត្រនិយមមានប្រជាប្រិយភាពខ្លាំង និងទទួលបានការគាំទ្រពីប្រជាពលរដ្ឋភាគច្រើន ក្នុងការបោះឆ្នោតសភានាខែកញ្ញា ឆ្នាំ 1955 សង្គមរាស្ត្រនិយមដណ្តើមបានសំឡេងគាំទ្រជាង 83% ដែលអាចឱ្យអង្គការនេះបង្កើតរដ្ឋាភិបាលជាឯកតោភាគី ។ ក្រោយការបោះឆ្នោត គណបក្សដទៃទៀតបានរលាយជាបន្តបន្ទាប់ ហើយរជ្ជកាលនៃប្រព័ន្ធពហុបក្សត្រូវបានបញ្ចប់ ហើយប្រព័ន្ធថ្មីមួយចូលមកជំនួសគឺ ប្រព័ន្ធឯកបក្សសង្គមរាស្ត្រនិយម ។ អង្គការសង្គមរាស្ត្រនិយមគ្រប់គ្រងរដ្ឋាភិបាលរហូតដល់ថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ដែលជាថ្ងៃដែលលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ព្រះប្រមុខរដ្ឋ នរោត្តមសីហនុពីអំណាច ។

## 2. សមាជជាតិ

ក្រោយពេលដែលអង្គការនយោបាយ "សង្គមរាស្ត្រនិយម" បានចាប់បដិសន្ធិឡើង គេបានរៀបចំបង្កើតសមាជ ដែលដំបូងឡើយសមាជិកអង្គការសង្គមរាស្ត្រនិយមប៉ុណ្ណោះដែលអាចចូលរួមក្នុងសមាជ ដើម្បីរៀបចំអនុម័តផែនការយុទ្ធសាស្ត្រនយោបាយនានា ។

ថ្ងៃទី 25 ខែកញ្ញា ឆ្នាំ 1955 អង្គការសង្គមរាស្ត្រនិយមបានរៀបចំសមាជ ដែលក្នុងនោះមានការចូលរួមពីសំណាក់មហាជនគ្រប់ស្រទាប់ រួមទាំងតំណាងគណបក្សផ្សេងៗទៀត ។ ទោះបីជាគេមិនទាន់ទទួលស្គាល់សមាជតាមផ្លូវច្បាប់ក៏ដោយ ក៏សមាជដើរតួជាវេទិកាចំហសម្រាប់មហាជន និងអ្នកដឹកនាំចោទ និងសួរដេញដោលគ្នាជុំវិញបញ្ហានយោបាយក្នុង និងក្រៅប្រទេស ។ ចាប់ពីពេលនោះមកគេហៅ "សមាជ" ថាជា "សមាជជាតិ" ។ មានពលរដ្ឋច្រើនសន្ធឹកសន្ធាប់រាប់ពាន់នាក់ (ដល់ 10 ពាន់នាក់) ចូលរួមក្នុងសមាជជាតិ ។ សមាជជាតិត្រូវបានរៀបចំ និងដឹកនាំដោយគណៈកម្មាធិការកណ្តាលនៃអង្គការសង្គមរាស្ត្រនិយមដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រធាន ។

សមាជជាតិសម្រេចបានសមិទ្ធផលច្រើនដូចជា ការប្រឆាំងនឹងអំពើពុករលួយ ការកំណត់ភាសាខ្មែរជាភាសាផ្លូវការ [1] ។ សភាតំណាងរាស្ត្រមានសិទ្ធិចូលរួមក្នុងការកែលំអសកម្មភាពរដ្ឋបាលនិងទាមទារឱ្យដាក់ទណ្ឌកម្មទៅលើមន្ត្រីរាជការណាដែលអសកម្មជាដើម ។ ប៉ុន្តែដោយទំហំការងារធំពេកសមាជជាតិមិនអាចឆ្លើយតបបានទាំងស្រុងទៅតាមបំណង និងតម្រូវការរបស់ប្រជាជនទេ គឺសម្រេចតែកិច្ចការណាដែលចាំបាច់ និងមានគម្រោងទុកជាមុនប៉ុណ្ណោះ ។

---

(1). មាត្រា2 នៃរដ្ឋធម្មនុញ្ញ ឆ្នាំ 1947-1970 បោះពុម្ពឆ្នាំ 1989 ហួត វុទ្ធី

ដោយមើលឃើញថា "សមាជជាតិ" ជាស្ថាប័នការពារអំណាចសង្គមរាស្ត្រនិយម សម្តេចព្រះនរោត្តម សីហនុ បានទាមទារឱ្យគេអនុម័តបញ្ចូលសមាជទៅជាស្ថាប័នរដ្ឋតាមច្បាប់។ ទោះបីជាមានការពិភាក្សាគ្នាយ៉ាងតឹងតែងក្តី នៅទីបំផុតសមាជត្រូវបានសភាអនុម័តឱ្យក្លាយជាស្ថាប័នរដ្ឋ បើយោងទៅតាមរដ្ឋធម្មនុញ្ញសម័យនោះ "សមាជជាតិគឺស្ថាប័ននយោបាយរដ្ឋ ដែលទាមទារឱ្យមានជំនួបប្រជាពលរដ្ឋជាមួយនឹងមន្ត្រីរដ្ឋាភិបាលដើម្បីពិភាក្សាអំពីប្រយោជន៍ជាតិរួម។ រដ្ឋាភិបាល និងសភាជាតិត្រូវបំពេញតាមនូវអ្វីៗដែលជាសេចក្តីសម្រេចរបស់សមាជជាតិ ដែលប្រារព្ធឡើងពីរដងក្នុងមួយឆ្នាំ។ ប្រសិនបើសភាជាតិ និងរដ្ឋាភិបាលសំដែងនូវការមិនពេញចិត្តចំពោះការអនុម័តរបស់សមាជជាតិ នោះ គេត្រូវលើកយករឿងនេះទៅពិភាក្សាបន្តនៅក្នុងសមាជជាតិលើកក្រោយទៀត បើពុំមានទស្សនៈជាឯកច្ឆន្ទនោះទេ បញ្ហានេះត្រូវលើកយកទៅធ្វើប្រជាមតិ"។

# ៣. នយោបាយអព្យាក្រឹត

## ៣.១. មូលហេតុនៃការប្រកាន់យកនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម

នយោបាយអព្យាក្រឹតនៅក្នុងកម្មវិធីនយោបាយការបរទេសកម្ពុជាជាដំបូង ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចចិត្តនៃសន្និសីទសឺណែវឆ្នាំ 1954។ សេចក្តីសម្រេចនេះជាការទាមទាររបស់ចិននិងសហភាពសូវៀត ដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាមេរិក កសាងមូលដ្ឋានទ័ពនៅក្នុងប្រទេសកម្ពុជា។



*ទំនាក់ទំនងការទូតជាមួយចិន*

ការជឿជាក់ទៅលើកម្មវិធីនយោបាយអព្យាក្រឹតរបស់សម្តេចព្រះ នរោត្តម សីហនុ បានលេចឡើងកាន់តែខ្លាំងថែមទៀត បន្ទាប់ពីព្រះអង្គបានជួបពិភាក្សាជាមួយនិងលោក នេរុ នាយករដ្ឋមន្ត្រីឥណ្ឌានៅក្នុងឱកាសដែលសម្តេចបានធ្វើទស្សនកិច្ចនៅប្រទេសឥណ្ឌាក្នុងខែមីនា ឆ្នាំ 1955 ។ ថ្ងៃទី 18 ខែមីនា ឥណ្ឌា-កម្ពុជាបានចុះហត្ថលេខាទៅលើសេចក្តីប្រកាសរួម ដែលនៅក្នុងនោះសម្តេចព្រះ នរោត្តម សីហនុ បានប្រកាសគាំទ្រដល់ការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព ។ នៅខែមេសា ឆ្នាំ 1955 ក្នុងឱកាសសន្និសីទប្រទេសអាស៊ី និងអាហ្វ្រិក នាទីក្រុងបានឌុង (ឥណ្ឌូណេស៊ី) សម្តេចព្រះ នរោត្តម សីហនុ បានធ្វើសេចក្តីអះអាងអំពីកម្មវិធីនយោបាយអព្យាក្រឹតរបស់ប្រទេសកម្ពុជា និងការរួមរស់ជាមួយគ្នាដោយសន្តិភាព ។ នៅក្នុងសន្និសីទបានឌុង សម្តេចព្រះ នរោត្តម សីហនុ បានជួបជាមួយនិងមេដឹកនាំចិនជូអេនឡាយ និងមេដឹកនាំវៀតណាមផាមវ៉ាន់ដុង ដែលបានប្រកាសអំពីការប្រឹងប្រែងរបស់ខ្លួនក្នុងការកសាងទំនាក់ទំនងជាមួយនិងប្រទេសកម្ពុជា ដោយឈរលើគោលការណ៍គោរពសិទ្ធិគ្នាទៅវិញទៅមក គោរពអធិបតេយ្យភាព បូរណភាពទឹកដី និងមិនលូកដៃចូលក្នុងបញ្ហាផ្ទៃក្នុងរបស់ប្រទេសជិតគ្នា ។

នៅថ្ងៃទី 14 ខែធ្នូ ឆ្នាំ 1955 ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិដែលនៅទីនោះតំណាងរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសអំពីការប្រឹងប្រែងរបស់ខ្លួនក្នុងការដើរលើមាគ៌ានយោបាយអព្យាក្រឹត ។

## 3.2. លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត

ជំហានដំបូង នយោបាយអព្យាក្រឹតរបស់សម្តេចព្រះ នរោត្តម សីហនុ បានធ្វើឱ្យកិត្យានុភាពកម្ពុជាល្បីរឹកសុសសាយក្នុងតំបន់ និងត្រូវបានពង្រឹងបន្ថែមទៀត ។ សូម្បីតែពួកប្រឆាំងនិងព្រះអង្គ ក៏មិនហ៊ានប៉ះពាល់នយោបាយអព្យាក្រឹតរបស់ព្រះអង្គដែរ ។ យើងបានទទួលស្គាល់គុណសម្បត្តិនៃនយោបាយអព្យាក្រឹត ដែលឱ្យយើងរស់នៅដោយសុខសន្តិភាពរយៈពេល 15ឆ្នាំក្នុងខណៈដែលប្រទេសជិតខាងកំពុងឆាបឆេះក្នុងភ្លើងសង្គ្រាម(វៀតណាម) ។

នយោបាយអព្យាក្រឹតភាពរបស់កម្ពុជាមានការចុះខ្សោយ នៅក្នុងដំណាក់កាលនៃសង្គ្រាមត្រជាក់ ដោយសារតែប្រទេសមហាអំណាចនៃប្លុកទាំងពីរប្រាកដជាមិនទុកប្រទេសកម្ពុជាបានសន្តិភាពតាមផ្លូវអព្យាក្រឹតរបស់ខ្លួនឡើយ ។

សកម្មភាពនយោបាយរបស់សហរដ្ឋអាមេរិក ថៃ និងវៀតណាមខាងត្បូង មានទិសដៅក្នុងការប្រឆាំងនិងនយោបាយសម្តេចព្រះ នរោត្តម សីហនុ ។ សហរដ្ឋអាមេរិកបន្តផ្តល់ជំនួយដល់កម្ពុជា ប៉ុន្តែជំនួយនេះ គឺមានទិសដៅចិញ្ចឹមពួកស្តាំនិយមនៅកម្ពុជាដើម្បីធ្វើជាមធ្យោបាយដើម្បីផ្តួលរំលំសម្តេច

ព្រះនរោត្តម សីហនុប៉ុណ្ណោះ ។ ជំនួយសហរដ្ឋអាមេរិកភាគច្រើនគឺជួយដល់វិស័យយោធា ហើយមួយផ្នែកទៀតបានធ្លាក់ក្នុងដៃអ្នកមានអំណាចពុករលួយ ។ ជាក់ស្តែង នៅពេលដែលគេបានទទួលលាភសក្ការៈតាមរយៈជំនួយសហរដ្ឋអាមេរិក ពួកមន្ត្រីឆក់ឱកាសទាំងនោះបានប្រឆាំងនឹងសម្តេចព្រះនរោត្តម សីហនុ កាន់តែខ្លាំង ។

រីឯពួកថៃ និងវៀតណាមខាងត្បូង បានធ្វើសកម្មភាពយ៉ាងចំហប្រឆាំងនឹងកម្ពុជាដូចជាការបិទព្រំដែនសេដ្ឋកិច្ច ធ្វើវិទ្ធង្សនាយោធាតាមព្រំដែនជាដើម ។ ថៃបានគាំទ្រសកម្មភាពពួកខ្មែរសេរី ដែលជាកងទ័ពឧទ្ទាមប្រឆាំងរដ្ឋាភិបាលកម្ពុជាដោយផ្តល់ដីឱ្យកសាងជំរំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេងឃោសនាប្រឆាំងនឹងនយោបាយសង្គមរាស្ត្រនិយម រីឯកងទ័ពវៀតណាម បានធ្វើការឈ្លានពានចូលក្នុងខេត្តតាមព្រំដែន ។

សរុបសេចក្តីមក យើងឃើញថានៅក្នុងស្ថានភាពនៃសង្គ្រាមត្រជាក់ ប្រទេសកម្ពុជាពិតជាមិនអាចប្រកាន់នយោបាយអព្យាក្រឹតបានទេ ពីព្រោះពុំអាចមានលទ្ធភាពការពារខ្លួនឯងទប់ទល់នឹងការលុកលុយពីសំណាក់ប្រទេសមហាអំណាចឡើយ ។

ដូចនេះ នយោបាយអព្យាក្រឹតកម្ពុជាត្រូវបានបញ្ចប់ដោយកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ដែលដឹកនាំដោយ លន់ នល់ សិរីមតៈ ដើម្បីទម្លាក់សម្តេចព្រះនរោត្តម សីហនុចេញពីតំណែងប្រមុខរដ្ឋ ។

## 4. ការឡើងកាន់អំណាចជាប្រមុខរដ្ឋរបស់សម្តេចព្រះ នរោត្តម សីហនុ

ថ្ងៃទី 3 ខែមេសា ឆ្នាំ 1960 ព្រះមហាក្សត្រនរោត្តម សុរាម្រិតបានចូលទិវង្គត ។ ការចូលទិវង្គតរបស់ព្រះមហាក្សត្រ បានក្លាយជាបញ្ហាស្មុគស្មាញបំផុតទាក់ទិននឹងដំណោះស្រាយអ្នកបន្តរាជ្យ ។ អនុលោមតាមរដ្ឋធម្មនុញ្ញឆ្នាំ 1947 ព្រះមហាក្សត្រថ្មីដែលមានខ្សែលោហិតព្រះបាទអង្គឌួង ត្រូវជ្រើសរើសដោយក្រុមប្រឹក្សារាជ្យសម្បត្តិ (មាត្រា25) ។

ថ្ងៃទី 6 ខែមេសាឆ្នាំ 1960 មានការប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិដែលក្នុងនោះមាន

- ទ្រង់ស៊ីសុវត្ថិមុនីរ៉េត ប្រធានក្រុមប្រឹក្សារាជវង្ស
- ទ្រង់វត្តានាយាវង្ស ប្រធានក្រុមប្រឹក្សាព្រះមហាក្សត្រ
- លោកជួបហែល ប្រធានសភាជាតិ
- សម្តេចព្រះ នរោត្តម សីហនុ ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី
- លោកជួប សំឡុត ប្រធានតុលាការកំពូល
- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ( មហានិកាយ និងធម្មយុត្តិកនិកាយ) ។

ដោយក្រុមប្រឹក្សារាជសម្បត្តិ មិនអាចជ្រើសរើសបេក្ខជនណាមួយឱ្យឡើងសោយរាជ្យជាព្រះមហាក្សត្រថ្មីបាន គេក៏បង្កើត "ក្រុមប្រឹក្សារាជានុសិទ្ធិ" ដែលមាននាទីបំពេញការងារព្រះមហាក្សត្រជាបណ្ដោះអាសន្ន ហើយក្រុមប្រឹក្សារាជានុសិទ្ធិបានតែងតាំងទ្រង់ស៊ីសុវត្ថិមុនិរ៉េតជាប្រធាន ។ ដោយយោងទៅតាមច្បាប់រដ្ឋធម្មនុញ្ញនៅពេលដែលព្រះមហាក្សត្រថ្មីមិនទាន់មាន តួនាទីប្រមុខរដ្ឋត្រូវបំពេញដោយប្រធានរដ្ឋសភា ។

សម្ដេចព្រះ នរោត្តម សីហនុ បានសុំលាលែងពីតំណែងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ។ រាជរដ្ឋាភិបាលបានសម្រេចចិត្តរៀបចំធ្វើប្រជាមតិដើម្បីពង្រឹងគោលជំហរនយោបាយសង្គមរាស្ត្រនិយម ។ ប្រជាមតិបានប្រព្រឹត្តឡើងនៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 1960 ។ សន្លឹកឆ្នោតដែលគេយកមកធ្វើប្រជាមតិមានសន្លឹកឆ្នោតដែលមានព្រះឆាយាល័ក្ខណ៍សម្ដេចព្រះ នរោត្តម សីហនុ មានន័យថាព្រមទទួលយកកម្មវិធីនយោបាយ "សង្គមរាស្ត្រនិយម" សន្លឹកឆ្នោតដែលមានរូបសឹងថ្មុំកថាញ់បានន័យថាគាំទ្រ "ខ្មែរសេរី" និងនយោបាយទំនោរទៅរកលោកខាងលិច និងសន្លឹកឆ្នោតពណ៌ក្រហមមានន័យថាគាំទ្រដល់ទស្សនៈ "ក្រុមប្រជាជន" ។ ជាលទ្ធផល ប្រជាជន 99.98% បានបោះឆ្នោតគាំទ្រកម្មវិធីនយោបាយសង្គមរាស្ត្រនិយម និងសម្ដេចព្រះ នរោត្តម សីហនុ ។

បន្ទាប់ពីបានប្រកាសលទ្ធផលប្រជាមតិរួចមក សម្ដេចព្រះ នរោត្តម សីហនុ បានធ្វើសុន្ទរកថានៅចំពោះមុខប្រជាជននាក្រុងកែប ដែលក្នុងនោះព្រះអង្គបានបញ្ជាក់អំពីសេចក្ដីបំណងប្រាថ្នារបស់ព្រះអង្គចង់កាន់តំណែងជា "ប្រមុខរដ្ឋ" បើ "ប្រជាពលរដ្ឋស្នើសុំព្រះអង្គ" ។ បន្ទាប់ពីនោះមានព្យុហយាត្រានៅទីក្រុងភ្នំពេញ និងក្រុងកែបដើម្បីគាំទ្រសម្ដេចព្រះ នរោត្តម សីហនុ ក្នុងតំណែងជាប្រមុខរដ្ឋ ។

ថ្ងៃទី 11 ខែមិថុនា ឆ្នាំ 1960 សភាជាតិ និងក្រុមប្រឹក្សារាជានុសិទ្ធិ បានអនុម័តសេចក្ដីសម្រេចចិត្តស្នើសុំឱ្យសម្ដេចព្រះ នរោត្តម សីហនុ ចូលកាន់តំណែងជាមេដឹកនាំជាន់ខ្ពស់ "ប្រមុខរដ្ឋ" នៅក្នុងប្រទេស ។ ថ្ងៃទី 13 ខែមិថុនា ក្រុមប្រឹក្សារាជានុសិទ្ធិត្រូវរំសាយ ។ ថ្ងៃទី 14 ខែមិថុនា នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញបានកើតឡើងនូវមាត្រាពិសេស ដែលក្នុងនោះបានចែងថា ក្នុងករណីដែលកាលៈទេសៈពុំអនុញ្ញាតឱ្យចាត់តាំងព្រះមហាក្សត្រថ្មី និងក្រុមប្រឹក្សារាជានុសិទ្ធិ ដោយអនុលោមទៅតាមបញ្ញត្តិ 30 និង 30 ស្ទួននៃរដ្ឋធម្មនុញ្ញ សភាទាំងពីរត្រូវរួមគ្នាប្រជុំតាមសេចក្ដីអញ្ជើញពីប្រធានរដ្ឋសភា និងដោយអនុលោមទៅតាមឆន្ទៈរបស់ប្រជារាស្ត្រ សភាទាំងពីរអាចលើកអំណាច និងបុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋ ប្រគល់ទៅឱ្យឥស្សរជនមួយរូបដែលប្រជាពលរដ្ឋស្រឡាញ់ទុកចិត្ត (មាត្រា122)[1] ។

---

(1). រដ្ឋធម្មនុញ្ញ ឆ្នាំ 1947-1970 បោះពុម្ពឆ្នាំ 1989 ហួត វុទ្ធី

ថ្ងៃទី20 ខែមិថុនា ឆ្នាំ 1960 សម្តេចព្រះ នរោត្តម សីហនុ បានចូលកាន់តំណែងជាព្រះប្រមុខរដ្ឋ ។ ទំនាស់ជុំវិញបញ្ហារាជបល្ល័ង្កត្រូវបានបញ្ចប់ ។ ស្ថាប័នរាជានិយមត្រូវបានថែរក្សាជាបន្ត ហើយព្រះមហាក្សត្រិយានី កុសុមៈនារីរតន៍ ដែលជាព្រះមាតាសម្តេចព្រះ នរោត្តម សីហនុ បានគង់ប្រថាប់ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក ។

# 5. សមិទ្ធផលសង្គមរាស្ត្រនិយម

## 5.1. លើវិស័យសេដ្ឋកិច្ច



*វិស័យកសិកម្ម (ការប្រមូលផលស្រូវ)*

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ការជ្រើសរើសពូជនយោបាយទឹក និងប្រើប្រាស់ជី ។

- ផលស្រូវនៅឆ្នាំ 1955 ទទួលបាន 1 484 000 តោន ហើយឆ្នាំ 1968 ទទួលបាន 3 250 000 តោន ។
- ផលកប្បាសនៅឆ្នាំ 1964 ទទួលបាន 5 000 តោន ក្នុងនោះ 2 000 តោនបម្រើរោងចក្រតម្បាញក្នុងស្រុក ហើយ 3 000 តោនទៀតនាំចេញទៅក្រៅប្រទេស ។
- ផលចិញ្ចឹមសត្វ : សត្វស្លាបនៅឆ្នាំ 1957 ទទួលបាន 3 730 000 ក្បាល ហើយនៅឆ្នាំ 1965 ទទួលបាន 4 190 000 ក្បាល ។ សត្វគោនៅឆ្នាំ 1955 មាន 300 000 ក្បាល នៅឆ្នាំ 1965 មាន 620 000 ក្បាល ។ ជ្រូកនៅឆ្នាំ 1955 មាន 390 000 ក្បាល នៅឆ្នាំ 1965 មាន 980 000 ក្បាល ។

- ព្រៃឈើជាធនធានធម្មជាតិដ៏សំខាន់សម្រាប់ជីវភាពប្រជាជនកម្ពុជា ទើបរាជរដ្ឋាភិបាលបង្កើតរុក្ខខិវានៅគ្រប់ខេត្តក្រុង ។
- វិស័យនេសាទមានការរីកចម្រើនគួរឱ្យកត់សម្គាល់និងអាចបម្រើជីវភាពប្រជាជនកម្ពុជាក្នុងប្រទេស និងនាំចេញទៅលក់នៅបរទេសថែមទៀត ។

ក្រៅពីនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមបសុពេទ្យដើម្បីព្យាបាលជំងឺសត្វ ។

## 5.2. វិស័យគមនាគមន៍

នៅឆ្នាំ 1954 ពង្រីកកំពង់ផែភ្នំពេញ និងកសាងកំពង់ផែទឹកប្រៃនៅក្រុងព្រះសីហនុ ដើម្បីបម្រើទំនាក់ទំនងអន្តរជាតិ ។

នៅឆ្នាំ 1956 កសាងផ្លូវជាតិលេខ 4 ពីភ្នំពេញទៅក្រុងព្រះសីហនុប្រវែង 226 km ។

នៅឆ្នាំ 1958 ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ។

នៅឆ្នាំ 1959 កសាងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ។

នៅឆ្នាំ 1960 ព្រះបាទនរោត្តម សីហនុបានដឹកនាំកសាងផ្លូវរថភ្លើងខ្សែទី 2 ភ្នំពេញ-ក្រុងព្រះសីហនុប្រវែង 270 km ។ នៅឆ្នាំដដែលនេះបានកសាងស្ពានជ្រោយចង្វា (ស្ពានមិត្តភាពកម្ពុជា-ជប៉ុន) ឆ្លងទន្លេសាប ។

នៅឆ្នាំ 1961 ព្រះរាជាណាចក្រកម្ពុជាបានភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ អូសាកា ។

## 5.3. វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម

នៅឆ្នាំ 1955 ក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បារាំង និងសាខាក្រុមហ៊ុនរបស់សហរដ្ឋអាមេរិកបានដាក់ទុនវិនិយោគនៅកម្ពុជា ។ ក្រុមហ៊ុនទាំងនោះមាន INTENATIONAL និង ញូវហែមពួរ (Newhampur) អេសូ(Esso) កាល់តិច(CALTEX)សែល(Shell) របស់ហូឡង់-អង់គ្លេស ។ ក្រៅពីនោះមានក្រុមហ៊ុនអង់គ្លេស និងជប៉ុនដែលបម្រើបម្រាស់លើឥណទានសម្រាប់ពាណិជ្ជកម្ម មានធនាគារឆារទែរិដ ធនាគារហុងកុងសៀងហៃ និងធនាគារអូហ្វូតូក្យូ ។



*រោងចក្រផលិតកៅស៊ូកង់ឡាននៅក្រុងតាខ្មៅ*

ចាប់ពីឆ្នាំ1956មក ការប្រើប្រាស់ឥណទានខាងពាណិជ្ជកម្មក្រៅប្រទេស កម្ពុជាបានប្រកួតប្រជែងជាមួយមូលធនបារាំង អាមេរិក អង់គ្លេស និងជប៉ុន ។

នៅឆ្នាំ 1962 មូលធនបារាំងបានកាន់កាប់សកម្មភាពពាណិជ្ជកម្មនៃក្រុមហ៊ុននាំចេញក្នុងប្រទេសកម្ពុជា $\frac{1}{3}$ ។

នៅឆ្នាំ 1963 រាជរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មថ្មីឈ្មោះ "ក្រុមហ៊ុនអាហារ័ណនីហារ័ណ" (សូណិចស៊ីម) ។ ក្រុមហ៊ុននេះមានមូលនិធិ 240 លានរៀល ក្នុងនោះមូលនិធិ 60% ជារបស់រដ្ឋនិង 40% ជារបស់ពាណិជ្ជករខ្មែរ ។

នៅឆ្នាំ 1964 រាជរដ្ឋាភិបាលបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ និងឯកជនពីរគឺក្រុមហ៊ុនខ្មែរនៃការទិញផលិតផលកសិកម្ម(សូវ៉ាចាំ) និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល(សូណាព្រឹម) ។ ក្រុមហ៊ុនទាំងពីរនេះមាននាទីបម្រើឱ្យក្រុមហ៊ុន "សូណិចស៊ីម" ។

ក្រៅពីនេះរាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា រោងចក្រវាយនភ័ណ្ឌ(កំពង់ចាម) រោងចក្រក្ដារបន្ទះដីឥដ្ឋ រោងចក្រកែវចម្ការដូង(កណ្ដាល) រោងចក្រក្រដាសឆ្លូង(ក្រចេះ) រោងចក្រស៊ីម៉ងត៍ចក្រីទីង(កំពត) រោងចក្រក្រចៅដូនទាវ(បាត់ដំបង) រោងចក្រស្ករសកំពង់ត្រាំ(កំពង់ស្ពឺ) រោងចក្រស្រាបៀរ និងដំឡើងត្រាក់ទ័រ(ក្រុងព្រះសីហនុ ) ។

## 5.4. វិស័យវប្បធម៌

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យសិក្សាធិការជាតិដោយបណ្តុះបណ្តាលគ្រូបង្រៀន កសាងសាលារៀនចាប់ពីបឋមសិក្សាដល់សកលវិទ្យាល័យ ។

| គ្រឹះស្ថានសិក្សា | 1955 | 1968 |
|---|---|---|
| សាលាបឋមសិក្សា | 2 731 សាលា | 5 857 សាលា |
| អនុវិទ្យាល័យ | 12 សាលា | 150 សាលា |
| គ្រូបឋមសិក្សា | 4 228 នាក់ | 22 752 នាក់ |
| គ្រូមធ្យមសិក្សា | 37 នាក់ | 5 009 នាក់ |

នៅឆ្នាំ 1960 រាជរដ្ឋាភិបាលបង្កើតសកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យវេជ្ជសាស្ត្រ ថែមទាំងបានបញ្ជូននិស្សិតខ្មែរឱ្យទៅសិក្សានៅបរទេស ពិសេសប្រទេសបារាំង ។

សាស្ត្រាចារ្យឧត្តមសិក្សាដែលមាន 7 នាក់ តែក្រោយមកកើនដល់ 1935 នាក់ ។

ចាប់ពីឆ្នាំ 1961 រាជរដ្ឋាភិបាលបានលើកស្ទួយវិស័យកីឡាឱ្យមានសន្ទុះខ្លាំងក្លាដោយបណ្តុះបណ្តាលកីឡាគ្រប់ខេត្តក្រុងថែមទាំងជួលគ្រូបង្វឹកពីបរទេសទៀតផង ។ នៅឆ្នាំ 1964 កសាងពហុកីឡាដ្ឋានជាតិអូឡាំពិកដែលអាចទទួលទស្សនិកជនបានចំនួន 50 000 នាក់ ។ ដោយឡែកខាងពុទ្ធសាសនាគឺមានការយកចិត្តទុកដាក់ខ្លាំងពីសំណាក់ព្រះបាទនរោត្តម សីហនុដោយបង្កើត ពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកមហាវិទ្យាល័យ ។



*ពហុកីឡាដ្ឋានជាតិអូឡាំពិក*

## ៥.៥. វិស័យសង្គមកិច្ច

ក្រោមមាគ៌ាសង្គមរាស្ត្រនិយម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើសុខមាលភាពនិងជីវភាពរស់នៅរបស់ប្រជារាស្ត្រ ដោយចាត់ឱ្យកសាងមន្ទីរពេទ្យគ្រប់ខេត្តក្រុងដើម្បីការពារនិងព្យាបាលជំងឺឱ្យប្រជារាស្ត្រ ដូចជា កសាងមន្ទីរពេទ្យកុមារ គន្ធបុប្ផា ឱសថាល័យព្រះសុរាម្រិត មហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យ មន្ទីរសម្ភពផះង៉ាំង៉ាម មន្ទីរពេទ្យព្រះកុសមៈ (ពេទ្យលោកសង្ឃ) ... ។

ការអភិវឌ្ឍជនបទប្រព្រឹត្តទៅយ៉ាងសស្រាក់សស្រាំដូចជា ការរក្សាអនាម័យតាមលំនៅឋាន ជីកអណ្តូងទឹក សង់ផ្ទះ ជីកស្រះ ... ឱ្យប្រជារាស្ត្រ។ មិនតែប៉ុណ្ណោះ នៅឆ្នាំ 1961 បានបង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគោក និងផ្តល់សិទ្ធិឱ្យស្ត្រីឈរឈ្មោះបោះឆ្នោត និងមានសិទ្ធិបោះឆ្នោត។ សមិទ្ធផលទាំងនេះជាគោលការណ៍ក្នុងរបបសង្គមរាស្ត្រនិយមដែលប្រកាន់យកនយោបាយលទ្ធិប្រជាធិបតេយ្យ។

## ? សំណួរ

1. ហេតុដូចម្តេចបានជាសម្តេចព្រះ នរោត្តម សីហនុ បានបង្កើតអង្គការនយោបាយ "សង្គមរាស្ត្រនិយម" ?
2. ចូររៀបរាប់អំពី "សមាជជាតិ"។
3. ហេតុដូចម្តេច បានជាមានការតែងតាំងសម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ ?
4. ចូររៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយម។
5. ចូររៀបរាប់អំពីនយោបាយអព្យាក្រឹត និងផលវិបាកនៃការប្រកាន់នយោបាយអព្យាក្រឹត។

# 3 សាធារណរដ្ឋខ្មែរ (1970-1975)

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយពីមូលហេតុនៃការលេចឡើងរបបសាធារណរដ្ឋខ្មែរ ។
- អធិប្បាយពីសង្គមសេដ្ឋកិច្ច នយោបាយក្នុងសម័យសង្គ្រាមស៊ីវិល ។
- ពន្យល់ពីមូលហេតុនៃការដួលរលំរបបសាធារណរដ្ឋខ្មែរ និងផលវិបាក ។

សង្គមរាស្ត្រនិយមជាសម័យកាលមួយ ដែលប្រទេសកម្ពុជាជួបនឹងភាពរីកចម្រើនលូតលាស់ ។ ប៉ុន្តែមិនបានយូរប៉ុន្មានសម័យនេះក៏បានដួលរលំដោយសារមនោគមន៍វិជ្ជារបស់ពួកមហាអំណាចសេរី និងកុម្មុយនីស្ត ។ ដោយសារបញ្ហាទាំងនេះហើយ ទើបសាធារណរដ្ឋខ្មែរកើតឡើង ។



*សន្និសីទរបស់ចលនាតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ (ថ្ងៃ23 ខែមីនា ឆ្នាំ1973) ខេត្តសៀមរាប*

# 1. ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ

## 1.1. ស្ថានភាពប្រទេសកម្ពុជាមុនព្រឹត្តិការណ៍ 18 មីនា ឆ្នាំ 1970

### ក. វិស័យសេដ្ឋកិច្ច

នៅខែវិច្ឆិកា ឆ្នាំ 1963 រាជរដ្ឋាភិបាលដែលដឹកនាំដោយ សម្តេច នរោត្តម សីហនុ បានផ្តាច់ជំនួយយោធាពីសហរដ្ឋអាមេរិក ដែលមានតម្លៃជាប្រាក់ចំនួន 15ភាគរយនៃថវិកាជាតិ ។ ក្រោយមកប្រទេសចិនបានផ្តល់ជំនួយសម្ភារៈយោធាមួយចំនួនដល់កងខេមរភូមិន្ទ ប៉ុន្តែមិនអាចស្តារស្ថានភាពកងទ័ពដែលកំពុងចុះខ្សោយលែងជាកងទ័ពប្រយុទ្ធតទៅទៀត ។ សម្តេច សីហនុក៏បានធ្វើជាតូបនីយកម្មក្នុងវិស័យនីហរ័ណ-អាហរ័ណផ្នែកសេដ្ឋកិច្ច និងបានបិទទ្វារធនាគារឯកជនខ្មែរទាំងឡាយ ។ ការសម្រេចព្រះទ័យទាត់ចោលជំនួយសហរដ្ឋអាមេរិក គឺព្រះអង្គមានបំណងចង់នៅក្រៅសង្គ្រាមវៀតណាម និងចង់រក្សាទំនាក់ទំនងល្អជាមួយសមាជិកប្លុកកុម្មុយនីស្ត ។

មិនយូរប៉ុន្មានជាតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេស បានជំរុញឱ្យមានពាណិជ្ជកម្មលួចលាក់ជាមួយពួកបះបោរកុម្មុយនីស្តនៅប្រទេសវៀតណាម ។ លុះដល់ឆ្នាំ 1967 ផលស្រូវរបស់ប្រទេសខ្មែរជាងមួយភាគបួនត្រូវបានគេរត់ពន្ធយកទៅលក់ឱ្យកងកម្លាំងកុម្មុយនីស្តយួនដោយផ្តល់តម្លៃខ្ពស់ជាងរដ្ឋាភិបាលខ្មែរ ។ ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលបានបាត់បង់ប្រាក់ចំណូលពន្ធលើការនាំចេញ ។ ចំណែកពាណិជ្ជកម្មក្រៅប្រទេសជួបការរអាក់រអួល ដោយសារការបាត់បង់ជំនាញគ្រប់គ្រងរបស់សហគ្រាស និងកង្វះបច្ចេកទេសជំនាញ ។

នៅក្នុងឆ្នាំ 1967-1968 សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានដំណើររាំងស្ទះដោយសារបាត់បង់ប្រាក់ចំណូលដែលជាលទ្ធផលនៃការរត់ពន្ធ ការគ្រប់គ្រងឧស្សាហកម្មរដ្ឋមិនបានល្អ និងការចំណាយខ្វះតុល្យភាព ។ បញ្ហាកសិកម្មក៏ជួបវិបត្តិ ប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាពនាំឱ្យទិន្នផលកសិកម្មទាប ។ សម្តេច នរោត្តម សីហនុ បានផ្តល់អំណាចនយោបាយទៅឱ្យលោកលន់ នល់ និងអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈកាន់តែច្រើនឡើងៗ ហើយព្រះអង្គសង្ឃឹមថា សេដ្ឋកិច្ចរបស់ប្រទេសជាតិនឹងមានការផ្លាស់ប្តូរ ។ ដោយយល់ឃើញថា ប្រជាប្រិយភាពសម្តេច នរោត្តម សីហនុ ថយចុះ សត្រូវរបស់ព្រះអង្គបានប្រមូលផ្តុំកម្លាំងយ៉ាងរឹងមាំត្រៀមខ្លួនទប់ទល់នឹងព្រះអង្គ ។

## ១. ការពង្រីកកម្លាំងកុម្មុយនិស្ត



*ក្បួនអមដំណើរមេខ្មែរក្រហមក្នុងតំបន់រំដោះឆ្នាំ 1973*

នៅក្នុងឆ្នាំ 1965 សាឡុត ស បានទៅវៀតណាមខាងជើង ដើម្បីចូលរួមការពិគ្រោះយោបល់។ ប៉ុន្តែមិនយូរប៉ុន្មាន សាឡុត ស បានធ្វើដំណើរទៅប្រទេសចិន។ នៅទីនោះមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីមន្ត្រីចិនចូលបដិវត្តន៍។ ដោយពេញចិត្តនិងដំណាក់កាលដំបូងៗនៃបដិវត្តន៍វប្បធម៌ចិន សាឡុត ស បានផ្លាស់ប្តូរភក្តីភាពទៅរកគំរូបដិវត្តន៍របស់ចិន។

ក្រោយពីត្រឡប់មកដល់មាតុប្រទេសវិញ សាឡុតស បានតាំងបញ្ជាការដ្ឋាននៅតំបន់ព្រៃភ្នំដាច់ស្រយាលក្នុងប្រទេសកម្ពុជា។

ក្រុមចលនាតស៊ូរបស់បក្សពួក សាឡុត ស បានដាក់ឈ្មោះខ្លួនថាបក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក) មានមូលដ្ឋាននៅភូមិភាគឦសាននិងពាយ័ព្យ។ កាលពីដំបូង ការតស៊ូនេះពុំមានសារៈសំខាន់អ្វីសោះ តែពីរបីឆ្នាំក្រោយមកដល់ដើមឆ្នាំ 1970 ទ័ពព្រៃនេះបានបង្កអសន្តិសុខ និងបានកាន់កាប់ទឹកដីស្ទើរមួយភាគប្រាំនៃទឹកដីកម្ពុជាទាំងមូល។ ក្នុងពេលនោះ នៅទីក្រុងភ្នំពេញ ពួកនិស្សិត និងគ្រូបង្រៀនជាច្រើនដែលពេញចិត្តនិងមនោគមន៍វិជ្ជាថ្មី សប្បាយចិត្តយ៉ាងខ្លាំងចំពោះលទ្ធភាពនៃបដិវត្តន៍វប្បធម៌នៅប្រទេសចិននិងការបះបោរនាខែឧសភា ឆ្នាំ 1968 នៅប្រទេសបារាំង។ ចលនាទាំងនេះហាក់ដូចជាបានផ្តល់ផ្លូវផ្សេងជំនួសអំពើពុករលួយរបស់ពួកអ្នកនយោបាយអភិរក្សនិយមខ្មែរតែប៉ុណ្ណោះ។

## គ. វិបត្តិផ្ទៃក្នុងរដ្ឋាភិបាល

នៅចុងឆ្នាំ 1969 មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួនបានចាប់ផ្តើមឃុបឃិតធ្វើផែនការក្បត់នឹងសម្តេចព្រះ នរោត្តម សីហនុ ។

អ្នកស៊ុមគ្រលុំដ៏សំខាន់ក្នុងផែនការក្បត់ គឺម្ចាស់មា (ពូ)របស់សម្តេចព្រះ នរោត្តម សីហនុ ព្រះនាម ស៊ីសុវត្ថិ សិរិមតៈ ជាមន្ត្រីរាជការមួយរូបដែលបានក្លាយជាឧបនាយករដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាលរបស់លោក លន់ នល់ ។

ទ្រង់ សិរិមតៈជាអ្នកមានទំនោរទៅរកពួកបស្ចិមប្រទេស និងមានទំនាក់ទំនងជាមួយពាណិជ្ជករធំៗនៅភ្នំពេញ ។

ចំពោះលោក លន់ នល់ ជានាយករដ្ឋមន្ត្រីនិងជាឥស្សរជនមួយរូបពិបាកយល់ ។ ជាទូទៅ គេបានដឹងថាលោក លន់ នល់ ពុំបានជំទាស់នឹងសម្តេចសីហនុ ចំពោះការទាត់ចោលជំនួយសហរដ្ឋអាមេរិក និងចងសម្ព័ន្ធភាពជាមួយពួកកុម្មុយនីស្តក្នុងការដឹកជញ្ជូនអាវុធឆ្លងកាត់ទឹកដីកម្ពុជាឡើយ ។ តាមពិត មន្ត្រីរបស់លោក លន់ នល់ ជាច្រើននាក់បានក្លាយទៅជាអ្នកមានស្តុកស្តម្ភដោយការរកស៊ីលក់អាវុធ ថ្នាំពេទ្យ និងគ្រឿងផ្គត់ផ្គង់ផ្សេងៗ ដល់ទាហានយួនកុម្មុយនីស្តក្នុងតម្លៃខ្ពស់បំផុត ។

នៅឆ្នាំ 1969 កងខេមរភូមិន្ទបានទទួលរងការវាយប្រហារពីសំណាក់ក្រុមបះបោរកុម្មុយនីស្តក្នុងតំបន់ដែលទ័ពយួនបានឈរជើង និងកាន់កាប់ ហើយប្រជាជនបានប្តឹងតវ៉ាអំពីវត្តមានយួននេះដែរ ។

លោកលន់ នល់ បានរងសម្ពាធពីមន្ត្រីរបស់លោកមួយចំនួន ដោយពួកគេបានចោទថាការផ្តាច់ជំនួយយោធាអាមេរិក និងបញ្ហាខ្មែរមិនបានលូកដៃចូលក្នុងសង្គ្រាមវៀតណាមទើបបណ្តាលឱ្យមានជនឆ្លៀតឱកាសប្រមូលលាភសក្ការៈតាមរយៈជំនួញទាំងនេះ ។ ប៉ុន្តែលោក លន់ នល់ មានសុទិដ្ឋិនិយមថា លោកជាអ្នកមានសមត្ថភាពលើសគេក្នុងការជួយសង្គ្រោះប្រទេសកម្ពុជាឱ្យផុតពីពួកយួនឈ្លានពានដែលលោកហៅថា "ថមិឡឥតសាសនា" ។

## 1.2. រដ្ឋប្រហារ ថ្ងៃទី 18 ខែមីនា ឆ្នាំ 1970

ក្នុងអំឡុងពេលជាងពីរខែបន្ទាប់មក អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ និងសហសេវិករបស់ទ្រង់បានខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេសដូចជា បិទកាស៊ីណូ បង្កើតសេវាសាធារណៈ និងឯកជន ឬធ្វើឯកជនូបនីយកម្មធនាគារជាដើម ។

នៅដើមខែមីនា កុបកម្មប្រឆាំងស្ថានទូតវៀតណាមខាងជើង និងការិយាល័យរបស់ក្រុមតំណាងអ្នកតស៊ូវៀតណាមខាងត្បូង ដែលគេហៅថារណសិរ្សសេរីការវៀតណាម បានផ្ទុះឡើងនៅកណ្តាលក្រុងភ្នំពេញ ។ កុបកម្មបានឈានដល់ការប្រើអំពើហិង្សា ដោយបានបំផ្លិចបំផ្លាញអគារទូតយ៉ាងដំណំ ។ ខណៈពេលនោះសម្តេចសីហនុបានបន្ទោសអ្នកប្រើអំពើហិង្សានេះពីទីក្រុងប៉ារីស ទោះបីជាកុបកម្មមានព្រះរាជានុញ្ញាតពីព្រះអង្គក៏ដោយ ។ ស្ថានការណ៍ និងការចលាចលបានឈានដល់រដ្ឋប្រហារដែលដឹកនាំដោយទ្រង់សិរីមតៈ ដូចដែលបានគ្រោងទុកអស់រយៈពេលច្រើនខែមកហើយ ។

រដ្ឋប្រហារនៅថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 បានប្រព្រឹត្តឡើងក្នុងសភាពការណ៍ស្ងៀមស្ងាត់ជាទីបំផុត ។ គេរក្សាទុករដ្ឋសភាធ្វើជាឧបករណ៍ពង្រឹងអំណាច ។ បន្ទាប់មកគេបានកោះប្រជុំអនុម័តបោះឆ្នោតគាំទ្រ 86 សំឡេងក្នុងចំណោម 89 ដកសេចក្តីទុកចិត្ត និងដកសម្តេចសីហនុចេញពីតំណែងព្រះប្រមុខរដ្ឋ ដោយតែងតាំងលោក ចេង ហេង ប្រធានរដ្ឋសភា ជាប្រមុខរដ្ឋស្តីទីរហូតដល់ពេលដែលគេធ្វើការបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋថ្មី ។ លោក លន់ នល់ នៅតែធ្វើជានាយករដ្ឋមន្ត្រីដដែល ដែលមានអ្នកអង្គម្ចាស់ សិរីមតៈជាអ្នកជំនួយការ ។

បន្ទាប់ពីទ្រង់ជ្រាបពីការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គពីតំណែងព្រះប្រមុខរដ្ឋ សម្តេចព្រះនរោត្តម សីហនុ បានស្តេចយាងទៅក្រុងប៉េកាំងនៃប្រទេសចិន បន្ទាប់ពីទស្សនកិច្ចរយៈពេលខ្លីនៅសហភាពសូវៀត ។

## 2. សង្គមសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរ

នៅថ្ងៃទី 29 ខែមករា ឆ្នាំ 1973 រដ្ឋាភិបាលសហរដ្ឋអាមេរិក និងវៀតណាមខាងជើងចុះហត្ថលេខាការព្រមព្រៀងនៅ ឡា សែល សាំង គ្លូ ( La Celle st Cloud) ដើម្បីបញ្ចប់សង្គ្រាមវៀតណាម ។ តែដោយអាមេរិកខ្លាចប្រទេសកម្ពុជាធ្លាក់ក្នុងរបបកុម្មុយនីស្ត និងជាជម្រកសម្រាប់កងទ័ពវៀតកុងវាយប្រទេសវៀតណាមខាងត្បូង ដែលអាចឱ្យកងទ័ពអាមេរិកមិនអាចដកខ្លួនពីវៀតណាម ចាប់ពីថ្ងៃទី 6 ខែកុម្ភៈ រហូតដល់ពាក់កណ្តាលអធ្រាត្រថ្ងៃទី 15 ខែសីហា ឆ្នាំ 1973 កងអាកាសចរបេ 52 របស់អាមេរិកបានទម្លាក់គ្រាប់បែកយ៉ាងខ្លាំងលើតំបន់ស្រែចម្ការក្នុងប្រទេសកម្ពុជា ។ ការទម្លាក់គ្រាប់បែកធ្វើឱ្យប្រជាជនមិនអាចរស់នៅបានក៏នាំគ្នាភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញ និងទីរួមខេត្តនានា ។

ក្នុងអំឡុងសង្គ្រាម 5ឆ្នាំ ក្រុងភ្នំពេញដូចជាបន្ទាយមួយដ៏ធំដែលត្រូវខ្មាំងឡោមព័ទ្ធជាប់ ។ ប្រជាជនក្នុងប្រទេសមួយភាគបីភៀសខ្លួនមករស់នៅទីក្រុងដែលនាំឱ្យមានកំណើនប្រជាជនហួសប្រមាណ ។ ប្រជាជនរងទុក្ខលំបាកវេទនា និងកំសត់ទុគ៌តពេកក្រៃ ។ អ្នកស្រែចម្ការដែលឃ្លាតចាកពីស្រុកភូមិ ត្រូវបាត់បង់មុខរបរ គ្មានការងារធ្វើ ព្រាត់ប្រាសគ្រួសារជាដើម ។ សង្គ្រាមបានបន្សល់ស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ម៉ឺននាក់ និងមានអ្នកជំងឺ របួស ពិការជាច្រើនពាន់នាក់ ។ល ។ បើក្នុងពេលមុនសង្គ្រាមគេចាត់ទុកក្រុងភ្នំពេញជាគជ់នៃអាស៊ីអាគ្នេយ៍នៅចុងបូព៌ាប្រទេស លុះក្នុងពេលសង្គ្រាម ទីក្រុងដ៏ឆើតឆាយនេះក្លាយទៅជាទីប្រជុំជនដ៏ធំមួយដែលមានប្រជាជនជាងពីរលាននាក់ដែលរស់នៅក្នុងសភាពគ្រោះថ្នាក់បំផុត ។

ប្រជាជនក្រុងភ្នំពេញរស់នៅក្នុងការព្រួយបារម្ភ និងតានតឹងក្នុងចិត្តជាប្រចាំ ព្រោះគ្រាប់រ៉ុក្កែតឬគ្រាប់កាំភ្លើងធំផ្លោងយ៉ាងច្រើនសន្ធឹកសន្ធាប់ធ្លាក់ចូលក្នុងទីក្រុង បណ្តាលឱ្យប្រជាជនស្លូតត្រង់ស្លាប់ជារៀងរាល់ថ្ងៃ ។ នៅយប់ថ្ងៃទី 20-21 ខែមេសា ឆ្នាំ 1972 មនុស្សបីរយនាក់នៅទួលគោក ទទួលមរណភាពដោយគ្រាប់ផ្លោងរបស់ពួកកុម្មុយនីស្ត ។ នៅដើមខែកញ្ញា ឆ្នាំ 1972 ស្ពានជ្រោយចង្វារត្រូវបានកម្ទេចដោយកម្លាំងខ្មែរក្រហម ។

ក្នុងឆ្នាំ 1974 សង្កាត់មួយទៀតនៅផ្សារដើមគត្រូវភ្លើងឆេះខ្ទេច ដោយត្រូវគ្រាប់កាំភ្លើងធំខ្មែរក្រហម ដែលបណ្តាលឱ្យប្រជាជនជាច្រើនគ្រួសារត្រូវស្លាប់និងខ្វះទីជម្រក ។ ចំណែកនៅតំបន់ជនបទ (ក្រៅពីទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួន) បានទទួលរងការបាញ់រះ និងទម្លាក់គ្រាប់បែកការបាញ់ផ្តក់ពីសំណាក់យន្តហោះអាមេរិក និងកងយោធារបបសាធារណរដ្ឋខ្មែរ ។

នៅអំឡុងពេលសង្គ្រាម សេដ្ឋកិច្ចនៅទ្រឹងគ្មានសកម្មភាព ។ ជនភៀសខ្លួនគ្មានការងារធ្វើនិងប្រមូលនិងកង្វះខាងស្បៀងអាហារប្រចាំថ្ងៃ ។ អតិផរណាប្រាក់រៀលចេះតែបន្ត រីឯតម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត ។ ស្បៀងមួយចំនួនត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តល់មកដោយដឹកមកតាមកងនាវា ដែលឡើងតាមទន្លេមេគង្គ ។ នៅខែមករា ឆ្នាំ 1975 ការផ្គត់ផ្គង់ស្បៀងតាមទន្លេនេះត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងស្រុង ។ នៅសល់តែផ្លូវអាកាសពីក្រុងបាងកកប៉ុណ្ណោះ ដែលនាំស្បៀងមកចិញ្ចឹមមនុស្សជាច្រើនលាននាក់នៅក្រុងភ្នំពេញ ។

## 3. សង្គ្រាមស៊ីវិលឆ្នាំ 1970-1975

ព្រះរាជាណាចក្រកម្ពុជាបានក្លាយទៅជា "សាធារណរដ្ឋខ្មែរ" នៅក្នុងខែតុលា ឆ្នាំ 1970 ។ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរបានគ្រងររស់អស់រយៈពេលបួនឆ្នាំដោយសារជំនួយយោធាអាមេរិក ។ សេដ្ឋកិច្ចត្រូវរាំងស្ទះ ទីក្រុង និងជនបទមួយចំនួនធំត្រូវកាត់ផ្តាច់ និងគ្រប់គ្រងដោយកម្លាំងកុម្មុយនីស្ត ។ ទីបំផុតរដ្ឋាភិបាលនេះគ្រប់គ្រងបានតែទីក្រុងភ្នំពេញប៉ុណ្ណោះ ។

រយៈពេលបួនឆ្នាំចុងក្រោយរបស់សាធារណរដ្ឋខ្មែរ ពោរពេញទៅដោយអំពើហិង្សានិងទុក្ខក្រៀមក្រំ ។ សេនាប្រមុខ លន់ នល់ មានជំងឺស្លាប់មួយចំហៀងខ្លួននៅដើមឆ្នាំ 1971 ហើយទោះបីជាជំងឺបានជាសះស្បើយយ៉ាងឆាប់រហ័សក៏ដោយ ក៏លោកមិនបានគ្រប់គ្រងនយោបាយពេញលេញដូចមុនឡើយ ។ ក្នុងឱកាសដែលមេដឹកនាំទន់ខ្សោយ ឥស្សរជននយោបាយជាច្រើនរូបនៅភ្នំពេញរវល់តែបង្កើតបក្សពួក និងប្រមូលទ្រព្យធនភ្លេចអស់ប្រយោជន៍ជាតិ ហើយនៅក្នុងចំណោមពួកគេទាំងនោះក៏មានលោក លន់ នន់ ជាប្អូនប្រុសរបស់លោក លន់ នល់ ផងដែរ ។ នាយទាហានខ្លះលក់យុទ្ធោបករណ៍ឱ្យពួកកុម្មុយនីស្តថែមទៀតផង ។

សេនាប្រមុខ លន់ នល់ មានការអល់អែកក្នុងការដាក់ទណ្ឌកម្មលើពួកទាហានប្រព្រឹត្តអំពើពុករលួយទាំងនោះ ពីព្រោះពួកគេមានស្វាមីភក្តិ និងស្មោះត្រង់នឹងលោក ។ ផ្ទុយទៅវិញ លោកលន់ នល់បានចំណាយពេលវេលាសរសេរលិខិតផ្ញើជូនលោកប្រធានាធិបតីអាមេរិក និចសុន សុំជំនួយបន្ថែមដើម្បីទប់អំណាចរដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរបន្តជីវិតតទៅមុខទៀត ។

នៅឆ្នាំ 1973 សហរដ្ឋអាមេរិកបានធ្វើឱ្យពួកកុម្មុយនីស្តខកខានមិនបានទទួលជោគជ័យដូចបំណង ដោយបើកយុទ្ធនាការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាដូចក្នុងសង្គ្រាមលោកលើកទីពីរដូច្នេះដែរ ។ គ្រាប់បែកជាងកន្លះលានតោនបានធ្លាក់មកលើជនបទនៃប្រទេសកម្ពុជាមុនពេលសភាអាមេរិកបានហាមឃាត់ការទម្លាក់គ្រាប់បែកបន្តទៅទៀតនៅឆ្នាំ 1973 ។ គេពុំបានធ្វើការប៉ាន់ប្រមាណអំពីចំនួនអ្នករបួសឬស្លាប់ទេ ប៉ុន្តែយុទ្ធនាការនេះក៏ជាការបង្អាក់ល្បឿនកងកម្លាំងកុម្មុយនីស្តក្នុងការឡោមព័ទ្ធទីក្រុងភ្នំពេញមួយរយៈដែរ ។ សង្គ្រាមបានអូសបន្លាយអស់រយៈពេលមួយឆ្នាំកន្លះតមកទៀត ។

នៅដើមឆ្នាំ 1973 ពួកកុម្មុយនីស្តខ្មែរបានពិសោធធ្វើកម្មវិធីសហករណ៍នីយកម្មនៅក្នុងតំបន់មួយចំនួនដែលគេគ្រប់គ្រង និងបានចាប់ផ្តើមអនុវត្តដោយបង្ខំនៅក្នុងតំបន់មួយចំនួនស្របពេលយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិកនៅតាមជនបទ ។

## 4. ការដួលរលំរបបសាធារណរដ្ឋខ្មែរ

ប្រជាជនក្នុងតំបន់រំដោះក៏ដូចនៅក្រុងភ្នំពេញនឿយណាយនឹងរបបសាធារណរដ្ឋខ្មែរ ដែលប្រកបដោយអំពើពុករលួយ និងពោរពេញដោយភាពអាប់អួ ។ មុនថ្ងៃរំដោះ ពួកខ្មែរក្រហមបានដាក់មីននៅគ្រប់ច្រកចូលតាមផ្លូវទឹកមកកាន់ទីក្រុងភ្នំពេញ ដើម្បីកាត់ផ្តាច់ការដឹកជញ្ជូនអង្ករ និងគ្រាប់រំសេវ ។ អាមេរិកដែលគាំទ្ររបបសាធារណរដ្ឋខ្មែរបានខិតខំដឹកជញ្ជូនអង្ករ និងគ្រាប់រំសេវតាមអាកាសមកកាន់ក្រុងភ្នំពេញ តែការផ្គត់ផ្គង់នេះត្រូវកាត់ផ្តាច់ទាំងស្រុងក្នុងរយៈពេល 3 ខែ ។ ក្រោយមក ពួកកុម្មុយនីស្តខ្មែរបានរឹតបន្តឹងការឡោមព័ទ្ធទីក្រុងភ្នំពេញដែលក្នុងពេលនោះ មានជនភៀសសឹកមករស់នៅក្រុងភ្នំពេញកើនឡើងដល់ប្រមាណ 2 លាននាក់ ។ នៅដើមខែមីនា សេនាប្រមុខ លន់ នល់ បានភៀសខ្លួនតាមយន្តហោះចេញពីប្រទេសកម្ពុជា ទៅកាន់សហរដ្ឋអាមេរិក ។ ការផ្តើមចរចាជាមួយសម្តេច សីហនុ នៅក្នុងរយៈពេលចុងក្រោយ ដែលផ្តួចផ្តើមឡើងដោយអាមេរិកនោះមិនបានលទ្ធផលអ្វីសោះ ។ នៅពេលនោះ សាឡុត ស បានសម្រេចចិត្តដណ្តើមយកទីក្រុងភ្នំពេញ ដោយមិនបាច់រង់ចាំការយល់ព្រមពីសម្ព័ន្ធមិត្តវៀតណាម ។

នៅព្រឹកថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 ទ័ពកុម្មុយនីស្តបានដើរជាជួរចូលមកទីក្រុងភ្នំពេញនៅម៉ោង 9 : 30នាទី ។ ពួកគេស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ ឬពណ៌អាចម៍សេះ ។ ពួកគេដើរដោយស្ងៀមស្ងាត់ ហើយមានអាវុធគ្រប់គ្នា ។ ទាហានខ្មែរក្រហមទាំងនេះ ភាគច្រើនមានអាយុចាប់ពី 15ឆ្នាំឡើង ។ ពួកគេមានទឹកមុខមាំមិនរីករាយនឹងការស្វាគមន៍របស់ប្រជាជន ។ ថ្ងៃដែលទាហានទាំងនេះចូលមកដល់ទីក្រុងភ្នំពេញ ត្រូវនឹងថ្ងៃបុណ្យចូលឆ្នាំខ្មែរ និងមុនជ័យជម្នះរបស់ពួកកុម្មុយនីស្តលើប្រទេសវៀតណាមខាងត្បូងពីរសប្តាហ៍ ។

ព្រឹត្តិការណ៍នេះ ពុំមែនជាការចៃដន្យទេ ពួកកុម្មុយនីស្តខ្មែរមានគំនិតថា ឆ្នាំខាងមុខត្រូវទុកដូចជាឆ្នាំទី 1 នៃបដិវត្តន៍ គឺកម្ពុជាព្រមទាំងកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយបដិវត្តន៍នៅក្នុងប្រទេសវៀតណាម ។

## 5. ការខូចខាតដោយសារសង្គ្រាម និងផលវិបាក

ប្រទេសកម្ពុជាបានសុខសន្តិភាព រួចផុតពីសង្គ្រាមបានតែ 27 ឆ្នាំ (1953-1970) ប៉ុណ្ណោះ ។ ប្រជាជនកម្ពុជាត្រឡប់មកទទួលរងភាពជូរចត់នៃសង្គ្រាមបន្តទៀត ។

ប្រជាជនជនបទជាច្រើនសែននាក់បានភៀសខ្លួនមករស់នៅទីក្រុង និងទីប្រជុំជននានា ដែលគ្រប់គ្រងដោយរបប លន់ នល់ ដើម្បីគេចពីអសន្តិសុខ ។ វាលស្រែចម្ការត្រូវបោះបង់ចោល ។ កំណើនប្រជាជនយ៉ាងរហ័សបែបនេះធ្វើឱ្យទីក្រុងភ្នំពេញមានភាពច្របូកច្របល់ អំពើចោរកម្ម ភាពអនាធិបតេយ្យ អំពើហិង្សា ការអត់ឃ្លាន ជំងឺ ការកើនតម្លៃទំនិញ និងកង្វះគ្រឿងឧបភោគបរិភោគ ។ល ។

សង្គ្រាមស៊ីវិលឆាបឆេះអស់រយៈពេល 5 ឆ្នាំ (1970-1975) បានសម្លាប់ប្រជាជនកម្ពុជាជាង 1 លាននាក់ ព្រមទាំងធ្វើឱ្យអន្តរាយផ្លូវថ្នល់ និងស្ពានពី 70% ទៅ 80% ។ វាលស្រែចម្ការក្លាយជាចម្ការមីន និងរណ្តៅគ្រាប់បែកបេ 52 ។ រោងចក្រឧស្សាហកម្ម 75% ត្រូវបំផ្លិចបំផ្លាញ ។ ចម្ការកៅស៊ូត្រូវបាត់បង់ ។ គ្រឹះស្ថានសិក្សានៅតំបន់រំដោះ និងតំបន់ប្រទាញប្រទង់ទាំងអស់ត្រូវបិទទ្វារ ។ គ្រូ និងសិស្សត្រូវភៀសខ្លួនមករៀននៅតាមបណ្តាទីរួមខេត្ត-ក្រុង ។ ការសូកប៉ាន់ និងការស៊ីសំណូក រីកដុះដាលរហូតដល់វិស័យសិក្សាធិការជាតិ ។ សិស្ស និងនិស្សិតមួយចំនួនធ្វើការសូកប៉ាន់ដើម្បីគេចផុតពីការចាប់បង្ខំឱ្យចូលកំណែនយោធា ។

សង្គ្រាមបានបង្កមហន្តរាយយ៉ាងធំ។ ក្រៅពីសម្លាប់ប្រជាជនកម្ពុជា គ្រប់ភាគីជម្លោះបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ថែមទាំងបានបំផ្លាញដល់ឫសគល់ប្រព័ន្ធអប់រំខ្មេចខ្ទី ដូចជាសាលារៀន គ្រឹះស្ថានសិក្សា វត្តអារាម និងធនធានមនុស្ស ធ្វើឱ្យការអភិវឌ្ឍជាតិមិនអាចប្រព្រឹត្តទៅបាន។ អស្ថិរភាពនយោបាយដោយសង្គ្រាមស៊ីវិល បង្កវិនាសកម្មគ្រប់វិស័យ និងជាឱកាសឱ្យក្រុមខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ 1975 ( 17 មេសា 1975 )។

## ? សំណួរ

1. ហេតុដូចម្ដេចបានជាលេចឡើងនូវរបបសាធារណរដ្ឋខ្មែរ ?
2. ហេតុអ្វីបានជាគេចាត់ទុកការបោះឆ្នោតសភាថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ជាការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្ដម សីហនុ ?
3. តើលោកសេនាប្រមុខលន់ នល់ ដោះស្រាយបញ្ហាជនបទបានដែរឬទេ ? ព្រោះអ្វី ?
4. តើពួកខ្មែរក្រហមមានសកម្មភាពយ៉ាងណា ដើម្បីអូសទាញប្រជាជនខ្មែរឱ្យគាំទ្រពួកគេ ?
5. តើមូលហេតុអ្វីដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ?

# 4 កម្ពុជាប្រជាធិបតេយ្យ (1975-1979)

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ បក្ស និងការបែងចែកភូមិភាគ ។
- ❑ ពណ៌នាពីសោកនាដកម្មរបស់ប្រជាជនកម្ពុជា និងការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។
- ❑ មើលឃើញគំរូមិនល្អ និងចងចាំជានិច្ចនូវអំពើអមនុស្សធម៌មកលើប្រជាជនខ្មែរត្រូវចៀសវាង ។

របបកម្ពុជាប្រជាធិបតេយ្យក៏បានកើតឡើងក្រោយពេលដែលរបបសាធារណរដ្ឋខ្មែរដួលរលំទាំងស្រុងនៅថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 ។

## 1. រចនាសម្ព័ន្ធដឹកនាំ

### 1.1. ការចូលកាន់អំណាចរបស់ខ្មែរក្រហម

#### ក. ការចូលកាន់កាប់ក្រុងភ្នំពេញ

ថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 ពួកខ្មែរក្រហមប្រកបដោយសម្លៀកបំពាក់ពណ៌ខ្មៅនិងពណ៌អាចម៍សេះ បានវាយលុកចូលក្រុងភ្នំពេញតាមគ្រប់មុខព្រួញ ហើយកាន់កាប់ក្រុងភ្នំពេញនៅម៉ោង 9 និង 30នាទី ។ ប្រជាជនក្រុងភ្នំពេញបាននាំគ្នាអបអរសាទរគងទ័ពខ្មែរក្រហម តែផ្ទុយទៅវិញពួកខ្មែរក្រហមបានគំរាមកំហែងបណ្តេញប្រជាជនឱ្យចេញពីក្រុងភ្នំពេញឱ្យអស់ក្នុងរយៈពេលបីថ្ងៃ ដោយអះអាងថាអង្គការត្រូវបោសសំអាតខ្មាំងក្នុងក្រុង ខ្លាចអាមេរិកទម្លាក់គ្រាប់បែក និងខ្វះមធ្យោបាយដឹកស្បៀងឱ្យប្រជាជនក្នុងក្រុងភ្នំពេញ ។ ប្រសិនបើនរណារឹងទទឹងនឹងបញ្ជាអង្គការ អ្នកនោះនឹងត្រូវអង្គការចាប់ចង ឬក៏បាញ់ចោលភ្លាមៗនៅនឹងកន្លែង ។

#### ខ. គោលការណ៍របស់ពួកខ្មែរក្រហម

1. ជម្លៀសប្រជាជនឱ្យចេញពីក្រុងភ្នំពេញទាំងអស់
2. លុបបំបាត់ទីផ្សារ
3. លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
4. ផ្សឹកលោកសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឱ្យទៅធ្វើស្រែចម្ការ នៅតំបន់មូលដ្ឋានជនបទ

5. ប្រហារជីវិតមេដឹកនាំរបស់របបលន់ នល់
6. បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
7. បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់
8. បញ្ជូនទ័ពទៅតាមព្រំប្រទល់ជាពិសេសព្រំប្រទល់វៀតណាម ។

## 1.2. ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

### ក. អង្គការ

ពាក្យអង្គការមួយម៉ាត់គ្របដណ្តប់ទាំងបក្សកុម្មុយនីស្ត ទាំងអង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ។ អង្គការបដិវត្តន៍ត្រូវបានបង្កើតឡើងដោយសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។

នៅខែកញ្ញា ឆ្នាំ 1975 គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាមាន ប៉ុល ពត នួន ជា សោ ភឹម អៀង សារី សុន សេន ឈិត ជឿន (ហៅតាម៉ុក) និងវន វេត ។

**ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ 1976-1978**




វនវេត និងញឹមរស់ ត្រូវបានអង្គការសម្លាប់នៅឆ្នាំ 1978 ។ សោភឹម ធ្វើអត្តឃាតនៅឆ្នាំ 1978 ។ សុនសេន ត្រូវអង្គការ(ប៉ុលពត)បានសម្លាប់នៅឆ្នាំ 1997 ។ ប៉ុលពត ស្លាប់ដោយជំងឺនៅឆ្នាំ 1998 ។ កែពក ស្លាប់នៅឆ្នាំ 2002 ។ ឈិត ជឿន ហៅតាម៉ុក ស្លាប់នៅឆ្នាំ 2006 ។ កាំង ហ្គេចអៀវ(ឌុច)ជាប់គុកក្នុងសំណុំរឿង 001 ។ ចំណែកនួនជា អៀងសារី ខៀវសំផន និងអៀងធារិទ្ធកំពុងកាត់ទោសក្នុងរឿង 002 ។ តែអៀង សារី បានស្លាប់នៅឆ្នាំ 2013 អៀង ធារិទ្ធបាត់ការចងចាំ ។

### ខ. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

ពីថ្ងៃទី 15 ដល់ថ្ងៃទី 19 ខែធ្នូឆ្នាំ 1975 រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តដោយសមាជិកចំនួន 1 000 នាក់ក្នុងមហាសន្និបាតជាតិនៅទីក្រុងភ្នំពេញ និងបានប្រកាសឱ្យប្រើនៅថ្ងៃទី 5 ខែមករា ឆ្នាំ1976 ។

ប្រទេសកម្ពុជាបានប្តូរឈ្មោះជាផ្លូវការថា "កម្ពុជាប្រជាធិបតេយ្យ" រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជនចំនួន 250 អាសនៈ ក្នុងនោះ 150 អាសនៈតំណាងវណ្ណៈកសិករ 50 អាសនៈតំណាងវណ្ណៈពលករ និងកម្មករ និង 50 អាសនៈទៀតតំណាងកងទ័ពបដិវត្តន៍កម្ពុជា ។ រដ្ឋធម្មនុញ្ញមិនបានចែងអ្វីទាំងអស់ ដែលទាក់ទងនឹងបក្សកុម្មុយនីស្តកម្ពុជា ។ រដ្ឋសភាបើកសម័យប្រជុំតែម្តងគត់នៅខែមេសា ឆ្នាំ 1976 ។

ចម្រៀងជាតិឈ្មោះថា "17 មេសាមហាជោគជ័យ" និពន្ធដោយ ប៉ុលពត ។ រូបភាពទង់ជាតិកម្ពុជាប្រជាធិបតេយ្យមានខ្លឹមសារដូចតទៅ ៖ ផ្ទៃក្រហមមានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌លឿងជានិមិត្តរូបនៃប្រពៃណីជាតិ និងប្រជាជនកម្ពុជាដែលជាអ្នកការពារ និងស្ថាបនាប្រទេសកម្ពុជាឱ្យថ្កុំថ្កើងរុងរឿង ។



*ទង់ជាតិ*

សញ្ញាជាតិ តាមមាត្រាទី 17 នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងថាសញ្ញាជាតិ មានប្រព័ន្ធស្រែនិងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន រោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវរាងជាស្នែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរ "កម្ពុជាប្រជាធិបតេយ្យ" នៅពីក្រោម ។



*សញ្ញាជាតិ*

## គ. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

បក្សកុម្មុយនីស្តកម្ពុជា គឺជាអង្គការតែមួយគត់ដែលមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រសួងដែលមានសកម្មភាពការងារមានក្រសួងការបរទេសដឹកនាំដោយ អៀងសារី ក្រសួងការពារជាតិដឹកនាំដោយ សុនសេន ក្រសួងឧស្សាហកម្មដឹកនាំដោយ ចេងអន និងក្រសួងសេដ្ឋកិច្ចដឹកនាំដោយ វនវេត ។ គណៈកម្មាធិការតែមួយគត់ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងអនុម័តគោលនយោបាយរដ្ឋាភិបាល និងលក្ខន្តិកៈផ្សេងៗ គឺគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលមានប៉ុលពតជាលេខាបក្ស និងនួនជា ជាអនុលេខាបក្ស ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមិនដែលយកចិត្តទុកដាក់គោរពរដ្ឋធម្មនុញ្ញ និងបទបញ្ញត្តិនានា ដែលបានអនុម័តបង្កើតឡើងដោយខ្លួនឯងម្តងណាទេ ។ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្សក៏មានតំណែងនៅក្នុងរដ្ឋាភិបាលដែរ ។

**រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ**

**ខៀវ សំផន**
ប្រធានគណៈប្រធានរដ្ឋ (ប្រមុខរដ្ឋ)

**នួន ជា**
ប្រធានសភាតំណាងប្រជាជនកម្ពុជា

**ប៉ុល ពត**
នាយករដ្ឋមន្ត្រី

**អៀង សារី**
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស

**វន វ៉េត**
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

**សុន សេន**
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ

## 1.3. ភូមិសាស្ត្ររដ្ឋបាល

នៅឆ្នាំ 1976 បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកតំបន់រដ្ឋបាលនៃរដ្ឋកម្ពុជាប្រជាធិបតេយ្យជា 6 ភូមិភាគ ដែលរួមមាន 32 តំបន់ ។ ភូមិភាគនីមួយៗ មានខេត្តពីរ ឬច្រើនរួមបញ្ចូលគ្នា ឬកាត់ស្រុកខ្លះចេញពីខេត្តខ្លះមកបញ្ចូលគ្នា ។ ភូមិភាគ និងតំបន់ទាំងអស់ សុទ្ធតែមានលេខសម្គាល់ ។ ក្រៅពីភូមិភាគ និងតំបន់ មានសមូហភាពថ្នាក់មូលដ្ឋានដែលបែងចែកជាឃុំ និងភូមិប្រមូលផ្តុំជាសហករណ៍ ។

### ក. ភូមិភាគបូព៌ា (ភូមិភាគ 203)

ភូមិភាគបូព៌ាមានមូលដ្ឋាននៅខេត្តកំពង់ចាមដឹកនាំដោយ សោ ភឹម ដែលធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ 1978 ។ ភូមិភាគនេះរួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គទាំងអស់ កាត់ចេញពីស្រុកមួយក្នុងខេត្តក្រចេះគឺស្រុកឆ្លូង និងកាត់យកស្រុកខ្លះពីខេត្តកណ្តាល មានស្រុកខ្សាច់កណ្តាល ល្វាឯម និងមុខកំពូល ។ ភូមិភាគនេះចែកចេញជាប្រាំតំបន់គឺ តំបន់ 20 តំបន់ 21 តំបន់ 22 តំបន់ 23 និងតំបន់ 24 ។

## ខ. ភូមិភាគនិរតី (ភូមិភាគ 405)

ភូមិភាគនិរតីមានមូលដ្ឋាននៅខេត្តតាកែវដឹកនាំដោយ ឈិត ជឿន ហៅតាម៉ុក ។ ភូមិភាគនេះរួមមានខេត្តកំពត និងខេត្តតាកែវទាំងមូលស្រុកពីរក្នុងខេត្តកំពង់ស្ពឺ (ស្រុកសំរោងទងនិងស្រុកគងពិសី) និងស្រុកប្រាំក្នុងខេត្តកណ្ដាល (ស្រុកកណ្ដាលស្ទឹង ស្អាង កោះធំ កៀនស្វាយ និងស្រុកលើកដែក) ។ ភូមិភាគនេះចែកចេញជាបួនតំបន់ គឺតំបន់ 13 តំបន់ 33 តំបន់ 35 និងតំបន់ 25 ។

## គ. ភូមិភាគឧត្ដរ (ភូមិភាគ 303)

ភូមិភាគឧត្ដរដឹកនាំដោយ កុយ ធួន ហៅ ធុច ពីឆ្នាំ 1970 ដល់ដើមឆ្នាំ 1976 ។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែងនៅឆ្នាំ 1976 កែ ពក ត្រូវបានចាត់តាំងជាលេខាភូមិភាគ ។ នៅឆ្នាំ 1977 កែ ពកត្រូវបានចាត់តាំងឱ្យធ្វើជាលេខាភូមិភាគកណ្ដាល ដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិភាគឧត្ដរគឺ កង ចាប ។ ភូមិភាគនេះរួមមានខេត្តកំពង់ធំ ផ្នែកខាងលិចទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ(ស្រុកព្រែកប្រសព្វ) ហើយចែកចេញជាបីតំបន់គឺ តំបន់ 41 តំបន់ 42 និងតំបន់ 43 ។

## ឃ. ភូមិភាគពាយ័ព្យ (ភូមិភាគ 560)

ភូមិភាគពាយ័ព្យដឹកនាំដោយ ញឹម រស់ ។ ភូមិភាគនេះរួមមានខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលចែកចេញជាប្រាំពីរតំបន់រួមមានតំបន់ 1 តំបន់ 2 តំបន់ 3 តំបន់ 4 តំបន់ 5 តំបន់ 6 និងតំបន់ 7 ។

## ង. ភូមិភាគបស្ចិម (ភូមិភាគ 401)

ភូមិភាគបស្ចិមដឹកនាំដោយ ជូ ជេត ។ ភូមិភាគនេះរួមមាន ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង និងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ ហើយចែកចេញជាប្រាំតំបន់គឺ តំបន់ 31 តំបន់ 32 តំបន់ 37 តំបន់ 15 និងតំបន់ 11 ។

## ច. ភូមិភាគឦសាន (ភូមិភាគ 108)

ភូមិភាគឦសានដឹកនាំដោយ ណៃ សារ៉ាន់ ហៅយ៉ា(សម្លាប់នៅឆ្នាំ 1976) ។ ភូមិភាគនេះរួមមានខេត្តរតនគិរី ខេត្តមណ្ឌលគិរី ផ្នែកខ្លះនៃខេត្តក្រចេះ និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែងដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ។ ភូមិភាគនេះចែកចេញជាប្រាំមួយតំបន់គឺ តំបន់ 101 តំបន់ 102 តំបន់ 104 តំបន់ 105 តំបន់ 107 និងតំបន់ 505 ។

ក្នុងឆ្នាំ 1976 កម្ពុជាប្រជាធិបតេយ្យបានបង្កើតតំបន់ស្វយ័តចំនួនពីរផ្សេងទៀត ដែលទាក់ទងការងារផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស ។ តំបន់ទាំងនេះមានតំបន់សៀមរាប ឧត្តរមានជ័យ (តំបន់ 106) និងតំបន់ព្រះវិហារ(តំបន់ 103) ។ ក្រុងកំពង់សោម(បច្ចុប្បន្នខេត្តព្រះសីហនុ) ក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ ។

នៅឆ្នាំ 1977 ភូមិភាគថ្មីមួយទៀតគឺភូមិភាគកណ្តាលត្រូវបានបង្កើតឡើង ។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ ចំណែកភូមិភាគឧត្តរថ្មីត្រូវបានប្តូរទីតាំងទៅតំបន់សៀមរាប ឧត្តរមានជ័យ និងតំបន់ព្រះវិហារ ។ តំបន់ក្រចេះ(តំបន់ 505) និងតំបន់មណ្ឌលគិរី(តំបន់ 105) ត្រូវបានបំបែកចេញពីភូមិភាគឦសាននិងបង្កើតជាតំបន់ស្វយ័ត ។

## 2. នយោបាយមហាលោតផ្លោះមហាអស្ចារ្យ

### 2.1. គម្រោងផែនការបួនឆ្នាំ (1977-1980)

ខ្មែរក្រហមបានធ្វើការសំអាតទីក្រុង និងទីប្រជុំជននានាដើម្បីកសាងកម្ពុជាមួយថ្មី និងមានភាពដាច់ខាត ។ នៅឆ្នាំ 1976 បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបចំផែនការបួនឆ្នាំលើកទីមួយ(1977-1980) ដែលតម្រូវឱ្យប្រមូលផ្តុំសម្បត្តិឯកជនទាំងអស់ និងផែនការដាំដុះស្រូវជាអាទិភាពរបស់ជាតិ ។ បញ្ហាសន្តិសុខជាតិ សមូហភាវូបនីយកម្មគឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។

នៅឆ្នាំ 1976 អង្គការតម្រូវឱ្យប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់(រួមទាំងសម្ភារៈផ្ទះបាយផង) ទុកជាសម្បត្តិសមូហភាព និងប្រើប្រាស់រួម ព្រមទាំងបែងចែកកម្លាំងពលកម្មទៅតាមក្រុមរៀងៗខ្លួន ដូចជា បុរស ស្ត្រី កុមារ ... ។ ផែនការបួនឆ្នាំមានគោលដៅពង្រីកផលិតផលស្រូវ ធ្វើយ៉ាងណាឱ្យលទ្ធផលជាមធ្យមទទួលបានបីតោនក្នុងមួយហិកតា ។

ម្យ៉ាងទៀត ផែនការបួនឆ្នាំមានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ អនុផលព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថានឹងធ្វើឱ្យកម្ពុជាមានឯករាជ្យពេញបរិបូរណ៍ទាំងវិស័យសេដ្ឋកិច្ច និងវិស័យនយោបាយដោយប្រែក្លាយកម្ពុជាពីប្រទេសកសិកម្មអន់ថយ ឱ្យទៅជាកសិកម្មទំនើបមួយ ។

ទិន្នផលស្រូវក្នុងផែនការបួនឆ្នាំនេះ ត្រូវបានគេបែងចែកជាបួនចំណែក ។ មួយចំណែកសម្រាប់ជាស្បៀងរបស់ប្រជាជន ដែលម្នាក់ទទួលបាន 312 គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ឬ 0.85 គីឡូក្រាមស្រូវសម្រាប់ពលរដ្ឋម្នាក់ក្នុងមួយថ្ងៃ ។ ក្រៅពីនេះ មានស្រូវសម្រាប់ធ្វើពូជនិងស្រូវសម្រាប់ទុកបម្រុង ។ ស្រូវសល់ពីការបែងចែកខាងលើត្រូវនាំចេញទៅបរទេស ហើយនាំចូលមកវិញនូវម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ គ្រឿងសព្វាវុធ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត ។

## 2.2. ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ក. ការបង្កើតសហករណ៍

ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ 1970-1975 ប្រជាជនភាគច្រើននៅតាមតំបន់រំដោះ ខ្មែរក្រហមបានរៀបចំជា "ក្រុមប្រវាស់ដៃ" ដែលមានសមាជិកពី 10 ទៅ 30 គ្រួសារក្នុងមួយក្រុម ។ បន្ទាប់ពីជ័យជម្នះឆ្នាំ 1975 ក្រុមប្រវាស់ដៃត្រូវរៀបចំជា "សហករណ៍កម្រិតទាប" ដែលមានសមាជិកច្រើនគ្រួសារ ឬភូមិមួយទាំងមូល ។ រហូតដល់ឆ្នាំ 1977 សហករណ៍កម្រិតទាបត្រូវបានរៀបចំឱ្យទៅជា "សហករណ៍កម្រិតខ្ពស់" ដែលរួមមានគ្រួសារច្រើនចាប់ពី 3-4 ភូមិ ឬឃុំមួយទាំងមូល ។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបង្កើតសហករណ៍ទាំងនេះឡើង ឆ្ពោះទៅរកការលុបបំបាត់កម្មសិទ្ធិឯកជន និងរបបមូលធននិយម ដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ ។ សហករណ៍ខ្មែរក្រហមមានន័យថាប្រជាជនរស់នៅរួម ធ្វើការរួម ហូបរួម និងចែករំលែកការកម្សាន្តជាសមូហភាព ។ គ្មានការរស់នៅបុគ្គល និងកម្មសិទ្ធិឯកជន ។

សហករណ៍ខ្មែរក្រហមគឺ ធ្វើយ៉ាងណាអាចឱ្យខ្លួនឧបត្ថម្ភខ្លួន ។ មេដឹកនាំខ្មែរក្រហមបានពណ៌នាថាសហករណ៍ជា "កម្លាំងចំបងខ្លាំងក្លា" ក្នុងការកសាងជាតិ និងជា "កំពែងដែកថែបយ៉ាងរឹងមាំបំផុត" សម្រាប់ការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់និងសត្រូវ ។

### ខ. វណ្ណៈសង្គមថ្មីពីរ

មេដឹកនាំខ្មែរក្រហមបានអះអាងថា ពួកគេកសាងប្រទេសមួយប្រកបដោយសមភាព ឯករាជ្យម្ចាស់ការ និងលុបបំបាត់កម្ពែលវណ្ណៈសង្គមចាស់ ប៉ុន្តែជាក់ស្តែងខ្មែរក្រហមបានបង្កើតឡើងនូវវណ្ណៈថ្មីពីរនៅក្នុងប្រទេសគឺ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី" ។

- ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ គឺប្រជាជនរស់នៅតាមតំបន់ជនបទគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាមុនថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 ។ ប្រជាជនទាំងនេះ ចែកជា 2 ទៀតគឺ ប្រជាជនពេញសិទ្ធិ និងប្រជាជនត្រៀម ។ ប្រជាជនពេញសិទ្ធិគឺ ប្រជាពលរដ្ឋណាគ្មានបងប្អូនសាច់ញាតិធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ ។ ប្រជាជនប្រភេទនេះត្រូវបានអនុញ្ញាតឱ្យទៅបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោត ទោះបីជាការបោះឆ្នោតមានតែម្តងគត់នៅថ្ងៃទី 20 ខែមីនា ឆ្នាំ 1976 [1] ក៏ដោយ ។ ប្រជាជនមូលដ្ឋានអាចក្លាយជាប្រធានសហករណ៍ ឬប្រធានកងផ្សេងៗ ។ ប្រជាជនត្រៀម គឺប្រជាជនមានបងប្អូនធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ ឬក្នុងរបបសីហនុ ។

---

(1). ការបោះឆ្នោតនេះមិនអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយឈ្មោះសមាជិកសភាតំណាងប្រជាជនក៏មិនត្រូវបានប្រកាសឱ្យប្រជាជនដឹងដែរ ។

- ប្រជាជនថ្មី ឬប្រជាជន 17 មេសា គឺប្រជាជនដែលជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានាក្រោយថ្ងៃ 17 ខែមេសា ឆ្នាំ 1975 ។ ប្រជាជនមួយចំនួននៃអ្នកទាំងនេះគឺជាប្រជាជនភៀសសឹកមកពីជនបទគេចពីសង្គ្រាម ។ អង្គការគ្មានទំនុកចិត្តលើប្រជាជនថ្មីទេ ព្រោះគេចាត់ទុកថាពួក 17 មេសាជាជនបញ្ចើចក្អែក ជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក ។ ពាក្យស្លោកមួយទៀតដែលអ្នករស់រួចជីវិតចងចាំមិនភ្លេចគឺ "ទុកមិនចំណេញ ដកចេញមិនខាត" ។ ប៉ុន្តែ ទំហំនៃអំពើឃោរឃៅមានកម្រិតខុសៗគ្នាទៅតាមតំបន់នីមួយៗដូចជា ប្រជាជននៅខេត្តស្វាយរៀង និងព្រៃវែងក្នុងភូមិភាគបូព៌ាបានទទួលការគាំពារពីបដិវត្តន៍ប្រសើរជាងប្រជាជនដែលជម្លៀសទៅខេត្តពោធិ៍សាត់ និងបាត់ដំបងនៃភូមិភាគពាយ័ព្យ ។

## គ. ពិធីរៀបមង្គលការ ឬអាពាហ៍ពិពាហ៍

មង្គលការក្នុងរបបកម្ពុជាប្រជាធិបតេយ្យខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ។ គូនគំលោះគ្រមុំចំនួនពី 3 ទៅ 10 គូក្នុងពិធីតូច ហើយពិធីធំមានពី 30 ទៅ 50 គូ ឬរហូតដល់ជាង 100 គូក៏មាន ។ ការរៀបការ គេរៀបចំប្រារព្ធឡើងក្នុងពិធីរួមក្នុងរាត្រីតែមួយយុវជនយុវនារីមិនអនុញ្ញាតឱ្យជ្រើសរើសគូស្រករតាមបំណងរបស់ខ្លួនទេ ។ អង្គការ ឬសង្គមគ្រួសារត្រូវរៀបចំឡើងដោយអង្គការដែលអះអាងថាជាឪពុកម្ដាយរបស់មនុស្សគ្រប់រូប ។

នារីមួយចំនួនត្រូវបង្ខំឱ្យរៀបការជាមួយយុទ្ធជនពិការដែលរងរបួសក្នុងសង្គ្រាម ។ បើគេជំទាស់និងបំណងអង្គការ គេត្រូវទទួលទណ្ឌកម្មដោយបញ្ជូនទៅការដ្ឋានឆ្ងាយដាច់ស្រយាលពីលំនៅឋាន ឱ្យធ្វើការងារជាទម្ងន់ ឬសម្លាប់ចោល ។

ថ្ងៃរៀបការបុរសនារីទាំងអស់ត្រូវឈរជាពីរជួរតាមគូបែរមុខរកគ្នា ។ បន្ទាប់មកប្រធានភូមិបញ្ជាឱ្យគូទាំងនោះចាប់ដៃគ្នា ហើយធ្វើការប្ដេជ្ញាចិត្តថាបម្រើអង្គការដោយឥតលក្ខខណ្ឌ ។ បន្ទាប់ពីបញ្ចប់ពិធីរៀបការ គ្រួសារថ្មីបានទទួលការអនុញ្ញាតឱ្យរស់នៅជាមួយគ្នាតែពីរ-បីថ្ងៃប៉ុណ្ណោះ បន្ទាប់មកត្រូវទៅធ្វើការតាមការដ្ឋានដើម ឬមុខព្រួញថ្មី ។

## ឃ. ការអប់រំ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានចាត់តាំងកុមារាកុមារីឱ្យធ្វើការងារតាមកង ។ ការងាររបស់កុមារគឺដើររើសអាចម៍គោ កាត់ទន្រ្ទានខែត្រ ប្រមូលជីលាមកមនុស្ស និងដឹកជញ្ជូនសម្ភារៈសឹកទៅសមរភូមិ ... ។ ម្យ៉ាងទៀត កុមារាកុមារីទាំងនោះត្រូវរស់នៅតាមកងបែកពីឪពុកម្ដាយ គេអប់រំកុមារទាំងអស់ឱ្យស្រឡាញ់អង្គការ និងដឹងគុណអង្គការដែលបានរំដោះ ។

ប្រព័ន្ធអប់រំកម្ពុជាប្រជាធិបតេយ្យ បណ្តុះស្មារតីកុមារឱ្យមានឆន្ទៈដាច់ខាត និងជឿជាក់លើអង្គការតែមួយគត់ ។ កុមារាកុមារីទាំងអស់ជាកូនរបស់អង្គការ ។ ប្រសិនបើឪពុកម្តាយណាវាយកូន មានន័យថាមើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ ។ កម្មាភិបាលខ្មែរក្រហមអប់រំកុមារឱ្យស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួន ពេលខ្លះកុមារទាំងនោះហ៊ានទាំងសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនដោយចោទថាខ្មាំង ។ តាមរយៈប្រព័ន្ធអប់រំបឺមហាគ្រោះថ្នាក់ទាំងទ្រឹស្តី និងការអនុវត្តដែលគេទទួលបាន កុមារទាំងឡាយជឿជាក់ដាច់ខាត និងគោរពតាមបញ្ជារបស់អង្គការយ៉ាងម៉ឺងម៉ាត់បំផុត ។

ក្នុងអំឡុងពេលសង្គ្រាមជាមួយវៀតណាមឆ្នាំ 1977-1978 ខ្មែរក្រហមបានបញ្ជូនកុមារឱ្យទៅសមរភូមិមុខ កុមាររាប់ពាន់នាក់បានស្លាប់ និងរបួស ។ ដូច្នេះកុមារត្រូវធ្វើពលិកម្មគ្រប់យ៉ាងចំពោះអង្គការ ។

# ១. សោកនាដកម្ម

## ១.1. ការបង្ខំធ្វើការជាទម្ងន់

ប្រជាជនគ្រប់រូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានការងារទាំងអស់ ។ កុមារត្រូវធ្វើការងារទៅតាមក្រុម ឬកងកុមារ ចំណែកមនុស្សចាស់មាននាទីមើលថែទាំកុមារតូចៗ សត្វពាហនៈ និងត្បាញកន្ត្រែងល្អី ។ អនីតិជនអាយុលើសពី 14ឆ្នាំ ត្រូវរែកដី លើកប្រព័ន្ធភ្លឺស្រែ លើកទំនប់ ជីកប្រឡាយជាដើម ។ មានការងារមួយចំនួនទៀតក្រៅពីការងារទាំងនេះដូចជាកាប់ឈើធ្វើផ្ទះ រានដីធ្វើចម្ការ និងដាំស្រូវ ហើយពួកគេត្រូវបញ្ជូនទៅការដ្ឋានផ្សេងៗតាមតម្រូវការរបស់អង្គការ ។ កម្មករ កម្មការិនីប្រហែល 2-3 ពាន់នាក់ដែលអង្គការទុកចិត្តត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅរោងចក្រក្នុងទីក្រុងភ្នំពេញ ។

ជាទូទៅ ប្រជាជនធ្វើការច្រើនជាងដប់ពីរម៉ោងក្នុងមួយថ្ងៃ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ដោយគ្មានពេលសម្រាក និងទទួលទានរបបអាហារតិចតួចបំផុត ។ ពេលខ្លះ ប្រជាជនធ្វើការតាំងពីព្រលឹមស្រាងៗ រហូតដល់ពាក់កណ្តាលយប់ ។ ពេលខ្លះ គេអុជភ្លើងបំភ្លឺដើម្បីធ្វើការបន្តរហូតទៀបភ្លឺ គ្មានប្រជាជនណាម្នាក់ហ៊ានតវ៉ានឹងការងារហួសកម្លាំងទាំងនេះឡើយ ។ ប្រធានសហករណ៍ មានភារកិច្ចគ្រប់គ្រងសកម្មភាព និងទង្វើរបស់ប្រជាជន ។ ជនណាមានកំហុស ឬតវ៉ាត្រូវគេចោទថាខ្មាំងប្រឆាំងបដិវត្តន៍ត្រូវបញ្ជូនទៅដាក់គុក ឬសម្លាប់ចោល ។

## ៣.២. វិសុទ្ធកម្ម និងការសម្លាប់រង្គាល

ខ្មែរក្រហមតែងតែស្រាវជ្រាវរកខ្មាំងបង្កប់ ។ ពួកគេជឿជាក់ថាមានខ្មាំងបង្កប់នៅគ្រប់ទីកន្លែងក្នុងជួរប្រជាជនទូទាំងប្រទេស ។ ជនស្លូតត្រង់ជាច្រើនត្រូវស្លាប់ដោយគេចោទថាខ្មាំង ឬភ្នាក់ងារសម្ងាត់របស់សហរដ្ឋអាមេរិក(សេ-អ៊ី-អា) ភ្នាក់ងារសម្ងាត់របស់សូវៀត(កា-ហ្សេ-បេ) ឬភ្នាក់ងារសម្ងាត់របស់វៀតណាម ។

នៅចុងឆ្នាំ 1977 បន្ទាប់ពីប៉ុលពតវិលត្រឡប់មកពីប្រទេសចិន កងទ័ពវៀតណាមបានវាយចូលភូមិភាគបូព៌ានៃប្រទេសកម្ពុជា ។ 3-4 ខែក្រោយមកទ័ពវៀតណាមបានដកថយទៅវិញដោយកៀរយកប្រជាជនស៊ីវិលខ្មែរមួយចំនួនទៅជាមួយផង ។ ហេតុការណ៍នេះនាំឱ្យមានការចាប់ខ្លួន និងសម្លាប់មនុស្ស អ្នកស្មោះត្រង់នឹងខ្មែរក្រហមជាច្រើននាក់ ។

វិសុទ្ធកម្មដ៏សាហាវយង់ឃ្នងបំផុតនៅក្នុងភូមិភាគនេះកើតឡើងនៅឆ្នាំ 1978 បន្ទាប់ពីកងពលនៃភូមិភាគនេះ បានធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ចាប់តាំងពីខែមិថុនាដល់ខែកញ្ញា ការប៉ះទង្គិចជាមួយវៀតណាមចេះតែបន្ត ។ ភូមិភាគបូព៌ាបានក្លាយទៅជាសមរភូមិរវាងកងទ័ពរដ្ឋាភិបាលខ្មែរក្រហមនិងកងទ័ពបះបោរ ។ ប្រជាជនប្រហែលមួយសែននាក់បានស្លាប់ក្នុងសមរភូមិ និងស្លាប់ដោយការសម្លាប់រង្គាល ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនកងទ័ពពីភូមិភាគនិរតីទៅបង្ក្រាបក្រុមបះបោរ ។ ប្រជាជនរាប់ពាន់នាក់បានរត់ទៅព្រំដែនវៀតណាមគេចពីការសម្លាប់រង្គាលនេះ ។

វិសុទ្ធកម្មនៅភូមិភាគឧត្តរផ្តោតទៅលើបញ្ញវន្ត និងអ្នកជាប់ពាក់ព័ន្ធនឹង កុយ ធួន ដែលធ្វើជាលេខាភូមិភាគឧត្តរ ។ អំឡុងពេលធ្វើវិសុទ្ធកម្ម អង្គការបានចាប់ខ្លួនរដ្ឋមន្ត្រីក្រសួងព័ត៌មាន ហ៊ូនិម ទីវអុល(គ្រូរបស់កុយធួន) កោត ឆាយ និងឌឿនជាដើម ដោយចោទថាពួកទាំងនេះមានគម្រោងការធ្វើរដ្ឋប្រហារ 3-4 លើក និងមានការបះបោរច្រើនផង ជាពិសេសការបះបោររបស់ខ្មែរអ៊ីស្លាម ។

## ៣.៣. ប្រព័ន្ធសន្តិសុខ និងគុកឥតជញ្ជាំង

សន្តិសុខផ្ទាល់ខ្លួន ក៏ដូចជាសន្តិសុខ និងសុវត្ថិភាពសង្គមត្រូវគេរិតបន្តឹង ។ សិទ្ធិសេរីភាពនិងជំនឿគ្រប់យ៉ាងត្រូវហាមឃាត់ ។ ប្រជាជនទូទាំងប្រទេសប្រៀបបានជាទាសករក្នុងសម័យទាសភាព គឺជាឧបករណ៍ផលិតកម្មប្រភេទដែលចេះនិយាយ ហើយត្រូវគេបង្ខំឱ្យធ្វើការយ៉ាងសកម្មគ្មានពេលសម្រាក បាក់កម្លាំង អត់អាហារ សុខភាពទ្រុឌទ្រោម រស់ទាំងអស់សង្ឃឹមរង់ចាំតែថ្ងៃស្លាប់ ។

### ក. មន្ទីរសន្តិសុខ

ប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហមគឺគុកសម្រាប់ដាក់មនុស្ស ។ នៅទូទាំងប្រទេសមានគុកជិត 200 កន្លែង ។ គេហៅគុកទាំងនេះថា "មន្ទីរសន្តិសុខ" ជំនួសពាក្យ "គុក ឬពន្ធនាគារ" ។

មន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរៀបចំឡើងជាប្រាំថ្នាក់ ។ មន្ទីរសន្តិសុខទាំងនេះជាកន្លែងឃុំឃាំង កន្លែងសួរចម្លើយ និងកន្លែងសម្លាប់ ។ អ្នកទោសដែលជាប់ឃុំក្នុងគុកបីថ្នាក់ដំបូង(ថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ) ភាគច្រើនជាអតីតទាហាន និងមន្ត្រីរដ្ឋការស៊ីវិលរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយអ្នកទោសផ្សេងទៀតគឺជាប្រជាជនសាមញ្ញដែលជាប់ចោទពីបទលួចចំណីអាហារ រត់ចោលកន្លែង ឬនិយាយអាក្រក់ពីអង្គការ ។ មន្ទីរសន្តិសុខថ្នាក់ភូមិភាគ សម្រាប់ឃុំឃាំងយុទ្ធជនខ្មែរក្រហម និងក្រុមគ្រួសារ ឬជនជាប់ចោទពីបទឧក្រិដ្ឋដែលប្រព្រឹត្តកំហុសក្នុងភូមិភាគ ។ មន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុត គឺមន្ទីរសន្តិសុខមជ្ឈិមនៅភ្នំពេញដែលមានឈ្មោះសម្ងាត់ថា "មន្ទីរស 21" ។ អ្នកទោសនៅមន្ទីរស 21 គឺជាកម្មាភិបាល និងកងទ័ពខ្មែរក្រហមដែលជាប់ចោទពីបទក្បត់បដិវត្តន៍ ។

### ខ. ខ្មាំងរបស់អង្គការ

ខ្មែរក្រហមចង់ឱ្យប្រជាជនកម្ពុជាទាំងអស់មានភាពស្អាតស្អំ ទាំងសតិអារម្មណ៍ និងប្រវត្តិរូប ។ ខ្មែរក្រហមចាត់ទុកថាកសិករក្រីក្រជាអ្នកបដិវត្តន៍ស្អាតស្អំបំផុត និងជាកម្លាំងស្នូលរបស់អង្គការ ។ អង្គការភ្នែកម្នាស់ គឺជាយន្តការតាមដាន និងរាយការណ៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទាំងក្នុងគ្រួសារ ទាំងក្នុងជួរប្រជាជន ដូចជារាយការណ៍ពីការរអ៊ូរទាំអំពីការងារលំបាក ការលួចម្ហូបអាហារ ឬជំងឺសតិអារម្មណ៍[1]ជាដើម គឺជាខ្មាំងជាមុខសញ្ញាដែលត្រូវកម្ទេច ។ ខ្មែរក្រហមបានបែងចែកសត្រូវជាពីរប្រភេទគឺ "សត្រូវខាងក្នុង" និង "សត្រូវខាងក្រៅ" ។

*សត្រូវខាងក្នុង :*

- **អ្នករដ្ឋការរបស់របបសាធារណរដ្ឋខ្មែរ :** ក្នុងឆ្នាំ 1975 ខ្មែរក្រហមបានសម្លាប់រង្គាលភ្នាក់ងាររដ្ឋការរបបសាធារណរដ្ឋខ្មែរជាច្រើនពាន់នាក់ ចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់កូនទាហាន សូម្បីតែសមាជិកគ្រួសារ និងសាច់ញាតិរបស់អ្នករដ្ឋការទាំងនោះក៏ត្រូវសម្លាប់ដែរ ។
- **ក្រុមជនជាតិភាគតិច :** ជនជាតិភាគតិចក្រុមណាមិនទទួលបានការទុកចិត្ត ឬមានការសង្ស័យពីបក្សត្រូវបានគេធ្វើទុកបុកម្នេញ ។

(1) ជំងឺពុត មិនឈឺពុតធ្វើជាឈឺ ។

- **ជនជាតិភាគតិចតំបន់ភ្នំ :** មុនឆ្នាំ 1975 មេដឹកនាំខ្មែរក្រហមភាគច្រើនធ្លាប់រស់នៅតំបន់ភ្នំក្នុងភូមិភាគឦសាន ។ មេដឹកនាំខ្មែរក្រហមមានជំនឿចិត្តលើជនជាតិភាគតិចតំបន់ភ្នំថាពួកគេមានចិត្តស្មោះត្រង់ ។ ប៉ុន្តែទោះបីជាខ្មែរក្រហមអះអាងថាស្រឡាញ់ស្មោះត្រង់ និងជឿទុកចិត្តលើជនជាតិតំបន់ភ្នំយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមបានចាប់ផ្តើមធ្វើការផ្លាស់ទីលំនៅពួកជនជាតិក្នុងខេត្តមណ្ឌលគិរីឱ្យទៅរស់នៅផ្ដុំគ្នាក្នុងស្រុកកោះញែកនៅដើមឆ្នាំ1972 បណ្ដាលឱ្យពួកគេស្លាប់ជាច្រើននាក់ ។
- **ជនជាតិខ្មែរអ៊ីស្លាម :** ខ្មែរក្រហមបានបង្ខំឱ្យជនជាតិចាមចាកចេញពីលំនៅឋានរបស់ខ្លួន ឱ្យរស់នៅលាយឡំគ្នាជាមួយជនជាតិខ្មែរ ហើយហាមនិយាយភាសាចាម និងលុបបំបាត់សាសនាអ៊ីស្លាម ។ ខ្មែរក្រហមបានសម្លាប់មេដឹកនាំសាសនាអ៊ីស្លាម(ហាគីម) និងជនទាំងឡាយណា ដែលប្រឆាំងនឹងអង្គការ ។
- **ជនជាតិភាគតិចវៀតណាម :** ក្នុងឆ្នាំ 1975 ជនជាតិវៀតណាមទាំងអស់ត្រូវបានគេបណ្តេញចេញពីប្រទេសកម្ពុជា ។ នៅឆ្នាំ 1977 និងឆ្នាំ 1978 ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ជនជាតិវៀតណាមដែលសេសសល់យ៉ាងរង្គាល ។
- **ជនជាតិភាគតិចចិន :** សមាជិកនៃសហគមន៍ចិន ជាពាណិជ្ជករ និងសហគ្រិនក្រុមហ៊ុនត្រូវបានបង្ខំឱ្យធ្វើការងារកសិកម្ម និងបង្អត់អាហារ ដូចប្រជាជនខ្មែរទូទៅដែរ ។ ប៉ុន្តែជនជាតិចិនភាគច្រើនដែលធ្លាប់រស់នៅទីក្រុងត្រូវស្លាប់ដោយអត់អាហារ និងទម្ងន់ការងារ ។
- **បញ្ញវន្ត :** មេដឹកនាំខ្មែរក្រហមមួយចំនួនជាបញ្ញវន្តបានចាត់ទុកបញ្ញវន្តដទៃទៀតជាសត្រូវចម្បងរបស់អង្គការ និងអ្នកធ្វើឱ្យប្រទេសជាតិក្លាយទៅជាអាយ៉ងរបស់បរទេស ។ បញ្ញវន្តសាស្ត្រាចារ្យ និងនិស្សិតមហាវិទ្យាល័យរាប់ពាន់នាក់ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។
- **ជនក្បត់ដទៃទៀត :** កម្មាភិបាលខ្មែរក្រហមជាច្រើននាក់ត្រូវបានចោទថាខ្មាំងក្បត់បដិវត្តន៍ និងត្រូវកម្ទេច ។ ជាទូទៅ ចម្លើយសារភាពរបស់អ្នកជាប់ឃុំឃាំងមានជាអាទិ៍ ការលួចមកលេងផ្ទះ ធ្វើឱ្យបែកបាក់ឧបករណ៍ប្រើប្រាស់ លួចចំណីអាហារ និយាយរិះគន់អង្គការ មកធ្វើការយឺតយ៉ាវ ខ្ជិលច្រអូសនឹងការងារ ត្អូញត្អែរពីលក្ខខណ្ឌរស់នៅ ឬក្នុងការគោរពជំនឿសាសនាជាដើម ។

*សត្រូវខាងក្រៅ*

មានសហរដ្ឋអាមេរិក ប្រទេសថៃ ជាពិសេសប្រទេសវៀតណាម និងអតីតសហភាពសូវៀត។ ខ្មែរក្រហមបានចោទប្រកាន់មនុស្សជាច្រើនរួមទាំងកម្មាភិបាល និងកងទ័ពរបស់ខ្លួនផងថា បានបម្រើមនោគមន៍វិជ្ជាប្រតិកិរិយាប្រឆាំងបដិវត្តន៍ ជាសត្រូវគឺជា "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង"។ ការសម្លាប់មនុស្សជាវិធីមួយដ៏មានប្រសិទ្ធភាព ដោយគ្រាន់តែចោទជននោះថាជាសត្រូវបង្កប់ស៊ីរូងផ្ទៃក្នុង ឬភ្នាក់ងារសម្ងាត់បម្រើនយោបាយឱ្យបរទេសត្រូវកម្ទេចដាច់ខាត។

## 3.4. មន្ទីរស-21 (គុកទួលស្លែង)



*ឧបករណ៍មួយចំនួន និងរូបគំនូរធ្វើទារុណកម្មក្នុងគុកទួលស្លែង*

គុកសំខាន់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺ "មន្ទីរសន្តិសុខស-21"។ អក្សរ "ស" តំណាងឱ្យពាក្យ "សន្តិសុខ" ហើយលេខ "21" តំណាងឱ្យលេខសម្ងាត់។ គុកនេះមានទីតាំងស្ថិតនៅប៉ែកខាងត្បូងទីក្រុងភ្នំពេញ (សង្កាត់ទួលស្វាយព្រៃ) ជាអតីតវិទ្យាល័យពញាយ៉ាត ឬទួលស្វាយព្រៃ។

មន្ទីរស-21 ជាគុកសម្ងាត់សម្រាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសដែលត្រូវបានចាប់បញ្ជូនមកដាក់នៅទីនោះ។ ចាប់ពីពាក់កណ្តាលឆ្នាំ 1976មក គ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងទេ។ ក្នុងចំណោមអ្នកទោសប្រហែលមួយម៉ឺនបួនពាន់នាក់ មានតែ 12នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នករួចជីវិតទាំងនោះ មានជំនាញពិសេសដែលមានប្រយោជន៍ដល់មន្ទីរស-21។ ពួកគេជាជាងគំនូរ ជាងជួសជុលនាឡិកា និងជាងចម្លាក់។

## ក. ថ្នាក់ដឹកនាំមន្ទីរស-21

មន្ទីរស-21 ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិដឹកនាំដោយ សុន សេន ហៅសម មិត្តខៀវ ។ សុន សេន ជានិស្សិតធ្លាប់បានទៅសិក្សានៅប្រទេសបារាំង និងធ្លាប់ធ្វើជាគ្រូបង្រៀន ។

មេដឹកនាំជាន់ខ្ពស់នៅមន្ទីរស-21 រួមមាន ឌុច ប្រធានមន្ទីរស-21 ឃិមវ៉ាត ហៅហ៊ី អនុប្រធានមន្ទីរស-21 ប៉េង បញ្ជាការលើអ្នកយាម ចាន់ ប្រធានអង្គភាពសួរចម្លើយ និងប៊ុនអ្នកសួរចម្លើយ ។ ប៊ុនជាអ្នកសួរចម្លើយអ្នកទោស កែវមាស ណៃសារ៉ាន់ ហ៊ូនឹម ទីវអុល និងភោគឆាយជាដើម ។

## ខ. រចនាសម្ព័ន្ធចាត់តាំងនៅក្នុងមន្ទីរស-21

បុគ្គលិកជាងមួយពាន់នាក់នៅបម្រើការក្នុងមន្ទីរស-21 ។ ក្នុងនោះ មនុស្សប្រហែល 3-4 រយនាក់បម្រើការជាបុគ្គលិកទូទៅ ដោយរួមទាំងអ្នកដាំបន្លែបង្ការសម្រាប់បម្រើសេចក្តីត្រូវការក្នុងគុក ។

## គ. បទបញ្ញត្តិសម្រាប់អ្នកទោស

បទបញ្ញត្តិនេះត្រូវបានបិទនៅលើជញ្ជាំងក្នុងបរិវេណគុក ។

**វិន័យសន្តិបាល នៅមន្ទីរស-21**

1. សួរអីឆ្លើយហ្នឹង មិនបង្វែងសំណួររបស់អញ ។
2. មិនឱ្យដោះស្រាយ យកលេសនេះ លេសនោះ តាមគំនិតឯងទេ ឬប្រកែក តមាត់មិនបានដាច់ខាត ។
3. មិនឱ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងបដិវត្តន៍ ។
4. សួរភ្លាម ឆ្លើយភ្លាម មិនឱ្យដំអក់មួយនាទីឡើយ ។
5. រឿងខុះខាត កុហកបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះ ខូចនោះ ក៏មិនឱ្យនិយាយ រឿងខ្លឹមសារបដិវត្តន៍ ក៏មិនឱ្យនិយាយ ។
6. វ៉ៃៗ ឬឆក់ខ្សែភ្លើងមិនឱ្យស្រែកៗដាច់ខាត ។
7. មិនឱ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំបញ្ជាអញ អត់បញ្ជា កុំធ្វើ អញបញ្ជាអ្វី ធ្វើហ្នឹងភ្លាម ប្រកែកច្រិមច្រមមិនបានទេ ។
8. កុំយកលេសកម្ពុជាក្រោម បាំងមុខមាត់ក្បត់បដិវត្តន៍របស់ឯងឱ្យសោះ ។
9. គ្រប់បញ្ហាខាងលើ មិនធ្វើតាម គឺមួយថ្ងៃរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ ។
10. ប្រឆាំងវិន័យអញមួយចំណុច ត្រូវរងរំពាត់ ១០រំពាត់ ឬឆក់ខ្សែភ្លើង ៥ឆាច់ ។

## 4. ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យមានមូលហេតុច្រើនយ៉ាង ៖

### 4.1. ប្រជាជនកម្ពុជាស្អប់របបប៉ុលពត

ផែនការបួនឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យបញ្ជាក់ថា កម្ពុជានឹងផលិតស្រូវឱ្យបានបីតោនក្នុងមួយហិកតារៀងរាល់ឆ្នាំ ។ នៅពេលទិន្នផលស្រូវមិនបានគ្រប់ផែនការកំណត់ កម្មាភិបាលខ្មែរក្រហមបានធ្វើរបាយការណ៍ក្លែងក្លាយ និងបញ្ជូនស្រូវយ៉ាងច្រើនតម្រូវតាមចំនួនផែនការកំណត់ ដោយទុកឱ្យប្រជាជនទទួលរងការអត់ឃ្លាន សុខភាពទ្រុឌទ្រោម និងស្លាប់ដោយកង្វះអាហារ ។

ដោយសារតែប្រតិបត្តិការទូទាំងប្រទេសជាការសម្ងាត់នោះ ធ្វើឱ្យផែនការក្នុងការប្រមូលផលស្រូវបីតោនក្នុងមួយហិកតាមិនអាចអនុវត្តបាន ។ តំបន់ទាំងអស់ទូទាំងប្រទេសមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ។ ប្រភពបញ្ហាទាំងអស់ត្រូវកប់បាត់គ្មានដំណោះស្រាយ ។ មេដឹកនាំថ្នាក់លើហាក់ដូចជាជឿទាំងស្រុងនូវអ្វីដែលថ្នាក់ក្រោមបានរាយការណ៍ ចំណែកថ្នាក់ក្រោមមិនហ៊ានរាយការណ៍ព័ត៌មានមិនល្អឡើយ ។ ដោយសារលក្ខខណ្ឌរស់នៅកាន់តែអាក្រក់ ប្រជាជនរាប់សែននាក់បានស្លាប់ជាបន្តបន្ទាប់ ក្រោមទម្ងន់ការងារហួសកម្លាំង កង្វះអាហារបរិភោគ និងការកាប់សម្លាប់ ។ ប្រជាជនបះបោរស្ទើរគ្រប់ទីកន្លែង ជាសញ្ញាបញ្ជាក់ពីការអស់ជំនឿ និងលែងគាំទ្ររបបឃោរឃៅកម្ពុជាប្រជាធិបតេយ្យតទៅទៀត ។

### 4.2. វិសុទ្ធកម្ម (ការចម្រាញ់យកមនុស្សបដិវត្តន៍បរិសុទ្ធ)

នៅពាក់កណ្ដាលឆ្នាំ 1976 សមាជិកសំខាន់ៗជាច្រើនរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានធ្វើវិសុទ្ធកម្ម ។ ការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្សកាន់តែកើតមានច្រើនឡើងៗ ទើបប៉ុលពតនិងសហការីជឿថាសត្រូវខ្លួនមាននៅគ្រប់ទីកន្លែង ។ គណៈភូមិភាគ គណៈតំបន់ និងមេបញ្ជាការកងទ័ពជាច្រើនរូបត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។ ក្នុងឆ្នាំ 1977 សភាពការណ៍កាន់តែអាក្រក់ និងធ្ងន់ធ្ងរទៅៗ ។ ប៉ុលពត បានបញ្ជាឱ្យសម្លាប់កម្មាភិបាលភូមិភាគបូព៌ា និងធ្វើវិសុទ្ធកម្មប្រជាជនក្នុងភូមិភាគនេះ ។ នៅចុងឆ្នាំ 1977 ប្រជាជនសេសសល់ត្រូវបានចោទថាក្បត់ចូលដៃជាមួយយួន ហើយត្រូវមជ្ឈិមបក្សចាត់ទុកថាខ្មាំង "ក្បាលយួន ខ្លួនខ្មែរ" ។ មជ្ឈិមបក្សបានបញ្ជូនកងទ័ពជាច្រើនទៅវាយប្រហារភូមិភាគនេះ ហើយសម្លាប់ប្រជាជនរាប់ម៉ឺននាក់ ។ ប្រជាជនសល់ពីការសម្លាប់បានរត់ភៀសខ្លួនទៅវៀតណាម ។

## 4.3. ការធ្វើសង្គ្រាមជាមួយវៀតណាម

នៅឆ្នាំ 1975 កម្ពុជាប្រជាធិបតេយ្យចាប់ផ្ដើមបង្កជម្លោះតាមព្រំដែនជាមួយវៀតណាម ។ នៅពាក់កណ្ដាលឆ្នាំ 1977 ខ្មែរក្រហមបានបាញ់ផ្លោងដាក់ខេត្តចូវដុក ស្រុកហាទៀង និងខេត្តផ្សេងៗទៀត ។

នៅខែធ្នូឆ្នាំ 1977 វៀតណាមបានប្រើយន្តហោះ និងកាំភ្លើងធំបើកការវាយប្រហារទ្រង់ទ្រាយធំចូលកាន់កាប់តំបន់ចំពុះទាក្នុងខេត្តស្វាយរៀង ។ ពេលនោះកម្ពុជាប្រជាធិបតេយ្យបានកាត់ផ្ដាច់ចំណងការទូត ដោយបណ្ដេញអ្នកការទូតវៀតណាមចេញពីប្រទេសកម្ពុជា ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យព្រមធ្វើការចរចា លុះត្រាណាកងទ័ពវៀតណាមទាំងអស់ដកចេញពីទឹកដីកម្ពុជាជាមុនសិន ។

នៅថ្ងៃទី 3 ខែមេសា ឆ្នាំ 1978 វិទ្យុក្រុងហាណូយផ្សាយជាភាសាខ្មែរបានអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់ក្រោកឈរឡើងប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្មាភិបាល កងទ័ព និងប្រជាជនដែលបានភៀសខ្លួនចូលក្នុងទឹកដីវៀតណាមបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពដឹកនាំដោយមេបញ្ជាការវៀតណាម ។ វិទ្យុក្រុងហាណូយដដែលបានផ្សព្វផ្សាយពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលដឹកនាំដោយសមមិត្ត ហេង សំរិន ។

នៅថ្ងៃទី 25 ខែធ្នូ ឆ្នាំ 1978 កងទ័ពជំនួយពីវៀតណាមបានវាយប្រហារយ៉ាងខ្លាំងក្លាមកលើកម្ពុជាប្រជាធិបតេយ្យ ចូលកាន់កាប់ខេត្តក្រចេះ និងខេត្តកំពង់ចាមក្នុងរយៈពេលមួយសប្ដាហ៍ ។ នៅថ្ងៃទី 7 ខែមករា ឆ្នាំ 1979 កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានកាន់កាប់ទីក្រុងភ្នំពេញ ។ កងទ័ពទាំងពីរបានរៀបចំមហាសន្និបាតមួយ បង្កើតក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដើម្បីបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នដឹកនាំដោយសមមិត្ត ហេង សំរិន ។

### ? សំណួរ

1 តើពួកខ្មែរក្រហមមានគោលនយោបាយដូចម្ដេចក្រោយថ្ងៃ 17 មេសា1975 ?

2. ហេតុអ្វីបានជាពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីប្រជុំជននានា ?

3 តើដូចម្ដេចហៅថាអង្គការ (ខ្មែរក្រហម) ?

4. ចូររៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងមជ្ឈិមបក្សកុម្មុយនីស្តឆ្នាំ 1976 ។

5. តើពួកខ្មែរក្រហមបែងចែកប្រទេសកម្ពុជាប៉ុន្មានភូមិភាគ ? អ្វីខ្លះ ?

6. តើជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹងបញ្ហាអ្វីខ្លះ ?

7 តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ?

មេរៀនទី

# 5 សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (1979-1993)

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីសេដ្ឋកិច្ច សង្គម កំណែទម្រង់រដ្ឋធម្មនុញ្ញឆ្នាំ 1989 និងនយោបាយបង្រួបបង្រួមជាតិ ។
- វិភាគការវិវត្តនយោបាយ និងសង្គមកម្ពុជា ។
- ចូលរួមក្នុងការស្តារ កសាង និងអភិវឌ្ឍប្រទេសកម្ពុជា ។

ប្រទេសកម្ពុជាបានឆ្លងផុតពីរបបកាប់សម្លាប់គ្នាឯងអស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាកើតឡើងនាថ្ងៃទី 7 ខែមករា ឆ្នាំ 1979 ក្រោមជំនួយឧបត្ថម្ភពីកម្លាំងកងទ័ពវៀតណាម ។

## 1. ការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ

### 1.1. កំណើតរណសិរ្ស



*លោក ហេង សំរិន*

នៅខែមករា ឆ្នាំ 1976 លោក ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងឃោសនាការរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានចេញមុខប្រឆាំងនឹង ប៉ុលពត ។ នៅខែមីនា ឆ្នាំ 1976 ប្រជាជននៅចម្ការហ្លួង និងនៅខេត្តសៀមរាបបានទាមទារឱ្យតម្លើងកម្រិតជីវភាព និងឱ្យគ្រួសារបានរស់នៅជួបជុំគ្នា ។ នៅដើមខែមករា ឆ្នាំ 1977 ប្រជាជននៅខេត្តសៀមរាបភាគខាងជើង និងនៅខេត្តបាត់ដំបងបានក្រោកឈរឡើងប្រឆាំងនឹងពួកប៉ុលពត ហើយនៅខែមីនា និងមេសា ឆ្នាំ 1977 ប្រជាជននៅខេត្តកំពង់ធំ មណ្ឌលគិរី កំពង់ឆ្នាំង និងនៅចម្ការហ្លួង ក៏បានបង្កើតចលនាប្រឆាំងពួកប៉ុលពតដែរ ។

មហាសន្និបាតតំណាងកម្លាំងរំដោះគ្រប់តំបន់ទូទាំងប្រទេស ក្រោមការដឹកនាំរបស់អ្នកស្នេហាជាតិបានបើកសម័យប្រជុំនៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1978 ក្នុងមូលដ្ឋានរំដោះ ។ មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងបានបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការមជ្ឈិមរណសិរ្ស ដែលមានសមាជិក 14 រូប ក្នុងនោះមាន ស.ម ហេង សំរិន ជាប្រធាន ស.ម ជា ស៊ីម អនុប្រធាន ស.ម រស់ សម័យ ជាអគ្គលេខាធិការ ហើយសមាជិកមាន ស.ម ម៉ាត់លី ប៊ុនមី មាសសំណាង ហ៊ុនសែន ប្រាជ្ញស៊ុន ចាន់វ៉ែន នូវសាម៉ុ មានសំអាន ជ័យកញ្ញា ឡុងស៊ីម និងហែមសាមិន ។

## 1.2. ជ័យជម្នះថ្ងៃទី 7 ខែមករា ឆ្នាំ 1979

ដោយមានជំនួយពីកងទ័ពវៀតណាម និងប្រជាជនកម្ពុជា ធ្វើឱ្យកងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រំដោះប្រជាជន និងទឹកដីនៃប្រទេសកម្ពុជាបានជាបន្តបន្ទាប់

នៅថ្ងៃទី 30 ខែធ្នូ ឆ្នាំ 1978 រំដោះបានលំផាត់ ទីរួមខេត្តក្រចេះ រ៉ុនសែ និងខន្ទេបិទ ។

នៅថ្ងៃទី 03 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តស្វាយរៀង ។

នៅថ្ងៃទី 04 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តស្ទឹងត្រែង ។

នៅថ្ងៃទី 05 និងទី 06 ខែមករា ឆ្នាំ 1979 រំដោះបានអ្នកលឿង និងទីរួមខេត្តកំពង់ចាម ។

នៅថ្ងៃទី 05 រហូតដល់ថ្ងៃទី 08 ខែមករា ឆ្នាំ 1979 មហាសន្និបាតជាតិលើកទី 3 បានប្រារព្ធឡើងដែលមានកម្លាំងដឹកនាំរណសិរ្សចូលរួមចំនួន 66 នាក់ ។ មហាសន្និបាតបានអនុម័តកម្មវិធីសង្គ្រោះជាតិកម្ពុជា និងរំដោះប្រទេសកម្ពុជាឱ្យបានទាំងស្រុង ។

នៅថ្ងៃទី 07 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តតាកែវ កំពង់សោម និងរាជធានីភ្នំពេញនៅវេលាម៉ោង 12 កន្លះ ។

នៅថ្ងៃទី 10 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តសៀមរាប ។

នៅថ្ងៃទី 11 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តកំពង់ឆ្នាំង ។

នៅថ្ងៃទី 13 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តបាត់ដំបង ។

នៅថ្ងៃទី 14 ដល់ទី 17 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តពោធិ៍សាត់ កោះកុង ។ល ។

ក្នុងរយៈពេលតែ 3 សប្តាហ៍ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមរំដោះប្រទេសកម្ពុជាបានស្ទើរទាំងស្រុងពីបនប្រល័យពូជសាសន៍ខ្មែរក្រហម ។

ក្រោយថ្ងៃរំដោះ 7 មករា 1979 ប្រជាជនខ្មែរបានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមបាននាំគ្នាវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ។ អ្នកខ្លះអស់សង្ឃឹមនឹងរស់នៅស្រុកខ្មែរ បាននាំគ្នាភៀសខ្លួនទៅកាន់ជំរំជនភៀសខ្លួននៅព្រំដែនថៃ ។ ពួកគេរស់នៅក្នុងជំរំជនភៀសខ្លួន ក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ។ ពេលមកដល់ស្រុកកំណើត អ្នកខ្លះបានជួបបងប្អូនឬឪពុកម្តាយអ្នកខ្លះទៀតព្រាត់ប្រាសឪពុកម្តាយឬសាច់ញាតិគ្រួសារ ខ្លះស្លាប់អស់ទាំងពូជតែម្តង ។ ប្រជាជនសល់ពីស្លាប់ភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា និងមនុស្សចាស់ជរា ។ ពួកគេមានតែបាតដៃទទេ ពុំមានគោក្របី រទេះ នង្គ័ល រនាស់ សម្រាប់ធ្វើស្រែចម្ការ និងបង្កបង្កើនផលឡើយ ។



*ទិដ្ឋភាពថ្ងៃរំដោះក្រុងភ្នំពេញ 7 មករា 1979*

## 2. ការស្តារ និងស្ថាបនាប្រទេសជាតិឡើងវិញ

### 2.1. ការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬ ក្រុមប្រវាស់ដៃ

ក្រុមសាមគ្គី ឬក្រុមប្រវាស់ដៃ ជួយសម្រាលបន្ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា និងមនុស្សចាស់ជរា ព្រោះពួកគេគ្មានឧបករណ៍បង្កបង្កើនផល ។ នៅតាមភូមិនីមួយៗ គេបែងចែកជាក្រុមសាមគ្គី ក្នុងមួយក្រុមមានប្រមាណជា ១០គ្រួសារ ឬច្រើនជាងនេះប្រែប្រួលទៅតាមចំនួនសមាជិកគ្រួសារ (កូនច្រើន ឬតិច) ។ គោក្របីដែលសេសសល់ពីរបបប៉ុលពតជាកម្លាំងអូសទាញយ៉ាងសំខាន់ សម្រាប់ភ្ជួររាស់ ដឹកជញ្ជូនស្បៀងអាហារ និងផលិតផលផ្សេងៗ ។

តាមគោលនយោបាយរបស់រណសិរ្ស ក្រុមសាមគ្គីបង្កបង្កើនផលនៃប្រជាជនកម្ពុជា បានប្តូរពីក្រុមសាមគ្គីប្រវាស់ដៃទៅម្ចាស់ការទាំងស្រុងក្នុងការរៀបចំទំនាក់ទំនងផ្នែកផលិតកម្ម និងជីវភាពរស់នៅដោយឈានទៅរករបបកម្មសិទ្ធិឯកជនវិញ ។

## 2.2. របទាសម្ព័ន្ធគ្រប់គ្រង



លោក ហេង សំរិន



លោក ជា ស៊ីម



លោក ហ៊ុន សែន

ថ្នាក់ដឹកនាំកំពូលគណបក្សប្រជាជនកម្ពុជា

នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រសួងសំខាន់ៗត្រូវកាន់កាប់ដោយអ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ា ពិសេសមកពីខេត្តកំពង់ចាម ស្វាយរៀង និងអ្នកដែលបានទៅហាត់រៀននៅប្រទេសវៀតណាម ក្រោយសន្និសីទក្រុងសឺណែវឆ្នាំ 1954 ។ អ្នកទាំងពីរក្រុមនេះមានឋានៈជារដ្ឋមន្ត្រី និងមានតួនាទីក្នុងស្ថាប័នរដ្ឋសំខាន់ដូចជា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ឬ ក្នុងជួរគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត-ក្រុង ។ ក្រោយមក ដោយសន្តិសុខក្នុងប្រទេសមានលំនឹង គេចាប់គិតពីសមត្ថភាព(ចំណេះដឹង) ឬជំនាញរបស់មន្ត្រីចាស់ៗ ដែលនៅសេសសល់ពីសម័យសង្គមរាស្ត្រនិយម និងសម័យលន់នល់ដូចជា វិស្វករ និស្សិតក្នុង និងក្រៅប្រទេស សាស្ត្រាចារ្យ កម្មករបច្ចេកទេស ។ មន្ត្រីសំខាន់ៗនៅក្នុងរដ្ឋាភិបាលពេលនោះមាន លោក ហ៊ុន សែន លោក ជា ស៊ីម និង លោក ហេង សំរិន ជាអ្នកតស៊ូដែលចេញមកពីវណ្ណៈកសិករ ។

## 2.3. អង្គការគ្រប់គ្រងសំខាន់ៗក្នុងរដ្ឋាភិបាល



ទង់ជាតិ



សញ្ញាជាតិ

នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា មានអង្គការសំខាន់ៗ 4 គឺ

- គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ប៉ែន សុវណ្ណ អតីតខ្មែរឥស្សរៈ ដែលបានរៀនសូត្រទ្រឹស្តីកុម្មុយនីស្តនៅប្រទេសវៀតណាមខាងជើងនាឆ្នាំ 1954 ។ នៅខែធ្នូ ឆ្នាំ 1981 តំណែងអគ្គលេខាបក្សត្រូវប្តូរមកលោក ហេង សំរិន ។ គណបក្សប្រជាជនមានការិយាល័យនៅគ្រប់ខេត្ត-ក្រុង ។ ការជ្រើសរើសឱ្យចូលបក្ខជន ឬក្រុមស្នូល បានប្រព្រឹត្តទៅតាមរយៈការត្រួតពិនិត្យប្រវត្តិរូបយ៉ាងហ្មត់ចត់ ។
- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រីដែលមានរដ្ឋមន្ត្រីចំនួន 17 រូប ។ ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី គឺលោក ប៉ែន សុវណ្ណ ដែលកាន់តំណែងរហូតដល់ឆ្នាំ 1981 ទើបលោក ចាន់ ស៊ី (អតីតខ្មែរឥស្សរៈសិក្សានៅហាណូយ) ឡើងជំនួស ។ ក្រុមប្រឹក្សារដ្ឋមន្ត្រី មានមុខងារយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចទិសដៅសំខាន់ៗ របស់បក្ស ។ ការប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវកំណត់យ៉ាងទៀងទាត់ដើម្បីចាត់វិធានការរដ្ឋបាលយ៉ាងច្បាស់លាស់សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួងមន្ទីរនានាចៀសវាងការអនុវត្តខុសទិសដៅ ។ នៅរាល់ពេលប្រជុំតំណាងក្រសួងនីមួយៗត្រូវឡើងរាយការណ៍បង្ហាញសមិទ្ធផល និងបញ្ហាផ្សេងៗដែលកើតមាន ។ រដ្ឋាភិបាលពេលនោះ មានក្រសួងកសិកម្ម ក្រសួងអប់រំ ក្រសួងការបរទេស ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងក្រសួងព័ត៌មាន ។ នៅឆ្នាំ 1981 ទើបក្រសួងផែនការត្រូវបានបង្កើតដើម្បីរៀបចំគម្រោងផែនការស្តារសេដ្ឋកិច្ចជាតិ ។
- ក្រុមប្រឹក្សារដ្ឋមានលោក ហេង សំរិន ជាប្រធាន ។ អង្គការនេះមានតួនាទីធ្វើការវិនិច្ឆ័យលើបញ្ហាច្បាប់របស់រដ្ឋដូចជា រៀបចំក្រមព្រហ្មទណ្ឌ និងកែប្រែទោសប្រហារជីវិតជាដើម ។

- រដ្ឋសភាជាតិ មានសមាជិក 117រូប ដែលកើតឡើងដោយការបោះឆ្នោតនៅខែឧសភា ឆ្នាំ 1981 ។ ការប្រជុំសភាលើកទី 1 បានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ 1981 ដើម្បីជ្រើសរើសប្រធានសភា គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋ ។

ពីថ្ងៃទី 29 ដល់ថ្ងៃទី 30 ខែមេសា ឆ្នាំ 1989 រដ្ឋសភាបានបើកសម័យប្រជុំវិសាមញ្ញ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ប្តូរឈ្មោះសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជារដ្ឋកម្ពុជាព្រមទាំងប្តូរទង់ជាតិ និងភ្លេងជាតិផងដែរ ។ ក្រោយវិសោធនកម្មច្បាប់កំពូលរបស់ជាតិ ប្រទេសកម្ពុជាបានលុបបំបាត់ទោសប្រហារជីវិត និងទទួលយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ច្បាប់ការពារកម្មសិទ្ធិឯកជន និងទីផ្សារសេរីត្រូវបង្កើតឡើង ។

## 2.4. ស្ថានភាពសេដ្ឋកិច្ច

តារាងផលិតផលស្រូវ កៅស៊ូ និងនេសាទប្រចាំឆ្នាំ

| ឆ្នាំ | ផលនេសាទត្រី / ឆ្នាំ | ផលិតផលកៅស៊ូ / ឆ្នាំ | ផលិតផលស្រូវ / ឆ្នាំ |
|---|---|---|---|
| 1979 | គ្មានតួលេខ | គ្មានតួលេខ | 265 220 តោន |
| 1980 | 20 000 តោន | 1 300 តោន | 1 715 310 តោន |
| 1981 | 51 600 តោន | 4 000 តោន | 1 489 610 តោន |
| 1982 | 68 714 តោន | 7 000 តោន | 1 989 200 តោន |
| 1983 | 68 260 តោន | 9 000 តោន | 2 036 200 តោន |
| 1984 | 65 126 តោន | 13 400 តោន | 1 258 250 តោន |
| 1985 | 67 577 តោន | 17 640 តោន | 1 789 490 តោន |
| 1986 | 73 621 តោន | 24 500 តោន | 2 086 080 តោន |
| 1987 | 74 154 តោន | 25 000 តោន | 1 813 350 តោន |
| 1988 | 77 393 តោន | 32 000 តោន | 2 700 000 តោន |

ប្រទេសកម្ពុជា ជាប្រទេសពឹងផ្អែកលើវិស័យកសិកម្មបែបយថាផល ។ ប្រជាជនខ្មែរ 90% ប្រកបរបរកសិកម្មសំខាន់គឺស្រូវ ។ នៅឆ្នាំ 1988 ផលស្រូវមាន 2 700 000 តោន ហើយបានកើនឡើងដល់ 3 000 000 តោននៅឆ្នាំ 1990 ។ ប្រជាជនម្នាក់បានទទួលផលស្រូវជាមធ្យម 350 គីឡូក្រាម ។

មហាសន្និបាតបក្សលើកទី 5 បានកំណត់វិធានការ 3 យ៉ាងក្នុងផលិតកម្មស្បៀងគឺ ពង្រីកផ្ទៃដីកសិកម្ម បង្កើនរដូវដាំដុះ និងប្រពលវប្បកម្ម ។ ក្រៅពីដំណាំស្រូវមានដំណាំស្បៀង និងដំណាំឧស្សាហកម្ម ។ ដំណាំទាំងនេះមិនត្រឹមតែឧបត្ថម្ភក្នុងស្រុកទេ ថែមទាំងនាំចេញទៅក្រៅប្រទេសទៀតផង ។

ចម្ការកៅស៊ូ ជាមូលដ្ឋានផលិតកម្មសំខាន់បំផុតរបស់រដ្ឋសម្រាប់នាំចេញ ។ ចម្ការកៅស៊ូនៅខេត្តរតនគិរី កំពង់សោម កំពង់ចាម ក្រចេះ ដែលទុកចោល ខ្វះការថែទាំ ត្រូវបានរដ្ឋស្តារឡើងវិញយ៉ាងឆាប់រហ័សនូវចម្ការកៅស៊ូចាស់ និងដំណើរការដាំថ្មីបន្ថែមទៀតចាប់ពីឆ្នាំ 1985 ។ ប៉ុន្តែក្រោយឆ្នាំ 1985 រដ្ឋាភិបាលបានប្រគល់ឱ្យរដ្ឋអំណាចខេត្តកាន់កាប់ថែទាំ និងធ្វើអាជីវកម្ម ។

អាជីវកម្មឈើ ជាផ្នែកមួយមានការរីកចម្រើនខ្លាំង ហើយក្លាយជាមុខព្រួញដ៏សំខាន់មួយក្នុងចំណោមមុខព្រួញទាំង 4 នៃសេដ្ឋកិច្ចជាតិ ។

ក្រោយថ្ងៃរំដោះ (7 មករា 1979) ការនេសាទត្រីទាំងទឹកសាប ទាំងទឹកប្រៃរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ផលនេសាទអាចដោះស្រាយជីវភាពជូនប្រជាជន និងអាចនាំចេញទៅលក់នៅបរទេសបានមួយចំនួនទៀត ។ ទន្ទឹមនឹងនេះ បទល្មើសនេសាទកើតមានគួរឱ្យព្រួយបារម្ភដូចជា នេសាទត្រីនៅរដូវត្រីពង ប្រើឧបករណ៍ទំនើប ការកាប់ព្រៃលិចទឹក ចាប់កូនត្រីធ្វើអាជីវកម្មខុសច្បាប់ ។ល ។

## 2.5. វិស័យអប់រំមុន និងក្រោយឆ្នាំ 1979

ក្រោយថ្ងៃរំដោះ 7 មករា ឆ្នាំ 1979 មក វិស័យវប្បធម៌ និងអប់រំត្រូវបានស្តារឡើងវិញ ។ រដ្ឋបានរៀបចំប្រព័ន្ធអប់រំយ៉ាងទូលំទូលាយមួយ និងពង្រីកបន្ថែមរហូតដល់តំបន់ដាច់ស្រយាល ។ ឆ្នាំសិក្សា 1982-1983 ចំនួនសិស្សមត្តេយ្យមាន 23 797 នាក់ និងសិស្សកម្រិតទី 1 (បឋមសិក្សា) មាន 1 597 081 នាក់ កម្រិតសិក្សាទី 2 (មធ្យមសិក្សា) មានប្រហែល 87 005 នាក់ កម្រិតសិក្សាទី 3 (មធ្យមសិក្សាទុតិយភូមិ) មានប្រហែល 3 493 នាក់ និងគ្រូបង្រៀនមាន 40 000 នាក់ ។ សាលាឧត្តមសិក្សា និងមធ្យមសិក្សាមុខរបរជាច្រើនបានបើកទ្វារ ហើយនិស្សិតបញ្ចប់ការសិក្សាបានចេញបម្រើការកសាងជាតិជាហូរហែ (សាលាគរុវិជ្ជាជាន់ខ្ពស់ មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ វិជ្ជាស្ថានបច្ចេកទេសជាន់ខ្ពស់) ។ ក្នុងរយៈពេលតែ 4 ឆ្នាំប៉ុណ្ណោះ ចលនាអក្ខរកម្មបានប្រព្រឹត្តទៅយ៉ាងផុលផុស ។ វិស័យវប្បធម៌គ្រប់ផ្នែកបានធ្វើសកម្មភាពឡើងវិញ ហើយទទួលការយកចិត្តទុកដាក់យ៉ាងសកម្មពីរដ្ឋ ។

ទិន្នន័យធនធានមនុស្សមុន និងក្រោយឆ្នាំ 1979

| ក្របខ័ណ្ឌរដ្ឋការតាមស្ថាប័ន | មុនឆ្នាំ 1979 | ក្រោយឆ្នាំ 1979 |
|---|---|---|
| សាស្ត្រាចារ្យឧត្តមសិក្សា | មាន 720 នាក់ | សល់ 50 នាក់ |
| គ្រូពេទ្យ | មាន 487 នាក់ | សល់ 54 នាក់ |
| ឱសថការី | មាន 196 នាក់ | សល់ 15 នាក់ |
| បញ្ញវ័ន្តនៅបរទេស | មាន 1 000 នាក់ | សល់ 85 នាក់ |
| សាស្ត្រាចារ្យវិទ្យាល័យ | មាន 2 300 នាក់ | សល់ 207 នាក់ |
| គ្រូបឋមសិក្សា | មាន 21 311 នាក់ | សល់ 2 717 នាក់ |
| និស្សិត | មាន 11 000 នាក់ | សល់ 450 នាក់ |
| សិល្បករ | មាន 1 241 នាក់ | សល់ 121 នាក់ |

## 3. នយោបាយបង្រួបបង្រួមជាតិ

ក្រោយពេលរំដោះប្រទេសជាតិឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ក្រុមកម្ពុជាប្រជាធិបតេយ្យបានរត់ចូលព្រៃដើម្បីធ្វើសង្គ្រាមប្រឆាំងរបបរដ្ឋកម្ពុជា ហើយបង្កអសន្តិសុខដល់ប្រជាជន និងសង្គមកម្ពុជា ។

### 3.1. កិច្ចចរចាសន្តិភាពនាក្រុងហ្វែរអង់តាជឺន័រ ថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1987



*ការចុះហត្ថលេខាព្រមព្រៀង និងការចរចាដើម្បីដោះស្រាយកម្ពុជា (ទីក្រុងហ្វែរអង់តាជឺន័រប្រទេសបារាំង)*

នៅខែវិច្ឆិកា ឆ្នាំ 1984 នៅប្រទេសបារាំងបានរៀបចំគម្រោងការជួបចរចារវាងសម្តេច នរោត្តម សីហនុ និងតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ប៉ុន្តែគម្រោងនេះត្រូវអាក់ខាន ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន និងក្រុមខ្មែរ(ត្រីភាគី) បដិសេធ ។

នៅឆ្នាំ 1985 សភាពការណ៍នយោបាយនៅអាស៊ីបានអនុគ្រោះដល់ការចរចាសន្តិភាពនៅកម្ពុជា ។ ពេលនោះមានផែនការស្តីពីការដាក់កំហិតរយៈពេលនៃការដកកងទ័ពវៀតណាមចេញពីកម្ពុជា ។ កងទ័ពវៀតណាមត្រូវដកចេញពីទឹកដីកម្ពុជាឱ្យអស់នៅឆ្នាំ 1990 ។

នៅឆ្នាំ 1987 មានការជួបគ្នាថ្នាក់កំពូលរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត ។ ហេតុការណ៍នោះ បានធ្វើឱ្យសភាពការណ៍នយោបាយនៅកម្ពុជាកាន់តែមានលក្ខណៈប្រសើរឡើង ។ នៅឆ្នាំ 1987 សម្តេច នរោត្តម សីហនុ បានប្រកាសលាចេញពីតំណែងជាប្រធានត្រីភាគី ។ នៅថ្ងៃទី 29 ខែកក្កដា ឆ្នាំ 1987 ទស្សនកិច្ចជាផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី នៅប្រទេសវៀតណាម បានពិភាក្សាលើរូបមន្តនៃការជួបគ្នារវាងគូវិវាទខ្មែរទាំងអស់ជាពីរដំណាក់គឺ ៖

- ការជួបគ្នារវាងភាគីបដិបក្ខខ្មែរទាំងពីរ
- ការជួបគ្នារវាងបណ្តាភាគីខ្មែរ និងប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានយោបាយនៅកម្ពុជា ។

នៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1987 មានការជួបគ្នាលើកទី I រវាងសម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន នាទីក្រុងផែរអង់តាឌឺន័រប្រទេសបារាំង ដោយមានការចុះហត្ថលេខាព្រមព្រៀង និងចរចារកដំណោះស្រាយនៅកម្ពុជា ។

សន្និសីទកំពូលនៃបណ្តាប្រទេសអាស៊ាននាថ្ងៃទី 14-15 ខែធ្នូ ឆ្នាំ 1987 បានសម្តែងការអបអរសាទរ ចំពោះការជួបគ្នារវាងសម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន ។

ជំនួបលើកទី 2 រវាងសម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន នៅថ្ងៃទី 21-22 ខែមករា ឆ្នាំ 1988 នៅប្រទេសបារាំង មិនបានចេញសេចក្តីប្រកាសរួមណាមួយឡើយ ។ ភាគីនីមួយៗប្រកាសដោយឡែកអំពីលទ្ធផលនៃកិច្ចចរចា ។ សម្តេច នរោត្តម សីហនុ បានលុបចោលនូវការជួបលើកទី 3 នាខែមេសា ឆ្នាំ 1988 នៅក្រុងព្យុងយ៉ាង កូរ៉េខាងជើង លើកទី 4 នាខែវិច្ឆិកា ឆ្នាំ 1988 នៅប្រទេសបារាំង និងលើកទី 5 នៅដើមឆ្នាំ 1989 នាទីក្រុងញូវដែលីប្រទេសឥណ្ឌា ។

វេទិកា សីហនុ - ហ៊ុនសែន បានប្រព្រឹត្តទៅជាបន្តបន្ទាប់នៅទីក្រុងប៉ារីស ហ្សាការតា (ឥណ្ឌូណេស៊ី) តូក្យូ និងប៉ាតាយ៉ា ដើម្បីស្វែងរកដំណោះស្រាយនយោបាយនៅកម្ពុជា ។

## ១.2. រដ្ឋធម្មនុញ្ញឆ្នាំ 1989 និងការបង្កើតរដ្ឋកម្ពុជា

### ក. រដ្ឋធម្មនុញ្ញឆ្នាំ 1989

ចាប់ពីថ្ងៃទី 29 - 30 ខែមេសា ឆ្នាំ 1989 សភាបានបើកសម័យប្រជុំវិសាមញ្ញមួយ ដើម្បីពិនិត្យរដ្ឋធម្មនុញ្ញឡើងវិញ និងបានប្តូរឈ្មោះសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅជារដ្ឋកម្ពុជានៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1989 ហើយបានប្តូរទង់ជាតិ និងភ្លេងជាតិផងដែរ ។ នេះជារបត់ប្រវត្តិសាស្ត្រថ្មីរបស់ប្រទេសកម្ពុជា ដែលបានលុបចំបាត់ច្បាប់ប្រហារជីវិត និងទទួលស្គាល់ឡើងវិញនូវព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។ ច្បាប់ការពារកម្មសិទ្ធិឯកជន និងទីផ្សារសេរីត្រូវបានបង្កើតឡើង ។ រដ្ឋធម្មនុញ្ញបានចែងថា ប្រទេសកម្ពុជាជាប្រទេសអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ។ ម្យ៉ាងទៀតនយោបាយរបស់បក្ស និងរដ្ឋកម្ពុជាបានបន្ធូរបន្ថយ ព្រមធ្វើកិច្ចចរចាជាមួយភាគីជម្លោះបីទៀត ដែលកំពុងរួមគ្នាតស៊ូនៅតាមព្រំដែនខ្មែរ-ថៃ ។

### ខ. ការបង្កើតរដ្ឋកម្ពុជា

កត្តាជាច្រើនជំរុញឱ្យវៀតណាមដកកងទ័ពដែលនៅសេសសល់របស់ខ្លួន (ប្រមាណពីរម៉ឺនប្រាំមួយពាន់នាក់) ចេញពីប្រទេសកម្ពុជានៅថ្ងៃទី 26 ខែកញ្ញា ឆ្នាំ 1989 ។

ក្រោយពីមានការព្រមព្រៀងរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ការដកទ័ពវៀតណាមចេញពីប្រទេសកម្ពុជាជាលើកចុងក្រោយគឺនៅថ្ងៃទី 26 ខែកញ្ញា ឆ្នាំ 1989 ។ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានប្រកាសធ្វើកំណែទម្រង់ជាបន្តបន្ទាប់ដែលទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំងរបស់ប្រជាជនកម្ពុជាទាំងមូល ។ ការធ្វើកំណែទម្រង់នេះមានគោលបំណងលើកកម្ពស់នយោបាយក្រៅប្រទេសរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជារួមមានការផ្លាស់ប្តូរភ្លេងជាតិ ទង់ជាតិ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ការកំណត់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងលុបចោលល័ក្ខខ័ណ្ឌកំណត់អាយុសាងផ្នួសចំពោះបុរសខ្មែរពីអាយុ 50ឆ្នាំឡើងទៅ ។ ច្បាប់ថ្មីផ្តល់សិទ្ធិកម្មសិទ្ធិដល់ប្រជាពលរដ្ឋ ប្រជាកសិករខ្មែរអាចផ្ទេរកម្មសិទ្ធិដីធ្លី ផ្ទះឬលំនៅឋានទៅឱ្យកូនចៅ ឬ សិទ្ធិទិញ និងលក់អចលនទ្រព្យជាដើម ។ ទោសប្រហារជីវិតត្រូវបានលុបចោល សេរីភាពសារព័ត៌មាន និងអង្គការសង្គមស៊ីវិលជាច្រើនត្រូវបង្កើតឡើង ។ ទោះបីជាគណបក្សប្រជាជនបដិវត្តន៍កម្ពុជា ប្រឈមមុខនឹងចរន្តនយោបាយថ្មីពីក្រៅ

តែការទទួលខុសត្រូវលើជីវិតនយោបាយរបស់កម្ពុជានៅតែបន្ត ស្របគ្នានឹងការរីកចម្រើនទីផ្សារសេរី តាមរយៈឥទ្ធិពលសកលភាវូបនីយកម្ម ហើយការកែទម្រង់ពីរបបសេដ្ឋកិច្ចផែនការ មករបបសេដ្ឋកិច្ចទីផ្សារសេរីបានដំណើរការប្រកបដោយជោគជ័យ។ ចាប់ពីពេលនោះមក ជីវភាពប្រជាជនមានការអភិវឌ្ឍគួរកត់សំគាល់។

## 3.3. កិច្ចចរចាក្រុងប៉ារីសថ្ងៃទី 23 ខែតុលា ឆ្នាំ 1991

ក្រោយពីវៀតណាមបានប្រកាសដកកងទ័ពរបស់ខ្លួនជាផ្លូវការចេញពីប្រទេសកម្ពុជានៅថ្ងៃទី 26 ខែកញ្ញា ឆ្នាំ 1989 មក កងទ័ពខ្មែរក្រហម និងកងទ័ពរបស់ក្រុមអ្នកតស៊ូទាំងពីរក្រុមផ្សេងទៀតបានបន្តវាយកងទ័ពកម្ពុជាតទៅទៀត។ រដ្ឋាភិបាលរដ្ឋកម្ពុជាបានខិតខំទាក់ទាញសេចក្តីអនុគ្រោះ និងរកការគាំទ្រពីមតិជាតិ និងអន្តរជាតិ ដើម្បីទប់ទល់នឹងកងទ័ពខ្មែរក្រហម រួមទាំងកម្លាំងចលនាតស៊ូទាំងពីរក្រុមទៀត។ លោក ស៊ីឌីសាវេតស៊ីឡា(Sidhi Savetsila)រដ្ឋមន្ត្រីការបរទេសថៃ និងលោក អាលីអាឡាតាស(Ali Alatas) រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ខិតខំរកដំណោះស្រាយបញ្ហាកម្ពុជាតាមរយៈកិច្ចប្រជុំនៅទីក្រុងហ្សាការតាបីលើក។



*សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន ក្នុងដំណើរការចរចាបញ្ចប់សង្គ្រាមរវាងខ្មែរ និងខ្មែរ*

សម័យប្រជុំលើកទី 1 នៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា នៅថ្ងៃទី 30 ខែកក្កដា ដល់ 30 ខែសីហា ឆ្នាំ 1989 នៅក្រុងប៉ារីស ដែលមានប្រទេសបារាំង និងឥណ្ឌូណេស៊ី ជាសហប្រធាន ភាគីខ្មែរទាំងពីរ បានឈានដល់ការព្រមព្រៀងគ្នាមួយដើម្បីបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់( Superme National Council = SNC ) នៅថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1990 ដែលមានសមាជិកទាំងអស់ចំនួន 12រូប ក្នុងនោះ 6 រូបមកពីភាគីរដ្ឋកម្ពុជា និង 6រូបទៀតមកពីចលនាតស៊ូត្រីភាគី ។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានធ្វើការប្រជុំលើកទី 1 នៅទីក្រុងបាងកក ហើយ 5លើកជាបន្តបន្ទាប់ទៀតនៅទីក្រុងប៉ារីស ញូវយ៉ក ហ្សាការតា ប៉ាតាយ៉ា និងប៉េកាំង ដោយបានយល់ព្រមទទួលយកសម្តេច នរោត្តម សីហនុ ឱ្យដឹកនាំក្រុមប្រឹក្សាជាតិជាន់ខ្ពស់ និងរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅកម្ពុជា ។

នៅខែមេសា ឆ្នាំ 1991 ប្រទេសចិនអនុញ្ញាតឱ្យខ្មែរក្រហមចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយគូវិវាទខ្មែរទាំងបួន ។ គូបដិបក្ខទាំងបួនជួបជុំគ្នានៅប៉ាតាយ៉ា(ប្រទេសថៃ) នាថ្ងៃទី 23-24 ខែមិថុនា ឆ្នាំ 1991 បានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ ។ នៅថ្ងៃទី 23 ខែតុលា ឆ្នាំ 1991 មានរៀបចំសន្និសីទនៅក្រុងប៉ារីសដើម្បីទម្លុះទម្លាយវិបត្តិនយោបាយនៅកម្ពុជា ។

នៅទីបំផុត កិច្ចចរចារកសន្តិភាពរវាងភាគីជម្លោះខ្មែរនាទីក្រុងប៉ារីស បានទទួលលទ្ធផលយ៉ាងល្អប្រសើរ ដោយតំណាងភាគីជម្លោះចាប់ដៃគ្នា យល់ព្រមធ្វើការបោះឆ្នោតជាសកល ដែលមានអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា( United Nations Transitional Authority in Cambodia UNTAC ) មើលការខុសត្រូវ ។

អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ( UNTAC ) មានទាហាន 17 000 នាក់និងមានជនស៊ីវិល 8 000 នាក់មកពី 22 ប្រទេស ។ មន្ត្រីជប៉ុនម្នាក់ឈ្មោះលោក យ៉ាស៊ូស៊ី អាកាស៊ី ( Yashusi AKashi )ទទួលខុសត្រូវលើអំណាចត្រួតត្រាបណ្តោះអាសន្ននៅកម្ពុជា រីឯកងទ័ពវិញស្ថិតនៅក្រោមបញ្ជាការរបស់ឧត្តមសេនីយ៍ជនជាតិអូស្ត្រាលីម្នាក់ឈ្មោះ លោក សង់ឌែសុន( Sanderson ) ។ អាជ្ញាធរបណ្តោះអាសន្ន ( UNTAC ) មានថវិកាចំនួន 3 000 លានដុល្លារ ដើម្បីបំពេញបេសកកម្ម 4 យ៉ាងគឺ ៖

- ដកអាវុធពីកងទ័ពរដ្ឋកម្ពុជា និងពីកងទ័ពភាគីខ្មែរក្រហម រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ( FNLPK ) និងកងទ័ពរាជានិយមរបស់សម្តេចព្រះ នរោត្តម សីហនុ (RNC)
- បញ្ចូលរដ្ឋអំណាចទាំងសងខាងឱ្យរួមគ្នា (រដ្ឋកម្ពុជា និងរដ្ឋាភិបាលត្រីភាគី)
- រៀបចំការបោះឆ្នោតដោយសេរី
- នាំជនភៀសខ្លួនប្រហែល 350 000 នាក់ ត្រឡប់មកមាតុភូមិវិញ ។

សម័យប្រជុំលើកទី 2 នៃសន្និសីទអន្តរជាតិ បានប្រព្រឹត្តទៅពីថ្ងៃទី 21 ដល់ 23 ខែតុលា ឆ្នាំ 1991 នៅរដ្ឋធានីសាធារណរដ្ឋបារាំង ។ ក្នុងនាមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលដឹកនាំដោយ សម្ដេច នរោត្តម សីហនុបានចុះហត្ថលេខានៅថ្ងៃទី 23 ខែតុលា ឆ្នាំ 1991 លើកិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមនៃជម្លោះនៅកម្ពុជា ក្នុងនោះផ្ដោតលើចំណុច 2 សំខាន់គឺ កិច្ចព្រមព្រៀងទាក់ទងនឹងអធិបតេយ្យភាព បូរណភាពដែនដី អព្យាក្រឹតភាព និងឯកភាពជាតិកម្ពុជា និងទី 2 សេចក្ដីថ្លែងការណ៍ស្ដីពីការស្ដារ និងកសាងប្រទេសកម្ពុជាឡើងវិញ ដែលហៅថាសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស ។ ប្រទេសដែលចូលរួមមាន 18 ប្រទេស គឺអូស្ត្រាលី ព្រុយណេ កាណាដា ចិន យូហ្គោស្លាវី សហរដ្ឋអាមេរិក បារាំង ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ហ្វីលីពីន អង់គ្លេស សិង្ហបុរី ថៃ សហភាពសូវៀត និងវៀតណាម ព្រមទាំងមានវត្តមានរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតំណាងចលនាមិនចូលបក្សសម្ព័ន្ធចូលរួមជាសក្ខីកម្មផងដែរ ។

## 3.4. ព្រះរាជាណាចក្រកម្ពុជាទី 2 (1993)

ការបោះឆ្នោតបានប្រព្រឹត្តទៅដោយមានគណបក្សចំនួន 20 ចូលរួម ។ ទោះបីក្រុមខ្មែរក្រហមធ្វើពហិការមិនចូលរួមក៏ដោយ ក៏ការបោះឆ្នោតបានដំណើរការតាមការគ្រោងទុក គឺថ្ងៃទី 23 ដល់ 28 ខែឧសភា ឆ្នាំ 1993 ។

ដោយផ្អែកលើសំឡេងគាំទ្ររបស់ប្រជាជននៅក្នុងការបោះឆ្នោតជាសកលលើកទី 1 នេះ ព្រះបាទ នរោត្តម សីហនុ បានតែងតាំងព្រះអង្គម្ចាស់រណឫទ្ធិ ធ្វើជានាយករដ្ឋមន្ត្រីទី 1 ហើយសម្ដេច ហ៊ុនសែន ធ្វើជានាយករដ្ឋមន្ត្រីទី 2 ។

ថ្ងៃទី24 ខែកញ្ញា ឆ្នាំ 1993 សម្ដេច សីហនុ ទ្រង់ឡើងសោយរាជ្យវិញក្នុង "ព្រះរាជាណាចក្រកម្ពុជាទី 2" ។ ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 1993 រដ្ឋសភាអនុម័តលើរដ្ឋធម្មនុញ្ញថ្មី ហើយត្រូវបានប្រកាសប្រើជាផ្លូវការនៅថ្ងៃទី 24 ខែកញ្ញា ឆ្នាំ 1993 ។ អាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ (UNTAC) ក៏ត្រូវបញ្ចប់បេសកកម្មដែរ ។

ចាប់ពីឆ្នាំ 1993 មកដល់បច្ចុប្បន្ន (2011) ប្រទេសកម្ពុជាបានបោះឆ្នោតជាសាកល ដោយសេរី ជ្រើសតាំងតំណាងរាស្ត្របាន 4ដង ឬ 4អាណត្តិនៃរដ្ឋសភារួចមកហើយ ។




*ការសម្ពោធរដ្ឋសភាថ្មី (07 07 2007)*

## ? សំណួរ

1. តើថ្ងៃទី 7 ខែមករា ឆ្នាំ 1979 បញ្ចាក់ពីកាលបរិច្ឆេទអ្វី ?
2. ហេតុអ្វីបានជាមានថ្ងៃទី 7 ខែមករា ឆ្នាំ 1979 ?
3. តើកត្តាអ្វីខ្លះនាំឱ្យថ្ងៃទី 7 ខែមករា ឆ្នាំ 1979 មានជ័យជម្នះលើរបបប្រល័យពូជសាសន៍ ?
4. ហេតុអ្វីបានជាគេបង្កើតឱ្យមានក្រុមសាមគ្គីបង្កបង្កើនផល ? ចូរពន្យល់ពីការបែងចែកកម្លាំងពលកម្ម ។
5. ហេតុអ្វីបានជារដ្ឋាភិបាលកម្ពុជាបង្កើតនយោបាយបង្រួបបង្រួមជាតិ ?
6. តើកិច្ចចរចាក្រុងប៉ារីសថ្ងៃទី 23 ខែតុលា ឆ្នាំ 1991 ផ្តល់សារៈសំខាន់អ្វីខ្លះដល់ប្រទេស និងប្រជាជនកម្ពុជា ?

## សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

1 តើបារាំងចូលគ្រប់គ្រងប្រទេសកម្ពុជាដំបូងក្នុងរជ្ជកាលព្រះរាជាខ្មែរអង្គណា ?

☐ ក. អង្គឌួង ☐ ខ. នរោត្តម ☐ គ. ស៊ីសុវត្ថិ ☐ ឃ. សីហនុ ។

2. តើសង្គមរាស្ត្រនិយមបានចាប់ផ្ដើមឡើងនៅឆ្នាំណា ?

☐ ក. 1952 ☐ ខ. 1953 ☐ គ. 1954 ☐ ឃ. 1955 ។

3 តើនរណាដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ (មេធំជាងគេ) ?

☐ ក. ប៉ុលពត ☐ ខ. អៀងសារី ☐ គ. ខៀវសំផន ☐ ឃ. សុនសេន ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1 កិច្ចចរចាសន្តិភាពនាទីក្រុងប៉ែអង់តាជីន័រថ្ងៃទី ខែ ឆ្នាំ ។

2 រដ្ឋប្រហារថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ធ្វើឡើងដោយ និង ។

3 ពួកខ្មែរក្រហមបានចូលកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី ខែ ឆ្នាំ ។

III. ចូរគូសភ្ជាប់ឈ្មោះអ្នកដឹកនាំទៅឈ្មោះរបប

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះរបប | ចម្លើយ |
|---|---|---|
| 1 ប៉ុលពត | ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា | 1 → |
| 2. នរោត្តមសីហនុ | ខ. សង្គមរាស្ត្រនិយម | 2. → |
| 3 លន់នល់ | គ. កម្ពុជាប្រជាធិបតេយ្យ | 3. → |
| 4 ហ៊ុនសែន | ឃ សាធារណរដ្ឋខ្មែរ | 4 → |
| 5 ហេងសំរិន | ង. រដ្ឋកម្ពុជា | 5 → |

IV. សំណួរត្រិះរិះ

1 តើលទ្ធផលវិជ្ជមាន និងអវិជ្ជមាននៃរបបអាណានិគមបារាំងមកលើកម្ពុជាមានអ្វីខ្លះ ?

2. ចូររៀបរាប់ពីសមិទ្ធផលសង្គមរាស្ត្រនិយម ។

3 តើផលវិបាកនៃសង្គ្រាមស៊ីវិលក្នុងរបបលន់នល់បានធ្វើឱ្យសង្គមខ្មែរជួបប្រទះអ្វីខ្លះ ?

4 តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យត្រូវរលំរលាយ ?

5 តើការបែងចែកផលកសិកម្មតាមកម្លាំងពលកម្ម (ក្រុមសាមគ្គីបង្កបង្កើនផល) ទទួលផលល្អនិងផលអាក្រក់ដូចម្ដេច ?

## ជំពូកទី 3 ប្រវត្តិសាស្ត្រតំបន់ក្នុងសង្គ្រាមត្រជាក់



នាយករដ្ឋមន្ត្រីនៃប្រទេសអាស៊ាន

ប្រទេសក្នុងតំបន់បានទទួលរងការត្រួតត្រាពីពួកអាណានិគមនិយម ពីឥទ្ធិពលនៃសង្គ្រាមលោកលើកទី 1 និងទី 2 ពីឥទ្ធិពលសង្គ្រាមត្រជាក់ និងសង្គ្រាមភេរវកម្មដូចគ្នា ។ តែបច្ចុប្បន្ន ប្រជាជននៅអាស៊ីអាគ្នេយ៍បាន និងកំពុងអភិវឌ្ឍប្រទេសជាតិខ្លួនឱ្យសម្បូររុងរឿងដោយប្រើនយោបាយសេដ្ឋកិច្ចសហការប្រទេសក្នុងតំបន់ ។ ប៉ុន្តែប្រទេសនៅមជ្ឈិមបូព៌ាកំពុងជួបប្រទះនឹងសង្គ្រាមរ៉ាំរ៉ៃ និងសង្គ្រាមភេរវកម្ម ។

មេរៀនទី

# 1 បម្រែបម្រួលសង្គមអាស៊ីអាគ្នេយ៍ក្រោយសង្គ្រាមលោកលើកទី២

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាអំពីបម្រែបម្រួលប្រទេសអាស៊ីអាគ្នេយ៍ក្នុងដំណាក់កាលអាណានិគមនិយម ។
- បង្ហាញអំពីចលនាតស៊ូ ដើម្បីឯករាជ្យជាតិ បណ្ដាប្រទេសទាំងនោះ ។
- ពន្យល់ពីភាពវិកវរក្នុងសង្គមដំណាក់ការនៃសង្គ្រាមត្រជាក់ ។

## 1. ការតស៊ូដើម្បីឯករាជ្យជាតិ

ការគ្រប់គ្រងពីសំណាក់ប្រទេសអាណានិគមនិយមមកលើបណ្ដាប្រទេសអាស៊ីអាគ្នេយ៍[1] បានលេចឡើងនូវការកែប្រែសង្គមយ៉ាងគំហុកពីរបបសក្តិភូមិ ទៅជាប្រព័ន្ធមូលធននិយមបែបលោកខាងលិច ។ ការផ្ទើកំណែទម្រង់នេះពុំបានធ្វើឱ្យសង្គមបូព៌ាក្លាយជាសង្គមទំនើបបែបលោកខាងលិចទាំងស្រុងបានទេគ្រាន់តែលេចឡើងនូវសង្គមមួយដែលមានលក្ខណៈពាក់កណ្ដាលមូលធននិយម និងពាក់កណ្ដាលសក្តិភូមិតែប៉ុណ្ណោះ ។ បម្រែបម្រួលរចនាសម្ព័ន្ធសង្គមបែបនេះបានធ្វើឱ្យគេដើរនៅលើផ្លូវមួយកាន់តែវិកវរខ្លាំងឡើងថែមទៀតប៉ុណ្ណោះ ។ នៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ បានលេចឡើងនូវចលនាតស៊ូក្នុងរូបភាពពីរយ៉ាងគឺ ៖

- ការតស៊ូដើម្បីឯករាជ្យជាតិ ប្រឆាំងនឹងរបបអាណានិគមនិយមអង់គ្លេស និងបារាំង ។ ការតស៊ូនេះជាចលនាមួយមានលក្ខណៈជាតិនិយម ។
- ការតស៊ូប្រឆាំងនឹងពួកមូលធន និងសក្តិភូមិ ។

(ក្នុងការតស៊ូមានការចូលរួមដោយកសិករ កម្មករ ពួកឈ្មួញ ពាណិជ្ជករជាតិតូចតាច សិប្បករ និងប្រជាជនក្រីក្រក្នុងទីក្រុងជាកម្លាំងចលករ និងមានចរិតជាចលនាប្រជាធិបតេយ្យ ។ )

ដូច្នេះយើងឃើញថានៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ ដំណាក់កាលតស៊ូប្រឆាំងនឹងរបបអាណានិគមនិយមបានលេចឡើងនូវចលនាតស៊ូមានចរិតជាបដិវត្តន៍ប្រជាជាតិ ប្រឆាំងនឹងប្រទេសអាណានិគមនិយម ដើម្បីឯករាជ្យជាតិផង ជាបដិវត្តន៍ប្រជាធិបតេយ្យ ប្រឆាំងនឹងរបបសក្តិភូមិមូល

(1) លើកលែងតែប្រទេសថៃមួយគត់ក្នុងតំបន់ ដែលមិនធ្លាប់ស្ថិតក្រោមអំណាចអាណានិគមនិយមណាមួយឡើយ ។

ធននិយមផ្ដាច់ការផង និងកសាងអំណាចប្រជាជននៅក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋផង ។ ទិសដៅដ៏សំខាន់របស់គេគឺការស្វែងរកមធ្យោបាយថ្មី លុបបំបាត់ភាពអន់ថយនៅក្នុងសង្គម ធ្វើទំនើបកម្មដើម្បីឈានទៅរកការរីកចម្រើនមួយជាប្រវត្តិសាស្ត្រ ។ ប៉ុន្តែក្នុងដំណាក់កាលក្រោយរបបអាណានិគមនិយម ប្រទេសអាស៊ីអាគ្នេយ៍បានជួបប្រទះនូវបញ្ហាជាច្រើន ពុំមានការអភិវឌ្ឍដូចការគិតទុកជាមុននោះទេ ។ ចលនាតស៊ូមានច្រើន ទោះបីមានទិសដៅដើម្បីឯករាជ្យជាតិដូចៗគ្នាក៏ពិតមែន ប៉ុន្តែក្រុមនីមួយៗសុទ្ធតែបំពាក់ដោយមនោគមន៍វិជ្ជាផ្សេងៗគ្នា ដែលយើងសង្កេតឃើញមានទិសដៅនៃការកសាងប្រទេស ឈរលើគោលការណ៍ពីរខុសគ្នាគឺ កំណែទម្រង់ប្រជាធិបតេយ្យសេរីនិយម និងបដិវត្តន៍ប្រជាធិបតេយ្យ(កុម្មុយនីស្តនិយម) ។

បញ្ញវ័ន្តបានក្លាយជាកម្លាំងឈានមុខនៅក្នុងចលនាតស៊ូរំដោះជាតិ និងក្នុងការកសាងប្រជាធិបតេយ្យនៅក្នុងប្រទេស ។ ក្រុមបញ្ញវ័ន្តច្រើនចេញមកពីជួរមន្ត្រីរាជការ នាយទាហាន កូនចៅអភិជន គហបតី និងពាណិជ្ជករ ។ បញ្ញវ័ន្តជាច្រើនបានកសាងចលនាតស៊ូក្នុងខណៈដែលពួកគេទៅសិក្សានៅក្នុងប្រទេសមហាអំណាចតែម្ដងដូចជាប្រទេសបារាំង អង់គ្លេសជាដើម ។ នៅទីនោះគេចងក្រងជាសមាគមបោះពុម្ពកាសែត ទស្សនាវដ្ដី ផ្សព្វផ្សាយអំពីចលនាតស៊ូរបស់គេ ។ ទោះបីបញ្ញវ័ន្តចេញពីប្រភពស្រទាប់សង្គមដូចៗគ្នាក៏ដោយ ក៏ចក្ខុវិស័យនៃការកសាងជាតិរបស់គេពុំដូចគ្នាទេ ។

ក្រុមកំណែទម្រង់ប្រជាធិបតេយ្យសេរីនិយមមានទិសដៅកសាងនយោបាយសេដ្ឋកិច្ចសង្គមដោយសន្សឹមៗ ក្រោយពេលទទួលបានឯករាជ្យ ។ ទិសដៅនេះបម្រើឱ្យផលប្រយោជន៍គហបតីជាតិ ។ កំណែទម្រង់សេរីនិយមទាមទារឱ្យមានការយកចិត្តទុកដាក់ចំពោះវឌ្ឍនភាពឧស្សាហកម្មជាតិ បង្កើតប្រព័ន្ធសិក្សាធិការតាមបទពិសោធន៍នៃប្រទេសលោកខាងលិច ។ ពួកគេទាមទារឱ្យមានកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋ និងសេដ្ឋកិច្ច បង្កើតឱ្យមានប្រព័ន្ធដឹកនាំទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ទំនើបកម្ម នៅក្នុងវិស័យយោធា និងវិស័យផ្សេងៗទៀត ។ អ្នកកំណែទម្រង់គហបតីប្រជាធិបតេយ្យនិយមបានគិតថាត្រូវតែទទួលឱ្យបាននូវការទាមទារទាំងអស់នេះដោយសន្តិវិធី ។

ក្រោមឥទ្ធិពលនៃបក្សកុម្មុយនីស្តពិភពលោក ចលនាតស៊ូប្រឆាំងនឹងរបបអាណានិគមនិយមបានលេចឡើងនូវបក្សកុម្មុយនីស្ត ដែលដឹកនាំចលនាតស៊ូប្រឆាំងពួកអាណានិគមដើម្បីឯករាជ្យនិងបន្តធ្វើបដិវត្តន៍ប្រជាធិបតេយ្យ ផ្ដួលរំលំអំណាចសក្តិភូមិមូលធនជាតិកសាងអំណាចប្រជាជន និងមូលដ្ឋានសង្គមនិយម និងឈានឡើងដល់របបកុម្មុយនីស្តនិយម ។

## 2. ភាពទីគឹមនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ក្នុងជំណាក់កាលសង្គ្រាមត្រជាក់




*ផែនទីអាស៊ីអាគ្នេយ៍*

នៅក្នុងជំណាក់កាលអាណានិគមនិយម សង្គ្រាមបានផ្ទុះឡើងមិនត្រឹមតែក្នុងរូបភាពជាចលនាតស៊ូដើម្បីឯករាជ្យជាតិ ឯកភាពផ្ទៃក្នុងនៃប្រទេសតំបន់អាស៊ីអាគ្នេយ៍ប៉ុណ្ណោះទេ ថែមទាំងបង្កនូវភាពចលាចល និងអស្ថេរភាពនយោបាយយ៉ាងខ្លាំង ។

ជាភ័ព្វសំណាងអាក្រក់ ក្រោយពេលដែលមហាអំណាចអឺរ៉ុបដកខ្លួនចេញផុតទៅប្រជាជនជាង 330 លាននាក់(ស្ថិតិឆ្នាំ 1989) នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅតែបន្តការបង្ហូរឈាមតទៅទៀត ជាពិសេសនៅតំបន់ឥណ្ឌូចិន សង្គ្រាមបានបន្តអស់រយៈពេលជាង 20 ឆ្នាំ ។ នៅក្នុងប្រទេសកម្ពុជាអស្ថិរភាពនយោបាយបន្តរហូតដល់ទសវត្សរ៍ឆ្នាំ 90 ទើបតែបញ្ចប់ដោយកិច្ចចរចាដើម្បីសន្តិភាពនៅថ្ងៃ 23 ខែតុលា ឆ្នាំ 1991 នាទីក្រុងប៉ារីស ។ នៅក្នុងទំព័រប្រវត្តិសាស្ត្របានចារទុកនូវសោកនាដកម្ម វិនាសកម្មដោយសារសង្គ្រាមដ៏ខ្លាំងក្លាមួយក្រោយឆ្នាំ 1945 ដែលប្រជាជនឥណ្ឌូចិន (កម្ពុជា វៀតណាម ឡាវ) បានជួបប្រទះ ។ ប្រទេសថៃជាសម្ព័ន្ធមិត្តមានភក្តីភាព ចំពោះសហរដ្ឋអាមេរិក បានផ្តល់មូលដ្ឋានទ័ព

អាកាសដល់សហរដ្ឋអាមេរិកដើម្បីបង្ហាញវត្តមានអាមេរិកនៅក្នុងទ្វីបអាស៊ី ក្នុងចំណោងទប់ទល់និងការពង្រឹង និងពង្រីកមនោគមន៍វិជ្ជាកុម្មុយនីស្តនៅក្នុងតំបន់នេះ ។ ប្រទេសម៉ាឡេស៊ី សិង្ហបុរី និងឥណ្ឌូណេស៊ី បានប្រឹងប្រែងយ៉ាងណា ដើម្បីជៀសវាងទំនាស់រវាងបណ្តាប្រទេសនៅក្នុងតំបន់ឥណ្ឌូចិន ។

ឥណ្ឌូណេស៊ី ដែលជាប្រទេសមួយមានផ្ទៃដីធំជាងគេ និងមានប្រជាជនច្រើនជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ (តាមស្ថិតិឆ្នាំ 1989 មានចំនួន 178.2 លាននាក់)បានផ្តួលរំលំស៊ូកាណូពីអំណាច នៅឆ្នាំ 1967 ។ ប្រទេសភូមា បានដឹកនាំនយោបាយមិនចូលបក្សសម្ព័ន្ធក្រោមរដ្ឋអំណាចយោធានិយម ដែលដឹកនាំដោយឧត្តមសេនីយ៍ នេវីន ពីឆ្នាំ 1962 ដល់ឆ្នាំ 1988 ត្រូវបានកាត់ផ្តាច់ពីពិភពលោក ។ ទីបំផុតប្រទេសហ្វីលីពីន ជារដ្ឋឯករាជ្យមួយដែលមានទំនាក់ទំនងដ៏ស្និតរមួតជាមួយនឹងសហរដ្ឋអាមេរិក ហើយមានការពាក់ព័ន្ធនឹងជំនួយពីសហរដ្ឋអាមេរិកយ៉ាងខ្លាំង ។ ហ្វីលីពីនបានអនុញ្ញាតឱ្យសហរដ្ឋអាមេរិកសង់មូលដ្ឋានទ័ពពីរកន្លែងគឺ សម្រាប់កងទ័ពនាវាចរណ៍ និងសម្រាប់កងទ័ពអាកាសចរណ៍នៅឆ្នេរ ស៊ូប៊ីក ( Subic Bay ) ដើម្បីការពារតំបន់ភូមិភាគខាងលិចនៃមហាសមុទ្រប៉ាស៊ីហ្វិក ។ វត្តមានរបស់សហរដ្ឋអាមេរិកនៅទីនេះបានត្រូវមហាជនជំទាស់តវ៉ា ព្រោះគេយល់ថាជាការរំលោភលើអធិបតេយ្យភាព និងបូរណភាពទឹកដីនៃប្រទេសឯករាជ្យមួយ ។

នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ក្រៅពីវិបត្តិសង្គម នៅមានបញ្ហាទំនាស់ជនជាតិនិងជំនឿសាសនាដែលនាំឱ្យមានរហូតដល់ការបង្ហូរឈាមគ្នា ។

នៅប្រទេសភូមាមានជនជាតិភាគតិចមួយចំនួនបានបះបោរជាញឹកញាប់ ។ នៅក្នុងប្រទេសហ្វីលីពីនពួកជីវពលអ៊ីស្លាមនិយមបានបះបោរជាទ្រង់ទ្រាយធំ ។ សឹងតែគ្រប់ប្រទេសទាំងអស់ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជួបប្រទះនឹងបញ្ហាច្រើនទាក់ទងនឹងរឿងជនជាតិ ។ "សង្គ្រាមត្រជាក់" រវាងសហភាពសូវៀត សហរដ្ឋអាមេរិក និងចិនប្រជាមានិតបាននាំមកនូវទំនាស់នៅក្នុងតំបន់ ហើយបានបញ្ឆេះភ្លើងសង្គ្រាមនៅក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ ។

ចិនប្រជាមានិត និងសហភាពសូវៀតបានប្រឹងបញ្ចេញឥទ្ធិពលរៀង១ខ្លួន សហរដ្ឋអាមេរិកក៏ដូច្នេះដែរ បានឧបត្ថម្ភគ្រឿងសព្វាវុធដល់គូប្រឆាំងនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាមខាងត្បូង ។

សហរដ្ឋអាមេរិកជាមហាអំណាចតែមួយគត់ ដែលបានបញ្ជូនកងទ័ពរបស់ខ្លួនទៅកាន់សមរភូមិវៀតណាម ។ ទំនាស់នៅក្នុងប្រទេសផ្សេងៗនៃតំបន់អាស៊ីអាគ្នេយ៍ ដែលកើតឡើងដោយសារ "សង្គ្រាមត្រជាក់" បានក្លាយទៅជាទំនាស់នៅក្នុងតំបន់ទាំងមូល ។




និមិត្តសញ្ញាអាស៊ាន និងទង់ជាតិបណ្ដាប្រទេសសមាជិកអាស៊ាន

## 3. សន្និដ្ឋាន

គួរកត់សំគាល់ដែរថា ទោះបីនៅក្នុងតំបន់អាស៊ីអាគ្នេយ៍កម្រិតជីវភាពរបស់ប្រជាជននៅទាប ដោយសារតែមូលហេតុនេះ បានលេចឡើងនូវបញ្ហាដ៏ច្រើនក៏ពិតមែន ប៉ុន្តែពួកកុម្មុយនីស្តចិន និងសហភាពសូវៀត មានឥទ្ធិពលតិចតួចណាស់នៅក្នុងតំបន់នេះ ។ ហេតុដូចម្ដេចបានជាមានបញ្ហាបែបនេះ ពីព្រោះតំបន់អាស៊ីអាគ្នេយ៍ជាតំបន់មួយ ដែលមានប្រពៃណីទំនៀមទម្លាប់ចាស់ ត្រូវបានប្រជាជនប្រកាន់ខ្ជាប់ខ្ជួន ហើយសាសនាមានតួនាទីដ៏សំខាន់ នៅក្នុងជួរប្រជាជនដែលប្រឈមមុខនឹងពួកកុម្មុយនីស្តដែលពួកគេមិនជឿថាមានព្រះ ។

ក្នុងតំបន់អាស៊ីអាគ្នេយ៍ពួកអ្នកជាតិនិយម ជាដំបូងបានពើបប្រទះនឹងការជ្រៀតជ្រែកពីសំណាក់ជនជាតិអឺរ៉ុបបន្ទាប់មកពួកយោធានិយមជប៉ុន ហើយទីបំផុតពួកអឺរ៉ុបដដែល ។ កត្តាមួយទៀតដែលជាស្ថានភាពមួយមិនសូវល្អចំពោះពួកកុម្មុយនីស្ត នៅក្នុងទ្វីបអាស៊ីគឺចាប់ពីឆ្នាំ 1949 មកមានតែប្រទេសចិនប្រជាមានិតតែប៉ុណ្ណោះ បានបញ្ចេញសកម្មភាព ។

ក្រោយការតស៊ូប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍សុទ្ធតែទទួលឯករាជ្យភាពលើកលែងតែសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានប្រឹងប្រែងកសាងប្រទេសដើម្បីជៀសវាងឥទ្ធិពលនៃពួកកុម្មុយនីស្តចិន ។ ទោះបីប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍មិនចូលចិត្តនយោបាយកុម្មុយនីស្តចិនក៏ដោយ ប៉ុន្តែគ្រប់បណ្តាប្រទេសទាំងអស់នៃតំបន់អាស៊ីអាគ្នេយ៍សុទ្ធតែមានប្រជាជនចិនរស់នៅយ៉ាងច្រើនទៀតផង ។ គ្រប់ដំណាក់កាលនៃការតស៊ូដើម្បីអំណាច មេដឹកនាំធ្វើរដ្ឋប្រហារតែងតែផ្សារភ្ជាប់ទៅនឹងមេដឹកនាំនយោបាយសេដ្ឋកិច្ច ឬម្ចាស់ផលិតកម្ម ។

## ? សំណួរ

1. តើចលនាតស៊ូមានប៉ុន្មានបែប ? អ្វីខ្លះ ?
2. តើអ្នកណាជាកម្លាំងស្នូលនៅក្នុងការដឹកនាំចលនាតស៊ូដើម្បីឯករាជ្យជាតិទាំងនេះ ?
3. តើភាពវិកវរអ្វីខ្លះដែលគួរឱ្យកត់សំគាល់នៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ក្នុងដំណាក់កាលក្រោយការទទួលបានឯករាជ្យជាតិ ?

# 2 ប្រទេសវៀតណាម

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញអំពីព្រឹត្តិការណ៍សំខាន់ៗក្រោយសង្គ្រាមលោកលើកទី 2 រហូតមកដល់បច្ចុប្បន្ន ។
- ❑ ពន្យល់ពីការតស៊ូដើម្បីឯករាជ្យជាតិ ការប្រឆាំងនឹងសហរដ្ឋអាមេរិក ការកសាងលទ្ធិសង្គមនិយម និងកំណែទម្រង់ "ដួយម៉ីយ" ។
- ❑ ដកស្រង់បទពិសោធល្អៗ ពីគំរូនៃកំណែទម្រង់សម្រាប់ការអភិវឌ្ឍជាតិ ។

## 1. ដំណាក់កាលតស៊ូដណ្ដើមឯករាជ្យពីបារាំង

### 1.1. អាណានិគមនិយមបារាំង

#### ក. ការមកដល់នៃអាណានិគមនិយមបារាំង

ក្រុមគ្រិស្តសាសនិកខូតបារាំងបានធ្វើសកម្មភាពនៅក្នុងប្រទេសវៀតណាមតាំងពីពាក់កណ្ដាលសតវត្សទី 17មកម្ល៉េះ ។ ក្រុមនេះបានជួយអធិរាជយ៉ាឡុង (1802-1820) កម្ចាត់ពួកបះបោរតៃសឺន ។ រាជរដ្ឋាភិបាលវៀតណាមជានិច្ចកាលតែងប្រុងប្រយ័ត្នចំពោះការហូរចូលនៃសាសនាគ្រប់រូបភាព ។ នៅពេលនោះការហូរចូលនៃសាសនាកាតូលិកនាំឱ្យមានការប្រឆាំងយ៉ាងខ្លាំងក្លា រហូតដល់ការធ្វើទារុណកម្មទៅលើអ្នកផ្សាយសាសនាគ្រិស្ត ដែលជាលេសមួយនាំឱ្យបារាំងធ្វើអន្តរាគមន៍ចូលក្នុងប្រទេសវៀតណាមដើម្បីការពារជនរងគ្រោះទាំងនោះ ។ នៅឆ្នាំ 1859 បារាំងបានលើកទ័ពចូលប្រទេសវៀតណាម លុះមកដល់ឆ្នាំ 1885 ប្រទេសវៀតណាមទាំងមូលធ្លាក់នៅក្រោមការត្រួតត្រារបស់បារាំង ។

#### ខ. នយោបាយសេដ្ឋកិច្ចរបស់អាណានិគមបារាំងក្រោយសង្គ្រាមលោកលើកទី 1

នៅក្រោយសង្គ្រាម រដ្ឋាភិបាលបារាំងបានបង្កើតគម្រោងដើម្បីទាញយកសេដ្ឋកិច្ចឥណ្ឌូចិន ដោយបញ្ជូនពួកមូលធនបារាំងឱ្យមកដាក់វិនិយោគទុន ដែលមានទឹកប្រាក់ 490 លានប្រង់នៅឆ្នាំ 1888 ដល់ 1918 ហើយទុនវិនិយោគនោះកើនឡើងដល់ 8000 លានប្រង់ក្នុងអំឡុងឆ្នាំ 1919 ដល់ 1929 ទៅលើអាជីវកម្មរ៉ែ ធ្យូងថ្ម និងដំណាំកៅស៊ូ ។

អាណានិគមបារាំងជួយរៀបចំប្រទេសវៀតណាមឱ្យទៅជារដ្ឋទំនើប ដោយបំភ្លឺទីក្រុងដោយភ្លើងអគ្គិសនី បង្កើតផ្លូវរថភ្លើងពីព្រៃនគរទៅហាណូយ ឆ្លងកាត់តាមកំពង់ផែទំនើបៗ ដូចជាព្រៃនគរ និងហៃផុងជាដើម ព្រមទាំងមានបរិក្ខារប្រសើរជាងពីសម័យមុនសង្គ្រាម ។ ប្រទេសវៀតណាមក៏មានផ្លូវក្រាលកៅស៊ូ និងក្រាលថ្មជាច្រើនខ្សែ ព្រមទាំងមានប្រព័ន្ធអប់រំទំនើបដោយបង្កើតសាលាបឋមសិក្សា និងមធ្យមសិក្សាបារាំង-វៀតណាម និងសាលាឧត្តមសិក្សានៅហាណូយទៀតផង ។

ក្រៅពីនេះ ពួកមូលធនបារាំងយកចិត្តទុកដាក់លើសហគ្រាសផលិតម្ហូបអាហារ តម្បាញ សម្ភារៈសំណង់ ម៉ាស៊ីនកិនស្រូវ ទឹក អគ្គិសនី សុរាគារ រោងចក្រធ្វើក្រដាស រោងពុម្ព រោងចក្រអារឈើ រោងចក្រឈើគូស សាប៊ូ កែវ និងបារី ។ល ។

## 1.2. ការប្រកាសឯករាជ្យពីបារាំង

ហូជីមិញ ជាមេដឹកនាំចលនាតស៊ូបក្សកុម្មុយនីស្តឥណ្ឌូចិន ពិសេសបក្សកុម្មុយនីស្តវៀតណាម ប្រឆាំងនឹងពួកអាណានិគមនិយមបារាំង និងជប៉ុនដើម្បីឯករាជ្យជាតិ ។ នៅថ្ងៃទី 2 ខែសីហា ឆ្នាំ 1945 ហូជីមិញ បានប្រកាសឯករាជ្យពីអាណានិគមនិយមបារាំងនៅកណ្ដាលទីលានបាឌិញ(Ba Dinh Square) ក្នុងទីក្រុងហាណូយ ។

នៅខែកញ្ញា ឆ្នាំ 1945 ជប៉ុនចុះចាញ់សង្គ្រាមលោកលើកទី 2 បារាំងវិលមកត្រួតត្រាប្រទេសវៀតណាមបន្តទៀត ។

កងទ័ព និងប្រជាជនវៀតណាមបានធ្វើការប្រយុទ្ធប្រឆាំងនឹងអាណានិគមបារាំងអស់រយៈពេលជាង 8ឆ្នាំ លុះត្រាទទួលជ័យជម្នះទាំងស្រុង ។ សមរភូមិឌៀនបៀនភូ(Dien Bien Phu) ជាសមរភូមិក្ដៅសម្រាប់បារាំង បន្ទាប់ពីវៀតណាមព័ទ្ធបន្ទាយបារាំងអស់រយៈពេល 57ថ្ងៃ ធ្វើឱ្យកងទ័ពបារាំងជាង 1ម៉ឺននាក់ដាច់ស្បៀងអាហារ ។ នៅថ្ងៃទី 7 ខែឧសភា ឆ្នាំ 1954 បារាំងបានដាក់អាវុធសុំចុះចាញ់ដោយប្រគល់ឯករាជ្យពិតប្រាកដឱ្យប្រទេសវៀតណាម ។

# 2. ដំណាក់កាលសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិក

នៅក្នុងប្រវត្តិសាស្ត្រអាស៊ី គេមិនដែលស្គាល់នូវសោកនាដកម្មដូចប្រជាជនវៀតណាម កម្ពុជា ឡាវដែលធ្លាប់ជួបប្រទះនៅក្នុងសង្គ្រាមនាទសវត្សរ៍ឆ្នាំ 60និង 70នោះទេ ។ សង្គ្រាមនៅវៀតណាមជាសង្គ្រាមបង្ហូរឈាមរវាងជនជាតិតែមួយ ក្រោមឥទ្ធិពលនៃសង្គ្រាមត្រជាក់របស់កំពូលមហាអំណាចពិភពលោក ដើម្បីឧត្តមភាពត្រួតត្រាពិភពលោក ។

មុនដំបូង សហរដ្ឋអាមេរិកជួយផ្នែកហិរញ្ញវត្ថុ បន្ទាប់មកបញ្ជូនកងទ័ព 500 ពាន់នាក់ទៅជួយភាគីវៀតណាមខាងត្បូងដើម្បីកម្ទេចពួកកុម្មុយនីស្តវៀតណាមខាងជើង ។ ប៉ុន្តែប្រទេសលោកខាងលិច និងសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិកបានថ្កោលទោសយ៉ាងខ្លាំងចំពោះទង្វើបែបនេះ ។ ពួកគេបានវាយតម្លៃផ្សេងៗគ្នាទៅលើមេរៀនសង្គ្រាមនៅកូរ៉េ និងនៅវៀតណាម ។ បារាំង និងអង់គ្លេសបានផ្តល់ដំបូន្មានដោយមិនបញ្ជូនកងទ័ពរបស់ខ្លួនទៅសមរភូមិវៀតណាមទេ ។ អ្នកដែលបានគាំទ្រសហរដ្ឋអាមេរិកយ៉ាងខ្លាំងគឺអូស្ត្រាលី និងនូវែលសេឡង់ ពួកគេបានបញ្ជូនកងទ័ពរាប់ពាន់នាក់ទៅកាន់សមរភូមិវៀតណាម រីឯថៃ និងហ្វីលីពីនបានបញ្ជូនទៅខ្លះដែរក្នុងនាមជាសម្ព័ន្ធមិត្ត ។ សហភាពសូវៀតនិងចិនប្រជាមានិតបានជួយឧបត្ថម្ភគ្រឿងសព្វាវុធដល់វៀតណាមកុម្មុយនីស្ត ហើយគេប្រឹងប្រែងបញ្ចៀសការចូលប្រយុទ្ធនៅលើសមរភូមិផ្ទាល់ ។ ពួកចិនកុម្មុយនីស្តមិនចង់ឃើញវត្តមានសហរដ្ឋអាមេរិកនៅជាប់នឹងដែនភាគខាងត្បូងរបស់ខ្លួនទេ ។ ចិនធ្លាប់ចូលរួមប្រយុទ្ធនៅលើសមរភូមិកូរ៉េខាងជើង គឺធ្វើយ៉ាងណាដើម្បីឱ្យប្រទេសមូលធននិយម សហរដ្ឋអាមេរិកទៅឱ្យឆ្ងាយពីព្រំដែនតំបន់ម៉ាន់ជូរីភាគខាងត្បូង ។

ក្នុងសង្គ្រាមវៀតណាម ពួកកុម្មុយនីស្តមានកម្លាំងច្រើន និងប្រកបទៅដោយបទពិសោធខ្ពស់ក្នុងការធ្វើសឹកសង្គ្រាម ។ បើសិនជាគ្មានការជ្រៀតជ្រែកពីសំណាក់សហរដ្ឋអាមេរិកនោះទេ ពួកកុម្មុយនីស្តប្រាកដជាយកជ័យជម្នះបានជាយូរណាស់មកហើយ ។

នៅក្នុងសង្គ្រាមវៀតណាម សហរដ្ឋអាមេរិកបានចំណាយអស់ធនធានយ៉ាងច្រើន ជាពិសេសបាត់បង់ជីវិតកងទ័ពចំនួន 57 ពាន់នាក់នៅលើសមរភូមិ និង 300 ពាន់នាក់ពិការដោយសារសង្គ្រាមនេះ ។

ការបាត់បង់ជីវិតកងទ័ពសហរដ្ឋអាមេរិកមិនច្រើនប៉ុន្មានទេ បើប្រៀបធៀបទៅនឹងការបាត់បង់ជីវិតរបស់ប្រជាជនវៀតណាម ។ សហរដ្ឋអាមេរិកមានបំណងរារាំងបញ្ឈប់ការជ្រៀតជ្រែករបស់វៀតណាមកុម្មុយនីស្តមកតំបន់ភូមិភាគកណ្តាល និងភូមិភាគខាងត្បូងវៀតណាមតែប៉ុណ្ណោះ ។ ចំណែកវៀតណាមសង្ឃឹមថាការចំណាយជីវិតមនុស្ស និងសម្ភារៈដ៏ច្រើនលើសលប់នោះដើម្បីបង្រួបបង្រួមវៀតណាមទាំងពីរឱ្យនៅក្រោមបក្សកុម្មុយនីស្តតែមួយ ។

នៅឆ្នាំ 1965 សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មវៀតណាមខាងជើងតាមរយៈការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង ។ ប្រតិបត្តិការ "សម្រែកផ្គរលាន់" មានទិសដៅចង់កម្ទេចភូមិករ ទីក្រុងនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមឱ្យទៅជាផេះ ។

ហូ ជីមិញបានវាយតម្លៃសភាពការណ៍នេះថា "សហរដ្ឋអាមេរិកអាចបន្តការប្រយុទ្ធ 10ឬ 20ឆ្នាំបាន ប៉ុន្តែមិនអាចបន្តសង្គ្រាមបានរហូតនោះឡើយ"។ ពួកកុម្មុយនីស្តមិនអាចយកជ័យជម្នះលើសហរដ្ឋអាមេរិកបានទេ ។ ប៉ុន្តែពួកគេបានដឹងយ៉ាងច្បាស់ថា បើសិនជាពួកគេអាចធ្វើឱ្យសហរដ្ឋអាមេរិកបាត់បង់កម្លាំងច្រើននៅក្នុងសង្គ្រាម នោះសហរដ្ឋអាមេរិកមិនអាចយកជ័យជម្នះបានឡើយ ហើយទីបំផុតសហរដ្ឋអាមេរិកនឹងទុកឱ្យសម្ព័ន្ធមិត្តរបស់ខ្លួនវៀតណាមខាងត្បូងនៅឯកោ ។ នៅខែកញ្ញា ឆ្នាំ 1969 ហូ ជីមិញបានទទួលមរណភាព ប៉ុន្តែសភាពការណ៍នៅក្នុងប្រទេសគ្មានអ្វីប្រែប្រួលឡើយ សមមិត្តរួមអាវុធរបស់ប្រធាន ហូ ជីមិញ បានបន្តវេនបដិវត្តន៍ ។

នៅក្នុងដំណាក់កាលនៃសង្គ្រាម មានប្រជាជនប្រហែល 1 លាននាក់បានបាត់បង់ជីវិត ។ កងទ័ពវៀតណាមខាងត្បូងបានបាត់បង់ជីវិតចំនួន 250 ពាន់នាក់ និងរបួសចំនួន 600 ពាន់នាក់ សរុបទាំងអស់វៀតណាមបានបាត់បង់ជីវិត និងរបួសពិការចំនួន 4 លាននាក់ ។

នៅខែមករា ឆ្នាំ 1973 កិច្ចសន្យាបញ្ចប់សង្គ្រាមត្រូវបានចុះហត្ថលេខា ។ សហរដ្ឋអាមេរិកត្រូវដកកងទ័ពចេញពីប្រទេសវៀតណាមក្នុងអំឡុងពេល 60 ថ្ងៃ រីឯការចរចាដើម្បីសន្តិភាពជាតួនាទីរបស់វៀតណាមទាំងសងខាង ។ សហរដ្ឋអាមេរិកបានដកកងទ័ពចេញហើយក៏ដោយ ប៉ុន្តែគេបានបន្សល់ទុកគ្រឿងសព្វាវុធដ៏ច្រើនសន្ធឹកសន្ធាប់ឱ្យវៀតណាមខាងត្បូង សង្គ្រាមនៅតែបន្តពួកវៀតមិញ និងវៀតកុងបានវាយលុកយ៉ាងខ្លាំងក្លា និងកាត់ផ្តាច់កងទ័ពវៀតណាមខាងត្បូងជាកង់ៗ ។

ថ្ងៃទី 30 ខែមេសា ឆ្នាំ 1975 កងទ័ពវៀតណាមខាងជើង និងវៀតកុងវាយយកបានទីក្រុងព្រៃនគរ ស្របពេលដែលកងទ័ពសហរដ្ឋអាមេរិកប្រញាប់ប្រញាល់រំដោះអ្នកឯកទេស អ្នកការទូតចេញពីអគារទូតចុងក្រោយបង្អស់ ។ ឧទ្ធម្ភាគចក្រចំនួន 70 គ្រឿងបានដឹកអ្នកដំណើរចំនួន 1 ពាន់នាក់ទៅកាន់កប៉ាល់ចម្បាំងរបស់សហរដ្ឋអាមេរិក ។ ក្រោយការបរាជ័យក្នុងសង្គ្រាម មេបញ្ជាការកងទ័ពនិងបុគ្គលិក រដ្ឋការក្រុងព្រៃនគររាប់ពាន់នាក់ត្រូវបានគេបញ្ជូនទៅមន្ទីរឃុំឃាំងដើម្បីអប់រំ ។

ចាប់ពីឆ្នាំ 1975 វៀតណាមរស់នៅដោយការកាត់ផ្តាច់ពីទំនាក់ទំនងនៃពិភពខាងក្រៅ មានតែសហភាពសូវៀតទេដែលផ្តល់ជំនួយដល់វៀតណាម ហើយជំនួយនេះត្រូវកាត់បន្ថយចាប់ពីឆ្នាំ 1985 ។

## ៣. ការកសាងលទ្ធិសង្គមនិយមនៅក្នុងកំណែទម្រង់ "ដូយម៉ើយ"

ខែធ្នូឆ្នាំ 1996 សាធារណរដ្ឋសង្គមនិយមវៀតណាម បានប្រារព្ធបុណ្យខួប 10 ឆ្នាំនៃកំណែទម្រង់របស់ខ្លួន ។ អស់រយៈពេល 10 ឆ្នាំគត់ ដែលបក្សកុម្មុយនីស្តវៀតណាមបានប្រារព្ធមហាសន្និបាតលើកទី 6 នៅក្នុងនោះបានលេចឡើងនូវការរិះគន់ និងការទទួលស្គាល់កំហុស ក្នុងការដឹកនាំប្រទេសជាតិ

ទៅកាន់ស្ថានភាពគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ហើយគេបានអនុម័តនូវយុទ្ធសាស្ត្រថ្មីដើម្បីអភិវឌ្ឍសង្គមវៀតណាម ដោយបានទទួលឈ្មោះថា "ដូយម៉ឺយ"។ "ដូយម៉ឺយ" កំណត់កម្មវិធីនយោបាយថ្មីគឺកំណែទម្រង់រ៉ាឌីកាល់ទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងស្រុង និងបើកទ្វារផ្តល់លទ្ធភាពដល់សហគ្រិនធ្វើសកម្មភាពនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ គេបានលើកឡើងកម្មវិធី "ទីផ្សារសេដ្ឋកិច្ច" ដោយនៅក្នុងនោះគេនៅថែរក្សាយន្តការនយោបាយទាំងស្រុងដោយឈរលើគោលការណ៍នៃបក្សកុម្មុយនិស្តជាបក្សដឹកនាំ។ ដើម្បីថែរក្សាស្ថេរភាពនយោបាយនៅក្នុងសង្គម គេកសាងទំនាក់ទំនងល្អលើនយោបាយការបរទេសក្នុងឆាកអន្តរជាតិ និងតំបន់ គឺដើម្បីរុញប្រទេសចេញឱ្យផុតពីស្ថានភាពហ៊ុមព័ទ្ធការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងចូលរួមទៅក្នុងសមាហរណកម្មនយោបាយ និងសេដ្ឋកិច្ចលើពិភពលោក។

ដូច្នេះ កម្មវិធីនយោបាយអភិវឌ្ឍន៍ជាតិត្រូវបានកំណត់នៅក្នុង "ដូយម៉ឺយ" នៅក្នុងដំណាក់កាលមួយយ៉ាងខ្លី។ ការកំណត់កម្មវិធីនយោបាយនៅក្នុង "ដូយម៉ឺយ" ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់វៀតណាម ដើម្បីធ្វើទំនើបកម្មសង្គម។

នៅក្នុងឆ្នាំ 1987 ផលិតផលស្រូវទទួលបាន 17.5 លានតោន ហើយបានកើនរហូតដល់ 27.5 លានតោននៅក្នុងឆ្នាំ 1995។ កំណើនផលិតផលកសិកម្ម បានធ្វើឱ្យមានកំណើនប្រជាជនពី 2.2% រហូតដល់ 5.8%។ នៅដើមទសវត្សរ៍ឆ្នាំ 90 វៀតណាមបានក្លាយជាប្រទេសទី 5 ខាងផលិតស្រូវនៅអាស៊ី ហើយទទួលចំណាត់ថ្នាក់ទី 3 ក្នុងចំណោមប្រទេសនាំអង្ករទៅកាន់ទីផ្សារពិភពលោក។

ចំពោះឧស្សាហកម្មមានការរីកចម្រើនយ៉ាងខ្លាំងនៅលើសហគ្រាសឯកជន ប៉ុន្តែគេខិតខំថែរក្សាសហគ្រាសរដ្ឋ។ ដំណាក់កាលកំណែទម្រង់ត្រឹមតែរយៈពេលបីឆ្នាំ(1988-1990) សហគ្រាសរដ្ឋរបស់វៀតណាមបានរៀបចំកែប្រែរចនាសម្ព័ន្ធដឹកនាំសម្របទៅនិងប្រព័ន្ធផ្សារសេរី និងឈានទៅរកការប្រកួតប្រជែងដូចសហគ្រាសឯកជនដែរ ដោយបង្កើនទាំងបរិមាណ លើកកម្ពស់ទាំងគុណភាព។ ចាប់ពីខែធ្នូ ឆ្នាំ 1987 មក វៀតណាមអនុម័តច្បាប់វិនិយោគ ផ្តល់ការជឿជាក់ និងទំនុកចិត្ត ដើម្បីទាក់ទាញអ្នកវិនិយោគទុនបរទេស។ ក្រោយពីមានច្បាប់នេះមក ទំហំទឹកប្រាក់វិនិយោគបានកើនឡើង 50% ជារៀងរាល់ឆ្នាំ នៅឆ្នាំ 1996 ទំហំទឹកប្រាក់វិនិយោគកើនដល់ 22 ពាន់លានដុល្លារសហរដ្ឋអាមេរិក។

នៅក្នុងឆ្នាំ 1996 គេបានប្រារព្ធមហាសន្និបាតលើកទី 8 នៃបក្សកុម្មុយនីស្តវៀតណាម។ នៅក្នុងនោះគេបានកំណត់នូវការជំរុញថែមទៀតទៅលើទំនើបកម្មសេដ្ឋកិច្ច និងមានការពេញចិត្តចំពោះលទ្ធផលប្រាំឆ្នាំកន្លងមក។ មហាសន្និបាតបានរៀបចំកម្មវិធីជាយុទ្ធសាស្ត្រ ជំរុញសេដ្ឋកិច្ចវៀតណាមឱ្យមានកំណើនពី 10-12 % ក្នុងមួយឆ្នាំ ដើម្បីទទួលបានជាលទ្ធផលនៅឆ្នាំ 2000 និងមានកំណើន

សេដ្ឋកិច្ចពីរដងនៅឆ្នាំ 2020 ។ វៀតណាមនឹងអាចក្លាយជាប្រទេសឧស្សាហកម្មមួយដោយមានមូលដ្ឋានសម្ភារៈបច្ចេកវិទ្យាទំនើប ហើយកម្រិតជីវភាពប្រជាជនត្រូវកើនឡើងពី 8-10ដងបើប្រៀបធៀបនឹងឆ្នាំ 1990 ។

នៅក្នុងខែកក្កដា ឆ្នាំ 1995 វៀតណាមបានក្លាយជាសមាជិកពេញសិទ្ធិរបស់សមាគមអាស៊ានដែលជាក្រុមប្រទេសតតិយលោកមួយមានថាមពលនយោបាយយ៉ាងខ្លាំងក្លា ។ ដូច្នេះការចូលជាសមាជិកអាស៊ានផ្តល់ឱ្យរដ្ឋបាលក្រុងហាណូយជាស្វ័យប្រវត្តិនូវជំហរនយោបាយដ៏រឹងមាំនៅក្នុង ទិសដៅពង្រឹងសមាហរណកម្មវៀតណាមឱ្យកាន់តែស៊ីជម្រៅថែមទៀតទាំងក្នុងតំបន់ ទាំងក្រៅតំបន់ និងនៅលើពិភពលោក ។

នៅខែកុម្ភៈ ឆ្នាំ 1996 សភាសហគមន៍អឺរ៉ុបបានផ្តល់សច្ចាប័នទៅលើ "កិច្ចព្រមព្រៀងរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសហគមន៍អឺរ៉ុប" ។ កិច្ចព្រមព្រៀងនេះផ្តោតទៅលើកិច្ចសហប្រតិបត្តិការនៅលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយជំរុញសកម្មភាពវិនិយោគពីប្រទេសសមាជិក EU និងបើកចំហទីផ្សារឱ្យគ្នាទៅវិញទៅមក ។

អាស្រ័យទៅនឹងការបោះពុម្ពផ្សាយជាអចិន្ត្រៃយ៍នូវការវាយតម្លៃរបស់អ្នកយកការណ៍អន្តរជាតិជាច្រើនបានបង្ហាញពីការយកចិត្តទុកដាក់លើសេដ្ឋកិច្ច និងការធ្វើវិនិយោគនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម មានកម្រិតខ្ពស់ជាងបណ្តាអតីតប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើត និងអតីតសហភាពសូវៀត ។

សមិទ្ធផលទាំងអស់នេះកើតចេញពីនយោបាយ "ដូយម៉ឺយ" ដែលមិនត្រឹមតែទទួលការគាំទ្រយ៉ាងខ្លាំងពីសំណាក់សមាជិកគណបក្សកុម្មុយនីស្តប៉ុណ្ណោះទេ តែថែមទាំងទទួលបានការអបអរសាទរពីប្រជាជនវៀតណាមជាទូទៅផងដែរ ។

## ? សំណួរ

1. ហេតុដូចម្តេចបានជាកងទ័ពវៀតណាមខាងជើងទទួលបានជ័យជម្នះលើកងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក ?
2. ហេតុអ្វីបានជាក្រោយសង្គ្រាមឆ្នាំ 1975 សេដ្ឋកិច្ចវៀតណាមត្រូវហ៊ុមព័ទ្ធដោយលោកខាងលិច ?
3. តើ "ដូយម៉ឺយ" មានគោលការណ៍ជាមូលដ្ឋានយ៉ាងណាខ្លះ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម ?

មេរៀនទី

# 3 ប្រទេសថៃ

**ចប់មេរៀននេះ សិស្សអាច**

- ❑ យល់ដឹងពីស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គមថៃ ។
- ❑ពន្យល់ពីប្រព័ន្ធដឹកនាំរដ្ឋ និងស្ថាប័នព្រះមហាក្សត្រក្រោយសង្គ្រាមលោកលើកទី 2 ។
- ❑ រក្សាសន្តិភាពទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ។

## 1. ការពង្រឹងរបបរាជានិយម

### 1.1. ពីប្រព័ន្ធដឹកនាំរាជានិយមផ្ដាច់ការទៅជារបបយោធានិយម

ទំនើបកម្មនៅក្នុងប្រទេសថៃបានចាប់ផ្ដើមតាំងពីពាក់កណ្ដាលសតវត្សទី 19 គឺផ្ដើមពីប្រព័ន្ធដឹកនាំនៃរបបរាជនិយមផ្ដាច់ការរហូតមករាជនិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ការផ្លាស់ប្ដូរនយោបាយបានធ្វើឱ្យឧត្ដមភាពស្ថាបន័ព្រះមហាក្សត្រធ្លាក់ចុះទាំងអំណាច និងតួនាទី ។ ប៉ុន្តែសព្វថ្ងៃ ព្រះមហាក្សត្រមានឥទ្ធិពលធំធេង មានអត្ថន័យជាប្រវត្តិសាស្ត្រ និងមានតួនាទីសម្របសម្រួលនៅក្នុងព្រះរាជអន្តរាគមន៍ដើម្បីឱ្យមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចក្នុងសង្គមថៃ ។

រាជានិយមថៃជាស្ថាប័នមួយមានឥរិយាបថជានិមិត្តរូបនៅក្នុងសាសនា ដែលមានប្រភពពីការសំយោគរវាងប្រព័ន្ធដឹកនាំតាមបែបជាប្រពៃណីថៃ រួមជាមួយនិងប្រព័ន្ធដឹកនាំបែបប្រពៃណីមនខ្មែរ និង តាមទស្សនាទាននៃព្រហ្មញ្ញសាសនាជាពិសេស "លទ្ធិទេវរាជ" ដែលជឿថាព្រះមហាក្សត្រកើតចេញពីអាទិទេព ។

ដូច្នេះទំនើបកម្មត្រូវការជាចាំបាច់នូវកំណែទម្រង់ ព្រោះភាពទុំជោរនៃប្រព័ន្ធសេដ្ឋកិច្ចបែបចាស់ទាមទារឱ្យមានប្រព័ន្ធថ្មីមកជំនួស ។ ជាក់ស្តែងនៅពេលសេដ្ឋកិច្ចមហាអំណាចអាណានិគមនិយមចូលមកដល់តំបន់ឥណ្ឌូចិន តែងតែប៉ះទង្គិចនិងប្រព័ន្ធសេដ្ឋកិច្ចរដ្ឋសៀម ។ ការធ្វើទំនើបកម្មទៅលើប្រព័ន្ធដឹកនាំរដ្ឋជាប់ទាក់ទងយ៉ាងខ្លាំងទៅលើផលប្រយោជន៍ប្រទេសមហាអំណាចដែលមានសកម្មភាពតាំងពីពាក់កណ្ដាលសតវត្សទី 19មកម្ល៉េះ ។

នៅក្នុងប្រព័ន្ធដឹកនាំរដ្ឋតាមបែបរាជានិយមផ្តាច់ការ សៀមត្រូវការពេលវេលាចាំបាច់ដើម្បីធ្វើកំណែទម្រង់រចនាសម្ព័ន្ធសង្គមថ្នាក់លើ ជាពិសេសទៅលើអភ័យឯកសិទ្ធិព្រះមហាក្សត្រដោយផ្ទាល់ និងទៅលើកម្រិតវប្បធម៌ ឆន្ទៈនយោបាយ និងទស្សនៈ។ នៅក្នុងសតវត្សទី 19 និងដើមសតវត្សទី 20 តួអង្គតំណាងឱ្យទំនើបកម្មនយោបាយ និងសង្គមនៅក្នុងប្រទេសគឺ ព្រះមហាក្សត្រ មង្គុត (1851-1868) និងជូឡាឡុងកន(1868-1910) ។ ស្តេចជូឡាឡុងកនចេះភាសាបរទេស និងធ្លាប់ធ្វើទស្សនកិច្ចជាច្រើនប្រទេស ជាពិសេសជក់ព្រះទ័យនឹងទ្វីបអឺរ៉ុប ។ ព្រះអង្គមានភាពក្លាហានក្នុងការទទួលយកសមិទ្ធផលនៃរចនាសម្ព័ន្ធដឹកនាំបែបលោកខាងលិច តាមការអប់រំបច្ចេកវិទ្យា ការអនុវត្តផ្ទាល់នៅក្នុងសង្គមសៀម និងថែមទាំងអញ្ជើញអ្នកឯកទេសបរទេសឱ្យមកធ្វើការក្នុងប្រទេសទៀតផង ។ សកម្មភាពរបស់ស្តេចជូឡាឡុងកន មានឥទ្ធិពលយ៉ាងធំធេងទៅលើទំនើបកម្មសង្គមសៀម ជាពិសេសទៅលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល តុលាការ និងហិរញ្ញវត្ថុ។ គេបានបង្កើតប្រព័ន្ធអប់រំសាធារណៈ លុបបំបាត់កម្មសិទ្ធិសក្តិភូមិ ។ ប្រព័ន្ធដឹកនាំរដ្ឋបាលដែនដីត្រូវបានគេធ្វើកំណែទម្រង់ជាច្រើនដំណាក់កាលក្នុងទិសដៅបញ្ចប់ប្រព័ន្ធដឹកនាំស្វ័យភាព លុបបំបាត់ស្ថានភាពខុសគ្នាតាមតំបន់ លុបប្រព័ន្ធ "ចិញ្ចឹម" និងអំណាចចំណុះនៅតាមជនបទដោយដាក់ជំនួសនូវអំណាចកណ្តាលវិញ ។ មន្ត្រីអាជ្ញាធរមូលដ្ឋានត្រូវទទួលការតែងតាំង និងទទួលប្រាក់បៀវត្សពីអំណាចកណ្តាល ។ កំណែទម្រង់បែបនេះផ្តល់នូវសោកនាដកម្មនាដំណាក់កាលចុងសតវត្សទី 19 និងដើមសតវត្សទី 20 ដោយសារការលុបបំបាត់អំណាចសក្តិភូមិពីមុនមកត្រូវទទួលបរាជ័យ ។

កំណែទម្រង់ប្រព័ន្ធដឹកនាំរដ្ឋទាមទារឱ្យមានធនធានមនុស្ស និងមន្ត្រីរាជការប្រកបដោយគុណសម្បត្តិ និងការអប់រំខ្ពស់ ។ គេបញ្ជូនយុវជន ក្នុងនោះមានបុត្រស្តេច បុត្រនៃញាតិវង្សានុវង្ស និងកូនមន្ត្រីជាន់ខ្ពស់ទៅបន្តការសិក្សានៅទ្វីបអឺរ៉ុប ។ ក្រោយមក ចំនួននិស្សិតចេញទៅសិក្សានៅក្រៅប្រទេសកើនឡើងភាគច្រើនជាកូនពាណិជ្ជករ និងកូននាយទាហាន ។

នៅឆ្នាំ 1886 ក្រុមយុវបញ្ញវន្តសៀមទីមួយបានត្រឡប់មកពីទ្វីបអឺរ៉ុប ពួកគេបានធ្វើញត្តិស្នើសុំព្រះមហាក្សត្របង្កើតសភាជាតិ ក្រុមប្រឹក្សារដ្ឋមន្ត្រី អនុម័តច្បាប់ការពារសិទ្ធិមនុស្ស សេរីភាពក្នុងការបញ្ចេញមតិ និងសមភាពប្រជាពលរដ្ឋនៅចំពោះមុខច្បាប់ ។ ព្រះមហាក្សត្រពុំអាចធ្វើអ្វីបាន ដូច្នេះការទាមទារនេះគ្មានលទ្ធផលឡើយ ។ នៅឆ្នាំ 1912 បន្ទាប់ពីស្តេច ជូឡាឡុងកនសោយទិវង្គត បានលេចឡើងគម្រោងធ្វើរដ្ឋប្រហារដោយលួចលាក់នៅក្នុងទិសដៅបង្កើតប្រព័ន្ធដឹកនាំរបបរាជនិយមអាស្រ័យរដ្ឋធម្មនុញ្ញ ឬលុបបំបាត់អំណាចព្រះមហាក្សត្រទាំងស្រុងតែម្តង ។ នៅឆ្នាំ 1932 មានមន្ត្រីគាំទ្រគោលការណ៍រដ្ឋប្រហារជាច្រើននាក់ ។ ក្រោយចលនាបដិវត្តន៍ ប្រព័ន្ធដឹកនាំរដ្ឋមានការផ្លាស់

ប្តូរទៅជារបបរាជនិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ នៅឆ្នាំ 1934 ស្តេចប្រាជាតទីប៉ុកបានយាងទៅប្រទេសអង់គ្លេសដើម្បីព្យាបាលជំងឺ ។ ទ្រង់បាត់បង់ក្តីសង្ឃឹមក្នុងការស្តាររាជបល្ល័ង្កឡើងវិញ ព្រះអង្គបានចាកចេញពីរាជបល្ល័ង្កក្នុងឆ្នាំ 1935 ។ ក្រុមប្រឹក្សាសម្ងាត់នៃរាជបល្ល័ង្កបានជ្រើសរើសទ្រង់អាណាន់ដាម៉ាឃីដុន ដែលមានព្រះជន្មនៅក្មេងខ្ចីនៅឡើយដែលត្រូវជាក្មួយរបស់ព្រះអង្គប្រាជាទីប៉ុក ឱ្យឡើងសោយរាជ្យ ។

ក្រោយព្រឹត្តិការណ៍បដិវត្តន៍ឆ្នាំ 1932 រហូតដល់ដើមទសវត្សរ៍ឆ្នាំ 50 ឧត្តមភាពនៃស្ថាប័នព្រះមហាក្សត្រនិងឥទ្ធិពលរបស់ស្តេចស្ថិតក្នុងស្ថានភាពអាក្រក់បំផុត ។ នៅចុងសម័យសង្គ្រាមលោកលើកទី 2 ទើបអំណាចព្រះមហាក្សត្របានដើរតួនាទីសំខាន់ឡើងវិញស្របពេលនឹងប្រទេសសម្ព័ន្ធមិត្តទទួលជ័យជម្នះលើកងទ័ពជប៉ុន ។ ពេលនោះសម្ព័ន្ធភាពជប៉ុន-ថៃ ពុំបានទទួលសច្ចាប័នពីសំណាក់ក្រុមប្រឹក្សារាជានុសិទ្ធិនៃព្រះមហាក្សត្រព្រឹទ្ធីបាំណូមីអុងទេ ។ ដូច្នេះ កិច្ចព្រមព្រៀងដែលមិនស្របនឹងច្បាប់រដ្ឋធម្មនុញ្ញគ្មានសុពលភាពអនុវត្តឡើយ ។ នៅក្នុងឱកាសនេះហើយថៃអាចរក្សាមុខមាត់នៅលើឆាកអន្តរជាតិ អាចចូលជាសមាជិកនៃក្រុមប្រទេសស្ថាបនិករបស់អង្គការសហប្រជាជាតិ ។

## 1.2. ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងស្ថាប័នព្រះមហាក្សត្រឡើងវិញ

នៅក្រោយសង្គ្រាមលោកលើកទី 2 រហូតដល់ឆ្នាំ 1973 យោធាថៃជាកម្លាំងដ៏សំខាន់មួយសម្រាប់ជំរុញដំណើរវិវត្តន៍នយោបាយសង្គម ។ ក្រោយមក គេមានប្រព័ន្ធសភានិយម និងការពង្រឹងគណបក្សនយោបាយឱ្យកាន់តែប្រសើរ ។ កម្លាំងកងទ័ពជាតិបានប្រកាសខ្លួនអព្យាក្រិតនៅឆ្ងាយពីឆាកនយោបាយ ។ ប្រព័ន្ធសភានិយមថៃមានលក្ខណៈទន់ខ្សោយដោយសារឥទ្ធិពលនៃនយោបាយយោធានិងឥទ្ធិពលសេដ្ឋកិច្ចអាមេរិក ដែលមានទិសដៅពង្រឹងកម្លាំងយោធាថៃផង និងក្រុមអ្នកនយោបាយថៃដែលមានទំនោរទៅរកលោកខាងលិចផង ។

ក្រោយសង្គ្រាមលោកលើកទី 2 ប្រទេសថៃបានជួបវិបត្តិរដ្ឋប្រហារជាច្រើនលើក (រដ្ឋប្រហារ-សភា-រដ្ឋធម្មនុញ្ញ-រដ្ឋប្រហារយោធា) ។ ប្រព័ន្ធសភាបានកែប្រែតាំងពីការតែងតាំងទាំងស្រុង ទៅជាការបង្កើតប្រព័ន្ធបោះឆ្នោតនៅក្នុងសភាថ្នាក់ក្រោម និងតែងតាំងសភាថ្នាក់លើ ។ ដូច្នេះស្ថេរភាព និងការអភិវឌ្ឍប្រទេសជាតិកើតមាននៅពេលក្រុមមន្ត្រីនយោបាយ យោធា និងស៊ីវិលបានផ្លាស់ប្តូរគ្នាគ្រប់គ្រងរដ្ឋ ។

ការដឹកនាំរបស់ពួកផ្តាច់ការយោធានិយមបានជំរុញវិស័យសេដ្ឋកិច្ចនៃរបបមូលធននិយមរីកចម្រើនយ៉ាងខ្លាំង ព្រមទាំងបង្កើតរចនាសម្ព័ន្ធមូលដ្ឋានសេដ្ឋកិច្ចទៅថ្ងៃអនាគត។ គេបានពង្រឹងតួនាទីយោធាឱ្យក្លាយជាអ្នករៀបចំនយោបាយសេដ្ឋកិច្ច និងសង្គមដោយជំរុញសហគ្រាសរដ្ឋឱ្យធ្វើសកម្មភាពនៅក្នុងវិស័យសេដ្ឋកិច្ច។ ក្រោយមក គេបានរៀបចំគម្រោងអភិវឌ្ឍប្រាំឆ្នាំតាមរយៈកំណែទម្រង់វិស័យសិក្សាធិការ វិស័យសុខាភិបាល និងស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍។ ប៉ុន្តែអំពើពុករលួយ និងសកម្មភាពទុច្ចរិតរបស់នាយទុន ធ្វើឱ្យពួកពាណិជ្ជករ អាណិកជន និងមន្ត្រីថៃធំៗក្លាយទៅជាអ្នកមានស្តុកស្តម្ភ។

## 2. ដំណើរវិវត្តនន៍យោបាយ សេដ្ឋកិច្ច និងសង្គម

ការផ្លាស់ប្តូររដ្ឋាភិបាល ដោយរដ្ឋប្រហារ នៃរបបផ្តាច់ការនៅក្នុងក្បាលម៉ាស៊ីនដឹកនាំ បាននាំប្រទេសទៅរកស្ថានភាពគ្មានច្បាប់ទម្លាប់។ នៅក្នុងការស្តារស្ថានភាពសង្គម មេដឹកនាំយោធាបានធ្វើសេចក្តីស្នើសុំព្រះរាជអន្តរាគមន៍ពីស្ថាប័នព្រះមហាក្សត្រដើម្បីធានាប្រក្រតីភាពស្ថាប័ន និងសណ្តាប់ធ្នាប់សង្គម។ ប៉ុន្តែមិនបានន័យថាជាការពង្រឹកអានុភាពរបស់ព្រះមហាក្សត្រទាំងស្រុងនោះឡើយ។

ស្តេចរាមាទី 9 (ភូមិពលអាឌុលយ៉ាតេជ) បានឡើងសោយរាជ្យបន្ទាប់ពីព្រឹត្តិការណ៍សោកនាដកម្មរបស់ព្រះរៀមព្រះអង្គព្រះនាម អាណាន់ដា ម៉ាឃីដុន។ យុវរាជអាឌុលយ៉ាតេជត្រូវគេបានរៀបចំរាជាភិសេកនៅក្នុងឆ្នាំ 1950។ បន្ទាប់ពីពេលនោះមកព្រះអង្គចាប់ផ្តើមធ្វើនយោបាយតាមរបៀបថ្មី។ ព្រះអង្គបានធ្វើដំណើរទៅគ្រប់ទីកន្លែងទូទាំងប្រទេស និងផ្តល់ឱកាសឱ្យកសិករចូលគាល់ព្រះអង្គដោយផ្ទាល់ជាមួយនឹងការលាតត្រដាងកង្វល់ផ្ទាល់ខ្លួន។ មន្ត្រីរាជការ ក្រុមគ្រូពេទ្យ និងអ្នកឯកទេសកសិកម្មជាដើម បានធ្វើដំណើរអមព្រះរាជទស្សនកិច្ចតាមជនបទក្នុងទិសដៅផ្តល់ការថែទាំសុខុមាលភាពដល់ប្រជាកសិករ អភិវឌ្ឍន៍ប្រព័ន្ធអប់រំនៅតាមមូលដ្ឋាន / បង្ហាត់បង្រៀនបច្ចេកវិទ្យាកសិកម្មថ្មី ជម្រើសពូជសត្វពាហនៈ ធ្វើផ្លូវ និងប្រព័ន្ធស្រោចស្រព។ល។ ដូច្នេះកម្មវិធីដ៏សំខាន់របស់ព្រះមហាក្សត្រគឺ "មិនឱ្យត្រីទៅអ្នកកំពុងឃ្លានទេ ប៉ុន្តែឱ្យសន្ទូច"។ កម្មវិធីថ្មីនេះ មិនគ្រាន់តែធ្វើឱ្យប្រជាជនភូមិភាគឦសានប្រទេសចេះបច្ចេកទេសទំនើបក្នុងវិស័យកសិកម្មប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យពួកគេបោះបង់ដំណាំកញ្ឆា និងអាភៀនទៀតផង។ ម្ចាស់ក្សត្រី ស៊ីរីគីត មហេសីព្រះអង្គក៏មានកម្មវិធី

ផ្ទាល់ជាច្រើនដែរក្នុងទិសដៅពង្រីកវិស័យសិប្បកម្មនៅតាមផ្ទះ ដែលអាចឱ្យកសិករទទួលបានប្រាក់ចំណូលបន្ថែម និងអាចថែរក្សាវប្បធម៌ជាតិទៀតផង ។ ជាការពិតកម្មវិធីទាំងអស់នេះពុំអាចដោះស្រាយបញ្ហាទាំងអស់បានទេ ប៉ុន្តែវាបានធ្វើឱ្យព្រះមហាក្សត្រកាន់តែមានប្រជាប្រិយភាព និងការគោរពពីប្រជាជន ជាពិសេសក្នុងចំណោមកសិករទោះបីប្រព័ន្ធទីផ្សារផ្តល់ឱ្យគេបានតិចតួចបំផុតក៏ដោយ ។

សកម្មភាពថ្មីនេះធ្វើឱ្យស្តេច ភូមិពលអាឌុលយ៉ាតេជ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសភាពការណ៍នយោបាយឆ្នាំ 1973 ហើយឥទ្ធិពលព្រះអង្គបានគ្របដណ្តប់ទៅលើគណបក្សនយោបាយ ក្នុងពេលដែលរដ្ឋាភិបាលបង្ក្រាបទៅលើនិស្សិតបះបោរយ៉ាងព្រៃផ្សៃនៅកណ្តាលទីក្រុងបាងកក ។ ចាប់ពីពេលនោះមក កិត្យានុភាពរបស់ព្រះមហាក្សត្រធំធេងណាស់ទៅលើគម្រោងធ្វើរដ្ឋប្រហារ ។

ក្នុងពេលជាមួយគ្នានេះដែរ ក្រុមញាតិវង្សានុវង្សរបស់ព្រះមហាក្សត្របានក្លាយជាម្ចាស់កម្មសិទ្ធិលើប្រាក់ជាច្រើនក្នុងធនាគារ និងម្ចាស់ក្រុមហ៊ុនធំ (ឧទាហរណ៍ "Siam Cement ") ។ល ។ ការវិវត្តទាំងអស់នេះជាការបញ្ជាក់ពីស្ថាប័នព្រះមហាក្សត្រទៅលើប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ហើយគេអាចថែរក្សាវប្បធម៌ប្រពៃណីទំនៀមទំលាប់របស់គេបានយ៉ាងត្រឹមត្រូវទៀតផង ។ ស្ថាប័នព្រះមហាក្សត្រថៃបានក្លាយជាស្ថាប័នទំនើបមួយនៅក្នុងសង្គម និងត្រូវបានគេតម្កល់ខ្ពស់ជាទីសក្ការៈ ។

## 3. សន្និដ្ឋាន

បម្រែបម្រួលស្ថានភាពសង្គមថៃ ជំរុញឱ្យមានការរីកចម្រើនលោតផ្លោះនៅក្នុងទំនាក់ទំនងនយោបាយសង្គមស្របតាមប្រព័ន្ធសភានិយម ។ សភាពការណ៍បែបនេះរំលឹកដល់ព្រឹត្តិការណ៍ឆ្នាំ 1932 នៅពេលប្រព័ន្ធដឹកនាំចាស់ហួសសម័យ (Archaic System) បានរារាំងដល់ដំណើរការវិវត្តសង្គមត្រូវជំនួសដោយកម្លាំងថ្មីនៅក្នុងសង្គមថៃ ។

ភាពឃោរឃៅបានបាត់បង់ពីសង្គមថៃយ៉ាងឆាប់រហ័សហើយលេចឡើងនូវតុល្យភាពកម្លាំងថ្មី និងកម្លាំងចាស់ ។ វរជននយោបាយថ្មីបានផ្សារខ្លួនចូលទៅក្នុងប្រព័ន្ធនយោបាយ ។ អ្នកនយោបាយយោធាមួយចំនួនបានចូលធ្វើសកម្មភាពនៅក្នុងគណបក្សនយោបាយជាមួយអ្នកនយោបាយស៊ីវិល ។ នៅក្នុងខណៈនេះ សមាសភាពវ៉ានីកាល់ ពួកវរជនចាស់ និងវរជនថ្មីបានរួបរួមពង្រីកកម្លាំង នៅលើឆាកនយោបាយ ដោយស្រុះស្រួលគ្នា និងគ្មានការប្រឈមមុខដាក់គ្នា ។ គួរកត់សំគាល់ថាកងទ័ពមានតួនាទីសំខាន់នៅក្នុងនយោបាយសង្គមថៃ ។ ស្ថាប័នកងទ័ពដើរទន្ទឹមគ្នានិងសភាគណបក្សនយោបាយ ប៉ុន្តែពេលខ្លះអំណាចព្រះមហាក្សត្រមានតួនាទីដ៏សំខាន់នៅក្នុងជីវភាពសង្គមថៃ ។

តួនាទីកងទ័ពថៃមានការប្រែប្រួលខ្លាំងណាស់ បើប្រៀបធៀបនឹងដំណាក់កាលរដ្ឋប្រហារយោធានិយមផ្ដាច់ការ និងដំណាក់កាលការរីកចម្រើននៃរបបប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណាក៏ដោយ តួនាទីកងទ័ពផ្សារភ្ជាប់នឹងអ្នកដឹកនាំជាន់ខ្ពស់ និងចូលរួមតស៊ូក្នុងការបោះឆ្នោតប្រកួតប្រជែងនយោបាយដើម្បីអាសនៈនៅក្នុងសភា គោរពទៅតាមបែបបទអ្នកនយោបាយស៊ីវិល ។

## ? សំណួរ

1. តើស្ដេច មង្គុត និងជូឡាឡុងកន បានដឹកនាំនយោបាយកំណែទម្រង់សង្គមសៀមយ៉ាងដូចម្ដេច ?
2. តើមូលហេតុអ្វីបានជាផ្ទុះរឿងបដិវត្តន៍ឆ្នាំ 1932 ?
3. តើអំណាចយោធាមានតួនាទីយ៉ាងណាក្នុងប្រទេសថៃ ?
4. តើស្ដេច "ភូមិពលអាឌុលយ៉ាតេជ" បានធ្វើសកម្មភាពអ្វីខ្លះដើម្បីពង្រឹងស្ថាប័នព្រះមហាក្សត្រឡើងវិញ ?
5. តើព្រះមហាក្សត្រមានតួនាទីអ្វីខ្លះក្នុងប្រព័ន្ធដឹកនាំរបបរាជនិយមអាស្រ័យរដ្ឋធម្មនុញ្ញថៃ ?

# 4 បណ្ដាប្រទេសនៅតំបន់មជ្ឈិមបូព៌ា

**ចប់មេរៀននេះ សិស្សអាច**

- យល់ដឹងអំពីព្រឹត្តិការណ៍ធំៗ កើតមានក្នុងតំបន់មជ្ឈិមបូព៌ា ។
- បង្ហាញអំពីឥទ្ធិពលនយោបាយមហាអំណាចលើតំបន់មជ្ឈិមបូព៌ា ។
- មានមនសិកាស្នេហាជាតិស្រឡាញ់សន្តិភាព និងការអភិវឌ្ឍ ។

សព្វថ្ងៃនេះតំបន់មជ្ឈិមបូព៌ានៅតែជាតំបន់ដែលកំពុងតែមានទំនាស់ប្រឈមមុខគ្នាយ៉ាងពុះកញ្ជ្រោល ទាំងបណ្ដាប្រទេសក្នុងតំបន់ ទាំងបណ្ដាប្រទេសក្រៅតំបន់ ។

## 1. បញ្ហាចម្រុះជាតិសាសន៍

### 1.1. ប្រទេសតួកគី

តំបន់មជ្ឈិមបូព៌ាគឺជាតំបន់ដ៏វិវដើបរំជួល និងចលាចលបំផុតនៅលើពិភពលោក ។ ក្រៅពីសង្គ្រាមរវាងអារ៉ាប់ និងពួកជ្វីប បញ្ហាទំនាស់ផ្ទៃក្នុងនៃប្រទេសទាំងនេះជាបញ្ហាមួយដ៏សែនស្មុគស្មាញនិងអាប់អួបំផុត ។ ប្រទេសតួកគីធ្លាប់ជាអាណាចក្រមួយដ៏ធំ មានជាតិសាសន៍តែមួយគត់នៅក្នុងតំបន់មជ្ឈិមបូព៌ា ប៉ុន្តែក្រោយមក ទឹកដីអាណាចក្រអារ៉ាប់ត្រូវបាត់បង់នៅឆ្នាំ 1919 ។ នៅឆ្នាំ 1990 អំបូរពូជសាសន៍តែមួយរបស់តួកគីត្រូវបានចុះថយតិចទៅៗ ដោយសារមានល្បាយពួកឃឺដរាប់លាននាក់ បានភៀសខ្លួនចេញពីតំបន់អ៊ីរ៉ាក់ខាងជើងចូលមករស់នៅក្នុងប្រទេសនេះ(ប្រជាជនតួកគីសរុបទាំងអស់ 56.5 លាននាក់) ។ ការប្រឈមមុខរវាងជនជាតិឃឺដ និងតួកគីជាបញ្ហាស្រួចស្រាល់រហូតមកទល់នឹងសព្វថ្ងៃ ។

### 1.2. ប្រទេសស៊ីរី

នៅឆ្នាំ 1987 ប្រទេសស៊ីរីមានប្រជាជនចំនួន 11.2 លាននាក់ស្ថិតនៅក្នុងអំបូរពូជសាសន៍ប្រាំបីផ្សេងៗគ្នា ក្នុងចំណោមនេះមានចំនួនជាងមួយលាននាក់កាន់សាសនាគ្រិស្ត ។ ប្រជាជនស៊ីរីភាគច្រើនកាន់សាសនាអ៊ិស្លាម-ស៊ូនីត ។ ប្រជាជនភាគតិចដែលប្រកាន់សាសនាអ៊ិស្លាម-អាឡាវីតមានតួនាទីសំខាន់ក្នុងវិស័យយោធា ។ តំណាងរបស់អ្នកកាន់សាសនាអ៊ិស្លាមនិកាយឌ្រូស៊ីមានតួនាទីសំខាន់ក្នុងកិច្ចការនយោបាយស៊ីរី រីឯនៅក្នុងទីក្រុងអាឡេប៉ូអ្នកកាន់សាសនាគ្រិស្តកាន់តែកើនចំនួនឡើង ។

## 1.3. ប្រទេសអ៊ីរ៉ង់

នៅក្នុងឆ្នាំ 1990 អ៊ីរ៉ង់(ពែក្ស)មានចំនួនប្រជាជន 59 លាននាក់ ដែលភាគច្រើនអ្នកកាន់សាសនាអ៊ីស្លាមស៊ីអ៊ីត ។ ការបែងចែកពួកអ៊ីស្លាមជានិកាយ ស៊ីអ៊ីតនិងស៊ូនីត បានកើតឡើងបន្ទាប់ពីមរណភាពរបស់ម៉ូហាម៉ាត់នៅឆ្នាំ 632 ដោយសារតែទំនាស់ក្នុងការទទួលសិទ្ធិបន្តកេរមរតកគ្រងរាជ្យលើអាណាចក្រអារ៉ាប់ហាលីហ្វាត ។ បរាជ័យនៅក្នុងការប្រកែកគ្នានេះគឺបងប្អូនជីដូនមួយរបស់ម៉ូហាម៉ាត់ គឺម៉ូហាមាត់អាលីបានបង្កើតលទ្ធិស៊ីអ៊ីតនិយម ។

## 1.4. ប្រទេសអ៊ីរ៉ាក់

នៅឆ្នាំ 1990 ប្រជាជនអ៊ីរ៉ាក់ទាំងអស់មានចំនួន 19 លាននាក់ដែលភាគច្រើនជាពួកអ៊ីស្លាមស៊ីអ៊ីតនិងពួកស៊ូនីតមានចំនួនមួយភាគបួនតែប៉ុណ្ណោះ ។ នៅភូមិភាគខាងជើងនៃប្រទេសអ៊ីរ៉ាក់មានពួកឃឺដរស់នៅច្រើន ។ នៅក្នុងតំបន់ម៉ូស៊ូលនៃប្រទេសអ៊ីរ៉ាក់មានពួកអាស៊ីរីរស់នៅ ពួកគេគោរពសាសនាគ្រិស្ត ។ នៅឆ្នាំ 1950-1951 នៅទីក្រុងបាកដាដមានជ្វីបរស់នៅខ្លះដែរ ។

## 1.5. ប្រទេសលីបង់

នៅក្នុងចំណោមប្រទេសអារ៉ាប់ទាំងអស់ ប្រជាជនដែលមានការបែងចែកច្រើនបែបច្រើនយ៉ាងជាងគេនោះគឺ ប្រជាជននៅក្នុងតំបន់ភ្នំនៃប្រទេសលីបង់ ។ ប្រជាជនលីបង់មានចំនួនបីលាននាក់ ហើយគ្មានក្រុមណាមួយត្រូវគេចាត់ទុកថាជាប្រជាជនភាគច្រើនឡើយ ។ ប្រជាជនអ៊ីស្លាមត្រូវគេបែងចែកជា ស៊ីអ៊ីត ស៊ូនីត និងឌ្រូស៊ី ក្រៅពីនេះមានពួកម៉ារ៉ូនីត គឺគ្រិស្តសាសនិកជនដែលមានមេដឹកនាំរបស់ខ្លួន ប៉ុន្តែពួកគេទទួលស្គាល់សម្តេចប៉ាបថាមានតួនាទីជាមេដឹកនាំវិហារកាតូលិករ៉ូម ។ ម៉ារ៉ូនីតគឺជាសហគមន៍អ្នកកាន់សាសនាគ្រិស្តធំបំផុត ។ កាលពីមុន គ្រិស្តសាសនិកជនមានចំនួនសឹងតែពាក់កណ្តាលប្រជាជនលីបង់ ប៉ុន្តែសព្វថ្ងៃនេះមានការថយចុះ ចំណែកអ្នកកាន់សាសនាអ៊ីស្លាមមានចំនួនកើនឡើង ។

ប្រជាជនលីបង់មានចំនួនមិនពិតប្រាកដ ព្រោះអស់រយៈពេលជាងហាសិបឆ្នាំមកហើយ រដ្ឋាភិបាលពុំបានធ្វើជំរឿនប្រជាជនប្រទេសនេះទាល់តែសោះ ។ នៅឆ្នាំ 1975 បានផ្ទុះឡើងនូវការលុបបំបាត់កិច្ចព្រមព្រៀងស្តីអំពីការបែងចែកអំណាចរវាងអ៊ីស្លាមនិងគ្រិស្តសាសនិកជន ។ នៅក្នុងទំនាស់នេះមានជំនួយពីកម្លាំងទ័ពរបស់អង្គការរំដោះជាតិប៉ាលេស្ទីនផង បានធ្វើឱ្យលីបង់ធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមស៊ីវិលយ៉ាងកាចសាហាវបំផុត ។

## 1.6. ប្រទេសហ្ស៊កដានី

ទឹកដីប្រទេសហ្ស៊កដានីបានរួមតូចបន្ទាប់ពីសង្គ្រាមជាមួយនឹងអ៊ីស្រាអែល នៅឆ្នាំ 1967 ។ ប្រទេសហ្ស៊កដានីមានប្រជាជន 3.7 លាននាក់(ស្ថិតិឆ្នាំ 1987) ។ នៅឆ្នាំ 1949 ក្រោយសង្គ្រាមអារ៉ាប់-អ៊ីស្រាអែល គេបានបណ្តេញពួកអ៊ីស្រាអែលចេញពីតំបន់ខាងលិចនៃទន្លេហ្ស៊កដង់ហើយបានពង្រីកទឹកដីនោះដោយសារតែប្រជាជនហ្ស៊កដានីរស់នៅលើសពី 800 ពាន់នាក់ និងជាកន្លែងដែលពួកប៉ាលេស្ទីនធ្លាប់រស់នៅ ។ ទំនាក់ទំនងរវាងអារ៉ាប់-ប៉ាលេស្ទីន និងអារ៉ាប់-ហ្ស៊កដានី ដែលមានបំណងចង់បង្កើតរដ្ឋឯករាជ្យរបស់ខ្លួនបានជួបប្រទះនឹងបញ្ហាស្មុគស្មាញយ៉ាងច្រើន ។ ហ្ស៊កដានីគឺពួកអ៊ីស្លាម-ស៊ូនីត ប៉ុន្តែប្រជាជនភាគច្រើនដែលរស់នៅតំបន់ខាងលិចទន្លេហ្ស៊កដង់ គឺជាអ្នកកាន់សាសនាគ្រិស្ត ។

## 1.7. ប្រទេសអ៊ីស្រាអែល

នៅក្នុងប្រទេសអ៊ីស្រាអែលតាមស្ថិតិឆ្នាំ 1991 មានប្រជាជនរស់នៅ 5 លាននាក់ដែលក្នុងនោះមានអារ៉ាប់ប្រហែលជា 900 ពាន់នាក់ ។ ក្រោយឆ្នាំ 1967 អ៊ីស្រាអែលបានចូលកាន់កាប់តំបន់ខាងលិចទន្លេហ្ស៊កដង់និងតំបន់កាសា(Gaza Area) ដែលមានប្រជាជនអារ៉ាប់ជាង 1.5 លាននាក់ ហើយបន្តការគ្រប់គ្រងរហូតមកទល់នឹងសព្វថ្ងៃ ។

## 1.8. ប្រទេសអារ៉ាប៊ីសាអូឌីត

ប្រទេសដែលធំជាងគេបង្អស់នៅក្នុងឧបទ្វីបអារ៉ាប់គឺប្រទេសអារ៉ាប៊ីសាអូឌីតដែលបានបង្រួបបង្រួមដោយការប្រឹងប្រែងពីសំណាក់ក្រុមសាអូឌីត និងក្រុមដែលមានភក្តីភាពជាមួយនឹងខ្លួន វ៉ាហាប៊ីដែលក្រោយមកនាទសវត្សរ៍ឆ្នាំ 20 នៃសតវត្សទី 20 ពួកគេបានវាយកម្ទេចសត្រូវដ៏សំខាន់របស់ខ្លួន គឺហ្ស៊ីសេន សារីហ្វដែលមកពីម៉េគី ។ នៅឆ្នាំ 1990 ប្រជាជនអារ៉ាប៊ីសាអូឌីតមានចំនួន 14 លាននាក់ ។

ដំបូងឡើយ ប្រទេសអារ៉ាប៊ីសាអូឌីតជាប្រទេសក្រីក្រ ដែលកម្លាំងនយោបាយរបស់គេអាស្រ័យនឹងមេកុលសម្ព័ន្ធ ហើយស្ថិតក្រោមការគ្រប់គ្រងរបស់មេដឹកនាំសាសនាមកពីម៉េគី និងមេឌីន ។ ការដឹកនាំតាមរបៀបបិតានិយមបានកើតឡើង ហើយបន្តរហូតមកដល់សព្វថ្ងៃ ប៉ុន្តែព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីតបានប្រែមុខមាត់ពីក្រតោកយ៉ាក ទៅជាប្រទេសអ្នកមានលើពិភពលោកដោយសារកំណប់អណ្តូងរ៉ែប្រេងដ៏ធំដែលផ្តើមធ្វើអាជីវកម្មតាំងពីទសវត្សរ៍ឆ្នាំ 30 មក ។

## 1.9. ប្រទេសយេម៉ែន

នៅឆ្នាំ 1990 ប្រទេសយេម៉ែនមានប្រជាជនចំនួន 11 លាននាក់ ។ ប្រទេសយេម៉ែនមានអណ្តូងប្រេងមិនធំទេ បើប្រៀបធៀបនឹងប្រទេសអារ៉ាប៊ីសាអូឌីត ។ យេម៉ែនមានចំណាត់ថ្នាក់ជាប្រទេសក្របំផុតនៅក្នុងតំបន់ ។ ប្រទេសយេម៉ែនមានក្រុមហ៊ុនធ្វើអាជីវកម្មប្រេងកាត និងឧស្ម័នធម្មជាតិមានចំនួនកាន់តែច្រើនឡើងៗ ។ ប្រជាជនយេម៉ែនស្ថិតនៅក្នុងក្រុមអ៊ីស្លាមស៊ីអ៊ីត ។ មុនពេលរកឃើញអណ្តូងរ៉ែប្រេង តំបន់នេះគ្រាន់តែជាតំបន់យុទ្ធសាស្ត្ររបស់អង់គ្លេសក្នុងការបង្ការផ្លូវពាណិជ្ជកម្មតាមរយៈការបង្ហូរប្រេងកាតពីអ៊ីរ៉ង់ និងអ៊ីរ៉ាក់តែប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមក អង់គ្លេសបានពង្រីកការគ្រប់គ្រងតំបន់ជុំវិញទីក្រុងអាដេន(Aden) និងផ្តល់ការគាំទ្រដល់កុលសម្ព័ន្ធនៅទីនោះដើម្បីបញ្ចៀសការបះបោរប្រឆាំងដែលនាំឱ្យខូចប្រយោជន៍ពាណិជ្ជកម្មរបស់ខ្លួន ។

## 1.10. ប្រទេសអេហ្ស៊ីប

អេហ្ស៊ីប ជាប្រទេសមួយធំស្ថិតក្នុងតំបន់មជ្ឈិមបូព៌ា ។ មួយភាគនៃទឹកដីអេហ្ស៊ីបស្ថិតក្នុងទ្វីបអាស៊ី ។ ចាប់ពីអំឡុងឆ្នាំ 1900 ប្រទេសអេហ្ស៊ីបមានកំណើនប្រជាជនយ៉ាងលឿន គ្រាន់តែក្នុងរយៈពេល 45 ឆ្នាំប្រជាជនអេហ្ស៊ីបបានកើនឡើងសឹងតែបីដងពី 18 លានដល់ 52 លាននាក់នៅក្នុងឆ្នាំ 1947 ។ ក្នុងខណៈនោះ រដ្ឋាភិបាលខិតខំប្រឹងប្រែងធ្វើទំនើបកម្មសេដ្ឋកិច្ច ប៉ុន្តែពុំបានធ្វើឱ្យជីវភាពកសិករមានការកើនឡើងនោះទេ ។ ប្រជាជនអេហ្ស៊ីបភាគច្រើនជាអ៊ីស្លាម ។ ក្រៅពីនេះមានពួកអារ៉ាប់ចំនួនប្រហែល 4 លាននាក់ប្រកាន់យកសាសនាគ្រិស្ត និងពួកជ្វីបតិចតួច ។ ប៉ុន្តែពួកជ្វីបត្រូវគេបណ្តេញចេញក្រោយឆ្នាំ 1956 ។

## 1.11. ប្រទេសស៊ូដង់

នៅឆ្នាំ 1898 ប្រទេសស៊ូដង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង់គ្លេស-អេហ្ស៊ីប ប៉ុន្តែជាក់ស្តែងគឺអង់គ្លេសជាអ្នកគ្រប់គ្រងទាំងស្រុង ។ នៅឆ្នាំ 1953 អង់គ្លេស និងអេហ្ស៊ីបបានឯកភាពគ្នាប្រគល់អំណាចគ្រប់គ្រងឱ្យរដ្ឋាភិបាលស៊ូដង់ ។ នៅឆ្នាំ 1955 ស៊ូដង់ធ្វើការបោះឆ្នោតបង្កើតរដ្ឋាភិបាលថ្មីជាផ្លូវការ និងប្រកាសឯករាជ្យនៅថ្ងៃទី 1 ខែមករា ឆ្នាំ 1956 ។ ប្រជាជនចំនួន $\frac{3}{4}$ នៃប្រជាជនស៊ូដង់គឺជាពួកស៊ូនីតដែលរស់នៅភាគកណ្តាល និងភាគខាងជើងប្រទេស ។ ប្រជាជនស៊ូដង់នៅភាគខាងត្បូងបានរក្សាប្រពៃណីបុរាណយ៉ាងខ្ជាប់ខ្ជួន ក្នុងចំណោមប្រជាជនទាំងនោះមានចំនួន 5 % ប្រកាន់យកសាសនាគ្រិស្ត ។ ស្ថិតិឆ្នាំ 1989 ប្រទេសស៊ូដង់មានប្រជាជនរស់នៅចំនួន 24.5 លាននាក់ ដែលក្នុងចំណោមនេះមាន $\frac{3}{4}$ ជាជនជាតិស្បែកខ្មៅអាហ្វ្រិក ។

### 1.12. ប្រទេសលីប៊ី

នៅឆ្នាំ 1990 ប្រទេសលីប៊ីមានប្រជាជនចំនួន 4.6លាននាក់ ដែលភាគច្រើនជាស៊ូនីត ។ ភាសាផ្លូវការគឺភាសាអារ៉ាប់ ប៉ុន្តែប្រទេសលីប៊ីមានតំបន់ដែលជនជាតិប៊ែរវ៉ាមរស់នៅ ។ ប្រទេសលីប៊ីធ្លាប់ជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសអារ៉ាប់ ប៉ុន្តែដោយសារតែការធ្វើអាជីវកម្មប្រេងកាតចាប់ពីទសវត្សរ៍ឆ្នាំ 60មក ប្រទេសលីប៊ីបានប្រែមុខមាត់យ៉ាងខ្លាំង ។

## 2. នយោបាយកំពូលមហាអំណាចដើម្បីគ្រប់គ្រងតំបន់មជ្ឈិមបូពា

តំបន់មជ្ឈិមបូពា ជាតំបន់មួយដែលសម្បូរទៅដោយសម្បត្តិធម្មជាតិដ៏ស្តុកស្តម្ភ គឺរ៉ែប្រេងកាត ។ រ៉ែប្រេងជាវត្ថុធាតុដើមចាំបាច់បំផុតក្នុងការអភិវឌ្ឍឧស្សាហកម្មជាតិ ។ នៅមុនសង្គ្រាមលោកលើកទី 2 អណ្តូងរ៉ែប្រេងកាតនៅតំបន់មជ្ឈិមបូពាពុំមានសារៈសំខាន់ទេ ពីព្រោះពេលនោះអ្នកនាំប្រេងចេញក្រៅប្រទេសធំជាងគេគឺ សហរដ្ឋអាមេរិក វេណេស៊ុយអេឡា និងម៉ិកស៊ិក ។ នៅក្នុងឆ្នាំ 1939 ប្រទេសវេណេស៊ុយអេឡាតែមួយបាននាំប្រេងចេញមានបរិមាណច្រើនជាងចំនួនប្រេងពីប្រទេសអារ៉ាប់ទាំងអស់រួមគ្នា ។ នៅក្នុងដំណាក់កាលនៃសង្គ្រាមលោកលើកទី 2 ប្រេងកាតអ៊ីរ៉ាក់បានក្លាយជាប្រភពថាមពលដែលជាប្រភពជីវិត និងជាកម្មវត្ថុដ៏សំខាន់សម្រាប់អង់គ្លេសចូលឈ្លានពានតំបន់នោះស្របពេលជាមួយនឹងសហភាពសូវៀតផងដែរ ។ ក្រោយបញ្ចប់សង្គ្រាម សេដ្ឋកិច្ចរបស់ប្រទេសលោកខាងលិចបានកាត់បន្ថយការប្រើធ្យូងថ្មមកប្រើប្រេងកាតវិញ ។ គេបានផលិតម៉ាស៊ីនដើរដោយថាមពលប្រេងកាតច្រើនសន្ធឹកសន្ធាប់ ។ ការធ្វើដំណើរតាមយន្តហោះត្រូវបានធានាជាប្រក្រតីក៏ដោយសារប្រភពថាមពលប្រេងពីប្រទេសតំបន់មជ្ឈិមបូពាដែរ ។

នៅឆ្នាំ 1919-1939 សហរដ្ឋអាមេរិក អង់គ្លេស និងហូឡង់ បានទទួលសិទ្ធិក្នុងការធ្វើអាជីវកម្មប្រេងកាតនៅតំបន់មជ្ឈិមបូពា និងជាអ្នកផ្គត់ផ្គង់ប្រេងផ្តាច់មុខ លើទីផ្សារពិភពលោក ។ នៅពេលនោះ ការធ្វើអាជីវកម្មប្រេងសំខាន់ជាងគេនៅលើពិភពលោកគឺនៅប្រទេសអ៊ីរ៉ង់ ។ ចក្រភពអង់គ្លេសមានភ័ព្វសំណាងល្អ ជៀសផុតពីការប្រកួតប្រជែងពីសំណាក់ប្រទេសដទៃទៀត ក្នុងការបូមយកប្រេងអ៊ីរ៉ង់រហូតដល់ឆ្នាំ 1951 ។ ក្រោយមក កើតមានទំនាស់ជុំវិញបញ្ហាការធ្វើជាតូបនីយកម្មអណ្តូងប្រេងកាតរបស់អ្នកកាន់អំណាចអ៊ីរ៉ង់ ។ នៅក្នុងពេលនោះ មហាអំណាចប្រេងកាតសហរដ្ឋអាមេរិកមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីរ៉ែប្រេងកាតរបស់ខ្លួន ។ រដ្ឋាភិបាលបានជួយដល់ក្រុមហ៊ុនអាមេរិកដែលប្រកបអាជីវកម្មយកប្រេង ធ្វើយ៉ាងណាដើម្បីទទួលបានសិទ្ធិធ្វើអាជីវកម្មប្រេងក្នុងប្រទេសទាំងនេះ ទោះបីជាប្រទេសនៅមជ្ឈិមបូពាទាំងនេះមានបញ្ហាសាសនា និងពូជសាសន៍ដ៏ស្មុគស្មាញយ៉ាងណាក៏

ដោយ ។ ក្រៅពីសហរដ្ឋអាមេរិក អង់គ្លេសបានសុខចិត្តបែងចែកប្រេងកាតរបស់អ៊ីរ៉ាក់ ជាមួយនឹងប្រទេសបារាំង ពីព្រោះប្រទេសមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់បារាំងពុំសម្បូរប្រេងកាត ។ ក្រោយឆ្នាំ 1945 បារាំងបានគ្រប់គ្រងប្រទេសស៊ីរី និងលីបង់ ហើយបានធ្វើបំពង់បង្ហូរប្រេងពីអណ្តូងរ៉ែប្រទេសអ៊ីរ៉ាក់ក្នុងតំបន់គីរគុក ខ្វាក់ទៅទ្រីប៉ូលី(Tripoli) ឆ្លងតាមបំពង់បង្ហូរប្រេងរបស់អង់គ្លេសដែលកាត់តាមតំបន់ហ្ស៊កដានី(Trans-Jordan)និងប៉ាលេស្ទីន ហើយត្រូវបានបញ្ចប់នៅត្រង់ទីក្រុងហៃហ្វា (Haifa) ។ ចាប់ពីទសវត្សរ៍ឆ្នាំ 50 ចក្រភពអង់គ្លេសមិនត្រឹមតែគ្រប់គ្រងលើនយោបាយនៅក្នុងតំបន់មជ្ឈិមបូព៌ាប៉ុណ្ណោះទេ ថែមទាំងជាកំពូលប្រទេសមហាអំណាចប្រេងកាតថែមទៀតផង ។

## 3. សន្និដ្ឋាន

តំបន់មជ្ឈិមបូព៌ាជាតំបន់ដ៏សំខាន់សម្រាប់អារ៉ាប់ និងសាសនាអ៊ីស្លាម ។ នៅទីនេះបានឮសូរការដង្ហោយហៅជាញឹកញាប់ពីការចង់បានការឯកភាពគ្នារវាងពួកអារ៉ាប់ និងសាមគ្គីភាពនៃពួកអ្នកកាន់សាសនាអ៊ីស្លាមក្នុងសម្ព័ន្ធភាពប្រទេសអារ៉ាប់ ។ សត្រូវរួមរបស់ពួកអារ៉ាប់គឺអ៊ីស្រាអែល ។ ដូចដែលយើងបានដឹងហើយថា អារម្មណ៍ដែលមានទៅលើអរិយធម៌រួមដូចជាភាសារួម និងការប្រកាន់សាសនារួម ត្រូវបានផ្សារភ្ជាប់គ្នាទៅនឹងប្រជាជនអារ៉ាប់ ដែលរស់នៅគ្រប់ទីកន្លែងក្នុងតំបន់មជ្ឈិមបូព៌ា ។ ប៉ុន្តែ កត្តាអត្តនោម័តនៃមេដឹកនាំអារ៉ាប់ក្នុងក្រុមផ្សេងៗគ្នា បានធ្វើឱ្យសម្ព័ន្ធភាពជនជាតិអារ៉ាប់ប្រកបទៅដោយភាពផុយស្រួយ ។

## ? សំណួរ

1. តើប្រភពនៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាលេចចេញមកពីបញ្ហាអ្វី ?
2. ហេតុដូចម្តេចបានជាប្រទេសមហាអំណាចប្រកួតប្រជែងគ្នា ដើម្បីគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា ?
3. ហេតុដូចម្តេចបានជាបណ្តាប្រទេសអារ៉ាប់ដែលជាប្រទេសសម្បូរទៅដោយធនធានស្តុកស្តម្ភ ប្រជាជនច្រើន ប៉ុន្តែមិនអាចធ្វើសង្គ្រាមយកជ័យជម្នះទៅលើប្រទេសអ៊ីស្រាអែលបាន ?

# 5 ប្រទេសអ៊ីស្រាអែល

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញអំពីការកើតឡើងនៃប្រទេសអ៊ីស្រាអែល ព្រឹត្តិការណ៍សំខាន់ៗនៃសង្គ្រាមអ៊ីស្រាអែលជាមួយនឹងប៉ាលេស្ទីន និងបណ្ដាប្រទេសអារ៉ាប់ ។ ។
- ពន្យល់ពីប្រភពធនធាន កម្លាំងសេដ្ឋកិច្ច យោធា និងបច្ចេកទេសនៃអ៊ីស្រាអែល ។
- សាមគ្គីភាពនាំមកនូវជ័យជំនះដូចប្រជាជនអ៊ីស្រាអែល ។

## 1. សេចក្ដីផ្ដើម

អ៊ីស្រាអែលជាប្រទេសចំណាស់មួយដែលមានប្រជាជនដើមគឺ ជនជាតិជ្វីប ។ ប៉ុន្តែ ប្រទេសនេះបានបាត់បង់ពីផែនទីពិភពលោកអស់រយៈពេលជិតពីរពាន់ឆ្នាំ ដែលគេតែងតែនិយាយតៗគ្នាថានេះជាបណ្ដាសាព្រះ ។ នៅឆ្នាំ 1947 អង់គ្លេសបានយល់ព្រមឱ្យបង្កើតរដ្ឋអធិបតេយ្យមួយនៅលើទឹកដីប៉ាលេស្ទីនឈ្មោះថា "អ៊ីស្រាអែល" ។ ដូច្នេះយើងឃើញថា ការយល់ព្រមបង្កើតរដ្ឋអធិបតេយ្យអ៊ីស្រាអែល នៅលើទឹកដីប៉ាលេស្ទីននេះជាដំបៅអាណានិគមនិយមមួយ ដែលមុនពេលគេចាកចេញពីទឹកដីរដ្ឋអាណានិគម គេតែងតែបន្សល់នូវបញ្ហាដែលមិនអាចដោះស្រាយបាន(បញ្ហាទឹកដីអធិបតេយ្យ) ។ អ៊ីស្រាអែលទទួលផលប្រយោជន៍ប្រសើរណាស់ក្នុងការបង្កើតរដ្ឋអធិបតេយ្យ ឯករាជភាពនៅលើទឹកដីដែលខ្លួនបាត់បង់ពីរពាន់ឆ្នាំមកហើយ ។ រីឯប៉ាលេស្ទីនវាយតម្លៃខុសដោយគិតថា ជាដំបូងគឺការទទួលឯករាជភាព អធិបតេយ្យភាព បន្ទាប់មកគេនឹងធ្វើសង្គ្រាមបណ្ដេញអ៊ីស្រាអែលដោយអាវុធ ។ ជាលទ្ធផល ផ្ទុយពីការគ្រោងទុក អ៊ីស្រាអែលទទួលជោគជ័យ និងបានពង្រីកទឹកដីរបស់ខ្លួនថែមទៀត ដែលក្លាយជាបញ្ហាដោះស្រាយមិនចេញរហូតដល់សព្វថ្ងៃនេះ ។

## 2. រចនាសម្ព័ន្ធដឹកនាំរដ្ឋអ៊ីស្រាអែល

ទោះបីអ៊ីស្រាអែលជាប្រទេសមួយថ្មីទើបនឹងកើតឡើងក្តី ប៉ុន្តែរដ្ឋនេះទទួលជោគជ័យក្នុងការអភិវឌ្ឍជាតិគ្រប់វិស័យ ។ ប្រជាជនអ៊ីស្រាអែលភាគច្រើនបានបង្ខំចិត្តចាកចេញពីទ្វីបអឺរ៉ុប ដោយសារការសម្លាប់រង្គាលជនជាតិជ្វីបពីសំណាក់ពួកហ្វាស៊ីសអាល្លឺម៉ង់ក្នុងអំឡុងសង្គ្រាមលោកលើកទី 2 ។

ពួកអន្តោប្រវេសន៍ជ្វីបក្នុងទឹកដីប៉ាលេស្ទីនមិនមែនទៅដល់តំបន់ដែលមានតែដីទទេស្អាតនោះទេ គឺមានការអភិវឌ្ឍរួចទៅហើយ ។ ជាដំបូង គេមានការជឿជាក់ថាជនជាតិទាំងពីរអាចរស់នៅជាមួយគ្នាបាន ប៉ុន្តែក្រោយមកបញ្ហាទំនាស់កើតឡើងដោយការដណ្តើមគ្នាធ្វើម្ចាស់គ្រប់គ្រងរៀងៗខ្លួន ។ ពួកអារ៉ាប់បានត្រូវគេបញ្ច្រៀតខ្នាតទៅលើទឹកដីគ្មានជីជាតិ ដែលនាំឱ្យកើតមានឡើងនូវការស្អប់ខ្ពើមរើសអើងយ៉ាងខ្លាំងទៅលើប្រជាជនចំណូលថ្មី ដែលធ្វើអន្តោប្រវេសន៍មកពីគ្រប់ច្រកល្ហកនៃពិភពលោក ។ ជនជាតិជ្វីបភាគច្រើនបានប្រកាសថាគេមានសិទ្ធិរស់នៅលើទឹកដីនេះ ពីព្រោះទីនេះជាមរតកនៃអាណាចក្ររបស់ស្តេចខ្លួនឈ្មោះ ដេវីដ មានរាជធានី យេរូសាលឹម ដែលកើតឡើងរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ ។ ពួកជ្វីបបានបាត់បង់រដ្ឋរបស់ខ្លួន ក្រោយពីពួករ៉ូមបានចូលកាន់កាប់តំបន់នោះ ។ ពួកជ្វីបបានថែរក្សាសាសនា វប្បធម៌ និងជំនឿរបស់ខ្លួន ដោយសង្ឃឹមថា ថ្ងៃណាមួយគេនឹងទទួលបានទឹកដីមាតុភូមិព្រះជាម្ចាស់របស់គេមកវិញ ។

សព្វថ្ងៃនេះមេដឹកនាំអ៊ីស្រាអែលជាជនភៀសខ្លួនចេញមកពីតំបន់អឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត ។ ប្រធានាធិបតីទីមួយរបស់អ៊ីស្រាអែល គឺលោក ហាអ៊ីម វ៉ាយស្មាន់ និង នាយករដ្ឋមន្ត្រីទីមួយលោក ដេវីដ បេន ហ្គូរ៉ុន( David Ben Guron) ជាអ្នកដឹកនាំនយោបាយដ៏ចំណាន គ្រប់គ្រងរដ្ឋថ្មីនេះរហូតដល់ឆ្នាំ 1973 ។ អ្នកស្រី ហ្គោលដាមែរ នាយករដ្ឋមន្ត្រីទី I មានដើមកំណើតនៅទីក្រុងគៀវ (ប្រទេសអ៊ុយក្រែន) ។ នៅឆ្នាំ 1906 គ្រួសារហ្គោលដាមែរ បានភៀសខ្លួនទៅសហរដ្ឋអាមេរិក ហើយនៅឆ្នាំ 1921 នៅពេលមានវ័យ 18ឆ្នាំបានប្តូរមករស់នៅទីក្រុងតីប៊ីត្ស ។ នៅឆ្នាំ 1969 ដោយបានទទួលជ័យជម្នះនៅក្នុងវិស័យនយោបាយ និងការខូត អ្នកស្រី ហ្គោលដាមែរបានក្លាយជានាយករដ្ឋមន្ត្រីអ៊ីស្រាអែលបន្ទាប់ពីមរណភាពលោកឡេវីអេស្កុល ។

ប្រជាជនអ៊ីស្រាអែលទាំងអស់រាប់បញ្ចូលទាំងនៅលើទឹកដី ដែលដណ្តើមបានក្នុងសង្គ្រាមឆ្នាំ 1967 បានកើនឡើង 6ដង ពី 750ពាន់នៅឆ្នាំ 1948 ដល់ 2800ពាន់នាក់ក្នុងឆ្នាំ 1968 និងកើនដល់ 4300 ពាន់នាក់នៅចុងទសវត្សរ៍ឆ្នាំ 80 ។

នៅក្នុងឆ្នាំ (1948-1949) មានអារ៉ាប់ប៉ាលេស្ទីន 600 ពាន់នាក់ បានភៀសខ្លួនទៅរស់នៅក្នុងជំរំជនភៀសខ្លួនក្នុងប្រទេសអារ៉ាប់ជិតខាងខ្លួន និងមានអារ៉ាប់ចំនួន 150 ពាន់នាក់បន្តការរស់នៅក្នុងប្រទេសអ៊ីស្រាអែល ។ នៅឆ្នាំ 1987 ចំនួនពួកនេះកើនដល់ 650 ពាន់នាក់ដែលមាន $\frac{2}{3}$ ក្នុងចំណោមនេះកាន់សាសនាអ៊ីស្លាមនិង $\frac{1}{3}$ កាន់សាសនាគ្រិស្ត ។

បញ្ហាចោទនៅចំពោះមុខរដ្ឋាភិបាលអ៊ីស្រាអែលគឺការទទួលយកជនភៀសខ្លួនរាប់សែននាក់ ។ អ៊ីស្រាអែលបើកទ្វារចំហសម្រាប់ជនជាតិជ្វីបនៅលើពិភពលោកទាំងអស់ ដែលមានបំណងចង់រស់នៅទីនេះ ។ ប្រទេសអ៊ីស្រាអែលមានចំណោទបញ្ហាទៅលើថវិកាជាតិយ៉ាងខ្លាំងដោយសារតម្លៃទំនិញមានកម្រិតខ្ពស់ការចំណាយទៅលើវិស័យយោធាកាន់តែច្រើនដូចជាប្រទេសតតិយលោកភាគច្រើនដែរ ។

មេបញ្ជាការអ៊ីស្រាអែលមានតួនាទីយ៉ាងសំខាន់ផ្នែកនយោបាយក្នុងប្រទេស ហើយតែងតែធ្វើការផ្លាស់ប្តូរមុខងារទៅជាអ្នកដឹកនាំនយោបាយនៅក្នុងជួររដ្ឋាភិបាល ។ "ខ្នែងស្រាក" ម៉ូហ្សេដាយ៉ាន់ គឺជាមេដឹកនាំម្នាក់ អនុវត្ត យុទ្ធសាស្ត្របែបនេះ ចាប់តាំងពីថ្ងៃបង្កើតអ៊ីស្រាអែលរហូតដល់ការផ្ទុះសង្គ្រាម នៅអ៊ីយ៉ូមគីរពួរនៅឆ្នាំ 1973 ។ ឧត្តមសេនីយ៍ អ៊ីត្សាក រ៉ាប៊ីន ជាអគ្គមេបញ្ជាការយោធា អ៊ីស្រាអែលនៅក្នុងពេល "សង្គ្រាមប្រាំមួយថ្ងៃ" ក្នុងឆ្នាំ 1967 ក្រោយមកលោកចូលទៅកាន់តំណែងជានាយករដ្ឋមន្ត្រី បន្ទាប់ពីអ្នកស្រីហ្គោលដាមែរ ។

## 3. សង្គ្រាមអ៊ីស្រាអែលនឹងប្រទេសអារ៉ាប់ "សង្គ្រាមប្រាំមួយថ្ងៃ"

### 3.1. មូលហេតុនៃសង្គ្រាម និងសម្ព័ន្ធភាពភាគីនៃសង្គ្រាម

នៅឆ្នាំ 1956 ក្រោយបញ្ចប់សង្គ្រាមនៅតំបន់ព្រៃកដឹកស៊ុយអេ អ៊ីស្រាអែលបានស្ថិតក្នុងស្ថានភាពទសវត្សរ៍សម្រាកពីការធ្វើសង្គ្រាម ។ តាមជំហរលោក ណាសែរ និងលោក ហ៊ូសេន គ្មានបំណងចង់ធ្វើសង្គ្រាមជាមួយអ៊ីស្រាអែលទៀតទេសម្រាប់ផលប្រយោជន៍ប៉ាលេស្ទីន ។ ប៉ុន្តែ នៅពេលដែលណាសែរបានបង្ហាញខ្លួនក្នុងតួនាទីជាមេដឹកនាំពិភពអារ៉ាប់ និងការប្រឹងប្រែងផ្សព្វផ្សាយនយោបាយមនោគមន៍វិជ្ជា បានប៉ះពាល់ដល់រាជាណាចក្រហ្ស៊ីកដានី និងអារ៉ាប៊ីសាអូឌីត ពួកគេធ្វើការប្រឆាំងយ៉ាងខ្លាំង ដូច្នេះណាសែរខិតខំពង្រឹងគោលជំហរប្រឆាំងនឹងសត្រូវរួមគឺ អ៊ីស្រាអែល ដើម្បីទាញចំណាប់អារម្មណ៍ពីពិភពអារ៉ាប់ ។ នៅថ្ងៃទី 26 ខែកក្កដា ឆ្នាំ1959 ណាសែរ បានធ្វើសុន្ទរកថានៅក្នុងទីក្រុងអាឡិចសង់ឌ្រីក្នុងខ្លឹមសារថា "ក្នុងនាមប្រជាពលរដ្ឋសាធារណរដ្ឋអារ៉ាប់រួមខ្ញុំសូមធ្វើសេចក្តីថ្លែងការណ៍ជាឱឡារិកថា នៅពេលនេះយើងនឹងកម្ទេចអ៊ីស្រាអែល" ។

នៅថ្ងៃទី 27 ខែឧសភា ឆ្នាំ 1967 រយៈពេល 9-10 ថ្ងៃ "សង្គ្រាមប្រាំមួយថ្ងៃ" ផ្ទុះឡើង ។ ណាស៊ែរ បានថ្លែងសុន្ទរកថាបែបនេះជាថ្មីម្តងទៀត ។ នៅថ្ងៃទី 31 ខែឧសភា ឆ្នាំ 1967 ប្រធានាធិបតីអ៊ីរ៉ាក់បានធ្វើសេចក្តីថ្លែងការណ៍ប្រកបដោយភាពជ្រុលនិយមថា ការចាប់បដិសន្ធិរដ្ឋអ៊ីស្រាអែល គឺជាកំហុសមួយដែលត្រូវការកែជាដាច់ខាត ។ ឥឡូវនេះ យើងមានលទ្ធភាពផុសខាត់ភាពថោកទាបឱ្យអស់ ដែលស្ថិតនៅលើស្មារបស់យើងពីឆ្នាំ 1948 មក ។ យើងមានទិសដៅយ៉ាងច្បាស់លាស់គឺឈូសអ៊ីស្រាអែលចេញពីផែនទីតំបន់មជ្ឈិមបូព៌ា ។ សុន្ទរកថាបែបនេះបានធ្វើឱ្យមតិសាធារណៈរំជើបរំជួលយ៉ាងខ្លាំង ប៉ុន្តែអ៊ីស្រាអែលបានមើលឃើញយ៉ាងច្បាស់អំពីបញ្ហារបស់ខ្លួន ទីមួយបើពួកគេទន់ខ្សោយ នោះគេនឹងជួបប្រទះភាពរង្គោះរង្គើ និងការគំរាមកំហែងសាជាថ្មី ទីពីរប្រទេសអារ៉ាប់មិនចង់បានសន្តិភាព និងមិនទទួលស្គាល់សិទ្ធិអ៊ីស្រាអែល ក្នុងតំបន់មជ្ឈិមបូព៌ាទេ ។

នៅក្នុងការឆ្លើយតបទៅនឹងបំណងរបស់ពួកអារ៉ាប់ មេដឹកនាំអ៊ីស្រាអែលបានបំពាក់អាវុធប្រជាជនខ្លួនគ្រប់ៗរូប ។ យោងតាមច្បាប់កាតព្វកិច្ចយោធា ប្រជាជនអ៊ីស្រាអែលទាំងបុរសទាំងស្ត្រីត្រូវចូលបម្រើក្នុងកងទ័ពពី 2-3 ឆ្នាំ ។ ក្រោយបញ្ចប់សង្គ្រាមពួកគេត្រូវស្ថិតនៅជាទ័ពបម្រុង (ទ័ពបម្រុងបុរសរហូតដល់វ័យ 49 ឆ្នាំ) ។ ប្រទេសអ៊ីស្រាអែលមានទាហាន ជាអចិន្ត្រៃយ៍ 80 ពាន់នាក់ ហើយក្នុងខណៈមានភាពអាសន្ន ចំនួននេះកើនឡើងរហូតដល់ 300 ពាន់នាក់ ។ កងទ័ពជើងគោក ជើងអាកាស និងជើងទឹកស្ថិតក្នុងស្ថានភាពប្រុងប្រយ័ត្នជានិច្ច ។

នៅឆ្នាំ 1966 ត្រូវពួកជ្រុលនិយមដណ្តើមយកបានអំណាចដឹកនាំប្រទេសស៊ីរី ។ ពួកគេបានប្រឹងប្រែងបង្កើតចលនាតស៊ូ ដើម្បីរំដោះប៉ាលេស្ទីន ។ ក្រោយពីបានអំណាច ពួកគេបានបង្កហេតុនៅតាមតំបន់ជាប់នឹងព្រំដែនអ៊ីស្រាអែល ព្រមទាំងផ្តល់សព្វាវុធទៅឱ្យកងកម្លាំងជីវពលប៉ាលេស្ទីន ។ នៅឆ្នាំ (1966-1967) កងកម្លាំងជីវពលប៉ាលេស្ទីន បានធ្វើការវាយឆ្មក់ទៅលើអ៊ីស្រាអែល ដោយបានធ្វើវិច្ឆេទកម្មដាក់គ្រាប់បែកជាច្រើនកន្លែង ។ អ៊ីស្រាអែលបានឆ្លើយតបដោយការវាយលុកទៅលើជំរំពួកប៉ាលេស្ទីន ។ បញ្ហាបានរីករាលដាលទៅដល់ប្រទេសអារ៉ាប់ផ្សេងទៀតមាន ហ្សកដានី ស៊ីរី និងអេហ្ស៊ីប ។ នៅថ្ងៃទី 22 ខែឧសភា ណាស៊ែរ បានសម្រេចចិត្តបិទច្រកចូលទៅឈូងសមុទ្រអាកាបារបស់កងនាវាចរអ៊ីស្រាអែល ។ ក្រុងវ៉ាស៊ីនតោន បានប្រឹងប្រែងរកដំណោះស្រាយ ប៉ុន្តែយឺតពេលបន្តិចព្រោះអ៊ីស្រាអែលបានត្រៀមខ្លួនប្រយុទ្ធជាស្រេច ។

ថ្ងៃទី ၊ ខែមិថុនា ឆ្នាំ 1967 នាយករដ្ឋមន្ត្រី លេវី អេស្កូលបានតែងតាំងឧត្តមសេនីយ៍ម៉ូហ្សេដាយ៉ាន់ ជារដ្ឋមន្ត្រីក្រសួងការពារជាតិ (ឋានៈជានាយអគ្គសេនាធិការ) ។ ឧត្តមសេនីយ៍ ម៉ូហ្សេដាយ៉ាន់ មានគោលជំហររឹងមាំ "ការការពារប្រកបដោយសុវត្ថិភាព គឺការវាយលុកឱ្យបានមុន" ។ ថ្ងៃទី 4 ខែមិថុនា អ៊ីរ៉ាក់បានប្រកាសភ្ជាប់ខ្លួនទៅនឹងសម្ព័ន្ធភាពហ្ស៊ីកដានី និងអេហ្ស៊ីប ។

## ៣.2. ដំណើរវិវត្តន៍នៃសង្គ្រាម

នៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 1967 អ៊ីស្រាអែលបានចាប់ផ្តើមបើកឆាក "សង្គ្រាមប្រាំមួយថ្ងៃ" ក្នុងរយៈពេល 24 ម៉ោងបុំណ្ណោះ កងទ័ពអ៊ីស្រាអែលបានវាយកម្ទេចទ័ពអាកាសអេហ្ស៊ីប និងសម្ព័ន្ធមិត្តឱ្យបរាជ័យទាំងស្រុង ។ សង្គ្រាមមានរយៈពេលតែប្រាំមួយថ្ងៃត្រូវបានបញ្ចប់ ។ កងទ័ពអ៊ីស្រាអែលបានចូលកាន់កាប់តំបន់ព្រៃកដីកស៊ុយអេ ឧបទ្វីបស៊ីណាអ៊ី តំបន់វេស្តបេង និងផ្នែកខ្លះនៃទឹកដី ហ្គោឡង់របស់ស៊ីរី រួមទាំងតំបន់ហ្គាសា ។ ការទទួលជ័យជម្នះរបស់អ៊ីស្រាអែលនៅឆ្នាំ 1967 បានបង្កើតបញ្ហាដល់តំបន់មជ្ឈិមបូព៌ាដែលមិនទាន់បានដោះស្រាយរហូតដល់ពេលបច្ចុប្បន្ន ។

## ៣.៣. ផលវិបាកក្រោយសង្គ្រាម

ស្តេចហ៊ូសេននៃប្រទេសហ្ស៊ីកដានីសម្រេចចិត្តចូលប្រយុទ្ធនឹងភាគីអេហ្ស៊ីបដោយចង់បានទឹកដីត្រើយខាងលិចទន្លេហ្ស៊ីកដង់ ដែលអ៊ីស្រាអែលបានចូលឈ្លានពានយកតាំងពីឆ្នាំ (1948-1949) ។ ទឹកដីនេះពីមុនជាទឹកដីអាណានិគមអង់គ្លេសស្ថិតក្រោមការគ្រប់គ្រងរបស់ប៉ាលេស្ទីន ។ អ៊ីស្រាអែលបានសម្រេចចិត្តផ្តល់ទឹកដីនេះឱ្យពួកអារ៉ាប់ដែលមានជនជាតិប៉ាលេស្ទីន 845 ពាន់នាក់រស់នៅទីនោះ ។ នៅអំឡុងពេលហ្ស៊ីកដានីគ្រប់គ្រងអារ៉ាប់ប៉ាលេស្ទីនមានលក្ខណៈប្រហាក់ប្រហែលនឹងអារ៉ាប់ហ្ស៊ីកដានី ប៉ុន្តែក្រោយពីការគ្រប់គ្រងដោយអ៊ីស្រាអែល ពួកគេចង់បានឯករាជ្យហើយបានព្យាយាមទាមទារបង្កើតរដ្ឋមួយដោយឡែកពីអ៊ីស្រាអែល ។ អ៊ីស្រាអែលតែងធ្វើការរារាំងនូវរាល់កិច្ចព្រមព្រៀងជាមួយនឹងហ្ស៊ីកដានី គេបានឮសូរកាន់តែខ្លាំងអំពីការអះអាងរបស់អ៊ីស្រាអែលថា ទឹកដីខាងលិចទន្លេហ្ស៊ីកដង់ តំបន់ហ្គាសា និងភូមិភាគខាងកើតសេរុយសាឡិមជាទឹកដីរបស់ខ្លួនតាំងពីប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ ។

## 4. សន្និដ្ឋាន

ទោះបីទស្សនៈពីរដែលខុសគ្នារបស់អារ៉ាប់ និងអ៊ីស្រាអែលយ៉ាងណាក្តី ដំណោះស្រាយរបស់អង្គការសហប្រជាជាតិលេខ 242 អនុម័តដោយក្រុមប្រឹក្សាសន្តិសុខ នាថ្ងៃទី 22 ខែវិច្ឆិកា ឆ្នាំ 1967 បានដាក់ចុះជាមូលដ្ឋានធ្វើការចរចាដើម្បីសន្តិភាព ។

សេចក្តីសម្រេចចិត្តនេះធានាដល់អ៊ីស្រាអែលនូវសន្តិសុខព្រំប្រទល់ ទាមទារឱ្យដកទ័ពចេញពីតំបន់វាយកាន់កាប់ និងគួសបញ្ជាក់កត្តាចាំបាច់នូវសេចក្តីសម្រេចចិត្តបញ្ហាជនភៀសខ្លួនប៉ាលេស្ទីន ។ ប៉ុន្តែដំណោះស្រាយនេះពុំបានដោះស្រាយបញ្ហាទាំងអស់ជាក់លាក់នោះទេ ។ តាំងពីខែកញ្ញា ឆ្នាំ 1967 គេបានសំដែងឡើងនៅក្នុងសន្និសីទ មេដឹកនាំប្រទេសអារ៉ាប់នៅទីក្រុងខាទូម ណាស៊ែរបានទាមទារឱ្យអ៊ីស្រាអែលដកកងទ័ពចេញពីទឹកដីឈ្លានពានទាំងស្រុង ហើយមិនអនុញ្ញាតឱ្យមានការចរចាអ្វីទាំងអស់ស្តីអំពីសន្តិភាពជាមួយនឹងអ៊ីស្រាអែល ក្នុងខណៈអ៊ីស្រាអែលពុំទាន់ទទួលស្គាល់ "សិទ្ធិរបស់ប៉ាលេស្ទីនក្នុងការរស់នៅលើទឹកដីប្រទេសរបស់ខ្លួនផ្ទាល់" ។ ឥរិយាបថបែបនេះរបស់មេដឹកនាំប្រទេសអារ៉ាប់ពិសេសអេហ្ស៊ីបបានប្រកាន់យករហូតដល់ឆ្នាំ 1977 ។ អ៊ីស្រាអែលមិនចង់ប្រគល់ទឹកដីដែលខ្លួនវាយដណ្តើមយកបានដោយគ្មានថ្នូរនោះឡើយ ។ នៅក្នុងដំណោះស្រាយលេខ 242 មិនគ្រាន់តែធានាដល់សន្តិសុខព្រំប្រទល់អ៊ីស្រាអែល និងការដកទ័ពចេញពីតំបន់ទាំងនោះប៉ុណ្ណោះទេ ថែមទាំងធ្វើការចរចាជាមួយពួកអារ៉ាប់ដោយបញ្ជាក់ពីទឹកដីតំបន់ណាដែលបន្សល់ទុកឱ្យអ៊ីស្រាអែលទៀតផង ។

## ? សំណួរ

1. តើរដ្ឋអ៊ីស្រាអែលថ្មីបានលេចឡើងយ៉ាងដូចម្តេច ?
2. តើជនជាតិជ្វីបមានមនសិការជាតិយ៉ាងណាខ្លះ ? ចូរពន្យល់ ។
3. ការរស់នៅរបស់ជនជាតិជ្វីបនៅទីកន្លែងផ្សេងៗគ្នា សូម្បីតែភាសាក៏ផ្សេងគ្នាទៅហើយ ចុះកត្តាអ្វីជាឫសគល់ជំរុញឱ្យជនជាតិនេះអាចរួបរួមគ្នា បង្កើតរដ្ឋជ្វីបដ៏ខ្លាំងក្លានេះឡើងវិញបាន ?
4. តើបណ្តាប្រទេសអារ៉ាប់មានចំណុចខ្សោយត្រង់ណា ទើបមិនអាចទទួលជោគជ័យលើអ៊ីស្រាអែលបាននៅក្នុងសង្គ្រាមប្រាំមួយថ្ងៃ ?

## ? សំណួរបញ្ចប់ជំពូកទី៣

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ**

1 តើនិមិត្តសញ្ញាអាស៊ានមានរាងជាអ្វី ?

☐ ក. រាងស្រូវ ☐ ខ. កណ្ដាប់ស្រូវ ☐ គ. ត្បាល់បុក ☐ ឃ. ជើងចាន ។

2. តើប្រទេសវៀតណាមស្ថិតក្រោមការត្រួតត្រារបស់បារាំងចាប់ពីឆ្នាំណា ?

☐ ក. 1859 ☐ ខ. 1863 ☐ គ. 1884 ☐ ឃ. 1885 ។

3. តើនៅមជ្ឈិមបូព៌ាមានប្រទេសប៉ុន្មាន ?

☐ ក. 8 ប្រទេស ☐ ខ. 9 ប្រទេស ☐ គ. 11 ប្រទេស ☐ ឃ. 12 ប្រទេស ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1 ប្រទេសអ៊ីស្រាអែលជាប្រទេសចំណាស់មួយដែលមានជនជាតិដើមគឺពួក .................... ។

2. ប្រទេសវៀតណាមទទួលបានឯករាជ្យពីអាណានិគមបារាំងនៅឆ្នាំ .................... ។

3. ក្រោយព្រឹត្តិការណ៍បដិវត្តន៍ឆ្នាំ 1932 រហូតដល់សព្វថ្ងៃអំណាចព្រះមហាក្សត្រថៃចុះ .......... ។

**III. ចូរគូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស**

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1 ហូជីមិញ | ក. អ៊ីស្រាអែល | 1. → ... |
| 2 ជូឡាឡុងកន | ខ. វៀតណាម | 2. → ... |
| 3 វ៉ាយស្មាន់ | គ. ថៃ | 3. → ... |

**IV. សំណួរត្រិះរិះ**

1 តើចលនាតស៊ូដើម្បីឯករាជ្យមានប៉ុន្មានបែបគឺអ្វីខ្លះ ?

2. តើដួយម៉ីយជាអ្វី ? តើការអនុវត្តរបស់ដួយម៉ីយមានប្រសិទ្ធភាព ឬទេ ? ព្រោះអ្វី ?

3. តើតួនាទីស្ដេចថៃក្នុងរដ្ឋធម្មនុញ្ញថៃមានអ្វីខ្លះ ?

4. តើប្រភពនៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាចេញពីបញ្ហាអ្វីខ្លះ ?

# ចូរថែទាំសៀវភៅរបស់អ្នក

សូមអ្នក : 

១ ដាក់ក្របសៀវភៅរបស់អ្នកដោយប្លាស្ទិច ឬក្រដាស (ក្រដាសកាសែតឬទស្សនាវដ្តីក៏អាចប្រើបានដែរ)។

២. សំអាតដៃរបស់អ្នកឱ្យបានស្អាត មុនពេលចាប់កាន់ឬបើកទំព័រសៀវភៅ។

៣. នៅពេលប្រើប្រាស់សៀវភៅថ្មីជាលើកដំបូង សូមដាក់សៀវភៅផ្តេកជាមុន រួចបើកមួយពីរ ឬបីទំព័រសិន។ នៅពេលបើកទំព័រសៀវភៅ សូមសង្កេតមើលគល់សន្ទឹកសៀវភៅផង។ បើមានរបើកឬរបេះចេញ សូមរកការបិទវាវិញយ៉ាងប្រុងប្រយ័ត្ន។

៤. ប្រើក្រដាសមួយសន្លឹក ដើម្បីសៀតសំគាល់ទំព័រក្នុងសៀវភៅ។

៥. បិទទំព័រសៀវភៅដែលរហែកឱ្យបានភ្លាមៗ។

៦. កាន់សៀវភៅដោយប្រុងប្រយ័ត្ននៅពេលហុចពីមនុស្សម្នាក់ទៅម្នាក់ទៀត។

៧. ទុកសៀវភៅកន្លែងស្ងួតស្អាតជានិច្ច។

៨. នៅពេលអ្នកបាត់សៀវភៅ សូមជំរាបលោកគ្រូ អ្នកគ្រូភ្លាម។

សូមអ្នក : 

១ កុំបត់ទំព័រសៀវភៅ។

២. កុំសរសេរនៅលើក្រប ឬទំព័រសៀវភៅ។

៣. កុំកាត់រូបភាពចេញពីសៀវភៅ។

៤ កុំហែក ឬផ្តាច់ទំព័រណាមួយចេញពីសៀវភៅ។

៥. កុំបើកចំហរសៀវភៅ ឬផ្កាប់ទុកចោលនៅពេលមិនប្រើប្រាស់។

៦ កុំប្រើខ្មៅដៃ ប៊ិច ឬវត្ថុក្រាស់ៗទៅសៀតសំគាល់ទំព័រក្នុងសៀវភៅ។

៧ កុំបង្ខំញាត់សៀវភៅទៅក្នុងសំពៀតដែលមានរបស់របរពេញហើយ។

៨. កុំយកសៀវភៅទូលបាំងថ្ងៃឬភ្លៀង។

៩ កុំអង្គុយលើសៀវភៅ។

កម្មសិទ្ធិរបស់រដ្ឋ

ក្រសួងអប់រំ យុវជន និង កីឡា
Ministry of Education Youth and Sport
គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ
Publishing and Distribution House
#148 មហាវិថីព្រះនរោត្តម #148 Blvd. Norodom

9 789995 00